គណិតវិទ្យាថ្ងៃនេះ

MathToday

# សៀវភៅគណិតវិទ្យាកម្រិតវិទ្យាល័យ

# ធរណីមាត្រវិភាគក្នុងលំហ

* សង្ខេបមេរៀននិងគន្លឹះដោះស្រាយសំខាន់ៗ
* លំហាត់ជ្រើសរើសអមដោយដំណោះស្រាយក្បោះក្បាយ
* លំហាត់ជ្រើសរើសសម្រាប់កិច្ចការផ្ទះ

**សម្រាប់ថ្នាក់ទី១២ ថ្នាក់វិទ្យាសាស្ត្រពិត**

អ្នករៀបរៀង លឹម ផល្គុន

2020

ស្របតាមកម្មវិធីសិក្សាគោលរបស់ក្រសួងអប់រំយុវជននិងកីឡា

# ជំពូកទី០១

# សង្ខេបមេរៀននិងរូបមន្តសំខាន់ៗ

## ១-កូអរដោនេនៃចំណុចកណ្តាលអង្កត់មួយក្នុងលំហ




$$I(\frac{x_A+x_B}{2}, \frac{y_A+y_B}{2}, \frac{z_A+z_B}{2})$$

កូអរដោនេចំណុច $I$ កណ្តាលអង្កត់ $[AB]$: $I\ (\frac{x_A+x_B}{2}, \frac{y_A+y_B}{2}, \frac{z_A+z_B}{2})$

## ២-កូអរដោនេចំណុចចែកក្នុងអង្កត់មួយក្នុងលំហ




កូអរដោនេចំណុច $P$ ចែកក្នុងអង្កត់ $[AB]$ តាមផលធៀប $\frac{PA}{PB}=\frac{m}{n}$

$P\ (\frac{mx_B+nx_A}{m+n}, \frac{my_B+ny_A}{m+n}, \frac{mz_B+nz_A}{m+n})$ ។

## ៣-កូអរដោនេចំណុចចែកក្រៅអង្កត់មួយក្នុងលំហ



កូអរដោនេចំណុច $Q$ ចែកក្រៅអង្កត់ $[AB]$ តាមផលធៀប $\frac{QA}{QB}=\frac{m}{n}$

$Q\ (\frac{mx_B-nx_A}{m-n},\frac{my_B-ny_A}{m-n},\frac{mz_B-nz_A}{m-n})$ ។

## ៤-កូអរដោនេទីប្រជុំទម្ងន់នៃត្រីកោណមួយ




$\overrightarrow{GA}+\overrightarrow{GB}+\overrightarrow{GC}=\vec{O}$

កូអរដោនេទីប្រជុំទម្ងន់ $G$ នៃត្រីកោណ $ABC$ :

$G\ (\frac{x_A+x_B+x_C}{3},\frac{y_A+y_B+y_C}{3},\frac{z_A+z_B+z_c}{3})$

## ៥-កូអរដោនេទីប្រជុំទម្ងន់នៃតេត្រាអ៊ែតមួយ




$\overrightarrow{GA}+\overrightarrow{GB}+\overrightarrow{GC}+\overrightarrow{GD}=\vec{O}$

កូអរដោនេទីប្រជុំទម្ងន់$G$ នៃតេត្រាអ៊ែត $ABCD$ :

$$G\left(\frac{x_A+x_B+x_C+x_D}{4},\frac{y_A+y_B+y_C+y_D}{4},\frac{z_A+z_B+z_c+z_D}{4}\right)$$

## ៦-កូអរដោនេនៃវ៉ិចទ័រភ្ជាប់ដោយពីរចំណុច




កូអរដោនេនៃវ៉ិចទ័រ ដែលភ្ជាប់ដោយពីរចំណុច $A$ និង $B$

$$\overrightarrow{AB}=(x_B-x_A,y_B-y_A,z_B-z_A)$$ ។

## ៧-ចម្ងាយរវាងពីរចំណុចក្នុងលំហ




ចម្ងាយរវាងពីរចំណុច $A$ និង $B$ នៅក្នុងលំហកំណត់ដោយ ៖

$$d(AB)=AB=\sqrt{(x_B-x_A)^2+(y_B-y_A)^2+(z_B-z_A)^2}$$ ។

## ៨-ប្រមាណវិធីវ៉ិចទ័រតាមកូអរដោនេនៅក្នុងលំហ

ឧបមាថាគេមានវ៉ិចទ័រ $\vec{u}=(u_1,u_2,u_3)$ និង $\vec{v}=(v_1,v_2,v_3)$

ក ) $\vec{u} = \vec{O} \Leftrightarrow \begin{cases} u_1 = 0 \\ u_2 = 0 \\ u_3 = 0 \end{cases}$

ខ ) $\vec{u} = \vec{v} \Leftrightarrow \begin{cases} u_1 = v_1 \\ u_2 = v_2 \\ u_3 = v_3 \end{cases}$

គ ) $\vec{u} = \lambda \vec{v} \Leftrightarrow \begin{cases} u_1 = \lambda v_1 \\ u_2 = \lambda v_2 \\ u_3 = \lambda v_3 \end{cases}$ ដែល $\lambda \in \mathbb{R}$ ។

ឃ ) $\vec{u} + \vec{v} = ( u_1 + v_1 , u_2 + v_2 , u_3 + v_3 )$

ង ) $\vec{u} - \vec{v} = ( u_1 - v_1 , u_2 - v_2 , u_3 - v_3 )$

ច ) $\lambda \vec{u} + \mu \vec{v} = ( \lambda u_1 + \mu v_1 , \lambda u_2 + \mu v_2 , \lambda u_3 + \mu v_3 )$ ដែល $\lambda , \mu \in \mathbb{R}$ ។

## ៩-ផលគុណស្កាលែក្នុងលំហ




ផលគុណស្កាលែរវាងពីរវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ក្នុងលំហគឺជាចំនួនពិតកំណត់

សរសេរដោយ $\vec{u} \cdot \vec{v} = |\vec{u}||\vec{v}| \cos\varphi$ ដែល $\varphi$ ជាមុំរវាង $\vec{u}$ និង $\vec{v}$ ។

## ១០-លក្ខណៈផលគុណស្កាលែក្នុងលំហ

ក ) $\vec{u}\cdot\vec{o}=\vec{o}\cdot\vec{u}=0$

ខ ) $\vec{u}\cdot\vec{v}=\vec{v}\cdot\vec{u}$

គ ) $\vec{u}\cdot\vec{u}=\vec{u}^{\,2}=|\vec{u}|^2$

ឃ ) $\lambda\vec{u}\cdot\vec{v}=\vec{u}\cdot\lambda\vec{v}=\lambda(\vec{u}\cdot\vec{v})$

ង ) $\vec{u}\cdot(\vec{v}+\vec{w})=\vec{u}\cdot\vec{v}+\vec{u}\cdot\vec{w}$

ច ) $\vec{u}\cdot(\vec{v}-\vec{w})=\vec{u}\cdot\vec{v}-\vec{u}\cdot\vec{w}$

ឆ ) $|\vec{u}+\vec{v}|^2=|\vec{u}|^2+|\vec{v}|^2+2\vec{u}\cdot\vec{v}$

ជ ) $|\vec{u}-\vec{v}|^2=|\vec{u}|^2+|\vec{v}|^2-2\vec{u}\cdot\vec{v}$

## ១១-កន្សោមវិភាគផលគុណស្កាលែក្នុងលំហ

ឧបមាថាគេមានវ៉ិចទ័រ $\vec{u}=(u_1,u_2,u_3)$ និង $\vec{v}=(v_1,v_2,v_3)$

ស្ថិតនៅក្នុងតម្រុយអរតូនរម៉ាល់ $(o,\vec{i},\vec{j},\vec{k})$ ។

ផលគុណស្កាលែរវាងវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ កំណត់ដោយ ៖

$\vec{u}\cdot\vec{v}=u_1v_1+u_2v_2+u_3v_3$ ។

## ១២-ណម ឬ ប្រវែងវ៉ិចទ័រមួយ

បើ $\vec{u}=(u_1,u_2,u_3)$ នោះ $|\vec{u}|=\sqrt{u_1^{\,2}+u_2^{\,2}+u_3^{\,2}}$ ។

## ១៣-កូស៊ីនូសនៃមុំផ្គុំដោយពីរវ៉ិចទ័រ

ឧបមាថាគេមានវ៉ិចទ័រ $\vec{u}=(u_1,u_2,u_3)$ និង $\vec{v}=(v_1,v_2,v_3)$

ស្ថិតនៅក្នុងតម្រុយអរតូនរម៉ាល់ $(o,\vec{i},\vec{j},\vec{k})$ ។

បើ $\varphi$ ជាមុំរវាង $\vec{u}$ និង $\vec{v}$ នោះគេបាន ៖

$$\cos\varphi = \frac{\vec{u}\cdot\vec{v}}{|\vec{u}||\vec{v}|} = \frac{u_1v_1 + u_2v_2 + u_3v_3}{\sqrt{u_1^2 + u_2^2 + u_3^2}\sqrt{v_1^2 + v_2^2 + v_3^2}}$$ ។

## ១៤-វ៉ិចទ័រអរតូកូណាល់ និង វ៉ិចទ័រកូលីនេអ៊ែរ

ក)វ៉ិចទ័រអរតូកូណាល់




✍ វ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ជាវ៉ិចទ័រអរតូកូណាល់គ្នាលុះត្រាតែ $\vec{u}\cdot\vec{v} = 0$ ។

✍ ឧបមាថាគេមានវ៉ិចទ័រ $\vec{u} = (u_1, u_2, u_3)$ និង $\vec{v} = (v_1, v_2, v_3)$

គេបាន $\vec{u} \perp \vec{v} \Leftrightarrow \vec{u}\cdot\vec{v} = u_1v_1 + u_2v_2 + u_3v_3 = 0$ ។

ខ) វ៉ិចទ័រកូលីនេអ៊ែគ្នា




✍ វ៉ិចទ័រ $\vec{u}$ និង $\vec{v}$ កូលីនេអ៊ែគ្នាលុះត្រាតែមានចំនួនពិត $\lambda$ ដែល $\vec{u} = \lambda\,\vec{v}$ ។

✍ ឧបមាថាគេមានវ៉ិចទ័រ $\vec{u} = (u_1, u_2, u_3)$ និង $\vec{v} = (v_1, v_2, v_3)$ ។

គេបាន $\vec{u}//\vec{v} \Leftrightarrow \frac{u_1}{v_1}=\frac{u_2}{v_2}=\frac{u_3}{v_3}$ ។

## ១៥-សមីការប៉ារ៉ាម៉ែត្រ និង សមីការឆ្លុះ

ក)សមីការប៉ារ៉ាម៉ែត្រ




បន្ទាត់$(L)$ មានមេគុណប្រាប់ទិស $\vec{u}=(\alpha,\beta,\gamma)$ ហើយកាត់តាមចំណុច

$M_0(x_0,y_0,z_0)$ មានសមីការប៉ារ៉ាម៉ែត្រកំណត់ដោយ ៖

$$\begin{cases} x = x_0+\alpha t \\ y = y_0+\beta t \\ z = z_0+\gamma t \quad , t\in\mathbb{R} \end{cases}$$

ខ)សមីការឆ្លុះ

បន្ទាត់$(L)$ មានមេគុណប្រាប់ទិស $\vec{u}=(\alpha,\beta,\gamma)$ ហើយកាត់តាមចំណុច

$M_0(x_0,y_0,z_0)$ មានសមីការឆ្លុះកំណត់ដោយ ៖

$$(L):\frac{x-x_0}{\alpha}=\frac{y-y_0}{\beta}=\frac{z-z_0}{\gamma}$$ ។

## ១៦-សមីការប្លង់




ប្លង់ $(p)$ ដែលកាត់តាមចំណុច $M_0(x_0, y_0, z_0)$ ហើយមានវ៉ិចទ័រណរម៉ាល់

$\vec{n} = (\alpha, \beta, \gamma)$ កំណត់ដោយ ៖

$(p):\ \alpha(x - x_0) + \beta(y - y_0) + \gamma(z - z_0) = 0$ ។

## ១៧-សមីការស្វ៊ែ




ស្វ៊ែ $(S)$ មានផ្ចិត $I(a, b, c)$ កាំ $R$ មានសមីការស្តង់ដា ៖

$(S):\ (x - a)^2 + (y - b)^2 + (z - c)^2 = R^2$ ។

## ១៨-ចម្ងាយពីចំណុចមួយទៅប្លង់




ចម្ងាយពីចំណុច $M_0(x_0,y_0,z_0)$ ទៅប្លង់ $(p): ax+by+cz+d=0$

កំណត់ដោយ $d(M_0,(p))=\dfrac{|ax_0+by_0+cz_0+d|}{\sqrt{a^2+b^2+c^2}}$ ។

## ១៩-ផលគុណវុចទ័រ




**និយមន័យ**

ផលគុណរវាងពីរវ៉ិចទ័រ $\vec{u}$ និង $\vec{v}$

ក្នុងលំហកំណត់ដោយ ៖

$\vec{u}\times\vec{v}=|\vec{u}||\vec{v}|\sin\varphi.\vec{k}$ ។

## ២០-កន្សោមផលគុណវុចទ័រក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន

ក្នុងលំហប្រកបដោយតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$

គេឲ្យវ៉ិចទ័រ $\vec{u}=(u_1,u_2,u_3)$ និង $\vec{v}=(v_1,v_2,v_3)$ ។ ផលគុណរវាងពីរវ៉ិចទ័រ

$\vec{u}$ និង $\vec{v}$ កំណត់ដោយ ៖

$$\vec{u}\times\vec{v}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ u_1 & u_2 & u_3\\ v_1 & v_2 & v_3\end{vmatrix}=\begin{vmatrix}u_2 & u_3\\ v_2 & v_3\end{vmatrix}\vec{i}-\begin{vmatrix}u_1 & u_3\\ v_1 & v_3\end{vmatrix}\vec{j}+\begin{vmatrix}u_1 & u_2\\ v_1 & v_2\end{vmatrix}\vec{k}$$

## ២១-ផ្ទៃក្រឡាត្រីកោណ




ផ្ទៃក្រឡានៃត្រីកោណ $ABC$ កំណត់ដោយ $S_{ABC}=\frac{1}{2}\left|\overrightarrow{AB}\times\overrightarrow{AC}\right|$

## ២២-ផ្ទៃក្រឡាប្រលេឡូក្រាម




ផ្ទៃក្រឡានៃប្រលេឡូក្រាម $ABCD$ កំណត់ដោយ $S_{ABCD}=\left|\overrightarrow{AB}\times\overrightarrow{AC}\right|$

## ២៣-មាឌប្រលេពីប៉ែត




មាឌនៃប្រលេពីប៉ែត $V = \left|(\overrightarrow{AB} \times \overrightarrow{AB}) \cdot \overrightarrow{AD}\right|$

## ២៤-មាឌតេត្រាអ៊ែត




$$V_{ABCD} = \frac{1}{6}\left|(\overrightarrow{AB} \times \overrightarrow{AB}) \cdot \overrightarrow{AD}\right|$$

## ២៥-ចម្ងាយពីចំណុចមួយទៅបន្ទាត់មួយក្នុងលំហ




ចម្ងាយពីចំណុច $P(\alpha,\beta,\gamma)$ ទៅបន្ទាត់ $(L): \begin{cases} x = x_0 + at \\ y = y_0 + bt \\ z = z_0 + ct \ , t \in \mathbb{R} \end{cases}$

កំណត់ដោយ $d(P,(L)) = \dfrac{\left|\overrightarrow{M_0P} \times \vec{u}\right|}{|\vec{u}|}$ ដែល $\vec{u} = (a,b,c), \mathrm{M}_0(x_0,y_0,z_0)$ ។

# ជំពូកទី០២

# កម្រងលំហាត់ជ្រើសរើស

## លំហាត់ទី០១

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច

$A(1,-2,1)$, $B(-1,0,2)$, $C(3,4,4)$ និង $D(5,2,5)$ ។

១.គណនាកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AB},\overrightarrow{AC},\overrightarrow{AD},\overrightarrow{BC},\overrightarrow{CD}$ និង $\overrightarrow{DB}$ ។

២.គណនារង្វាស់ទ្រនុងទាំងអស់របស់តេត្រាអ៊ែត $ABCD$ ។

៣.គណនាផលគុណស្កាលែ $\overrightarrow{AB}.\overrightarrow{CD},\overrightarrow{AC}.\overrightarrow{DB}$ និង $\overrightarrow{AD}.\overrightarrow{BC}$ ។

៤.ចូរផ្ទៀងផ្ទាត់ថា $\overrightarrow{AB}.\overrightarrow{CD}+\overrightarrow{AC}.\overrightarrow{DB}+\overrightarrow{AD}.\overrightarrow{BC}=0$ ។

៥.រកកូអរដោនេនៃចំណុច $G$ ដែល $\overrightarrow{GA}+\overrightarrow{GB}+\overrightarrow{GC}+\overrightarrow{GD}=\overrightarrow{O}$ ។

## លំហាត់ទី០២

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច ៖

$A(1,4,-5)$ , $B(-1,6,-4)$, $C(3,-2,4)$ និង $D(5,-4,3)$ ។

១.គណនា $\overrightarrow{AD}$ និង $\overrightarrow{BC}$ រួចទាញថាចតុកោណ $ABCD$ ជាប្រលេឡូក្រាម។

២.គណនារង្វាស់ជ្រុងនិងអង្កត់ទ្រូងរបស់ប្រលេឡូក្រាម $ABCD$ ។

៣.គណនាផលគុណស្កាលែ $\overrightarrow{AC}.\overrightarrow{DB}$ ។

៤.$I$ ជាចំណុចកណ្តាលនៃ$[AD]$ ហើយ $K\in[BC]$ ដែល $\overrightarrow{BK}=\frac{1}{4}\overrightarrow{BC}$ ។

គណនាកូអរដោនេនៃចំណុច $I$ និង $K$ រួចគណនារង្វាស់ $IK$ ។

៥.គណនាផលគុណស្កាលែ $\overrightarrow{IB}.\overrightarrow{IC}$ និង $\overrightarrow{KA}.\overrightarrow{KD}$ ។

## លំហាត់ទី០៣

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច

$A(2,-3,1)$ , $B(3,5,5)$ , $C(6,-7,8)$ និង $D(10,-2,-3)$ ។

១.គណនា $\overrightarrow{AB}.\overrightarrow{AC}$ , $|\overrightarrow{AB}|$ និង $|\overrightarrow{AC}|$ រួចទាញរកប្រភេទនៃត្រីកោណ $ABC$ ។

២.គណនា $\overrightarrow{DA}.\overrightarrow{AB}$ និង $\overrightarrow{DA}.\overrightarrow{AC}$ រួចទាញថា $\overrightarrow{DA}\perp\overrightarrow{BC}$ ។

៣.ស្រាយថា $BCD$ ជាត្រីកោណសម័ង្ស ។

៤.រកកូអរដោនេនៃចំណុច $E$ ដោយដឹងថា $\overrightarrow{AE}=\overrightarrow{AB}+\overrightarrow{AC}+\overrightarrow{AD}$ ។

៥.ចូរស្រាយថា $(AE)\perp(BCD)$ ។

## លំហាត់ទី០៤

ក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យត្រីកោណ $ABC$

មានកំពូល $A(-2,3,-4)$ , $B(4,9,-1)$ និង $C(2,-5,4)$ ។

១.គណនា $AB,AC$ និង $BC$ រួចបង្ហាញថា $ABC$ ជាត្រីកោណកែងត្រង់ $A$ ។

២.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(AB),(AC)$ និង $(BC)$ ។

៣.រកកូអរដោនេនៃចំណុច $I$ ដោយដឹងថា $BC.\overrightarrow{IA}+AC.\overrightarrow{IB}+AB.\overrightarrow{IC}=\overrightarrow{O}$ ។

៤.ចូរផ្ទៀងផ្ទាត់ថា $BC.IA^2+AC.IB^2+AB.IC^2=BC.AC.AB$ ។

៥.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(IA),(IB),(IC)$ ។

## លំហាត់ទី០៥

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យពីរចំណុច ៖

$A(2,-3,1)$ និង $B(6,9,7)$ ។

១.គណនាកូអរដោនេ $I$ កណ្ដាលអង្កត់ $[AB]$ រួចគណនាប្រវែង $AB$ ។

២.សរសេរសមីការទូទៅនៃស្វ៊ែ $(S)$ មានអង្កត់ផ្ចិត $AB$ ។

៣.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(AB)$ និងសមីការប្លង់មេដ្យាទ័រនៃ $[AB]$ ។

៤.គេឲ្យចំណុច $C(1,1,-2)$ ។ ចូរផ្ទៀងផ្ទាត់ថា $C\in(S)$ រួចសរសេរសមីការនៃ
ប្លង់ $(P)$ ប៉ះនឹងស្វ៊ែ $(S)$ ត្រង់ចំណុច $C$ ។

៥.$D$ ជាចំណុចមួយដែល $\overrightarrow{CD}=\overrightarrow{CA}+\overrightarrow{CB}$ ។ រកកូអរដោនេនៃចំណុច $D$ រួច
ទាញរកប្រភេទនៃចតុកោណ $CADB$ ។

## លំហាត់ទី០៦

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យចំណុច $A$ មាន
កូអរដោនេ $(3,1,1)$ និងប្លង់ $(P)$ មានសមីការ $2x-y-2z+6=0$ ។

១.គណនាចម្ងាយពីចំណុច $A$ ទៅប្លង់ $(P)$ ។

២.$H$ ជាជើងនៃចំណោលកែងនៃចំណុច $A$ លើប្លង់ $(P)$ ។គណនាកូអរដោនេនៃ
ចំណុច $H$ រួចសរសេរសមីការទូទៅនៃស្វ៊ែ $(S)$ មានផ្ចិត $H$ ហើយកាត់តាម $A$ ។

៣.$B$ ជាចំណុចមានអាប់ស៊ីស $x_b=0$ ហើយ $B\in(P)$ និង $B\in(S)$ ។
ចូរគណនាកូអរដោនេនៃចំណុច $B$ ។

៤.$C$ ជាចំណុចមានអរដោនេ $y_c = 0$ ហើយ $C \in (P)$ និង $C \in (S)$ ។

ចូរគណនាកូអរដោនេនៃចំណុច $C$ ។

៥.គេឲ្យចំណុច $D(3,4,4)$ ។ ចូរផ្ទៀងផ្ទាត់ថា $D \in (P)$ និង $D \in (S)$ ។

ចូរសរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(L)$ ប៉ះនឹងស្វ៊ែ $(S)$ ត្រង់ចំណុច $D$

ដោយដឹងថា $(L) \subset (P)$ ។

## លំហាត់ទី០៧

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o, \vec{i}, \vec{j}, \vec{k}\right)$ គេឲ្យបន្ទាត់ $(L)$ មាន

សមីការឆ្លុះ $\frac{x-3}{2} = \frac{y-3}{2} = z-2$ និងចំណុច $A(2,-1,3)$ ។

$H$ ជាជើងនៃចំណោលកែងនៃចំណុច $A$ ទៅលើបន្ទាត់ $(L)$ ។

១.គណនាកូអរដោនេនៃចំណុច $H$ រួចគណនាប្រវែង $AH$ ។

២.សរសេរសមីការស្តង់ដានៃស្វ៊ែ $(S)$ មានផ្ចិត $H$ ហើយកាត់តាមចំណុច $A$ ។

៣.គណនាកូអរដោនេនៃចំណុច $B$ និង $C$ ជាប្រសព្វរវាងបន្ទាត់ $(L)$ និងស្វ៊ែ $(S)$ ។

៤.$P$ ជាចំណុចមួយផ្ទៀងផ្ទាត់ $\overrightarrow{AP} = \overrightarrow{AB} + \overrightarrow{AC}$ ។ គណនាកូអរដោនេនៃ $P$ ។

៥.ផ្ទៀងផ្ទាត់ថា $P \in (S)$ រួចរកប្រភេទនៃចតុកោណ $PBAC$ ។

## លំហាត់ទី០៨

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o, \vec{i}, \vec{j}, \vec{k}\right)$ គេឲ្យស្វ៊ែ $(S)$ មាន

សមីការ $x^2 + y^2 + z^2 - 4x + 2y - 2z - 3 = 0$ និងចំណុច $P(-1,5,7)$ ។

១.គណនាកូអរដោនេនៃផ្ចិត $I$ និងកាំ $r$ របស់ស្វ៊ែ $(S)$ រួចគណនា $IP$ ។

២.បន្ទាត់$(IP)$ប្រសព្វស្វ៊ែ$(S)$ ត្រង់ចំណុច$A$ និង $B$ ដែល$A$ នៅចន្លោះចំណុច $I$ និង$P$ ។ គណនា $PA$ និង $PB$ ។

៣.គណនាកូអរដោនេនៃចំណុច $A$ និង $B$ ។

៤.រកសំណុំនៃចំណុច$M$ ស្ថិតនៅលើស្វ៊ែ$(S)$ដែលផ្ទៀងផ្ទាត់$PM^2 = PA.PB$ ។

## <u>លំហាត់ទី០៩</u>

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន$\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច

$A(0;-3;-4)$ ; $B(2,1,8)$ ; $C(2;4;5)$ និង $D(4;-2,-3)$ ។ $M$ និង $N$ ជាពីរចំណុចស្ថិតនៅលើបន្ទាត់រៀងគ្នា $(AB)$ និង $(CD)$ ។

កំណត់កូអរដោនេនៃចំនុច $M$ និង $N$ ដើម្បីឲ្យអង្កត់$MN$មានប្រវែងខ្លីបំផុត រួចកំណត់ប្រវែងខ្លីបំផុតនោះ ។

## <u>លំហាត់ទី១០</u>

ក្នុងតម្រុយអរតូណម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$ គេមានបីចំណុច $A(-1,2,3)$ , $B(0,-1,1)$ និង $C(2,3,5)$ ។

១.ចូរកំណត់សមីការប្លង់ $(P)$កាត់តាមចំណុច $A$ ហើយកែងនឹងវ៉ិចទ័រ $\overline{BC}$ និងសមីការប៉ារ៉ាម៉ែត្របន្ទាត់ $(L)$ កាត់តាមពីរចំណុច$B$ និង $C$ ។

២.គណនាកូអរដោនេនៃចំណុចប្រសព្វ $H$ រវាងបន្ទាត់ $(L)$ ជាមួយប្លង់ $(P)$ ។

៣.រកប្រភេទនៃត្រីកោណ $ABC$ រួចគណនាផ្ទៃក្រលានៃ $\Delta ABC$ ។

## លំហាត់ទី១១

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន$\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបន្ទាត់$(L)$មាន

សមីការប៉ារ៉ាម៉ែត្រ$(L):\begin{cases}x=2+t\\y=6+4t\\z=2-t\quad ,t\in\mathbb{R}\end{cases}$ និងប្លង់$(P):2x+2y+z-9=0$។

១.គណនាកូអរដោនេនៃចំណុចប្រសព្វ$A$រវាងបន្ទាត់$(L)$និងប្លង់$(P)$។

២.$M$ ជាចំណុចមានអាប់ស៊ីស$x=3$និងស្ថិតនៅលើ$(L)$ហើយ $H$ជាចំណោលកែងនៃចំណុច$M$ទៅលើប្លង់$(P)$។គណនាកូអរដោនេនៃចំណុច$M$និង$H$។

៣.គេសង់ប្លង់$(Q)$កែងនឹងបន្ទាត់$(L)$ត្រង់$M$ហើយគេតាង$(d)$ ជាបន្ទាត់ប្រសព្វរវាងប្លង់$(P)$និង$(Q)$។សរសេរសមីការប្លង់$(Q)$និងសមីការប៉ារ៉ាម៉ែត្របន្ទាត់$(d)$។

៤.គេគូសបន្ទាត់$(AH)$ប្រសព្វប្លង់$(Q)$ត្រង់$K$។ចូរសរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(AH)$ រួចគណនាកូអរដោនេនៃចំណុច$K$ ។

៥.គណនា$MA$និង$MK$ រួចទាញបញ្ជាក់ប្រភេទនៃត្រីកោណ$AMK$ ។

## លំហាត់ទី១២

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន$\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបន្ទាត់$(L)$មាន

សមីការប៉ារ៉ាម៉ែត្រ$(L):\begin{cases}x=1+t\\y=5-4t\\z=4-t\quad ,t\in\mathbb{R}\end{cases}$ និងប្លង់$(P):x+2y+2z-10=0$។

១.គណនាកូអរដោនេនៃចំណុចប្រសព្វ$A$រវាងបន្ទាត់$(L)$និងប្លង់$(P)$។

២.គេសង់ប្លង់$(Q)$កែងនឹងបន្ទាត់$(L)$ត្រង់$A$និងសង់បន្ទាត់$(d)$កែងនឹងប្លង់$(P)$

ត្រង់ចំណុច $A$ ដែរ។ចូរសរសេរសមីការប្លង់ $(Q)$ និងសមីការប៉ារ៉ាម៉ែត្របន្ទាត់ $(d)$ ។

៣. $M$ ជាចំណុចមានអាប់ស៊ីស $x=0$ និងស្ថិតនៅលើបន្ទាត់ $(d)$ ហើយ $H$ និង $K$ ជាជើងនៃចំណោលកែងនៃចំណុច $M$ ទៅលើបន្ទាត់ $(d)$ និងប្លង់ $(Q)$ រៀងគ្នា។ គណនាកូអរដោនេនៃចំណុច $M,H$ និង $K$ ។

៤.ចូរស្រាយថាបួនចំណុច $M,H,A,K$ ស្ថិតនៅក្នុងប្លង់តែមួយ។

៥.ចូរស្រាយថាចតុកោណ $MHAK$ ជាការេ។

**<u>លំហាត់ទី១៣</u>**

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបន្ទាត់ $(L)$ មាន

សមីការប៉ារ៉ាម៉ែត្រ $(L):\begin{cases} x=1+t \\ y=4-t \\ z=9-4t \quad ,t\in\mathbb{R} \end{cases}$ និងប្លង់ $(P): 2x+y-2z-6=0$ ។

១.គណនាកូអរដោនេនៃចំណុចប្រសព្វ $A$ រវាងបន្ទាត់ $(L)$ និងប្លង់ $(P)$ ។

២.គេឲ្យ $B(5,6,5)$ ។ ចូរផ្ទៀងផ្ទាត់ថា $B\in(P)$ ។

៣.ពីចំណុច $B$ គេគូសបន្ទាត់ $(BH)$ កែងនឹងបន្ទាត់ $(L)$ ដោយ $H\in(L)$ ។
គណនាកូអរដោនេនៃចំណុច $H$ រួចសរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(BH)$ ។

៤.គេយក $I$ ជាចំណុចកណ្ដាលនៃ $[AB]$ ។ គណនាកូអរដោនេនៃចំណុច $I$ រួចទាញបង្ហាញថា $\overrightarrow{IH}$ ជាវ៉ិចទ័រនរម៉ាល់នៃប្លង់ $(P)$ ។

៥. $K$ ជាចំណុចឆ្លុះគ្នានៃចំណុច $H$ ធៀបនឹងប្លង់ $(P)$ ។គណនាកូអរដោនេនៃ $K$ រួចស្រាយបញ្ជាក់ថាចតុកោណ $AHBK$ ជាការេ។

## លំហាត់ទី១៤

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច

$A(1,2,3),B(3,6,-1),C(4,3,3)$ និង $D(2,1,1)$ ។

១.ចូរសរសេរសមីការស្តង់ដានៃស្វ៊ែ $(S)$ មានអង្កត់ផ្ចិត $[AB]$ ។

២.បង្ហាញថា $C\in(S)$ និង $D\in(S)$ ។សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(CD)$ ។

៣.សរសេរសមីការប្លង់ $(P)$ និងប្លង់ $(Q)$ ដែលកាត់តាមចំណុចរៀងគ្នា $C$ និង $D$

ហើយកែងនឹងវ៉ិចទ័រ $\overrightarrow{AB}$ ។

៤.ចូរបង្ហាញថាបួនចំណុច $A,B,C,D$ មិនស្ថិតក្នុងប្លង់តែមួយ។

៥.គណនាមាឌតេត្រាអ៊ែត $ABCD$ ។

## លំហាត់ទី១៥

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច

$A(3,-4,-2),B(1,0,-5),C(5,-2,-5)$ និង $D(4,-2,0)$ ។

១.គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$ រួចទាញថាបីចំណុច $A,B,C$ មិនស្ថិត

នៅលើបន្ទាត់តែមួយ។ គណនាផ្ទៃក្រឡានៃត្រីកោណ $ABC$ ។

២.គណនា $\overrightarrow{AD}$ រួចផ្ទៀងផ្ទាត់ថា $\overrightarrow{AD}=-\frac{1}{6}\overrightarrow{AB}\times\overrightarrow{AC}$ ។ គណនារង្វាស់ $AD$

រួចទាញរកមាឌនៃតេត្រាអ៊ែត $ABCD$ ។

៣.គណនា $\overrightarrow{OB}$ និង $\overrightarrow{DC}$ រួចទាញថា $OBCD$ ជាប្រលេឡូក្រាម។

៤.សរសេរសមីការប្លង់ $(ABC)$ និងសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(d)$ គូសចេញពី

គល់ $O$ ហើយកែងនឹងប្លង់ $(ABC)$ ត្រង់ $H$ ។

៥.គណនាកូអរដោនេនៃចំណុច $H$ រួចបង្ហាញថា $AHBC$ ជាប្រលេឡូក្រាម។

## លំហាត់ទី១៦

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបីចំណុច

$A(2,-3,4),B(3,1,3),C(-1,0,4)$ និងប្លង់ $(P): x-2y+2z-7=0$ ។

១.គណនា $AB,AC$ និង $BC$ រួចបង្ហាញថា $ABC$ ជាត្រីកោណសម័ង្ស។

២.ផ្ទៀងផ្ទាត់ថា $B\in(P)$ និង $C\in(P)$ ។សរសេរសមីការប៉ារ៉ាម៉ែត្របន្ទាត់ $(BC)$ ។

៣. $H$ ជាជើងនៃចំណោលកែងនៃ $A$ លើប្លង់ $(P)$ ។គណនាកូអរដោនេនៃ $H$ ។

៤.គេតាង $\vec{u}=\frac{1}{3}\overrightarrow{HB}$ , $\vec{v}=\frac{1}{3}\overrightarrow{HC}$ និង $\vec{w}=\frac{1}{3}\overrightarrow{HA}$ ។

ចូរស្រាយថា $\left(\vec{u},\vec{v},\vec{w}\right)$ ជាគោលអរតូនរម៉ាល់មានទិសដៅវិជ្ជមាន។

៥.ចូរសរសេរសមីការប្លង់ $(HAB),(HAC)$ និង $(HBC)$ ។

## លំហាត់ទី១៧

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច

$S(3,4,4)$ , $A(2,6,2),B(-1,3,5)$ និង $C(3,1,1)$ ។

១.គណនា $AB,AC$ , $SB$ និង $SC$ រួចទាញរកប្រភេទត្រីកោណ $ABC$ & $SBC$ ។

២.គណនាផលគុណស្កាលែ $\overrightarrow{SA}.\overrightarrow{AB}$ និង $\overrightarrow{SA}.\overrightarrow{AC}$ ។

៣.ស្រាយបញ្ជាក់ថាប្លង់ $(P)$ កាត់តាម $S$ ហើយកែងនឹងវ៉ិចទ័រ $\overrightarrow{SA}$ មានសមីការ

$x-2y+2z-3=0$ ។

៤.តាង $I$ ជាចំណុចកណ្តាលនៃ $[BC]$ ។ គណនាកូអរដោនេនៃចំណុច $I$ ។

សរសេរសមីការប្លង់មេដ្យាទ័រ $(Q)$ នៃអង្កត់ $[BC]$ ។

៥.ចូរផ្ទៀងផ្ទាត់ថា $A\in(Q)$ និង $S\in(Q)$ ។ គណនារង្វាស់មុំ $\angle SIA$ ។

## **លំហាត់ទី១៨**

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច

$A(2,3,-1),B(-1,0,-1),C(5,3,5)$ និង $D(8,6,5)$ ។

១.គណនា $\overrightarrow{AD}$ និង $\overrightarrow{BC}$ រួចទាញបញ្ជាក់ប្រភេទចតុកោណ $ABCD$ ។

២.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(BC)$ និង $(CD)$ ។

៣. $H$ ជាចំណោលកែងនៃ $A$ លើ $BC$ ហើយ $K$ ជាចំណោលកែងនៃ $H$ លើ $CD$ ។

គណនាកូអរដោនេនៃចំណុច $H$ និង $K$ ។

៤.គណនា $AH$ និង $BC$ រួចគណនាផ្ទៃក្រឡាចតុកោណ $ABCD$ ។

៥.ចូរស្រាយថា $KCH$ ជាត្រីកោណកែងសមបាត។

៦.រកកូអរដោនេនៃចំណុច $L$ ដោយដឹងថា $HKCL$ ជាការេ។

តើចំណុច $B,L,D$ រត់ត្រង់គ្នាឬទេ ?

## **លំហាត់ទី១៩**

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបីចំណុច

$A(-4,1,-2),\ B(-1,7,4)$ និង $C(4,-7,2)$ ។

១.គណនា $AB,AC$ និង $BC$ រួចទាញថា $ABC$ ជាត្រីកោណកែង។

២.កំណត់សមីការប្លង់$(ABC)$ ។

៣.រកកូអរដោនេនៃចំណុច$I$ ដែលផ្ទៀងផ្ទាត់ $BC.\overrightarrow{IA}+AC.\overrightarrow{IB}+AB.\overrightarrow{IC}=\overrightarrow{O}$

៤.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(IA),(IB),(IC)$ ។

៥.គេឲ្យចំណុច $M(x,y,z)$នៃលំហ។ ចូរស្រាយបញ្ជាក់ថា ៖

$BC.MA^2+AC.MB^2+AB.MC^2=(BC+AC+AB)MI^2+BC.AC.AB$

## លំហាត់ទី២០

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន$\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបីចំណុច

$A(1,-1,-3)$ , $B(2,-3,-1)$ និង $C(4,1,3)$ ។

១.គណនា $AB,AC$ និង $BC$ ។

២.រកកូអរដោនេនៃចំណុច $D$ ដោយដឹងថា$ABCD$ ជាប្រលេឡូក្រាម។

៣.រកកូអរដោនេចំណុច$I$កណ្តាលអង្កត់$[BC]$រួចសរសេរសមីការប្លង់មេដ្យាទ័រ
នៃអង្កត់$[BC]$ ។

៤.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(ID)$ ។

៥.សរសេរសមីការស្វ៊ែ$(S)$ មានផ្ចិត$I$ និងកាំ $r=AB$ ។

## លំហាត់ទី២១

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន$\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យពីរចំណុច

$A(1,1,0)$ និង $B(3,-3,4)$ ។

១.សរសេរសមីការប្លង់មេដ្យាទ័រ$(P)$ នៃអង្កត់$[AB]$ ។

២.សរសេរសមីការទូទៅនៃស្វ៊ែ$(S)$មានអង្កត់ផ្ចិត $AB$ ។

៣.ចូរផ្ទៀងផ្ទាត់ថា $O\in(S)$ ( $O$ ជាគល់នៃតម្រុយអរតូនរម៉ាល់ )។

សរសេរសមីការប្លង់$(Q)$ ប៉ះនឹងស្វ៊ែ$(S)$ ត្រង់$O$ ។

៤.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(L)$ ជាប្រសព្វរវាងប្លង់$(P)$និង$(Q)$ ។

## លំហាត់ទី២២

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន$\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបីចំណុច

$A(1,1,1)$ , $B(2,-3,4)$ និង $C(3,-4,-2)$ ។

១.រកកូអរដោនេនៃចំណុច$G$ ដោយដឹងថា $\overrightarrow{GA}+\overrightarrow{GB}+\overrightarrow{GC}=\vec{O}$ ។

២.សរសេរសមីការទូទៅនៃស្វ៊ែ$(S)$មានផ្ចិត$O$និងកាំ$OG$ ។

៣.សរសេរសមីការប្លង់$(P)$ ប៉ះនឹងស្វ៊ែ$(S)$ ត្រង់$G$ ។

៤.សរសេរសមីការប្លង់$(Q)$ កាត់តាម$G$ ហើយកែងនឹង $\vec{n}=(9,3,1)$ ។

៥.ចូរផ្ទៀងផ្ទាត់ថាបីចំណុច$A,B,C$ ស្ថិតនៅក្នុងប្លង់ $(P)$ ។

៦.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(L)$ ជាប្រសព្វរវាងប្លង់ $(P)$ និង$(Q)$ ។

## លំហាត់ទី២៣

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន$\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច

$A(1,-2,-4)$ , $B(-1,-4,-3)$,$C(3,4,5)$ និង $D(7,-7,-2)$ ។

១.គណនាផលគុណស្កាលែ $\overrightarrow{AD}.\overrightarrow{AB}$ និង $\overrightarrow{AD}.\overrightarrow{AC}$ រួចទាញថា $\overrightarrow{AD}\perp\overrightarrow{BC}$ ។

២.គណនាជ្រុងទាំងបីនៃត្រីកោណ$ABC$ ។

៣.ស្រាយថាប្លង់$(ABC)$ មានសមីការ $6x-5y+2z-8=0$ ។

៤.យក$I$ ជាចំណុចកណ្តាលនៃ$[BC]$ ។ គណនាកូអរដោនេនៃចំណុច $I$ រួច

សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(ID)$ ។

៤.សរសេរសមីការប្លង់មេដ្យាទ័រ$(Q)$ នៃអង្កត់$[BC]$ ។

៥.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(L)$ ជាប្រសព្វរវាងប្លង់ $(P)$ និង$(Q)$ ។

**លំហាត់ទី២៤**

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន$\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យពីរចំណុច

$A(-4,1,3)$និង $B(2,3,-1)$ និងប្លង់$(P): x+2y-2z-1=0$ ។

១.ចូរសរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(AB)$ ។

២.គណនាកូអរដោនេនៃចំណុច$M$ ជាប្រសព្វរវាងបន្ទាត់$(AB)$និងប្លង់$(P)$រួច

បង្ហាញថា $M$ ជាចំណុចកណ្តាលនៃអង្កត់$[AB]$ ។

៣.$H$ ជាចំណោលកែងនៃចំណុច$B$ លើប្លង់$(P)$ ។ សរសេរសមីការប៉ារ៉ាម៉ែត្រ

នៃបន្ទាត់$(BH)$ រួចគណនាកូអរដោនេនៃចំណុច$H$ ។

៤.$K$ ជាចំណោលកែងនៃ$A$ លើបន្ទាត់$(BH)$ ។ បង្ហាញថា$MH$ ជាបាតមធ្យម

នៃត្រីកោណ$ABK$ រួចទាញរកកូអរដោនេនៃចំណុច$K$ ។

៥.$L$ ជាចំណោលកែងនៃ$A$លើប្លង់$(P)$។បង្ហាញថា$ALHK$ជាចតុកោណកែង

រួចទាញរកកូអរដោនេនៃចំណុច $L$ ។

## លំហាត់ទី២៥

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបន្ទាត់ពីរ ៖

$$(L_1): \frac{x+1}{-1}=\frac{y+3}{-2}=\frac{z-5}{2} \quad \text{និង} \quad (L_2): \begin{cases} x=2+t \\ y=3 \\ z=-1-t \quad ,t\in\mathbb{R} \end{cases}$$

១.គណនាកូអរដោនេនៃចំណុចប្រសព្វ $M$ រវាងបន្ទាត់ $(L_1)$ និង $(L_2)$ ។

២.$A$ និង $B$ ជាពីរចំណុចស្ថិតនីលើបន្ទាត់$(L_2)$ ហើយមានអាប់ស៊ីសរៀងគ្នា $x_a=-1$ និង $x_b=5$ ។ គណនាកូអរដោនេនៃចំណុច $A$ និង $B$ ។

៣.$H$ និង $K$ ជាជើងនៃចំណោលកែងនៃចំណុច $A$ និង $B$ទៅលើបន្ទាត់$(L_1)$ រៀងគ្នា ។ គណនាកូអរដោនេនៃចំណុច$H$ និង $K$ ។

៤.គណនា $\overrightarrow{AK}$ និង $\overrightarrow{HB}$ រួចទាញរកប្រភេទនៃចតុកោណ $AHBK$ ។

៥.គណនា $AH$ និង $HK$ រួចទាញរកផ្ទៃក្រឡានៃចតុកោណ $AHBK$ ។

## លំហាត់ទី២៦

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច៖

$A(1,1,1),B(2,3,3),C(6,-1,5)$ និង $D\left(6,-4,\frac{7}{2}\right)$ ។

១.គណនាកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AB},\overrightarrow{AC},\overrightarrow{AD},\overrightarrow{BC}$ និង $\overrightarrow{CD}$ ។

២.បង្ហាញថា $\overrightarrow{AD}//\overrightarrow{BC}$ និង$\overrightarrow{AB}\perp\overrightarrow{AD}$ រួចរកប្រភេទនៃចតុកោណ$ABCD$។

៣.គណនា $\overrightarrow{AC}.\overrightarrow{CD}$ រួចទាញរកប្រភេទនៃត្រីកោណ$ACD$ ។

៤.$H$ ជាជើងនៃចំណោលកែងចំណុច $C$ លើ $[AD]$ ។គណនាកូអរដោនេនៃ $H$ ។

៥.គណនា $AB$ , $BC$ និង $AD$ រួចទាញរកផ្ទៃក្រឡានៃចតុកោណ $ABCD$ ។

## លំហាត់ទី២៧

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច

$A(4,1,4),B(3,5,5),C(3,-1,2)$ និង $D\left(\frac{5}{2},1,\frac{5}{2}\right)$ ។

១.គណនា $\overrightarrow{AB}.\overrightarrow{AD}$ និង $\overrightarrow{AD}.\overrightarrow{DC}$ រួចទាញរកប្រភេទនៃចតុកោណ $ABCD$ ។

២.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(AD)$ និង $(BC)$ ។

៣.$M$ ជាចំណុចស្ថិតនៅលើបន្ទាត់ $(AD)$ ដោយដឹងថាចំណុច $M$ មានអាប់ស៊ីស

$x_m = 1$ ។ ចូរគណនាកូអរដោនេនៃចំណុច $M$ ។

៤.គណនា $\overrightarrow{MB}.\overrightarrow{MC}$ រួចទាញរកប្រភេទនៃត្រីកោណ $MBC$ ។

៥.គណនា $MB$ និង $MC$ រួចទាញរកផ្ទៃក្រឡានៃត្រីកោណ $MBC$ ។

## លំហាត់ទី២៨

ក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យស្វ៊ែ $(S)$ សមីការ

$(x-1)^2+(y+1)^2+(z-2)^2=9$ និងបន្ទាត់ $(L)$: $\begin{cases} x=-4+3t \\ y=-7+4t \\ z=2+t \quad , t\in\mathbb{R} \end{cases}$

១.គណនាកូអរដោនេនៃចំណុចប្រសព្វ $A$ និង $B$ រវាងបន្ទាត់ $(L)$ និងស្វ៊ែ $(S)$ ។

(គេដឹងថាចំណុច $A$ មានអាប់ស៊ីសអវិជ្ជមាន )។

២.សរសេរសមីការប្លង់$(P)$ និង $(Q)$ ប៉ះទៅនឹងស្វ៊ែ$(S)$រៀងគ្នាត្រង់ $A$ និង $B$ ។

៣.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(d)$ ជាប្រសព្វរវាងប្លង់$(P)$ និង $(Q)$ ។

៤.សរសេរសមីការប្លង់$(\pi)$ កាត់តាមចំណុច $A$ ហើយកែងនឹងបន្ទាត់$(d)$ ។

៥.ចូរផ្ទៀងផ្ទាត់ថា $B\in(\pi)$ រួចសរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(\Delta)$ ដែលកែងនឹងប្លង់$(\pi)$ ត្រង់ $B$ ។

**<u>លំហាត់ទី២៩</u>**

ក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន$\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យស្វ៊ែ$(S)$សមីការ

$(x+5)^2+(y+2)^2+(z+1)^2=36$ និងបន្ទាត់$(L)$: $\begin{cases} x=-1+2t \\ y=3+t \\ z=-3+2t \quad , t\in\mathbb{R} \end{cases}$

១.គណនាកូអរដោនេនៃផ្ចិត $I$ និងកាំ $r$ របស់ស្វ៊ែ$(S)$ ។

២.យក $H$ ជាជើងនៃចំណោលកែងនៃចំណុច $I$ លើបន្ទាត់$(L)$ ។
គណនាកូអរដោនេនៃចំណុច $H$ និងរង្វាស់ $IH$ រួចទាញថាបន្ទាត់$(L)$ ប៉ះទៅនឹងស្វ៊ែ$(S)$ ត្រង់ចំណុច $H$ ។

៣.$A$ និង $B$ ជាចំណុចពីរស្ថិតនៅលើបន្ទាត់$(L)$ ហើយមានអាប់ស៊ីសរៀងគ្នា $x_a=-5$ និង $x_b=5$ ។ គណនាកូអរដោនេនៃចំណុច $A$ និង $B$ ។

៤.គណនា $AB$ , $IA$ និង $IB$ រួចទាញបញ្ជាក់ប្រភេទនៃត្រីកោណ $IAB$ ។

៥.គណនាផលគុណវ៉ិចទ័រ $\overrightarrow{IA}\times\overrightarrow{IB}$ រួចគណនាផ្ទៃក្រឡានៃត្រីកោណ $IAB$ ។

៦.សរសេរសមីការប្លង់$(IAB)$និងសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(IA)$,$(IB)$,$(IH)$

## លំហាត់ទី៣០

គេឲ្យប្លង់ពីរ $(\alpha): x+2y+2z-11=0$ , $(\beta): 2x-2y+z-1=0$

និងបន្ទាត់ $(\Delta): x=3+t\ ,y=6-4t\ ,\ z=7-t$ ដែល $t\in\mathbb{R}$

១.គណនាកូអរដោណេចំណុចប្រសព្វ $A$ និង $B$ រវាងបន្ទាត់ $(\Delta)$ ជាមួយប្លង់ $(\alpha)$ និង $(\beta)$ រៀងគ្នា ។

២.យក $C$ ជាចំណុចមានអាប់ស៊ីស $x=1$ ហើយស្ថិតនៅក្នុងប្លង់ $(\alpha)$ និង $(\beta)$ ។ រកកូអរដោនេនៃចំណុច $C$ រួចរក្រេបភេទនៃ $\Delta ABC$ ។

៣.កំណត់សមីការស្វ៊ែ $(S)$ មានផ្ចិតនៅលើបន្ទាត់ $(\Delta)$ ហើយប៉ះរួមទៅនឹងប្លង់ $(\alpha)$ និង $(\beta)$ ។

## លំហាត់ទី៣១

ក្នុងលំហប្រដាប់ដោយតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$

គេឲ្យប្លង់ $(p):\ x-2y+2z-6=0$ និងបន្ទាត់ $(L): \dfrac{x+1}{-1}=\dfrac{y-3}{2}=\dfrac{z+3}{-2}$ ។

១.ចូរបង្ហាញថា $(L)\perp(p)$ រួចគណនាកូអរដោនេចំណុចប្រសព្វ $M$ រវាងបន្ទាត់ $(L)$ ជាមួយប្លង់ $(p)$ ។

២.តាង $A,B,C$ ជាចំណុចប្រសព្វរវាង $(p)$ ជាមួយអ័ក្ស $(ox),(oy),(oz)$ រៀងគ្នា។ ចូរគណនា $\overrightarrow{AB}\times\overrightarrow{AC}$ រួចទាញរកផ្ទៃក្រឡានៃត្រីកោណ $ABC$ ។

៣.គណនាកូអរដោនេចំណុច $D$ ដោយដឹងថា $ABCD$ ជាប្រលេឡូក្រាម។

## លំហាត់ទី៣២

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យវ៉ិចទ័រពីរ

$\vec{u}=2\vec{i}-\vec{j}$ និង $\vec{v}=2\vec{i}-2\vec{j}-\vec{k}$ ។

១.គណនា $\vec{n}=\vec{u}\times\vec{v}$ និង $|\vec{n}|$ ។

២.កំណត់សមីការប្លង់ $(p)$ កាត់តាមចំណុច $A(-1,2,-3)$ ហើយកែងនឹង $\vec{n}$ ។

៣.កំណត់សមីការស្វ៊ែ $(S)$ មានផ្ចិត $O$ ហើយប៉ះនឹងប្លង់ $(p)$ ។

## លំហាត់ទី៣៣

ក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$ គេឲ្យបួនចំណុច

$A(1,2,3);B(2,3,-6);\ C(-2,1,-2)$ និង $D(0,4,0)$ ។

១.ចូរគណនាផលគុណវ៉ិចទ័រ $\overrightarrow{BC}\times\overrightarrow{BD}$ រួចទាញថាបីចំណុច $B,C,D$ មិនរត់ត្រង់គ្នា ។

គណនាផ្ទៃក្រលានៃត្រីកោណ $BCD$ រួចកំណត់សមីការប្លង់ $(BCD)$ ។

២.គណនាមាឌតេត្រាអ៊ែត $ABCD$ រួចទាញរកចម្ងាយពី $A$ ទៅប្លង់ $(BCD)$ ។

៣.$H$ ជាចំណោលកែងនៃ $A$ លើប្លង់បាត $(BCD)$ ។

កំណត់សមីការបន្ទាត់ $(AH)$ រួចរកកូអរដោនេ $H$ ។

## លំហាត់ទី៣៤

នៅក្នុងតម្រុយអរតូណម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$ មួយគេឲ្យមាន

ចំណុច $A(0,2,1),B(2,1,-1),C(-4,5,3)$ និង $D(4,6,3)$ ។

១.ចូរស្រាយថា $\overrightarrow{AB}\times\overrightarrow{AC}=\overrightarrow{AD}$ រួចគណនាផ្ទៃក្រឡានៃ $\Delta ABC$ ។

២.កំណត់សមីការប្លង់ $(ABC)$ ។

៣.គណនា $(\overrightarrow{AB}\times\overrightarrow{AC}).\overrightarrow{AD}$ រួចទាញរកមាឌនៃតេត្រាអ៊ែត $ABCD$ ។

៤.ទាញរកចម្ងាយពីចំណុច $D$ ទៅប្លង់ $(ABC)$ ។

## លំហាត់ទី៣៥

ក្នុងតំរុយអរតូណរម៉ាល់ដែលមានទិសដៅវិជ្ជមាន $\left(0,\vec{i},\vec{j},\vec{k}\right)$ គេឲ្យចំណុច

$A(0,0,2)$ ,$B(2,0,1)$ ,$C(2,2,3)$ និង $D(0,2,4)$ ។

១.បង្ហាញថាចតុកោណ $ABCD$ ជាប្រលេឡូក្រាម។

២.គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AD}$ រួចគណនាក្រឡាផ្ទៃប្រលេឡូក្រាម $ABCD$

៣.សរសេរសមីការប្លង់ $(ABC)$ និងសមីការប៉ារ៉ាម៉ែត្របន្ទាត់ $(L)$ កែងទៅនឹងប្លង់ $(ABC)$ ត្រង់ $D$ ។

៤.កំណត់កូអរដោនេនៃចំនុច $E$ បើគេដឹងថា $\overrightarrow{AE}=\frac{1}{2}\left(\overrightarrow{AB}\times\overrightarrow{AD}\right)$ ។

៥.គណនាមាឌរបស់ពីរ៉ាមីតដែលមានកំពស់ $[AE]$ និងបាតជាចតុកោណ $ABCD$ ។

## លំហាត់ទី៣៦

ក្នុងតម្រុយអរតូណរម៉ាល់ $(o,\vec{i},\vec{j},\vec{k})$ គេមានបួនចំណុច៖

$A(4,0,0)$ $B(0,-2,0)$ , $C(0,0,2)$ និង $D(4,2,2)$ ។

១.បង្ហាញថាចតុកោណ $ABCD$ ជាប្រលេឡូក្រាម ។

២.ចូរកំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(BC)$ និងសមីការនៃប្លង់កាត់តាមបី
ចំណុច $A,B$ និង $C$ ។

៣.យក $H$ ជាចំណោលកែងនៃ $A$ លើបន្ទាត់ $(BC)$ ។ រកកូអរដោនេនៃចំណុច
$H$ រួចគណនា $AH$ និងផ្ទៃក្រលាប្រលេឡូក្រាម $ABCD$ ។

៤.គេមានចំណុច $S(1,6,-6)$ ។ បង្ហាញថាបន្ទាត់ $(SA)$ កែងនឹងប្លង់ $(ABCD)$
រួចគណនាមាឌនៃពីរ៉ាមីត $SABCD$ ។

## លំហាត់ទី៣៧

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$ គេឲ្យប្លង់
$(P): x+2y+2z-4=0$ ។ តាង $A,B$ និង $C$ ជាចំណុចប្រសព្វរវាងប្លង់ $(P)$
ជាមួយអក្ស័ $(ox)$ , $(oy)$ និង $(oz)$ រៀងគ្នា ។

១.ចូរគណនាកូអរដោនេនៃចំណុច $A,B$ និង $C$ រួចសង់ចំណុចនេះ។

២.គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$ រួចរកផ្ទៃក្រឡានៃ $\Delta ABC$ ។

៣.គណនាផលគុណស្កាលែ $(\overrightarrow{AB}\times\overrightarrow{AC})\cdot\overrightarrow{AO}$ ។ទាញរកមាឌចតុមុខ $OABC$

៤.សរសេរសមីការស្តង់ដានៃស្វ៊ែ $(S)$ ចារឹកក្រៅចតុមុខ $OABC$ រួចបញ្ជាក់
កូអរដោនេផ្ចិត និងកាំរបស់ស្វ៊ែ $(S)$ ផង។

## លំហាត់ទី៣៨

ក្នុងតម្រុយអរតូណម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$ គេមានចំណុច
$A(1,2,3)$ និងប្លង់ $(\alpha): x+2y-2z-8=0$ ។

១.កំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(\Delta)$ គូសចេញពីចំណុច $A$ ហើយកែង

នឹងប្លង់ $(\beta)$ ត្រង់ចំណុច $H$ ។

២.គណនាកូអរដោនេនៃចំណុច $H$ និងចំណុច $A'$ ឆ្លុះគ្នានឹង $A$ ធៀបនឹង $(\alpha)$ ។

៣.កំណត់សមីការប្លង់ $(\beta)$ កាត់តាមចំណុច $A'$ ហើយស្របនឹងប្លង់ $(\alpha)$ ។

## **លំហាត់ទី៣៩**

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$ គេឲ្យពីរចំណុច $A(1,-2,2)$ និង $B(2,2,1)$ ។

១.គណនា $\overrightarrow{OA}.\overrightarrow{OB}$ , $|\overrightarrow{OA}|$ និង $|\overrightarrow{OB}|$ រួចរកប្រភេទនៃត្រីកោណ $OAB$ និងគណនាផ្ទៃក្រឡា $\Delta ABC$ ។

២.ចូររកកូអរដោនេនៃចំណុច $C$ ជាកំពូលនៃការេ $OACB$ ។

៣.គណនាផលគុណវិចទ័រ $\overrightarrow{CA}\times\overrightarrow{CB}$ រួចគណនាផ្ទៃក្រឡា $\Delta CAB$

៤.ចូរសរសេរសមីការប្លង់ $(ABC)$ និងសមីការឆ្លុះនៃបន្ទាត់ $(AB)$ ។

៥.គេឲ្យចំណុច $S(-1,5,1)$ ។គណនាមាឌតេត្រាអ៊ែត $SABC$ ។

## **លំហាត់ទី៤០**

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេមានចំណុច

$A(1,1,-1),B(4,-1,-3),C(-2,5,2)$ និង $D(3,2,7)$ ។

១.គណនាផលគុណវិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$ រួចទាញថាបីចំណុច $A,B,C$ មិនរត់ត្រង់គ្នា។

២.គណនាផ្ទៃក្រឡានៃត្រីកោណ $ABC$ ។

៣.សរសេរសមីការប្លង់ $(ABC)$ និងសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(L)$ គូសចេញពី $D$

ហើយកែងនិងប្លង់ $(ABC)$។

៤.គណនាកូអរដោនេនៃចំណុច $H$ ជាប្រសព្វរវាងបន្ទាត់ $(L)$ និងប្លង់ $(ABC)$។

៥.កំណត់មាឌតេត្រាអ៊ែត $ABCD$ រួចទាញរកចម្ងាយពីចំណុច $D$ ទៅប្លង់ $(ABC)$។

## លំហាត់ទី៤១

ក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$
គេឲ្យប្លង់ $(P): x+2y-2z+1=0$ និងចំណុច $A(2,4,1)$ និង $B(-2,8,3)$។
$(Q)$ ជាប្លង់កាត់តាមពីរចំណុច $A$ និង $B$ ហើយកែងនិងប្លង់ $(P)$។ $(L)$ ជាបន្ទាត់ប្រសព្វរវាងប្លង់ $(P)$ និងប្លង់ $(Q)$ ។

១.ចូររកសមីការប្លង់ $(Q)$ និងសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(L)$។

២.$H$ ជាជើងនៃចំណោលកែងចំណុច $A$ លើបន្ទាត់ $(L)$ ហើយ $A'$ ជាចំណុចឆ្លុះគ្នានៃ $A$ ធៀបនិងបន្ទាត់ $(L)$។គណនាកូអរដោនេនៃចំណុច $H$ និង $A'$ ។

៣.រកកូអរដោនេនៃចំណុច $M$ ស្ថិតនៅលើបន្ទាត់ $(L)$ ដោយដឹងថាផលបូក $AM+BM$ មានតម្លៃអប្បបរមា ។

## លំហាត់ទី៤២

គេឲ្យប្លង់ $(p): x+2y-2z+1=0$ និងចំណុចពីរ $A(2,4,1)$ និង $B(6,0,-1)$

ចូររកកូអរដោនេនៃចំណុច $M$ ស្ថិតនៅក្នុងប្លង់ $(p)$ ដោយដឹងថា $MA+MB$

មានតម្លៃអប្បរមា ។

## លំហាត់ទី៤៣

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$ គេឲ្យបួនចំណុច $A(2,4,-5),B(6,-4,3),C(-1,1,7)$ និង $D(-4,7,1)$ ។

១.គណនាកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AB}$ , $\overrightarrow{BC}$ , $\overrightarrow{CD}$ និង $\overrightarrow{AD}$ រួចគណនា រង្វាស់នៃជ្រុងនៃចតុកោណ $ABCD$ ។

២.ចូរបង្ហាញថា $\overrightarrow{AB}\perp\overrightarrow{AD}$ និង $\overrightarrow{AB}//\overrightarrow{CD}$ រួចទាញរកប្រភេទ នៃចតុកោណ $ABCD$ និងគណនាផ្ទៃក្រឡារបស់វា។

៣.តាង $E$ ជាប្រសព្វរវាងបន្ទាត់ $(AD)$ និង $(BC)$ ។ គណនា $EC$ និង $ED$ ។

៤.គណនា $\overrightarrow{AB}\times\overrightarrow{AC}$ រួចទាញរកផ្ទៃក្រឡានៃត្រីកោណ $ABC$ និង $ACD$ ។

៥.រកសមីការនៃប្លង់ $(ABC)$ និងសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(AD)$ និង $(BC)$ ។

## លំហាត់ទី៤៤

នៅក្នុងតម្រុយអរតូនរម៉ាល់ $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបន្ទាត់និងស្វ៊ែមានសមីការ

$(L):\dfrac{x-1}{-2}=\dfrac{y-4}{3}=\dfrac{z-3}{2}$ និង $(S):\ (x-1)^2+(y+1)^2+(z-2)^2=9$

ចូរបង្ហាញថាបន្ទាត់ $(L)$ ប៉ះនឹងស្វ៊ែ $(S)$ ត្រង់ចំណុច $A$ មួយរួចគណនាកូអរដោនេ នៃចំណុចប៉ះ $A$ ខាងលើ ។

## លំហាត់ទី៤៥

គេឲ្យគូប $ABCDEFGH$ មួយមានទ្រនុងស្មើ $1$ ។លំហមានទិសដៅតាម តម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(A,\overrightarrow{AB},\overrightarrow{AD},\overrightarrow{AE})$ គេតាង $I,J,K$ ជាបីចំណុចផ្ទៀងផ្ទាត់ $\overrightarrow{AI}=\dfrac{1}{3}\overrightarrow{AE}$ , $\overrightarrow{BK}=\dfrac{1}{3}\overrightarrow{BC}$ និង $\overrightarrow{CJ}=\dfrac{2}{3}\overrightarrow{CG}$ ។

១.កំណត់កូអរដោនេនៃចំណុច $I,J,K$ ។

២.គណនាផលគុណស្កាលែ $\overrightarrow{KI}.\overrightarrow{KJ}$ រួចទាញរកប្រភេទនៃត្រីកោណ $IJK$ ។

៣.គណនាផលគុណវ៉ិចទ័រ $\overrightarrow{KI}\times\overrightarrow{KJ}$ រួចគណនាផ្ទៃក្រឡានៃត្រីកោណ $IJK$ ។

៤.$L$ ជាចំណុចមួយនៃ$[GH]$ដែលផលគុណស្កាលែ $\overrightarrow{LI}.\overrightarrow{LJ}$ អប្បបរមា។

ចូរកំណត់កូអរដោនេនៃចំណុច $L$ ។

៥.ចូរស្រាយថាបួនចំណុច $I,J,K,L$ ស្ថិតនៅក្នុងប្លង់តែមួយ។

## <u>លំហាត់ទី៤៦</u>

គេឲ្យគូប $ABCDEFGH$ មួយមានទ្រនុងស្មើ$1cm$ ។ $K,L$ និង $M$ ជាចំណុចកណ្ដាលរៀងគ្នានៃ $[EF],[CD]$និង$[DH]$។

១)គណនាផលគុណស្កាលែ $\overrightarrow{MK}\cdot\overrightarrow{ML}$ រួចទាញរកឈ្មោះនៃ $\Delta KLM$

២)$P$ ជាចំណុចមួយនៃ $[EH]$ ហើយគេតាង $\angle KPL=\varphi$ ។

ចូរស្រាយបញ្ជាក់ថាគ្រប់ទីតាំងនៃ $P$ ប្រែប្រួលក្នុង$[EH]$គេមាន$\varphi\le\frac{\pi}{2}$ ។

តើពេលណាទើបគេបាន $\varphi=\frac{\pi}{2}$ ។

## <u>លំហាត់ទី៤៧</u>

គេឲ្យគូប$ABCDEFGH$ មួយមានទ្រនុងស្មើ$1$ ។លំហមានទិសដៅតាមតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន$(A,\overrightarrow{AB},\overrightarrow{AD},\overrightarrow{AE})$ យក $I,J,K$ និង$L$ ជាចំណុចកណ្ដាលរៀងគ្នា នៃ $[EF],[BC],[DH]$ និង$[BF]$ ។

១.ចូរស្រាយបំភ្លឺថា $IJK$ ជាត្រីកោណសមង្ស។

២.ចូរស្រាយបញ្ជាក់ថា $\overrightarrow{IJ}\times\overrightarrow{IK}=\frac{3}{4}\overrightarrow{AG}$ រួចគណនាផ្ទៃក្រឡានៃ$\Delta IJK$។

៣.ចូរស្រាយបញ្ជាក់ថាបន្ទាត់$(IJ)$និង$(KL)$អរតូកូណាល់គ្នា។

៤.គណនារង្វាស់មុំ $\angle ILJ$ ។

៥.គណនាផលគុណស្កាលែ $\overrightarrow{IL}.\overrightarrow{IK}$ និង $\overrightarrow{JL}.\overrightarrow{JK}$ រួចទាញរកប្រភេទនៃត្រីកោណ $ILK$ និងត្រីកោណ $JLK$ ។

៦.គណនា $(\overrightarrow{IJ}\times\overrightarrow{IK}).\overrightarrow{IL}$ រួចទាញថាចំណុច $I,J,K,L$ ស្ថិតនៅក្នុងប្លង់តែមួយ។

**<u>លំហាត់ទី៤៨</u>**

គូប $ABCDEFGH$ មួយមានទ្រនុងស្មើ1 ។លំហមានទិសដៅតាមតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(A,\overrightarrow{AB},\overrightarrow{AD},\overrightarrow{AE})$ គេតាង $I,J,K$ ជាបីចំណុចផ្ទៀងផ្ទាត់ $\overrightarrow{AI}=\frac{1}{3}\overrightarrow{AE}$ ,$\overrightarrow{BK}=\frac{1}{3}\overrightarrow{BC}$ និង $\overrightarrow{CJ}=\frac{2}{3}\overrightarrow{CG}$ ។

១.កំណត់កូអរដោនេនៃចំណុច $I,J,K$ ។

២.គណនាផលគុណស្កាលែ $\overrightarrow{KI}.\overrightarrow{KJ}$ រួចទាញរកប្រភេទនៃត្រីកោណ $IJK$

៣.គណនាផលគុណវ៉ិចទ័រ $\overrightarrow{KI}\times\overrightarrow{KJ}$ រួចគណនាផ្ទៃក្រឡានៃត្រីកោណ $IJK$

៤.$L$ ជាចំណុចមួយនៃ$[GH]$ដែលផលគុណស្កាលែ $\overrightarrow{LI}.\overrightarrow{LJ}$ អប្បបរមា។
ចូរកំណត់កូអរដោនេនៃចំណុច $L$ ។

៥.ចូរស្រាយថាបួនចំណុច $I,J,K,L$ ស្ថិតនៅក្នុងប្លង់តែមួយ។

**<u>លំហាត់ទី៤៩</u>**

គេឲ្យគូប $ABCDEFGH$ មានទ្រនុងស្មើនឹង $1cm$ ។$I$ ជាចំណុចកណ្តាលនៃទ្រនុង $[EH]$ , $K$ ជាផ្ចិតការេ $CDHG$ ហើយ $M$ និង $N$ ជាចំណុចពីរ

នៃទ្រនុង $[BC]$ និង $[BF]$ រៀងគ្នាដោយដឹងថា $\overrightarrow{MI}\cdot\overrightarrow{MK}$ និង $\overrightarrow{NI}\cdot\overrightarrow{NK}$ មានតម្លៃអប្បបរមា ។ តើបួនចំណុច $I, K, M, N$ ស្ថិតនៅក្នុងប្លង់តែមួយឬទេ ?បើសិនជាវាមិនស្ថិតក្នុងប្លង់តែមួយទេចូរគណនាមាឌតេត្រាអ៊ែតដែលមានកំពូល $I, K, M, N$ ។

## លំហាត់ទី៥០

គេឲ្យគូប $ABCD$ មួយមានទ្រនុងស្មើ $1cm$ ។ $I$ ជាចំណុចកណ្តាល $[EF]$ $J\in[BC]$ ដែល $IJ\perp IH$ ហើយ $K\in[CD]$ ដែល $\overrightarrow{CK}=\frac{3}{8}\overrightarrow{CD}$ ។

១.ចូរស្រាយបញ្ជាក់ថាបួនចំណុច $H, I, J, K$ ស្ថិតក្នុងប្លង់តែមួយ។

២.រកទីតាំងនៃចំណុច $P\in[DH]$ ដោយដឹងថា $\overrightarrow{PI}.\overrightarrow{PJ}$ មានតម្លៃតូចបំផុត។

## លំហាត់ទី៥១

គេឲ្យគូប $ABCDEFGH$ មួយមានទ្រនុងស្មើ $1cm$ ។ $I$ ជាចំណុចកណ្តាលនៃទ្រនុង $[BF]$ ហើយ $K\in[BC]$ និង $J\in[DH]$ ដោយដឹងថា ៖

$$\overrightarrow{BK}=\frac{3}{4}\overrightarrow{BC} \text{ និង } \overrightarrow{DJ}=\frac{3}{4}\overrightarrow{DH} \text{ ។}$$

១.ចូររកប្រភេទនៃត្រីកោណ $IJK$ ។

២.$P$ និង $Q$ ជាពីរចំណុចស្ថិតលើ $[IJ]$ ដោយដឹងថា $\overrightarrow{PF}.\overrightarrow{PH}$ និង $\overrightarrow{QE}.\overrightarrow{QG}$ មានតម្លៃអប្បបរមា ។ ចូរស្រាយថា $P\equiv Q$ ។

## លំហាត់ទី៥២

គេឲ្យគូប $ABCDEFGH$ មួយមានទ្រនុងស្មើ $1cm$ ។ $M$ ជាចំណុចកណ្តាលនៃទ្រនុង $[BF]$ ។ $P\in[CD]$ ដែល $\overrightarrow{CP}=\frac{1}{4}\overrightarrow{CD}$ និង $Q\in[DH]$ ដែល $\overrightarrow{DQ}=\frac{3}{8}\overrightarrow{DH}$ ។

១.ចូរស្រាយថា $MPE$ និង $MPQ$ សុទ្ធតែជាត្រីកោណកែង ។

២.ចូរស្រាយថាបួនចំណុច $M,P,Q,E$ ស្ថិតនៅក្នុងប្លង់តែមួយ ។

៣.កំណត់ប្រភេទនៃចតុកោណ $MPQE$ ។

៤.តាង $S$ ជាប្រសព្វរវាងបន្ទាត់ $(MP)$ និង $(EQ)$ ហើយយក $\angle ESM = \varphi$ ។

ចូរគណនាតម្លៃ $\tan\varphi$ ។

## លំហាត់ទី៥៣

គេឲ្យគូប $ABCDEFGH$ មួយមានទ្រនុងស្មើ $1cm$ ។ $M,N,P$ និង $Q$

ជាបួនចំណុចផ្ទៀងផ្ទាត់ $\overrightarrow{BM} = \frac{2}{3}\overrightarrow{MF}$ , $\overrightarrow{BN} = \frac{1}{3}\overrightarrow{BC}$ , $\overrightarrow{DP} = \frac{1}{3}\overrightarrow{DH}$

និង $\overrightarrow{EQ} = \frac{1}{3}\overrightarrow{EH}$ ។

១.ចូរស្រាយថាបួនចំណុច $M,N,P$ និង $Q$ មិនស្ថិតក្នុងប្លង់តែមួយ ។

២.រកប្រភេទនៃត្រីកោណ $MNP$ និង $MQP$ ។

៣.គេតាង $I$ ជាចំណុចប្រសព្វរវាងប្លង់ $(MPQ)$ និងបន្ទាត់ $(BC)$ ហើយ $J$

ជាចំណុចប្រសព្វរវាង $(MNP)$ និងបន្ទាត់ $(EH)$ ។

រកប្រភេទនៃត្រីកោណ $MIP$ និង ត្រីកោណ $MJP$ ។

## លំហាត់ទី៥៤

គេឲ្យគូប $ABCDEFGH$ មួយមានទ្រនុង $1cm$ ។ $K$ ជាផ្ចិតការេ $AEFB$

ហើយ $L$ ជាចំណុចកណ្ដាលនៃ $[BC]$ ។

១.ចូររកប្រភេទនៃត្រីកោណ $HKL$ ។

២. $M\in[HD]$ ដែល $\overrightarrow{MK}.\overrightarrow{ML}$ មានតម្លៃអប្បបរមាហើយ $P\in[BF]$ ដែល $\overrightarrow{BP}=\overrightarrow{DM}$ ។ ចូរស្រាយថាបួនចំណុច $P,K,M,L$ ស្ថិតនៅក្នុងប្លង់តែមួយ។

## លំហាត់ទី៥៥

គេឲ្យគូប $ABCDEFGH$ មួយមានទ្រនុងស្មើ1 ។លំហមានទិសដៅតាមតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(A,\overrightarrow{AB},\overrightarrow{AD},\overrightarrow{AE})$ គេតាង $I,J,K$ ជាបីចំណុចផ្ទៀងផ្ទាត់ $\overrightarrow{AI}=\frac{1}{3}\overrightarrow{AE}$ ,$\overrightarrow{BK}=\frac{1}{3}\overrightarrow{BC}$ និង $\overrightarrow{CJ}=\frac{2}{3}\overrightarrow{CG}$ ។

១.កំណត់កូអរដោនេនៃចំណុច $I,J,K$ ។

២.គណនាផលគុណស្កាលែ $\overrightarrow{KI}.\overrightarrow{KJ}$ រួចទាញរកប្រភេទនៃត្រីកោណ $IJK$ ។

៣.គណនាផលគុណវិចទ័រ $\overrightarrow{KI}\times\overrightarrow{KJ}$ រួចគណនាផ្ទៃក្រឡានៃត្រីកោណ $IJK$ ។

៤.$L$ ជាចំណុចមួយនៃ$[GH]$ដែលផលគុណស្កាលែ $\overrightarrow{LI}.\overrightarrow{LJ}$ អប្បបរមា។

ចូរកំណត់កូអរដោនេនៃចំណុច $L$ ។

៥.ចូរស្រាយថាបួនចំណុច $I,J,K,L$ ស្ថិតនៅក្នុងប្លង់តែមួយ។

## លំហាត់ទី៥៦

គេឲ្យគូប $ABCDEFGH$ មួយមានទ្រនុងស្មើ1។លំហមានទិសដៅតាមតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(A,\overrightarrow{AB},\overrightarrow{AD},\overrightarrow{AE})$ គេយក $I$ ជាចំណុចកណ្តាលនៃ$[AB]$ ហើយ $J$ ជាចំណុចផ្ទៀងផ្ទាត់ $\overrightarrow{EJ}=\frac{1}{4}\overrightarrow{EH}$ ។

១.គណនាផលគុណស្កាលែ $\overrightarrow{IC}.\overrightarrow{IJ}$ រួចទាញរកប្រភេទនៃត្រីកោណ $CIJ$ ។

២. $K$ ជាចំណុចមួយនៃ $[DH]$ ដែលផលគុណស្កាលែ $\overrightarrow{KI}.\overrightarrow{KJ}$ អប្បបរមា។

ចូរកំណត់កូអរដោនេនៃចំណុច $K$ ។

៣.ចូរស្រាយថាបួនចំណុច $C,I,J,K$ បង្កើតបានជាតេត្រាអ៊ែតមួយរួចគណនាមាឌនៃតេត្រាអ៊ែតនេះ ។

## លំហាត់ទី៥៧

គេឲ្យគូប $ABCDEFGH$ មួយមានទ្រនុងស្មើ $1$ ។ក្នុងលំហមានទិសដៅតាមតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(A,\overrightarrow{AB},\overrightarrow{AD},\overrightarrow{AE})$ គេយក $I$ ជាចំណុចកណ្ដាលនៃ $[BC]$ និង $K$ ជាផ្ចិតការេ $AEFB$ ។

១.គណនាផលគុណស្កាលែ $\overrightarrow{KI}\cdot\overrightarrow{KH}$ រួចទាញថា $IKH$ ជាត្រីកោណកែង។

២.ស្រាយថា $\overrightarrow{KI}\times\overrightarrow{KH}=\frac{3}{4}\overrightarrow{AF}$ រួចទាញរកផ្ទៃក្រឡានៃ $\Delta IKH$ ។

៣.គណនាមាឌនៃតេត្រាអ៊ែត $AKIH$ រួចទាញរកចម្ងាយពី $A$ ទៅប្លង់ $(IKH)$ ។

## លំហាត់ទី៥៨

គេឲ្យគូប $ABCDEFGH$ មួយមានទ្រនុងស្មើ $1$ ។ លំហមានទិសដៅតាមតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(A,\overrightarrow{AB},\overrightarrow{AD},\overrightarrow{AE})$ យក $I,J,K$ និង $L$ ជាចំណុចកណ្ដាលរៀងគ្នា នៃ $[EF],[BC],[DH]$ និង $[BF]$ ។

១.ចូរស្រាយបំភ្លឺថា $IJK$ ជាត្រីកោណសមង្ស័។

២.ចូរស្រាយបញ្ជាក់ថា $\overrightarrow{IJ}\times\overrightarrow{IK}=\frac{3}{4}\overrightarrow{AG}$ រួចគណនាផ្ទៃក្រឡានៃ $\Delta IJK$ ។

៣.ចូរស្រាយបញ្ជាក់ថាបន្ទាត់$(IJ)$និង$(KL)$អរតូកូណាល់គ្នា។

៤.គណនារង្វាស់មុំ $\angle ILJ$ ។

៥.គណនាផលគុណស្កាលែ $\overrightarrow{IL}.\overrightarrow{IK}$ និង $\overrightarrow{JL}.\overrightarrow{JK}$ រួចទាញរកប្រភេទនៃ
ត្រីកោណ $ILK$ និងត្រីកោណ $JLK$ ។

៦.គណនា$(\overrightarrow{IJ}\times\overrightarrow{IK}).\overrightarrow{IL}$ រួចទាញថា $I,J,K,L$ ស្ថិតនៅក្នុងប្លង់តែមួយ។

**<u>លំហាត់ទី៥៩</u>**

គេអោយគូប $ABCDEFGH$ មួយមានទ្រនុងស្មើ1។លំហមានទិសដៅតាម
តម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $\left(A,\overrightarrow{AB},\overrightarrow{AD},\overrightarrow{AE}\right)$ គេយក $I$ ជាចំណុច
កណ្តាលនៃអង្កត់ $[EF]$ និង $K$ ជាផ្ចិតការេ $ADHE$ ។

១. ចូរផ្ទៀងផ្ទាត់ថា $\overrightarrow{BK}=\overrightarrow{IG}\times\overrightarrow{IA}$ រួចគណនាក្រឡាផ្ទៃត្រីកោណ $IGA$ ។

២. គណនាមាឌតេត្រាអែត $ABIG$ រួចទាញរកចម្ងាយពី $B$ ទៅប្លង់$(AIG)$ ។

**<u>លំហាត់ទី៦០</u>**

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន$\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច ៖
$A(-3,3,7),B(3,6,1),C(1,2,-3)$ និង $D(-5,-1,3)$ ។

១.ចូរស្រាយបញ្ជាក់ថា $ABCD$ ជាចតុកោណកែង។

២.គណនាផលគុណវ៉ិចទ័រ $\overrightarrow{DA}\times\overrightarrow{DC}$ រួចសរសេរសមីការប្លង់$(DAC)$ ។

៣.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(\Delta)$ និង$(\Delta')$ ដែលកែងនឹងប្លង់$(DAC)$

រៀងគ្នាត្រង់ $C$ និង $D$ ។

៤.ចំណុច $M\in(\Delta)$ មានអាប់ស៊ីស $x_m=9$ និងចំណុច $N\in(\Delta')$ មានអាប់ស៊ីស $x_n=-7$ ។ចូរគណនាកូអរដោនេនៃចំណុច $M$ និង $N$ រួចសរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(MN)$ ។

៥.រកកូអរដោនេនៃចំណុច $P$ ជាប្រសព្វរវាងបន្ទាត់ $(MN)$ និងប្លង់ $(DAC)$ ។

៦.ចូរស្រាយបញ្ជាក់ថាបន្ទាត់ $(BM)$ អរតូកូណាល់នឹងប្លង់ $(BAN)$ ហើយបន្ទាត់ $(AN)$ អរតូកូណាល់នឹងប្លង់ $(ABM)$ ។ទាញឲ្យបានថាមុខខាងទាំងអស់នៃតេត្រាអ៊ែត $ABMN$ សុទ្ធតែជាត្រីកោណកែង។

៧.យក $I$ ជាចំណុចកណ្តាលនៃ $[MN]$ ។ចូរស្រាយថា $I$ ជាផ្ចិតនៃស្វ៊ែ $(S)$ ចារឹកក្រៅតេត្រាអ៊ែត $ABMN$ រួចសរសេរសមីការស្តង់ដានៃស្វ៊ែ $(S)$ ។

www.mathtoday.wordpress.com

# ជំពូកទី០៣

# ផ្នែកដំណោះស្រាយលំហាត់ជ្រើសរើស

## លំហាត់ទី០១

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច

$A(1,-2,1)$, $B(-1,0,2)$, $C(3,4,4)$ និង $D(5,2,5)$ ។

១.គណនាកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AB},\overrightarrow{AC},\overrightarrow{AD},\overrightarrow{BC},\overrightarrow{CD}$ និង $\overrightarrow{DB}$ ។

២.គណនារង្វាស់ទ្រនុងទាំងអស់របស់តេត្រាអ៊ែត $ABCD$ ។

៣.គណនាផលគុណស្កាលែ $\overrightarrow{AB}.\overrightarrow{CD},\overrightarrow{AC}.\overrightarrow{DB}$ និង $\overrightarrow{AD}.\overrightarrow{BC}$ ។

៤.ចូរផ្ទៀងផ្ទាត់ថា $\overrightarrow{AB}.\overrightarrow{CD}+\overrightarrow{AC}.\overrightarrow{DB}+\overrightarrow{AD}.\overrightarrow{BC}=0$ ។

៥.រកកូអរដោនេនៃចំណុច $G$ ដែល $\overrightarrow{GA}+\overrightarrow{GB}+\overrightarrow{GC}+\overrightarrow{GD}=\vec{O}$ ។

## ដំណោះស្រាយ

**១.គណនាកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AB},\overrightarrow{AC},\overrightarrow{AD},\overrightarrow{BC},\overrightarrow{CD}$ និង $\overrightarrow{DB}$ ៖**

គេមាន $A(1,-2,1)$, $B(-1,0,2)$, $C(3,4,4)$ និង $D(5,2,5)$

យើងបាន $\overrightarrow{AB}=(-2,2,1)$ , $\overrightarrow{AC}=(2,6,3)$ , $\overrightarrow{AD}=(4,4,4)$ , $\overrightarrow{BC}=(4,4,2)$

$\overrightarrow{CD}=(2,-2,1)$ និង $\overrightarrow{DB}=(-6,-2,-3)$ ។

២.គណនារង្វាស់ទ្រនុងទាំងអស់របស់តេត្រាអ៊ែត $ABCD$ ៖

យើងបាន $AB=|\overrightarrow{AB}|=\sqrt{4+4+1}=\sqrt{9}=3$

$AC=|\overrightarrow{AC}|=\sqrt{4+36+9}=\sqrt{49}=7$

$AD=|\overrightarrow{AD}|=\sqrt{16+16+16}=4\sqrt{3}$

$BC=|\overrightarrow{BC}|=\sqrt{16+16+4}=\sqrt{36}=6$

$CD=|\overrightarrow{CD}|=\sqrt{4+4+1}=\sqrt{9}=3$

$DB=|\overrightarrow{DB}|=\sqrt{36+4+9}=\sqrt{49}=7$

ដូចនេះ $AB=3, AC=7, AD=4\sqrt{3}, BC=6, CD=3, DB=7$ ( ឯកតាប្រវែង )។

៣.គណនាផលគុណស្កាលែ $\overrightarrow{AB}.\overrightarrow{CD}, \overrightarrow{AC}.\overrightarrow{DB}$ និង $\overrightarrow{AD}.\overrightarrow{BC}$ ៖

យើងមាន $\overrightarrow{AB}=(-2,2,1)$ , $\overrightarrow{AC}=(2,6,3)$ , $\overrightarrow{AD}=(4,4,4)$ , $\overrightarrow{BC}=(4,4,2)$

$\overrightarrow{CD}=(2,-2,1)$ និង $\overrightarrow{DB}=(-6,-2,-3)$

យើងបាន $\overrightarrow{AB}.\overrightarrow{CD}=(-2)(2)+(2)(-2)+(1)(1)=-7$

$\overrightarrow{AC}.\overrightarrow{DB}=(2)(-6)+(6)(-2)+(3)(-3)=-33$

$\overrightarrow{AD}.\overrightarrow{BC}=(4)(4)+(4)(4)+(4)(2)=40$

ដូចនេះ $\overrightarrow{AB}.\overrightarrow{CD}=-7, \overrightarrow{AC}.\overrightarrow{DB}=-33$ និង $\overrightarrow{AD}.\overrightarrow{BC}=40$ ។

៤.ផ្ទៀងផ្ទាត់ថា $\overrightarrow{AB}.\overrightarrow{CD}+\overrightarrow{AC}.\overrightarrow{DB}+\overrightarrow{AD}.\overrightarrow{BC}=0$ ៖

គេមាន $\overrightarrow{AB}.\overrightarrow{CD}=-7, \overrightarrow{AC}.\overrightarrow{DB}=-33$ និង $\overrightarrow{AD}.\overrightarrow{BC}=40$

យើងបាន $\overrightarrow{AB}.\overrightarrow{CD}+\overrightarrow{AC}.\overrightarrow{DB}+\overrightarrow{AD}.\overrightarrow{BC}=-7-33+40=0$ ពិត

ដូចនេះ $\overrightarrow{AB}.\overrightarrow{CD}+\overrightarrow{AC}.\overrightarrow{DB}+\overrightarrow{AD}.\overrightarrow{BC}=0$ ។

៥.រកកូអរដោនេនៃចំណុច $G$ ដែល $\overrightarrow{GA}+\overrightarrow{GB}+\overrightarrow{GC}+\overrightarrow{GD}=\overrightarrow{O}$ ៖

តាង $G(x_G,y_G,z_G)$ ដោយគេមាន $A(1,-2,1)$, $B(-1,0,2)$,$C(3,4,4)$

និង $D(5,2,5)$ នោះគេបាន៖

$$\begin{cases}\overrightarrow{GA}=(1-x_G,-2-y_G,1-z_G)\\ \overrightarrow{GB}=(-1-x_G,-y_G,2-z_G)\\ \overrightarrow{GC}=(3-x_G,4-y_G,4-z_G)\\ \overrightarrow{GD}=(5-x_G,2-y_G,5-z_G)\end{cases}$$

ធ្វើផលបូកវ៉ិចទ័រទាំងបួនខាងលើនេះគេបាន ៖

$$\overrightarrow{GA}+\overrightarrow{GB}+\overrightarrow{GC}+\overrightarrow{GD}=(8-4x_G,4-4y_G,12-4z_G)$$

ដោយ $\overrightarrow{GA}+\overrightarrow{GB}+\overrightarrow{GC}+\overrightarrow{GD}=\overrightarrow{O}$ សមមូល $\begin{cases}8-4x_G=0\\ 4-4y_G=0\\ 12-4z_G=0\end{cases}$ ឬ $\begin{cases}x_G=2\\ y_G=1\\ z_G=3\end{cases}$

ដូចនេះ $G(2,1,3)$ ។

www.mathtoday.wordpress.com

## លំហាត់ទី០២

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច ៖

$A(1,4,-5)$ , $B(-1,6,-4)$,$C(3,-2,4)$ និង $D(5,-4,3)$ ។

១.គណនា $\overrightarrow{AD}$ និង $\overrightarrow{BC}$ រួចទាញថាចតុកោណ $ABCD$ ជាប្រលេឡូក្រាម។

២.គណនារង្វាស់ជ្រុងនិងអង្កត់ទ្រូងរបស់ប្រលេឡូក្រាម $ABCD$ ។

៣.គណនាផលគុណស្កាលែ $\overrightarrow{AC}.\overrightarrow{DB}$ ។

៤.$I$ ជាចំណុចកណ្តាលនៃ$[AD]$ ហើយ $K\in[BC]$ ដែល $\overrightarrow{BK}=\frac{1}{4}\overrightarrow{BC}$ ។

គណនាកូអរដោនេនៃចំណុច $I$ និង $K$ រួចគណនារង្វាស់ $IK$ ។

៥.គណនាផលគុណស្កាលែ $\overrightarrow{IB}.\overrightarrow{IC}$ និង $\overrightarrow{KA}.\overrightarrow{KD}$ ។

## ដំណោះស្រាយ

១.គណនា $\overrightarrow{AD}$ និង $\overrightarrow{BC}$ រួចទាញថាចតុកោណ $ABCD$ ជាប្រលេឡូក្រាម ៖

$A(1,4,-5)$ , $B(-1,6,-4)$,$C(3,-2,4)$ និង $D(5,-4,3)$



យើងបាន $\overrightarrow{AD}=\overrightarrow{OD}-\overrightarrow{OA}=(5,-4,3)-(1,4,-5)=(4,-8,8)$

ហើយ $\overrightarrow{BC}=\overrightarrow{OC}-\overrightarrow{OB}=(3,-2,4)-(-1,6,-4)=(4,-8,8)$

ដូចនេះ $\overrightarrow{AD}=(4,-8,8)$ និង $\overrightarrow{BC}=(4,-8,8)$ ។

ដោយ $\overrightarrow{AD}=\overrightarrow{BC}$ ដូចនេះចតុកោណ $ABCD$ ជាប្រលេឡូក្រាម។

២.គណនារង្វាស់ជ្រុងនិងអង្កត់ទ្រូងរបស់ប្រលេឡូក្រាម $ABCD$ ៖

យើងមាន $A(1,4,-5)$ , $B(-1,6,-4)$,$C(3,-2,4)$ និង $D(5,-4,3)$

យើងបាន $AB=\sqrt{(-1-1)^2+(6-4)^2+(-4+5)^2}=\sqrt{4+4+1}=\sqrt{9}=3$

$$AD=\sqrt{(5-1)^2+(-4-4)^2+(3+5)^2}=\sqrt{16+64+64}=\sqrt{144}=12$$

$$AC=\sqrt{(3-1)^2+(-2-4)^2+(4+5)^2}=\sqrt{4+36+81}=\sqrt{121}=11$$

$$BD=\sqrt{(5+1)^2+(-4-6)^2+(3+4)^2}=\sqrt{36+100+49}=\sqrt{185}$$

ដូចនេះ $AB=DC=3$ , $AD=BC=12$ , $AC=11$ , $BD=\sqrt{185}$ ។

៣.គណនាផលគុណស្កាលែ $\overrightarrow{AC}.\overrightarrow{DB}$ ៖

យើងមាន $\overrightarrow{AC}=(2,-6,9)$ , $\overrightarrow{DB}=(-6,10,-7)$

យើងបាន $\overrightarrow{AC}.\overrightarrow{DB}=(2)(-6)+(-6)(10)+(9)(-7)=-12-60-63=-135$

ដូចនេះ $\overrightarrow{AC}.\overrightarrow{DB}=-135$ ។

៨.គណនាកូអរដោនេនៃចំណុច $I$ និង $K$ រួចគណនារង្វាស់ $IK$

គេមាន $A(1,4,-5)$ , $B(-1,6,-4)$,$C(3,-2,4)$ និង $D(5,-4,3)$

ដោយ $I$ ជាចំណុចកណ្ដាលនៃ $[AD]$ នោះ $I\left(\frac{1+5}{2},\frac{4-4}{2},\frac{-5+3}{2}\right)$

ដូចនេះ $I(3,0,-1)$ ។

តាង $K(x_k,y_k,z_k)$ នោះ $\overrightarrow{BK}=(x_k+1,y_k-6,z_k+4)$ និង $\overrightarrow{BC}=(4,-8,8)$

ដោយ $\overrightarrow{BK}=\frac{1}{4}\overrightarrow{BC}$ សមមូល $\begin{cases}x_k+1=1\\ y_k-6=-2\\ z_k+4=2\end{cases}$ ឬ $\begin{cases}x_k=0\\ y_k=4\\ z_k=-2\end{cases}$

ដូចនេះ $K(0,4,-2)$ ។

ហើយ $IK=\sqrt{(0-3)^2+(4-0)^2+(-2+1)^2}=\sqrt{26}$ ( ឯកតាប្រវែង )។

៩.គណនាផលគុណស្កាលែ $\overrightarrow{IB}.\overrightarrow{IC}$ និង $\overrightarrow{KA}.\overrightarrow{KD}$ ៖

យើងមាន $A(1,4,-5)$ , $B(-1,6,-4)$,$C(3,-2,4)$ និង $D(5,-4,3)$

ហើយ $I(3,0,-1)$ និង $K(0,4,-2)$ នោះគេបាន ៖

$\overrightarrow{IB}=(-4,6,-3)$ , $\overrightarrow{IC}=(0,-2,5)$, $\overrightarrow{KA}=(1,0,-3)$ , $\overrightarrow{KD}=(5,-8,5)$

យើងបាន $\overrightarrow{IB}.\overrightarrow{IC}=0-12-15=-27$ និង $\overrightarrow{KA}.\overrightarrow{KD}=5+0-15=-10$

ដូចនេះ $\overrightarrow{IB}.\overrightarrow{IC}=-27$ និង $\overrightarrow{KA}.\overrightarrow{KD}=-10$ ។

## លំហាត់ទី០៣

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច

$A(2,-3,1)$ , $B(3,5,5)$ , $C(6,-7,8)$ និង $D(10,-2,-3)$ ។

១.គណនា $\overrightarrow{AB}.\overrightarrow{AC}$ , $|\overrightarrow{AB}|$ និង $|\overrightarrow{AC}|$ រួចទាញរកប្រភេទនៃត្រីកោណ $ABC$ ។

២.គណនា $\overrightarrow{DA}.\overrightarrow{AB}$ និង $\overrightarrow{DA}.\overrightarrow{AC}$ រួចទាញថា $\overrightarrow{DA}\perp\overrightarrow{BC}$ ។

៣.ស្រាយថា $BCD$ ជាត្រីកោណសម័ង្ស ។

៤.រកកូអរដោនេនៃចំណុច $E$ ដោយដឹងថា $\overrightarrow{AE}=\overrightarrow{AB}+\overrightarrow{AC}+\overrightarrow{AD}$ ។

៥.ចូរស្រាយថា $(AE)\perp(BCD)$ ។

## ដំណោះស្រាយ

១.គណនា $\overrightarrow{AB}.\overrightarrow{AC}$ , $|\overrightarrow{AB}|$ និង $|\overrightarrow{AC}|$ រួចទាញរកប្រភេទនៃត្រីកោណ $ABC$ ៖

គេមាន $A(2,-3,1)$ , $B(3,5,5)$ , $C(6,-7,8)$ និង $D(10,-2,-3)$

គេបាន $\overrightarrow{AB}=(1,8,4)$ និង $\overrightarrow{AC}=(4,-4,7)$

យើងបាន $\overrightarrow{AB}.\overrightarrow{AC}=(1)(4)+(8)(-4)+(4)(7)=4-32+28=0$ ។

ហើយ $|\overrightarrow{AB}|=\sqrt{1+64+16}=\sqrt{81}=9$ និង $|\overrightarrow{AC}|=\sqrt{16+16+49}=9$ ។

ដូចនេះ $\overrightarrow{AB}.\overrightarrow{AC}=0$ , $|\overrightarrow{AB}|=9$ , $|\overrightarrow{AC}|=9$ ។

ដោយ $\overrightarrow{AB}.\overrightarrow{AC}=0\Leftrightarrow\overrightarrow{AB}\perp\overrightarrow{AC}$ និង $AB=AC=9$ នោះ $ABC$ ជាត្រីកោណកែងសមបាតកំពូល $A$ ។

២.គណនា $\overrightarrow{DA}.\overrightarrow{AB}$ និង $\overrightarrow{DA}.\overrightarrow{AC}$ រួចទាញថា $\overrightarrow{DA}\perp\overrightarrow{BC}$ ៖

គេមាន $A(2,-3,1)$ , $B(3,5,5)$ , $C(6,-7,8)$ និង $D(10,-2,-3)$

នោះ $\overrightarrow{DA}=(-8,-1,4)$, $\overrightarrow{AB}=(1,8,4)$ និង $\overrightarrow{AC}=(4,-4,7)$

យើងបាន $\overrightarrow{DA}.\overrightarrow{AB}=-8-8+16=0$ និង $\overrightarrow{DA}.\overrightarrow{AC}=4-32+28=0$

ដូចនេះ $\overrightarrow{DA}.\overrightarrow{AB}=0$ និង $\overrightarrow{DA}.\overrightarrow{AC}=0$ ។

ដោយ $\overrightarrow{DA}.\overrightarrow{AB}=0\Leftrightarrow\overrightarrow{DA}\perp\overrightarrow{AB}$ និង $\overrightarrow{DA}.\overrightarrow{AC}=0\Leftrightarrow\overrightarrow{DA}\perp\overrightarrow{AC}$

គេទាញ $\overrightarrow{DA}\perp(ABC)$ ដោយ $\overrightarrow{BC}\subset(ABC)$ នោះគេទាញ $\overrightarrow{DA}\perp\overrightarrow{BC}$ ។

៣.ស្រាយថា $BCD$ ជាត្រីកោណសម័ង្ស

គេមាន $BC=\sqrt{(6-3)^2+(-7-5)^2+(8-5)^2}=\sqrt{9+144+9}=9\sqrt{2}$

$BD=\sqrt{(10-3)^2+(-2-5)^2+(-3-5)^2}=\sqrt{49+49+64}=9\sqrt{2}$

$CD=\sqrt{(10-6)^2+(-2+7)^2+(-3-8)^2}=\sqrt{16+25+121}=9\sqrt{2}$

ដោយ $BC=BD=CD=9\sqrt{2}$ នោះ $BCD$ ជាត្រីកោណសម័ង្ស។

៤.រកកូអរដោនេនៃចំណុច $E$ ដោយដឹងថា $\overrightarrow{AE}=\overrightarrow{AB}+\overrightarrow{AC}+\overrightarrow{AD}$ ៖

តាង $E(x_E,y_E,z_E)$ ដោយ $A(2,-3,1)$ , $B(3,5,5)$ , $C(6,-7,8)$ និង
$D(10,-2,-3)$ នោះ $\overrightarrow{AE}=(x_E-2,y_E+3,z_E-1)$ , $\overrightarrow{AB}=(1,8,4)$

$\overrightarrow{AC}=(4,-4,7)$ , $\overrightarrow{AD}=(8,1,-4)$ ។

គេបាន $\overrightarrow{AB}+\overrightarrow{AC}+\overrightarrow{AD}=(13,5,7)$ ដោយ $\overrightarrow{AE}=\overrightarrow{AB}+\overrightarrow{AC}+\overrightarrow{AD}$

គេទាញបាន $\begin{cases} x_E-2=13 \\ y_E+3=5 \\ z_E-1=7 \end{cases}$ សមមូល $\begin{cases} x_E=15 \\ y_E=2 \\ z_E=8 \end{cases}$

ដូចនេះ $E(15,2,8)$ ។

៨.ស្រាយថា $(AE)\perp(BCD)$ ៖

មាន $E(15,2,8)$, $A(2,-3,1)$ , $B(3,5,5)$ , $C(6,-7,8)$ និង $D(10,-2,-3)$

នោះ $\overrightarrow{AE}=(13,5,7)$ , $\overrightarrow{BC}=(3,-12,3)$ , $\overrightarrow{BD}=(7,-7,-8)$

គេមាន $\overrightarrow{AE}\,.\,\overrightarrow{BC}=39-60+21=0\Leftrightarrow\overrightarrow{AE}\perp\overrightarrow{BC}$

ហើយ $\overrightarrow{AE}.\overrightarrow{BD}=91-35-56=0\Leftrightarrow\overrightarrow{AE}\perp\overrightarrow{BD}$

ដោយ $\overrightarrow{AE}\perp\overrightarrow{BC}$ និង $\overrightarrow{AE}\perp\overrightarrow{BD}$ នោះ $\overrightarrow{AE}\perp(BCD)$ ។

ដូចនេះ $(AE)\perp(BCD)$ ។

www.mathtoday.wordpress.com

## លំហាត់ទី០៤

ក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យត្រីកោណ $ABC$ មានកំពូល $A(-2,3,-4)$ , $B(4,9,-1)$ និង $C(2,-5,4)$ ។

១.គណនា $AB,AC$ និង $BC$ រួចបង្ហាញថា $ABC$ ជាត្រីកោណកែងត្រង់ $A$ ។

២.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(AB)$,$(AC)$ និង $(BC)$ ។

៣.រកកូអរដោនេនៃចំណុច $I$ ដោយដឹងថា $BC.\overrightarrow{IA}+AC.\overrightarrow{IB}+AB.\overrightarrow{IC}=\overrightarrow{O}$ ។

៤.ចូរផ្ទៀងផ្ទាត់ថា $BC.IA^2+AC.IB^2+AB.IC^2=BC.AC.AB$ ។

៥.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(IA)$,$(IB)$,$(IC)$ ។

## ដំណោះស្រាយ

**១.គណនា $AB,AC$ និង $BC$ រួចបង្ហាញថា $ABC$ ជាត្រីកោណកែងត្រង់ $A$ ៖**

$A(-2,3,-4)$ , $B(4,9,-1)$ និង $C(2,-5,4)$

យើងបាន $AB=\sqrt{(4+2)^2+(9-3)^2+(-1+4)^2}=\sqrt{36+36+9}=9$

$AC=\sqrt{(2+2)^2+(-5-3)^2+(4+4)^2}=\sqrt{16+64+64}=12$

$BC=\sqrt{(2-4)^2+(-5-9)^2+(4+1)^2}=\sqrt{4+196+25}=15$

ដូចនេះ $AB=9$ , $AC=12$ , $BC=15$ ( ឯកតាប្រវែង )។

ម្យ៉ាងទៀតដោយ $AB^2+AC^2=81+144=225=BC^2$

ដូចនេះ $ABC$ ជាត្រីកោណកែងត្រង់ $A$ ( តាមទ្រឹស្តីបទពីតាគ័រ )។

២.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(AB),(AC)$ និង $(BC)$ ៖

គេមាន $A(-2,3,-4)$ , $B(4,9,-1)$ និង $C(2,-5,4)$
បន្ទាត់$(AB),(AC)$ និង $(BC)$មានវ៉ិចទ័រប្រាប់ទិសរៀងគ្នា៖

$\overrightarrow{AB}=(6,6,3)$ , $\overrightarrow{AC}=(4,-8,8)$ និង $\overrightarrow{BC}=(-2,-14,5)$

ដូចនេះសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(AB),(AC)$ និង $(BC)$អាចសរសេរ៖

$$(AB):\begin{cases}x=-2+6t\\ y=3+6t\\ z=-4+3t\ ,\ t\in\mathbb{R}\end{cases}\ ,\ (AC):\begin{cases}x=-2+4u\\ y=3-8u\\ z=-4+8u\ ,\ u\in\mathbb{R}\end{cases}$$

និង $(BC):\begin{cases}x=4-2v\\ y=9-14v\\ z=-1+5v\ ,\ v\in\mathbb{R}\end{cases}$ ។

៣.រកកូអរដោនេនៃចំណុច $I$ ដោយដឹងថា $BC.\overrightarrow{IA}+AC.\overrightarrow{IB}+AB.\overrightarrow{IC}=\overrightarrow{O}$

តាង $I(x_I,y_I,z_I)$ ដោយ $A(-2,3,-4)$ , $B(4,9,-1)$ និង $C(2,-5,4)$

នោះ $\begin{cases}\overrightarrow{IA}=(-2-x_I,3-y_I,-4-z_I)\\ \overrightarrow{IB}=(4-x_I,9-y_I,-1-z_I)\\ \overrightarrow{IC}=(2-x_I,-5-y_I,4-z_I)\end{cases}$ ដោយ $\begin{cases}AB=9\\ AC=12\\ BC=15\end{cases}$

នោះ $\begin{cases}BC.\overrightarrow{IA}=(-30-15x_I,45-15y_I,-60-15z_I)\\ AC.\overrightarrow{IB}=(48-12x_I,108-12y_I,-12-12z_I)\\ AB.\overrightarrow{IC}=(18-9x_I,-45-9y_I,36-9z_I)\end{cases}$

គេបាន $BC.\overrightarrow{IA}+AC.\overrightarrow{IB}+AB.\overrightarrow{IC}=(36-36x_I,108-36y_I,-36-36z_I)$

ដោយ $BC.\overrightarrow{IA}+AC.\overrightarrow{IB}+AB.\overrightarrow{IC}=\overrightarrow{O}$ សមមូល $\begin{cases}36-36x_I=0\\108-36y_I=0\\-36-36z_I=0\end{cases}$

គេទាញបាន $\begin{cases}x_I=1\\y_I=3\\z_I=-1\end{cases}$ ។

ដូចនេះ $I(1,3,-1)$ ។

៤.ផ្ទៀងផ្ទាត់ថា $BC.IA^2+AC.IB^2+AB.IC^2=BC.AC.AB$

គេមាន $I(1,3,-1)$ , $A(-2,3,-4)$ , $B(4,9,-1)$ និង $C(2,-5,4)$

គេបាន $IA=\sqrt{(-2-1)^2+(3-3)^2+(-4+1)^2}=3\sqrt{2}$

$IB=\sqrt{(4-1)^2+(9-3)^2+(-1+1)^2}=3\sqrt{5}$

$IC=\sqrt{(2-1)^2+(-5-3)^2+(4+1)^2}=3\sqrt{10}$

ដោយ $AB=9, AC=12$ , $BC=15$ នោះគេបាន ៖

$BC.IA^2+AC.IB^2+AB.IC^2=(15)(3\sqrt{2})^2+(12)(3\sqrt{5})^2+(9)(3\sqrt{10})^2=1620$

ហើយ $BC.AC.AB=(9)(12)(15)=1620$

ដូចនេះ $BC.IA^2+AC.IB^2+AB.IC^2=BC.AC.AB$ ពិត។

៨.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(IA),(IB),(IC)$ ៖

គេមាន $I(1,3,-1)$ , $A(-2,3,-4)$ , $B(4,9,-1)$ និង $C(2,-5,4)$

បន្ទាត់ $(IA),(IB),(IC)$ មានវ៉ិចទ័រប្រាប់ទិសរៀងគ្នា ៖

$\overrightarrow{IA}=(-3,0,-3)$ , $\overrightarrow{IB}=(3,6,0)$ និង $\overrightarrow{IC}=(1,-8,5)$

ដូចនេះសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(IA),(IB),(IC)$ អាចសរសេររៀងគ្នា ៖

$$(IA):\begin{cases}x=1-3t\\ y=3\\ z=-1-3t \quad , t\in\mathbb{R}\end{cases}$$

$$(IB):\begin{cases}x=1+3u\\ y=3+6u\\ z=-1 \qquad , u\in\mathbb{R}\end{cases}$$

$$(IC):\begin{cases}x=1+v\\ y=3-8v\\ z=-1+5v \quad , v\in\mathbb{R}\end{cases}$$

www.mathtoday.wordpress.com

## លំហាត់ទី០៥

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន$\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យពីរចំណុច ៖

$A(2,-3,1)$ និង $B(6,9,7)$ ។

១.គណនាកូអរដោនេ $I$ កណ្ដាលអង្កត់$[AB]$រួចគណនាប្រវែង $AB$ ។

២.សរសេរសមីការទូទៅនៃស្វ៊ែ$(S)$ មានអង្កត់ផ្ចិត$AB$ ។

៣.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(AB)$និងសមីការប្លង់មេដ្យាទ័រនៃ$[AB]$ ។

៤.គេឲ្យចំណុច $C(1,1,-2)$ ។ ចូរផ្ទៀងផ្ទាត់ថា $C\in(S)$ រួចសរសេរសមីការនៃ

ប្លង់$(P)$ ប៉ះនឹងស្វ៊ែ$(S)$ ត្រង់ចំណុច $C$ ។

៥.$D$ ជាចំណុចមួយដែល$\overrightarrow{CD}=\overrightarrow{CA}+\overrightarrow{CB}$ ។ រកកូអរដោនេនៃចំណុច$D$ រួច

ទាញរកប្រភេទនៃចតុកោណ $CADB$ ។

## ដំណោះស្រាយ

**១.គណនាកូអរដោនេ $I$ កណ្ដាលអង្កត់$[AB]$រួចគណនាប្រវែង $AB$ ៖**

គេមាន $A(2,-3,1)$ និង $B(6,9,7)$

ដោយ$I$ ជាចំណុចកណ្ដាលអង្កត់ $[AB]$ នោះ $I\left(\frac{2+6}{2},\frac{-3+9}{2},\frac{1+7}{2}\right)$

ដូចនេះ $I(4,3,4)$ ។

ហើយ $AB=\sqrt{(6-2)^2+(9+3)^2+(7-1)^2}=\sqrt{16+144+36}=14$

ដូចនេះ $AB=14$ (ឯកតាប្រវែង)។

២.សរសេរសមីការទូទៅនៃស្វ៊ែ $(S)$ មានអង្កត់ផ្ចិត $AB$ ៖

ផ្ចិតរបស់ស្វ៊ែ $(S)$ មានអង្កត់ផ្ចិត $AB$ គឺ $I(4,3,4)$ និងមានកាំ $r=\frac{AB}{2}=\frac{14}{2}=7$

សមីការស្វ៊ែ $(S)$ អាចសរសេរ ៖

$$(S):(x-x_I)^2+(y-y_I)^2+(z-z_I)^2=r^2$$

$$(x-4)^2+(y-3)^2+(z-4)^2=7^2$$

$$x^2-8x+16+y^2-6y+9+z^2-8z+16=49$$

$$x^2+y^2+z^2-8x-6y-8z-8=0$$

ដូចនេះ $(S):x^2+y^2+z^2-8x-6y-8z-8=0$ ។

៣.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(AB)$ និងសមីការប្លង់មេដ្យាទ័រនៃ $[AB]$ ៖

គេមាន $A(2,-3,1)$ និង $B(6,9,7)$

វ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $(AB)$ គឺ $\overrightarrow{AB}=(4,12,6)$ ។

ដូចនេះសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(AB)$ អាចសរសេរ៖

$$(AB):\begin{cases}x=2+4t\\y=-3+12t\\z=1+6t\quad ,t\in\mathbb{R}\end{cases}$$

តាង $(\pi)$ ជាប្លង់មេដ្យាទ័រនៃអង្កត់ $[AB]$ ។

វ៉ិចទ័រណរម៉ាល់នៃប្លង់ $(\pi)$ គឺ $\vec{n}=\overrightarrow{AB}=(4,12,6)$ ហើយ $I(4,3,4)\in(\pi)$

សមីការប្លង់ $(\pi)$ អាចសរសេរ ៖

$$(\pi): a(x-x_I)+b(y-y_I)+c(z-z_I)=0$$

$$4(x-4)+12(y-3)+6(z-4)=0$$

$$4x-16+12y-36+6z-24=0$$

$$4x+12y+6z-76=0$$

$$2x+6y+3z-38=0$$

ដូចនេះ $(\pi): 2x+6y+3z-38=0$ ។

៨. ផ្ទៀងផ្ទាត់ថា $C\in(S)$ ៖

គេមាន $C(1,1,-2)$ និង $(S): x^2+y^2+z^2-8x-6y-8z-8=0$

យកកូអរដោនេនៃចំណុច $C$ ជំនួសក្នុងសមីការស្វ៊ែ $(S)$ គេបាន ៖

$1+1+4-8-6+16-8=0$ ឬ $0=0$ ផ្ទៀងផ្ទាត់។

ដូចនេះ $C\in(S)$ ។

**សរសេរសមីការនៃប្លង់ $(P)$ ប៉ះនឹងស្វ៊ែ $(S)$ ត្រង់ចំណុច $C$ ៖**

គេមាន $I(4,3,4)$ និង $C(1,1,-2)$ នោះ $\overrightarrow{IC}=(-3,-2,-6)$ ជាវ៉ិចទ័រណរម៉ាល់

នៃប្លង់ $(P)$ ដែលប៉ះនឹងស្វ៊ែ $(S)$ ត្រង់ចំណុច $C$ ។

សមីការនៃប្លង់ $(P)$ អាចសរសេរ ៖

$$(P): a(x-x_c)+b(y-y_c)+c(z-z_c)=0$$

$$-3(x-1)-2(y-1)-6(z+2)=0$$

$$-3x+3-2y+2-6z-12=0$$

$$-3x-2y-6z-7=0$$

$$3x+2y+6z+7=0$$

ដូចនេះ $(P): 3x+2y+6z+7=0$ ។

៥.រកកូអរដោនេនៃចំណុច $D$ រួចទាញរកប្រភេទនៃចតុកោណ $CADB$ ៖

គេមាន $A(2,-3,1)$ , $B(6,9,7)$ និង $C(1,1,-2)$

នោះ $\overrightarrow{CA}=(1,-4,3)$ , $\overrightarrow{CB}=(5,8,9)$ និង $\overrightarrow{CA}+\overrightarrow{CB}=(6,4,12)$

តាង $D(x_d,y_d,z_d)$ នោះ $\overrightarrow{CD}=(x_d-1,y_d-1,z_d+2)$

ដោយ $\overrightarrow{CD}=\overrightarrow{CA}+\overrightarrow{CB}$ សមមូល $\begin{cases} x_d-1=6 \\ y_d-1=4 \\ z_d+2=12 \end{cases}$ ឬ $\begin{cases} x_d=7 \\ y_d=5 \\ z_d=10 \end{cases}$

ដូចនេះ $D(7,5,10)$ ។

គេមាន $\overrightarrow{AC}=(-1,4,-3)$ , $\overrightarrow{AD}=(5,8,9)$ , $\overrightarrow{DB}=(-1,4,-3)$

ដោយ $\overrightarrow{AC}.\overrightarrow{AD}=-5+32-27=0 \Leftrightarrow \overrightarrow{AC}\perp\overrightarrow{AD}$ និង $\overrightarrow{AC}=\overrightarrow{DB}$

ដូចនេះចតុកោណ $CADB$ ជាចតុកោណកែង ។

www.mathtoday.wordpress.com

## លំហាត់ទី០៦

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យចំណុច $A$ មានកូអរដោនេ $(3,1,1)$ និងប្លង់ $(P)$ មានសមីការ $2x-y-2z+6=0$ ។

១.គណនាចម្ងាយពីចំណុច $A$ ទៅប្លង់ $(P)$ ។

២.$H$ ជាជើងនៃចំណោលកែងនៃចំណុច $A$ លើប្លង់ $(P)$ ។គណនាកូអរដោនេនៃចំណុច $H$ រួចសរសេរសមីការទូទៅនៃស្វ៊ែ $(S)$ មានផ្ចិត $H$ ហើយកាត់តាម $A$ ។

៣.$B$ ជាចំណុចមានអាប់ស៊ីស $x_b=0$ ហើយ $B\in(P)$ និង $B\in(S)$ ។ ចូរគណនាកូអរដោនេនៃចំណុច $B$ ។

៤.$C$ ជាចំណុចមានអរដោនេ $y_c=0$ ហើយ $C\in(P)$ និង $C\in(S)$ ។ ចូរគណនាកូអរដោនេនៃចំណុច $C$ ។

៥.គេឲ្យចំណុច $D(3,4,4)$ ។ ចូរផ្ទៀងផ្ទាត់ថា $D\in(P)$ និង $D\in(S)$ ។ ចូរសរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(L)$ ប៉ះនឹងស្វ៊ែ $(S)$ ត្រង់ចំណុច $D$ ដោយដឹងថា $(L)\subset(P)$ ។

## ដំណោះស្រាយ

**១.គណនាចម្ងាយពីចំណុច $A$ ទៅប្លង់ $(P)$**

គេមាន $A(3,1,1)$ និង $(P):\ 2x-y-2z+6=0$

យើងបាន $d\left(A,(P)\right)=\dfrac{|2x_a-y_a-2z_a+6|}{\sqrt{2^2+(-1)^2+(-2)^2}}=\dfrac{|2(3)-(1)-2(1)+6|}{3}=3$

ដូចនេះ $d\left(A,(P)\right)=3$ ( ឯកតាប្រវែង )។

២.គណនាកូអរដោនេនៃចំណុច $H$ ៖

តាង $H(x_h,y_h,z_h)$ ។ ដោយ $H$ ជាជើងនៃចំណោលកែងនៃចំណុច $A$ លើ $(P)$

នោះ $H\in(P)$ សមមូល $2x_h-y_h-2z_h+6=0\quad(1)$

ប្លង់ $(P)$ មានវ៉ិចទ័រណរម៉ាល់ $\vec{n}=(2,-1,-2)$ ហើយ $\overrightarrow{AH}=(x_h-3,y_h-1,z_h-1)$

ដោយ $\overrightarrow{AH}\perp(P)$ និង $\vec{n}\perp(P)$ នោះ $\overrightarrow{AH}//\vec{n}$ នាំឲ្យ $\overrightarrow{AH}=\lambda\,\vec{n}\ ,\lambda\in\mathbb{R}$

គេទាញ $\begin{cases}x_h-3=2\lambda\\y_h-1=-\lambda\\z_h-1=-2\lambda\end{cases}$ ឬ $\begin{cases}x_h=3+2\lambda\\y_h=1-\lambda\\z_h=1-2\lambda\end{cases}\quad(2)$

យកសមីការ $(2)$ ជំនួសក្នុង $(1)$ គេបាន ៖

$$2(3+2\lambda)-(1-\lambda)-2(1-2\lambda)+6=0$$
$$6+4\lambda-1+\lambda-2+4\lambda+6=0$$
$$9\lambda+9=0$$
$$\lambda=-1$$

យក $\lambda=-1$ ជួសក្នុង $(2)$ គេបាន $\begin{cases}x_h=3-2=1\\y_h=1+1=2\\z_h=1+2=3\end{cases}$

ដូចនេះ $H(1\,,2\,,3)$ ។

សរសេរសមីការទូទៅនៃស្វ៊ែ $(S)$ មានផ្ចិត $H$ ហើយកាត់តាម $A$ ៖

សមីការស្វ៊ែ $(S)$ មានផ្ចិត $H(1,2,3)$ អាចសរសេរ ៖

$(S):(x-1)^2+(y-2)^2+(z-3)^2=r^2$

ដោយ $(S)$ កាត់តាមចំណុច $A(3,1,1)$ នោះកូអរដោនេនៃ $A$ ផ្ទៀងផ្ទាត់ $(S)$

គេបាន $(3-1)^2+(1-2)^2+(1-3)^2=r^2$ ឬ $r^2=9$ ឬ $r=3$

គេបាន $(S):(x-1)^2+(y-2)^2+(z-3)^2=9$

ដោយពន្លាតសមីការនេះរួចបង្រួមគេបាន ៖

$(S): x^2+y^2+z^2-2x-4y-6z+5=0$ ។

៣.គណនាកូអរដោនេនៃចំណុច $B$

ដោយ $B$ ជាចំណុចមានអាប់ស៊ីស $x_b=0$ នោះ $B(0,y_b,z_b)$ ហើយ $B\in(P)$ និង $B\in(S)$ នោះគេបាន $\begin{cases}-y_b-2z_b+6=0\\ {y_b}^2+{z_b}^2-4y_b-6z_b+5=0\end{cases}$

សមមូល $\begin{cases}y_b=-2z_b+6 & (b_1)\\ {y_b}^2+{z_b}^2-4y_b-6z_b+5=0 & (b_2)\end{cases}$

យកសមីការ $(b_1)$ ជួសក្នុង $(b_2)$ គេបាន ៖

$(-2z_b+6)^2+{z_b}^2-4(-2z_b+6)-6z_b+5=0$

$4{z_b}^2-24z_b+36+{z_b}^2+8z_b-24-6z_b+5=0$

$5{z_b}^2 - 22z_b + 17 = 0$ ដោយ $a+b+c=0$ នោះ $z_b' = 1$ , $z_b'' = \frac{17}{5}$

ចំពោះ $z_b' = 1$ នោះ $y_b = -2+6 = 4$ ។

ដូចនេះ $B_1(0,4,1)$ ។

ចំពោះ $z_b'' = \frac{17}{5}$ នោះ $y_b = -\frac{34}{5} + 6 = -\frac{4}{5}$ ។

ដូចនេះ $B_2\left(0,-\frac{4}{5},\frac{17}{5}\right)$ ។

**៤.គណនាកូអរដោនេនៃចំណុច $C$ ៖**

ដោយ $C$ ជាចំណុចមានអរដោនេ $y_c = 0$ នោះ $C(x_c,0,z_c)$ ហើយ $C \in (P)$ និង $C \in (S)$ នោះគេបាន $\begin{cases} 2x_c - 2z_c + 6 = 0 \\ {x_c}^2 + {z_c}^2 - 2x_c - 6z_c + 5 = 0 \end{cases}$

សមមូល $\begin{cases} x_c = z_c - 3 & (c_1) \\ {x_c}^2 + {z_c}^2 - 2x_c - 6z_c + 5 = 0 & (c_2) \end{cases}$

យកសមីការ $(c_1)$ ជួសក្នុង $(c_2)$ គេបាន ៖

$$(z_c - 3)^2 + {z_c}^2 - 2(z_c - 3) - 6z_c + 5 = 0$$

$$\begin{aligned} {z_c}^2 - 6z_c + 9 + {z_c}^2 - 2z_c + 6 - 6z_c + 5 &= 0 \\ 2{z_c}^2 - 14z_c + 20 &= 0 \\ 2(z_c - 2)(z_c - 5) &= 0 \end{aligned}$$

គេទាញឫស $z_c' = 2$ , $z_c'' = 5$ ។

ចំពោះ $z_c' = 2$ នោះ $x_c = 2-3 = -1$ ។

ដូចនេះ $C_1(-1,0,2)$ ។

ចំពោះ $z_c'' = 5$ នោះ $x_c = 5-3 = 2$ ។

ដូចនេះ $C_2(2,0,5)$ ។

៥.ផ្ទៀងផ្ទាត់ថា $D \in (P)$ និង $D \in (S)$ ៖

គេមាន $D(3,4,4)$ ហើយ $(P): 2x - y - 2z + 6 = 0$

និង $(S): x^2 + y^2 + z^2 - 2x - 4y - 6z + 5 = 0$ ។

យកកូអរដោនេនៃចំណុច $C$ ជំនួសក្នុង $(P)$ គេបាន ៖

$6 - 4 - 8 + 6 = 0$ ឬ $0 = 0$ ផ្ទៀងផ្ទាត់នោះ $D \in (P)$ ។

យកកូអរដោនេនៃចំណុច $C$ ជំនួសក្នុង $(S)$ គេបាន ៖

$9 + 16 + 16 - 6 - 16 - 24 + 5 = 0$ ឬ $0 = 0$ ផ្ទៀងផ្ទាត់នោះ $D \in (S)$ ។

ដូចនេះ $D \in (P)$ និង $D \in (S)$ ។

សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(L)$ ប៉ះនឹងស្វ៊ែ $(S)$ ត្រង់ចំណុច $D$ ដោយដឹងថា $(L) \subset (P)$ ៖




គេមាន $(L) \subset (P)$ និង $\overrightarrow{AH} \perp (P)$ នោះ $\overrightarrow{AH} \perp (L)$ ហើយ $(L)$ ប៉ះនឹង $(S)$ ត្រង់ $D$ នោះ $\overrightarrow{HD} \perp (L)$ ។

ដោយ $\overrightarrow{AH}\perp(L)$ និង $\overrightarrow{HD}\perp(L)$ នោះ $(L)\perp(HAD)$ ហេតុនេះវ៉ិចទ័រណរម៉ាល់

នៃប្លង់ $(HAD)$ ជាវ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $(L)$ ។

វ៉ិចទ័រណរម៉ាល់នៃប្លង់ $(HAD)$ គឺ $\overrightarrow{N}=\overrightarrow{HA}\times\overrightarrow{HD}$ ដោយ $H(1,2,3),A(3,1,1)$

និង $D(3,4,4)$ នោះ $\overrightarrow{HA}=(2,-1,-2)$ & $\overrightarrow{HD}=(2,2,1)$

គេបាន $\overrightarrow{N}=\overrightarrow{HA}\times\overrightarrow{HD}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 2 & -1 & -2\\ 2 & 2 & 1\end{vmatrix}=3\vec{i}-6\vec{j}+6\vec{k}$

សមីការប៉ារ៉ាម៉ែត្របន្ទាត់ $(L)$ ឲ្យតាមរូបមន្ត $(L):\begin{cases}x=x_d+at\\ y=y_d+bt\\ z=z_d+ct\end{cases}\ ,t\in\mathbb{R}$

ដូចនេះ $(L):\begin{cases}x=3+3t\\ y=4-6t\\ z=4+6t\end{cases}$ ដែល $t\in\mathbb{R}$ ជាប៉ារ៉ាម៉ែត្រ។

www.mathtoday.wordpress.com

## លំហាត់ទី០៧

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន$\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបន្ទាត់$(L)$មាន

សមីការឆ្លុះ: $\frac{x-3}{2}=\frac{y-3}{2}=z-2$ និងចំណុច $A(2,-1,3)$ ។

$H$ ជាជើងនៃចំណោលកែងនៃចំណុច$A$ ទៅលើបន្ទាត់$(L)$ ។

១.គណនាកូអរដោនេនៃចំណុច$H$ រួចគណនាប្រវែង$AH$ ។

២.សរសេរសមីការស្តង់ដានៃស្វ៊ែ$(S)$ មានផ្ចិត$H$ ហើយកាត់តាមចំណុច$A$ ។

៣.គណនាកូអរដោនេនៃចំណុច$B$និង$C$ជាប្រសព្វរវាងបន្ទាត់$(L)$និងស្វ៊ែ$(S)$។

៤.$P$ ជាចំណុចមួយផ្ទៀងផ្ទាត់$\overrightarrow{AP}=\overrightarrow{AB}+\overrightarrow{AC}$ ។ គណនាកូអរដោនេនៃ$P$ ។

៥.ផ្ទៀងផ្ទាត់ថា$P\in(S)$ រួចរកប្រភេទនៃចតុកោណ$PBAC$ ។

## ដំណោះស្រាយ

**១.គណនាកូអរដោនេនៃចំណុច$H$ រួចគណនាប្រវែង$AH$ ៖**

គេមាន $(L):\frac{x-3}{2}=\frac{y-3}{2}=z-2$ និងចំណុច $A(2,-1,3)$

តាង$H(x_h,y_h,z_h)$ ។ ដោយ $H$ ជាជើងនៃចំណោលកែងនៃចំណុច$A$ ទៅលើ

បន្ទាត់$(L)$ នោះ $H\in(L)$ សមមូល $\frac{x_h-3}{2}=\frac{y_h-3}{2}=z_h-2$

សមមូល $x_h=2z_h-1$ , $y_h=2z_h-1$ ។

គេបាន $H(2z_h-1\,,2z_h-1\,,z_h)$ ។

វ៉ិចទ័រប្រាប់ទិសនៃបន្ទាត់$(L)$ គឺ $\vec{u}=(2,2,1)$ ។ ដោយ$\overrightarrow{AH}\perp(L)$ នោះគេបាន

$\overrightarrow{AH}\perp\vec{u}\Leftrightarrow\overrightarrow{AH}.\vec{u}=0$ ដោយ $\overrightarrow{AH}=(2z_h-3\,,2z_h\,,z_h-3)$

គេបាន $\overrightarrow{AH}\,.\,\vec{u}=2(2z_h-3)+2(2z_h)+(z_h-3)=0$

សមមូល $4z_h-6+4z_h+z_h-3=0$

$$9z_h-9=0$$

$$z_h=1$$

ហើយ $x_h=2(1)-1=1$ និង $y_h=2(1)-1=1$ ។

ដូចនេះ $H(1,1,1)$ ។

២.សរសេរសមីការស្តង់ដានៃស្វ៊ែ$(S)$ មានផ្ចិត$H$ ហើយកាត់តាមចំណុច$A$ ៖



កាំរបស់ស្វ៊ែ $(S)$ មានផ្ចិត $H$ កាត់តាម $A$ គឺ ៖

$$R = HA = \sqrt{(2-1)^2+(-1-1)^2+(3-1)^2} = 3$$

ដូចនេះសមីការស្វ៊ែ $(S)$ សរសេរ $(S):(x-1)^2+(y-1)^2+(z-1)^2=9$ ។

៣.គណនាកូអរដោនេនៃចំណុច $B$ និង $C$ ជាប្រសព្វរវាងបន្ទាត់ $(L)$ និងស្វ៊ែ $(S)$ ៖

គេមាន $(S):(x-1)^2+(y-1)^2+(z-1)^2=9$

និង $(L):\ \dfrac{x-3}{2}=\dfrac{y-3}{2}=z-2$

តាង $\dfrac{x-3}{2}=\dfrac{y-3}{2}=z-2=t$ នោះ $\begin{cases} x=3+2t \\ y=3+2t \\ z=2+t \end{cases}\ (1)$

យក $(1)$ ជួសក្នុង $(S)$ គេបាន ៖

$$(3+2t-1)^2+(3+2t-1)^2+(2+t-1)^2=9$$

$$(2t+2)^2+(2t+2)^2+(t+1)^2=9$$

$$4t^2+8t+4+4t^2+8t+4+t^2+2t+1=9$$

$$9t^2+18t=0$$

$$9t(t+2)=0$$

គេទាញឫស $t_1=0$ , $t_2=-2$ ។

ចំពោះ $t_1=0$ តាម $(1)$ គេបាន $x=3, y=3, z=2$ ។

ចំពោះ $t_2=-2$ តាម $(1)$ គេបាន $x=-1, y=-1, z=0$ ។

ដូចនេះ $B(3,3,2)$ និង $C(-1,-1,0)$ ។

៤.គណនាកូអរដោនេនៃ $P$ ៖

គេមាន $A(2,-1,3)$ , $B(3,3,2)$ និង $C(-1,-1,0)$ ។

តាង $P(x_p,y_p,z_p)$ នោះ $\overrightarrow{AP}=(x_p-2\,,\,y_p+1,z_p-3)$

ហើយ $\overrightarrow{AB}=(1,4,-1)$ , $\overrightarrow{AC}=(-3,0,-3)$ នោះ $\overrightarrow{AB}+\overrightarrow{AC}=(-2,4,-4)$

ដោយ $\overrightarrow{AP}=\overrightarrow{AB}+\overrightarrow{AC}$ សមមូល $\begin{cases} x_p-2=-2 \\ y_p+1=4 \\ z_p-3=-4 \end{cases}$ ឬ $\begin{cases} x_p=0 \\ y_p=3 \\ z_p=-1 \end{cases}$

ដូចនេះ $P(0,3,-1)$ ។

៥.ផ្ទៀងផ្ទាត់ថា $P\in(S)$ រួចរកប្រភេទនៃចតុកោណ $PBAC$ ៖

គេមាន $P(0,3,-1)$ និង $(S):(x-1)^2+(y-1)^2+(z-1)^2=9$

យកកូអរដោនេនៃចំណុច $P$ ជួសក្នុងសមីការ $(S)$ គេបាន ៖

$(0-1)^2+(3-1)^2+(-1-1)^2=9$ ឬ $9=9$ ផ្ទៀងផ្ទាត់។

ដូចនេះ $P\in(S)$ ។

គេមាន $P(0,3,-1)$ , $A(2,-1,3)$ , $B(3,3,2)$ និង $C(-1,-1,0)$ ។

នោះ $\overrightarrow{AP}=(2,-4,4)$ និង $\overrightarrow{BC}=(-4,-4,-2)$

គេបាន $\overrightarrow{AP}.\overrightarrow{BC}=-8+16-8=0 \Leftrightarrow \overrightarrow{AP}\perp\overrightarrow{BC}$

ហើយ $|\overrightarrow{AP}|=\sqrt{4+16+16}=6$ , $|\overrightarrow{BC}|=\sqrt{16+16+4}=6$ នោះ $AP=BC$

ចតុកោណ $PBAC$ មានអង្កត់ទ្រូង $AP=BC=6$ និង $AP\perp BC$ ជាការេ។

www.mathtoday.wordpress.com

## លំហាត់ទី០៨

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យស្វ៊ែ $(S)$ មានសមីការ $x^2+y^2+z^2-4x+2y-2z-3=0$ និងចំណុច $P(-1,5,7)$ ។

១.គណនាកូអរដោនេនៃផ្ចិត $I$ និងកាំ $r$ របស់ស្វ៊ែ $(S)$ រួចគណនា $IP$ ។

២.បន្ទាត់ $(IP)$ ប្រសព្វស្វ៊ែ $(S)$ ត្រង់ចំណុច $A$ និង $B$ ដែល $A$ នៅចន្លោះចំណុច $I$ និង $P$ ។ គណនា $PA$ និង $PB$ ។

៣.គណនាកូអរដោនេនៃចំណុច $A$ និង $B$ ។

៤.រកសំណុំនៃចំណុច $M$ ស្ថិតនៅលើស្វ៊ែ $(S)$ ដែលផ្ទៀងផ្ទាត់ $PM^2=PA.PB$ ។

## ដំណោះស្រាយ

**១.គណនាកូអរដោនេនៃផ្ចិត $I$ និងកាំ $r$ របស់ស្វ៊ែ $(S)$ រួចគណនា $IP$**

សមីការ $x^2+y^2+z^2-4x+2y-2z-3=0$ អាចសរសេរជាទម្រង់ស្តង់ដា

$(S):(x-2)^2+(y+1)^2+(z-1)^2=9$ ។

ដូចនេះកូអរដោនេនៃផ្ចិតនិងកាំនៃស្វ៊ែគឺ $I(2,-1,1)$ និង $r=3$ ។

ម្យ៉ាងទៀតគេមាន $P(-1,5,7)$ នោះ $\overrightarrow{IP}=(-3,6,6)$ ។

គេបាន $IP=|\overrightarrow{IP}|=\sqrt{9+36+36}=\sqrt{81}=9$ ។

ដូចនេះ $IP=9$ (ឯកតាប្រវែង)។

២.គណនា $PA$ និង $PB$ ៖




បន្ទាត់$(IP)$ប្រសព្វស្វ៊ែ$(S)$ ត្រង់ចំណុច $A$ និង $B$ ដែល $A$ នៅចន្លោះចំណុច $I$ និង $P$ នោះគេបាន $PA = IP - IA = IP - r = 9 - 3 = 6$ (ឯកតាប្រវែង)។

ហើយ $PB = IP + IB = IP + r = 9 + 3 = 12$ (ឯកតាប្រវែង)។

ដូចនេះ $PA = 6$ , $PB = 12$ (ឯកតាប្រវែង)។

៣.គណនាកូអរដោនេនៃចំណុច $A$ និង $B$ ៖

យើងមាន $IA = 3$ , $IP = 9$ នោះ $\overrightarrow{IA} = \frac{1}{3}\overrightarrow{IP}$ ដោយ $\overrightarrow{IP} = (-3,6,6)$

និង $\overrightarrow{IA} = (x_a - 2, y_a + 1, z_a - 1)$ នោះគេបាន ៖

$$\begin{cases} x_a - 2 = -1 \\ y_a + 1 = 2 \\ z_a - 1 = 2 \end{cases} \quad \text{សមមូល} \quad \begin{cases} x_a = 1 \\ y_a = 1 \\ z_a = 3 \end{cases}$$

ដូចនេះ $A(1,1,3)$ ។

ម្យ៉ាងទៀតគេមាន $AB = 2r = 6$ និង $AP = 6$ នោះ $A$ ជាចំណុចកណ្ដាលនៃ

អង្កត់ $[BP]$ ។ គេបាន $\begin{cases} x_a = \dfrac{x_b + x_p}{2} \\ y_a = \dfrac{y_b + y_p}{2} \\ z_a = \dfrac{z_b + z_p}{2} \end{cases}$ នោះ $\begin{cases} x_b = 2x_a - x_p \\ y_b = 2y_a - y_p \\ z_b = 2z_a - z_p \end{cases}$

ដោយ $A(1,1,3)$ និង $P(-1,5,7)$ នោះ $\begin{cases} x_b = 2+1 = 3 \\ y_b = 2-5 = -3 \\ z_b = 6-7 = -1 \end{cases}$

ដូចនេះ $B(3,-3,-1)$ ។

៤.រកសំណុំនៃចំណុច $M$ ស្ថិតនៅលើស្វ៊ែ $(S)$ ដែលផ្ទៀងផ្ទាត់ $PM^2 = PA.PB$ ៖

តាង $(C)$ ជារង្វង់បានមកពីប្រសព្វរវាងប្លង់ $(MAB)$ ជាមួយស្វ៊ែ $(S)$ ។

តាមទ្រឹស្ដីបទស្វ័យគុណចំណុច $P$ ធៀបទៅនឹងរង្វង់ $(C)$ ដែល $PM^2 = PA.PB$

នោះគេបាន $PM$ ជាបន្ទាត់ប៉ះទៅនឹងរង្វង់ $(C)$ ត្រង់ $M$ ។

ដោយ $[AB]$ ជាអង្កត់ផ្ចិតរបស់ស្វ៊ែ $(S)$ នោះប្លង់ $(MAB)$ ជាប្លង់វិជ្ឈមាត្រនៃ $(S)$

នោះគេទាញបានផ្ចិត $I$ របស់ស្វ៊ែ $(S)$ គឺជាផ្ចិតនៃរង្វង់ $(C)$ ។

គេទាញបាន $PM \perp IM$ ហើយដោយ $M \in (S)$ នោះសំណុំចំណុច $M$ គឺជា

រង្វង់ $(C')$ ដែលជាប្រសព្វរវាងស្វ៊ែ $(S)$ និងប្លង់ដែលកាត់តាម $M$ ហើយកែងនឹង

$[AB]$ ត្រង់ចំណុច $H$ ដែល $H$ ជាផ្ចិតនិង $MH$ ជាកាំរបស់រង្វង់ $(C')$ ។

យើងអាចគណនារង្វាស់ $MH$ និងកូអរដោនេចំណុច $H$ ដូចខាងក្រោម៖

គេមាន $PM^2 = PA.PB = 6\times12 = 72$ នោះ $PM = 6\sqrt{2}$ និង $IM = r = 3$

ក្នុងត្រីកោណកែង $PMI$ មាន $MH$ ជាកម្ពស់គេមានទំនាក់ទំនង ៖

$\dfrac{1}{MH^2} = \dfrac{1}{IM^2} + \dfrac{1}{PM^2} = \dfrac{1}{9} + \dfrac{1}{72} = \dfrac{1}{8}$ នោះគេទាញបាន $MH = 2\sqrt{2}$ ។

ក្នុងត្រីកោណកែង $IMH$ គេមាន $IM^2 = IH^2 + MH^2$ (ពីតាគ័រ)

គេទាញ $IH = \sqrt{3^2 - (2\sqrt{2})^2} = \sqrt{9-8} = 1$ ។

ដោយ $IA = 3$ នោះ $\overrightarrow{IH} = \dfrac{1}{3}\overrightarrow{IA}$ ដោយ $I(2,-1,1), A(1,1,3)$

គេបាន $\overrightarrow{IA} = (-1,2,2)$ និង $\overrightarrow{IH} = (x_h - 2, y_h + 1, z_h - 1)$

$$\overrightarrow{IH} = \frac{1}{3}\overrightarrow{IA} \text{ សមមូល } \begin{cases} x_h - 2 = -\dfrac{1}{3} \\ y_h + 1 = \dfrac{2}{3} \\ z_h - 1 = \dfrac{2}{3} \end{cases} \text{ ឬ } \begin{cases} x_h = \dfrac{5}{3} \\ y_h = -\dfrac{1}{3} \\ z_h = \dfrac{5}{3} \end{cases}$$

ដូចនេះ $H\left(\dfrac{5}{3}, -\dfrac{1}{3}, \dfrac{5}{3}\right)$ ជាកូអរដោនេផ្ចិតនៃរង្វង់ $(C')$ ។

## លំហាត់ទី០៩

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច

$A(0;-3;-4)$ ; $B(2,1,8)$ ; $C(2;4;5)$ និង $D(4;-2,-3)$ ។ $M$ និង $N$ ជាពីរចំណុចស្ថិតនៅលើបន្ទាត់រៀងគ្នា $(AB)$ និង $(CD)$ ។

កំណត់កូអរដោនេនៃចំនុច $M$ និង $N$ ដើម្បីឲ្យអង្កត់ $MN$ មានប្រវែងខ្លីបំផុត រួចកំណត់ប្រវែងខ្លីបំផុតនោះ ។

## ដំណោះស្រាយ

កំណត់កូអរដោនេនៃចំនុច $M$ និង $N$

តាង $M(x_1;y_1;z_1)$ និង $N(x_2;y_1;z_2)$

គេមាន $\overrightarrow{AB}(2;4;12)$ ; $\overrightarrow{CD}(2;-6;-8)$

$\overrightarrow{AM}(x_1;y_1+3;z_1+4)$ និង $\overrightarrow{CN}(x_2-2;y_2-4;z_2-5)$

ដោយ $M\in(AB)\Rightarrow\overrightarrow{AM}\,//\,\overrightarrow{AB}$

គេទាញ $\dfrac{x_1}{2}=\dfrac{y_1+3}{4}=\dfrac{z_1+4}{12}=p\Rightarrow\begin{cases}x_1=2p\\y_1=4p-3\\z_1=12p-4\end{cases}\quad(i)$

ដូចគ្នាដែរ $N\in(CD)\Rightarrow\overrightarrow{CN}\,//\,\overrightarrow{CD}$

គេទាញ $\dfrac{x_2-2}{2}=\dfrac{y_2-4}{-6}=\dfrac{z_2-5}{-8}=q\Rightarrow\begin{cases}x_2=2q+2\\y_2=-6q+4\\z_2=-8q+5\end{cases}\quad(ii)$

កំប៉ុសង់ស្កាលែនៃវ៉ិចទ័រ $\overrightarrow{MN}$ គឺ ៖

$\overrightarrow{MN}=(2q-2p+2\ ;-6q-4p+7\ ;-8q-12p+9)$

ដើម្បីឲ្យអង្គត់ $MN$ មានប្រវែងខ្លីបំផុត រួចកំនត់ប្រវែងខ្លីបំផុតលុះត្រាតែ ៖

$\overrightarrow{MN}\perp\overrightarrow{AB}$ និង $\overrightarrow{MN}\perp\overrightarrow{CD}$ សមមូល $\overrightarrow{MN}.\overrightarrow{AB}=0$ និង $\overrightarrow{MN}.\overrightarrow{CD}=0$

$\overrightarrow{MN}.\overrightarrow{AB}=-22p-58q+80=0\Rightarrow 11p+59q-40=0(1)$

$\overrightarrow{MN}.\overrightarrow{CD}=62p+48q-55=0\ \ (2)$

តាមសមីការ (1) និង (2) គេបានប្រព័ន្ធ $\begin{cases}11p+59q-40=0\\62p+48q-55=0\end{cases}$

បន្ទាប់ពីដោះស្រាយគេទទួលបានចម្លើយ $p=q=\dfrac{1}{2}$ ។

យកតម្លៃ $p=\dfrac{1}{2}$ និង $q=\dfrac{1}{2}$ ជំនួសក្នុង $(i)$ និង $(ii)$

គេបាន $M(1\ ;-1\ ;2\ )$ និង $N(3\ ;1\ ;1\ )$ ។

**កំណត់ប្រវែងខ្លីបំផុតរបស់ អង្កត់ $MN$ ៖**

គេមាន $\overrightarrow{MN}=(2\ ;2\ ;-1)$ នោះគេបាន $|\overrightarrow{MN}|=\sqrt{4+4+1}=\sqrt{9}=3$

ដូចនេះប្រវែងខ្លីបំផុតរបស់អង្កត់ $MN$ គឺ $MN=3$ (ឯកតាប្រវែង)។

www.mathtoday.wordpress.com

## លំហាត់ទី១០

ក្នុងតម្រុយអរតូណម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$ គេមានបីចំណុច $A(-1,2,3)$ , $B(0,-1,1)$ និង $C(2,3,5)$ ។

១.ចូរកំណត់សមីការប្លង់ $(P)$ កាត់តាមចំណុច $A$ ហើយកែងនឹងវ៉ិចទ័រ $\overline{BC}$ និងសមីការប៉ារ៉ាម៉ែត្របន្ទាត់ $(L)$ កាត់តាមពីរចំណុច $B$ និង $C$ ។

២.គណនាកូអរដោនេនៃចំណុចប្រសព្វ $H$ រវាងបន្ទាត់ $(L)$ ជាមួយប្លង់ $(P)$ ។

៣.រកប្រភេទនៃត្រីកោណ $ABC$ រួចគណនាផ្ទៃក្រលានៃ $\Delta ABC$ ។

## ដំណោះស្រាយ

**១.កំណត់សមីការប្លង់ $(P)$ និងសមីការប៉ារ៉ាម៉ែត្របន្ទាត់ $(L)$**

វ៉ិចទ័រណរម៉ាល់នៃប្លង់ $(P)$ គឺ $\vec{n}=\overrightarrow{BC}=(2,4,4)$ ។

សមីការប្លង់ $(P)$ កាត់តាមចំណុច $A$ អាចសរសេរតាមរូបមន្ត

$$(P): a(x-x_A)+b(y-y_A)+c(z-z_A)=0$$

$$(P): 2(x+1)+4(y-2)+4(z-3)=0$$
$$(P): 2x+4y+4z-18=0$$
$$(P): x+2y+2z-9=0$$

ដូចនេះ $(P): x+2y+2z-9=0$ ។

វ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $(L)$ គឺ $\vec{u}=\overrightarrow{BC}=(2,4,4)$

សមីការបន្ទាត់ $(L)$ កាត់តាមពីរចំណុច $B$ និង $C$ អាចសរសេរ៖

តាមរូបមន្ត $(L):\begin{cases} x = x_B + at \\ y = y_B + bt \\ z = z_B + ct \quad , t \in \mathbb{R} \end{cases}$

ដូចនេះ $(L):\begin{cases} x = 2t \\ y = -1 + 4t \\ z = 1 + 4t \quad , t \in \mathbb{R} \end{cases}$

២.គណនាកូអរដោនេនៃចំណុចប្រសព្វ $H$ ៖

យកសមីការ $(L)$ ជំនួសក្នុង $(P)$ គេបាន ៖

$18t - 9 = 0$ នាំឲ្យ $t = \frac{1}{2}$ ។

យកតម្លៃ $t = \frac{1}{2}$ ជួសក្នុងសមីការ$(L)$គេបាន $\begin{cases} x = 1 \\ y = -1 + 2 = 1 \\ z = 1 + 2 = 3 \end{cases}$

ដូចនេះ $H(1,1,3)$ ។

៣.រកប្រភេទនៃត្រីកោណ $ABC$ រួចគណនាផ្ទៃក្រលានៃ $\Delta ABC$

គេមាន $\overrightarrow{AB} = (1,-3,-2)$ ; $\overrightarrow{BC} = (2,4,4)$ ; $\overrightarrow{CA} = (-3,-1,-2)$

ដោយ $|\overrightarrow{AB}| = \sqrt{1+9+4} = \sqrt{14}$ ; $|\overrightarrow{CA}| = \sqrt{9+1+4} = \sqrt{14}$

នោះគេទាញ $|\overrightarrow{AB}| = |\overrightarrow{CA}| = \sqrt{14}$ ។

ដូចនេះ $ABC$ ជាត្រីកោណសមបាតកំពូល $A$ ។ ម្យ៉ាងទៀត $\overrightarrow{AH} = (2,-1,0)$

គេបាន $\overrightarrow{AH}.\overrightarrow{BC} = (2)(2) + (-1)(4) + (0)(4) = 0$ សមមូល $\overrightarrow{AH} \perp \overrightarrow{BC}$

នោះ $AH$ ជាកម្ពស់នៃ $\Delta ABC$ ។ គេបាន $S_{ABC} = \frac{1}{2}AH.BC$

តែ $AH = \sqrt{4+1+0} = \sqrt{5}$ ,$BC = \sqrt{4+16+16} = 6$

ដូចនេះ $S_{ABC} = 3\sqrt{5}$ (ឯកតាផ្ទៃ)។

## លំហាត់ទី១១

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបន្ទាត់ $(L)$ មាន

សមីការប៉ារ៉ាម៉ែត្រ $(L):\begin{cases}x=2+t\\y=6+4t\\z=2-t\quad ,t\in\mathbb{R}\end{cases}$ និងប្លង់ $(P):2x+2y+z-9=0$ ។

១.គណនាកូអរដោនេនៃចំណុចប្រសព្វ $A$ រវាងបន្ទាត់ $(L)$ និងប្លង់ $(P)$ ។

២. $M$ ជាចំណុចមានអាប់ស៊ីស $x=3$ និងស្ថិតនៅលើ $(L)$ ហើយ $H$ ជាចំណោលកែងនៃចំណុច $M$ ទៅលើប្លង់ $(P)$ ។គណនាកូអរដោនេនៃចំណុច $M$ និង $H$ ។

៣.គេសង់ប្លង់ $(Q)$ កែងនឹងបន្ទាត់ $(L)$ ត្រង់ $M$ ហើយគេតាង $(d)$ ជាបន្ទាត់ប្រសព្វរវាងប្លង់ $(P)$ និង $(Q)$ ។សរសេរសមីការប្លង់ $(Q)$ និងសមីការប៉ារ៉ាម៉ែត្របន្ទាត់ $(d)$ ។

៤.គេគូសបន្ទាត់ $(AH)$ ប្រសព្វប្លង់ $(Q)$ ត្រង់ $K$ ។ចូរសរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(AH)$ រួចគណនាកូអរដោនេនៃចំណុច $K$ ។

៥.គណនា $MA$ និង $MK$ រួចទាញបញ្ជាក់ប្រភេទនៃត្រីកោណ $AMK$ ។

## ដំណោះស្រាយ

**១.គណនាកូអរដោនេនៃចំណុចប្រសព្វ $A$ រវាងបន្ទាត់ $(L)$ និងប្លង់ $(P)$**

តាង $A(x_a,y_a,z_a)$ ។ ដោយ $A\in(L)$ និង $A\in(P)$ គេបាន៖

$$\begin{cases}x_a=2+t\\y_a=6+4t\quad(1)\\z_a=2-t\end{cases}\quad \text{និង}\quad 2x_a+2y_a+z_a-9=0\quad(2)$$

យកសមីការ $(1)$ ជួសក្នុងសមីការ $(2)$ គេបាន៖

$2(2+t)+2(6+4t)+(2-t)-9=0$

$4+2t+12+8t+2-t-9=0$

$9t+9=0$

គេទាញបាន $t=-1$ យកជំនួសក្នុងសមីការ$(1)$ គេបាន $\begin{cases} x_a = 2-1=1 \\ y_a = 6-4=2 \\ z_a = 2+1=3 \end{cases}$

ដូចនេះ $A(1,2,3)$ ។




២.គណនាកូអរដោនេនៃចំណុច $M$ និង $H$

ដោយ $M \in (L)$ ជាចំណុចមានអាប់ស៊ីស $x=3$នោះគេបាន$\begin{cases} x_m = 2+t=3 \\ y_m = 6+4t \\ z_m = 2-t \end{cases}$

គេទាញបាន $t=1$ ហើយ $y_m = 6+4=10$ , $z_m = 2-1=1$ ។

ដូចនេះ $M(3,10,1)$ ។

ម្យ៉ាងទៀត $H$ ជាចំណោលកែងនៃចំណុច $M$ ទៅលើប្លង់ $(P)$ នោះ $H\in(P)$

គេបាន $2x_h+2y_h+z_h-9=0\quad(3)$

ប្លង់ $(P):2x+2y+z-9=0$ មានវ៉ិចទ័រណរម៉ាល់ $\vec{n_p}=(2,2,1)$ ។

គេមាន $\overrightarrow{MH}\perp(P)$ និង $\vec{n_p}\perp(P)$ នោះ $\overrightarrow{MH}//\vec{n_p}$ គេទាញ $\overrightarrow{MH}=\lambda\vec{n_p}$

ដោយ $\overrightarrow{MH}=(x_h-3,y_h-10,z_h-1)$ និង $\vec{n_p}=(2,2,1)$

គេបាន $\begin{cases}x_h-3=2\lambda\\ y_h-10=2\lambda\\ z_h-1=\lambda\end{cases}$ ឬ $\begin{cases}x_h=3+2\lambda\\ y_h=10+2\lambda\\ z_h=1+\lambda\end{cases}\quad(4)$

យក $(4)$ ជួសក្នុង $(3)$ គេបាន $2(3+2\lambda)+2(10+2\lambda)+(1+\lambda)-9=0$

$$6+4\lambda+20+4\lambda+1+\lambda-9=0$$

$$9\lambda+18=0$$

$$\lambda=-2$$

យក $\lambda=-2$ ជួសក្នុង $(4)$ គេបាន $\begin{cases}x_h=3-4=-1\\ y_h=10-4=6\\ z_h=1-2=-1\end{cases}$ ។

ដូចនេះ $H(-1,6,-1)$ ។

៣.សរសេរសមីការប្លង់ $(Q)$ និងសមីការប៉ារ៉ាម៉ែត្របន្ទាត់ $(d)$

ដោយប្លង់ $(Q)$ កែងនឹងបន្ទាត់ $(L)$ ត្រង់ $M$ នោះវ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $(L)$ គឺជាវ៉ិចទ័រណរម៉ាល់របស់ប្លង់ $(Q)$ គឺ $\overrightarrow{n_Q}=\overrightarrow{u_L}=(1,4,-1)$ និង $M(3,10,1)\in(Q)$

សមីការនៃប្លង់ $(Q)$ អាចសរសេរតាមរូបមន្ត ៖

$(Q):a(x-x_m)+b(y-y_m)+c(z-z_m)=0$

$1(x-3)+4(y-10)-(z-1)=0$

$x-3+4y-40-z+1=0$

$x+4y-z-42=0$

ដូចនេះ $(Q): x+4y-z-42=0$ ។

ហើយដោយ $(d)$ ជាបន្ទាត់ប្រសព្វរវាងប្លង់$(P)$និង$(Q)$នោះវាជាសំណុំចម្លើយ

នៃប្រព័ន្ធសមីការ $\begin{cases} 2x+2y+z-9=0 \\ x+4y-z-42=0 \end{cases}$

យក $y=t$ $,t\in\mathbb{R}$ នោះគេបាន $\begin{cases} 2x+2t+z-9=0 & (i) \\ x+4t-z-42=0 & (ii) \end{cases}$

បូកសមីការ $(i)\&(ii)$ គេបាន $3x+6t-51=0$ នោះ $x=17-2t$

តាម$(i)$ គេបាន $2(17-2t)+2t+z-9=0$ នោះ $z=-25+2t$

ដូចនេះសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់គឺ$(d)$: $\begin{cases} x=17-2t \\ y=t \\ z=-25+2t \quad , \quad t\in\mathbb{R} \end{cases}$

៨.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(AH)$ រួចគណនាកូអរដោនេនៃចំណុច $K$ ។

បន្ទាត់$(AH)$មានវិុចទ័រប្រាប់ទិស $\overrightarrow{AH}=(-2,4,-4)$ឬ $\frac{1}{2}\overrightarrow{AH}=(-1,2,-2)$

តាមរូបមន្ត $(AH)$: $\begin{cases} x=x_a+at \\ y=y_a+bt \\ z=z_a+ct \quad ,t\in\mathbb{R} \end{cases}$

ដូចនេះ $(AH)$: $\begin{cases} x=1-t \\ y=2+2t \\ z=3-2t \quad , \ t\in\mathbb{R} \end{cases}$

ម្យ៉ាងទៀតដោយបន្ទាត់$(AH)$ ប្រសព្វប្លង់$(Q)$ត្រង់ $K$ នោះគេបាន ៖

$\begin{cases} x_k = 1 - t \\ y_k = 2 + 2t \\ z_k = 3 - 2t \end{cases}$ $(5)$ និង $x_k + 4y_k - z_k - 42 = 0$ $(6)$

យកសមីការ$(5)$ ជំនួសក្នុង$(6)$ គេបាន $(1-t)+4(2+2t)-(3-2t)-42=0$

ឬ $1-t+8+8t-3+2t-42=0$

ឬ $9t-36=0$ នោះគេទាញបាន $t=4$ យកជួសក្នុង$(5)$នោះ$\begin{cases} x_k = 1-4 = -3 \\ y_k = 2+8 = 10 \\ z_k = 3-8 = -5 \end{cases}$

ដូចនេះ $K(-3\ ,10\ ,-5)$ ។

ឌ.គណនា $MA$ និង $MK$ រួចទាញបញ្ជាក់ប្រភេទនៃត្រីកោណ $AMK$ ៖

គេមាន $A(1,2,3)$ , $M(3,10,1)$ និង $K(-3\ ,10\ ,-5)$ ។

គេបាន $\overrightarrow{MA} = (2,8,-2)$ & $\overrightarrow{MK} = (-6\ ,0\ ,-6)$

នោះ $MA = |\overrightarrow{MA}| = \sqrt{4+64+4} = \sqrt{72} = 6\sqrt{2}$

ហើយ $MK = |\overrightarrow{MK}| = \sqrt{36+0+36} = \sqrt{72} = 6\sqrt{2}$

ដូចនេះ $MA = MK = 6\sqrt{2}$ (ឯកតាប្រវែង)។

គេមាន $\overrightarrow{MA}.\overrightarrow{MK} = -12+0+12 = 0 \Leftrightarrow \overrightarrow{MA} \perp \overrightarrow{MK}$ និង $MA = MK = 6\sqrt{2}$

ដូចនេះ $AMK$ ជាត្រីកោណកែងសមបាតកំពូល $M$ ។

www.mathtoday.wordpress.com

## លំហាត់ទី១២

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបន្ទាត់ $(L)$ មាន

សមីការប៉ារ៉ាម៉ែត្រ $(L):\begin{cases}x=1+t\\y=5-4t\\z=4-t\quad,t\in\mathbb{R}\end{cases}$ និងប្លង់ $(P):x+2y+2z-10=0$ ។

១.គណនាកូអរដោនេនៃចំណុចប្រសព្វ $A$ រវាងបន្ទាត់ $(L)$ និងប្លង់ $(P)$ ។

២.គេសង់ប្លង់ $(Q)$ កែងនឹងបន្ទាត់ $(L)$ ត្រង់ $A$ និងសង់បន្ទាត់ $(d)$ កែងនឹងប្លង់ $(P)$ ត្រង់ចំណុច $A$ ដែរ។ចូរសរសេរសមីការប្លង់ $(Q)$ និងសមីការប៉ារ៉ាម៉ែត្របន្ទាត់ $(d)$ ។

៣. $M$ ជាចំណុចមានអាប់ស៊ីស $x=0$ និងស្ថិតនៅលើបន្ទាត់ $(d)$ ហើយ $H$ និង $K$ ជាជើងនៃចំណោលកែងនៃចំណុច $M$ ទៅលើបន្ទាត់ $(d)$ និងប្លង់ $(Q)$ រៀងគ្នា។ គណនាកូអរដោនេនៃចំណុច $M,H$ និង $K$ ។

៤.ចូរស្រាយថាបួនចំណុច $M,H,A,K$ ស្ថិតនៅក្នុងប្លង់តែមួយ។

៥.ចូរស្រាយថាចតុកោណ $MHAK$ ជាការេ។

## ដំណោះស្រាយ

**១.គណនាកូអរដោនេនៃចំណុចប្រសព្វ $A$ រវាងបន្ទាត់ $(L)$ និងប្លង់ $(P)$**

តាង $A(x_a,y_a,z_a)$ ។ ដោយ $A\in(L)$ និង $A\in(P)$ គេបាន៖

$$\begin{cases}x_a=1+t\\y_a=5-4t\\z_a=4-t\end{cases}\quad(1)\text{ និង }x_a+2y_a+2z_a-10=0\quad(2)\text{ ។}$$

យកសមីការ $(1)$ ជួសក្នុង $(2)$ គេបាន៖

$$(1+t)+2(5-4t)+2(4-t)-10=0$$
$$1+t+10-8t+8-2t-10=0$$
$$-9t+9=0$$
$$t=1$$

យក $t=1$ ជំនួសក្នុង $(1)$ គេបាន $\begin{cases} x_a=1+1=2 \\ y_a=5-4=1 \\ z_a=4-1=3 \end{cases}$

ដូចនេះ $A(2,1,3)$ ។




២.សរសេរសមីការប្លង់ $(Q)$ និងសមីការប៉ារ៉ាម៉ែត្របន្ទាត់ $(d)$

ដោយប្លង់ $(Q)$ កែងនឹងបន្ទាត់ $(L)$ ត្រង់ $A$ នោះវិចទ័រប្រាប់ទិសនៃបន្ទាត់ $(L)$ គឺជា

វ៉ិចទ័រណរម៉ាល់នៃប្លង់$(Q)$ គឺ $\overrightarrow{n_Q}=\overrightarrow{u_L}=(1,-4,-1)$ ។

សមីការនៃប្លង់$(Q)$ អាចសរសេរតាមរូបមន្ត ៖

$(Q): a(x-x_a)+b(y-y_a)+c(z-z_a)=0$ ដោយ $A(2,1,3)$

$$1(x-2)-4(y-1)-1(z-3)=0$$
$$x-2-4y+4-z+3=0$$
$$x-4y-z+5=0$$

ដូចនេះ $(Q): x-4y-z+5=0$ ។

ម្យ៉ាងទៀតដោយបន្ទាត់$(d)$កែងនឹងប្លង់$(P)$ត្រង់ចំណុច$A$ដែរនោះវ៉ិចទ័រណរម៉ាល់នៃប្លង់$(P)$គឺជាវ៉ិចទ័រប្រាប់ទិសនៃបន្ទាត់$(d)$គឺ $\overrightarrow{u_d}=\overrightarrow{n_p}=(1,2,2)$ ។

សមីការបន្ទាត់$(d)$ អាចសរសេរតាមរូបមន្ត $(d):\begin{cases} x=x_a+at \\ y=y_a+bt \\ z=z_a+ct \quad ,t\in\mathbb{R} \end{cases}$

ដោយ $A(2,1,3)$ ដូចនេះ $(d):\begin{cases} x=2+t \\ y=1+2t \\ z=3+2t \quad ,t\in\mathbb{R} \end{cases}$ ។

**៣.គណនាកូអរដោនេនៃចំណុច $M, H$ និង $K$**

ដោយ$M$ ជាចំណុចមានអាប់ស៊ីស$x=0$និងស្ថិតនៅលើបន្ទាត់$(d)$នោះគេបាន៖

$\begin{cases} x_m=2+t=0 \\ y_m=1+2t \\ z_m=3+2t \end{cases}$ គេទាញបាន $t=-2$ និង $y_m=1-4=-3, z_m=3-4=-1$ ។

ដូចនេះ $M(0,-3,-1)$ ។

តាង $H(x_h,y_h,z_h)$ ជាជើងនៃចំណោលកែងនៃចំណុច$M$ ទៅលើបន្ទាត់$(d)$

គេបាន $H\in(L)$ សមមូល $\begin{cases}x_h=1+t\\ y_h=5-4t \quad (3)\\ z_h=4-t\end{cases}$ និង

គេមាន $\overrightarrow{MH}=(1+t\ ,8-4t\ ,5-t)$ ហើយដោយ $\overrightarrow{MH}\perp(L)$ និង $\overrightarrow{u_L}//(L)$

គេបាន $\overrightarrow{MH}\perp\overrightarrow{u_L}\Leftrightarrow\overrightarrow{MH}.\overrightarrow{u_L}=0$ ដោយ $\overrightarrow{u_L}=(1,-4,-1)$

នោះ $\overrightarrow{MH}.\overrightarrow{u_L}=(1+t)-4(8-4t)-(5-t)=0$

$$1+t-32+16t-5+t=0$$

$$18t-36=0$$

$$t=2$$

យកតម្លៃ $t=2$ ជួសក្នុង $(3)$ គេបាន $\begin{cases}x_h=1+2=3\\ y_h=5-8=-3\\ z_h=4-2=2\end{cases}$

ដូចនេះ $H(3,-3,2)$ ។

តាង $K(x_k,y_k,z_k)$ ជាជើងនៃចំណោលកែងនៃចំណុច $M$ ទៅលើប្លង់ $(Q)$

គេមាន $K\in(Q)$ សមមូល $x_k-4y_k-z_k+5=0\ (4)$

គេមាន $\overrightarrow{MK}\perp(Q)$ និង $\overrightarrow{n_Q}\perp(Q)$ នោះគេទាញ $\overrightarrow{MK}//\overrightarrow{n_Q}$

សមមូល $\overrightarrow{MK}=\lambda\overrightarrow{n_Q}$ ដោយ $\overrightarrow{MK}=(x_k\ ,y_k+3\ ,\ z_k+1)$ និង $\overrightarrow{n_Q}=(1,-4,-1)$

គេបាន $\begin{cases}x_k=\lambda\\ y_k+3=-4\lambda\\ z_k+1=-\lambda\end{cases}$ សមមូល $\begin{cases}x_k=\lambda\\ y_k=-3-4\lambda \quad (5)\\ z_k=-1-\lambda\end{cases}$

យក $(5)$ ជួសកក្នុង $(4)$ គេបាន $\lambda-4(-3-4\lambda)-(-1-\lambda)+5=0$

$$\lambda+12+16\lambda+1+\lambda+5=0$$

គេទាញបាន $\lambda = -\frac{18}{18} = -1$ យកជួសក្នុង$(5)$គេបាន$\begin{cases} x_k = -1 \\ y_k = -3+4 = 1 \\ z_k = -1+1 = 0 \end{cases}$

ដូចនេះ $K(-1,1,0)$ ។

៨.ស្រាយថាបួនចំណុច $M,H,A,K$ ស្ថិតនៅក្នុងប្លង់តែមួយ៖

គេមាន$M(0,-3,-1),H(3,-3,2),A(2,1,3)$ និង $K(-1,1,0)$ ។

គេបាន $\overrightarrow{MH}=(3,0,3),\overrightarrow{MA}=(2,4,4),\overrightarrow{MK}=(-1,4,1)$

នោះ $\left(\overrightarrow{MH}\times\overrightarrow{MA}\right)\cdot\overrightarrow{MK} = \begin{vmatrix} 3 & 0 & 3 \\ 2 & 4 & 4 \\ -1 & 4 & 1 \end{vmatrix} = 3(4-16)-0(2+4)+3(8+4)$

$= -36+0+36 = 0$

គេទាញបាន $\overrightarrow{MH},\overrightarrow{MA},\overrightarrow{MK}$ ជាវ៉ិចទ័រកូប្លានែ( ស្ថិតក្នុងប្លង់តែមួយ )។

ដូចនេះបួនចំណុច $M,H,A,K$ ស្ថិតនៅក្នុងប្លង់តែមួយ។

៩.ស្រាយថាចតុកោណ $MHAK$ ជាការេ៖

គេមាន $\overrightarrow{MH}=(3,0,3)$ & $\overrightarrow{MK}=(-1,4,1)$

គេបាន $\overrightarrow{MH}.\overrightarrow{MK} = -3+0+3 = 0 \Leftrightarrow \overrightarrow{MH}\perp\overrightarrow{MK}$

ហើយ $|\overrightarrow{MH}| = \sqrt{9+0+9} = 3\sqrt{2}$ , $|\overrightarrow{MK}| = \sqrt{1+16+1} = 3\sqrt{2}$

នោះគេទាញ $MH = MK = 3\sqrt{2}$ ។ម្យ៉ាងទៀត$MK\perp AK$ និង $MH\perp AH$

ព្រោះ$H \& K$ ជាជើងនៃចំណោលកែងនៃ$M$ លើបន្ទាត់$(L)$និងប្លង់$(Q)$ ។

ដូចនេះចតុកោណ$MHAK$ ជាការេ។

## លំហាត់ទី១៣

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបន្ទាត់ $(L)$ មាន

សមីការប៉ារ៉ាម៉ែត្រ $(L):\begin{cases}x=1+t\\ y=4-t\\ z=9-4t\end{cases}, t\in\mathbb{R}$ និងប្លង់ $(P):2x+y-2z-6=0$ ។

១.គណនាកូអរដោនេនៃចំណុចប្រសព្វ $A$ រវាងបន្ទាត់ $(L)$ និងប្លង់ $(P)$ ។

២.គេឲ្យ $B(5,6,5)$ ។ ចូរផ្ទៀងផ្ទាត់ថា $B\in(P)$ ។

៣.ពីចំណុច $B$ គេគូសបន្ទាត់ $(BH)$ កែងនឹងបន្ទាត់ $(L)$ ដោយ $H\in(L)$ ។

គណនាកូអរដោនេនៃចំណុច $H$ រួចសរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(BH)$ ។

៤.គេយក $I$ ជាចំណុចកណ្ដាលនៃ $[AB]$ ។ គណនាកូអរដោនេនៃចំណុច $I$ រួចទាញបង្ហាញថា $\overrightarrow{IH}$ ជាវ៉ិចទ័រនរម៉ាល់នៃប្លង់ $(P)$ ។

៥.$K$ ជាចំណុចឆ្លុះគ្នានៃចំណុច $H$ ធៀបនឹងប្លង់ $(P)$ ។គណនាកូអរដោនេនៃ $K$ រួចស្រាយបញ្ជាក់ថាចតុកោណ $AHBK$ ជាការេ។

## ដំណោះស្រាយ

**១.គណនាកូអរដោនេនៃចំណុចប្រសព្វ $A$ រវាងបន្ទាត់ $(L)$ និងប្លង់ $(P)$**

តាង $A(x_a,y_a,z_a)$ ។ ដោយ $A\in(L)$ និង $A\in(P)$ គេបាន៖

$\begin{cases}x_a=1+t\\ y_a=4-t\\ z_a=9-4t\end{cases}$ (1) និង $2x_a+y_a-2z_a-6=0$ (2)។

យកសមីការ (1) ជំនួសក្នុង (2) គេបាន $2(1+t)+(4-t)-2(9-4t)-6=0$

ឬ $2+2t+4-t-18+8t-6=0$

$$9t-18=0$$

$$t=2$$

យក $t=2$ ជួសក្នុង $(1)$ គេបាន $\begin{cases} x_a=1+2=3 \\ y_a=4-2=2 \\ z_a=9-8=1 \end{cases}$

ដូចនេះ $A(3,2,1)$ ។




២. ផ្ទៀងផ្ទាត់ថា $B\in(P)$ ៖

គេមាន $B(5,6,5)$ និង $(P): 2x+y-2z-6=0$ ។

យកកូអរដោនេនៃចំណុច $B$ ទៅជំនួសក្នុងសមីការនៃប្លង់ $(P)$ គេបាន៖

$2(5)+6-2(5)-6=0$ ឬ $0=0$ ផ្ទៀងផ្ទាត់។

ដូចនេះ $B\in(P)$ ។

៣.គណនាកូអរដោនេនៃចំណុច $H$ រួចសរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(BH)$

តាង $H(x_h, y_h, z_h)$ ដោយ $H \in (L)$ នោះ $\begin{cases} x_h = 1+t \\ y_h = 4-t \\ z_h = 9-4t \end{cases}$ (3)

គេមាន $\overrightarrow{BH} = (t-4, -t-2, -4t+4)$ ។

បន្ទាត់ $(BH)$ កែងនឹងបន្ទាត់ $(L)$ ហើយ $\overrightarrow{u_L} = (1, -1, -4)$ ស្របនឹងបន្ទាត់ $(L)$

គេទាញបាន $\overrightarrow{BH} \perp \overrightarrow{u_L} \Leftrightarrow \overrightarrow{BH} \cdot \overrightarrow{u_L} = 0$

សមមូល $(t-4)-(-t-2)-4(-4t+4)=0$

សមមូល $t-4+t+2+16t-16=0$

សមូល $18t-18=0$ នោះ $t=1$ យកជួសក្នុង $(1)$ គេបាន $\begin{cases} x_h = 1+1=2 \\ y_h = 4-1=3 \\ z_h = 9-4=5 \end{cases}$

ដូចនេះ $H(2,3,5)$ ។

៤.គណនាកូអរដោនេនៃ $I$ រួចទាញបង្ហាញថា $\overrightarrow{IH}$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(P)$

គេមាន $A(3,2,1)$ និង $B(5,6,5)$

ដោយ $I$ ជាចំណុចកណ្ដាលនៃ $[AB]$ នោះ $I\left(\dfrac{3+5}{2}, \dfrac{2+6}{2}, \dfrac{1+5}{2}\right)$

ដូចនេះ $I(4,4,3)$ ។

ម្យ៉ាងទៀតគេមាន $H(2,3,5)$ និង $I(4,4,3)$ នោះ $\overrightarrow{IH} = (2,1,-2)$

ដោយ $(P): 2x+y-2z-6=0$ នោះ $\overrightarrow{n_p} = (2,1,-2) = \overrightarrow{IH}$ ។

ដូចនេះ $\overrightarrow{IH}$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(P)$ ។

៨.គណនាកូអរដោនេនៃ $K$ ៖

$K$ ជាចំណុចឆ្លុះគ្នានៃចំណុច $H$ ធៀបនឹងប្លង់ $(P)$ ហើយ $\overrightarrow{IH}\perp(P)$ នោះគេទាញបាន $I$ ជាចំណុចកណ្តាលនៃ $[HK]$ ។

ហេតុនេះ $\begin{cases} x_k = 2x_I - x_h \\ y_k = 2y_I - y_h \\ z_k = 2z_I - z_h \end{cases}$ ដោយ $H(2,3,5)$ និង $I(4,4,3)$

គេបាន $\begin{cases} x_k = 8-2=6 \\ y_k = 8-3=5 \\ z_k = 6-5=1 \end{cases}$ ។ ដូចនេះ $K(6,5,1)$ ។

ស្រាយបញ្ជាក់ថាចតុកោណ $AHBK$ ជាការេ៖




$A(3,2,1)$ , $H(2,3,5)$ , $B(5,6,5)$ និង $K(6,5,1)$

$\overrightarrow{AB}=(2,4,4)$ និង $\overrightarrow{HK}=(4,2,-4)$

គេបាន $|\overrightarrow{AB}|=\sqrt{4+16+16}=6$ , $|\overrightarrow{HK}|=\sqrt{16+4+16}=6$ នោះ $AB=HK$

ហើយ $\overrightarrow{AB}.\overrightarrow{HK}=8+8-16=0 \Leftrightarrow \overrightarrow{AB}\perp\overrightarrow{HK}$ ។

ចតុកោណ $AHBK$ មានអង្កត់ទ្រូង $AB$ & $HK$ ស្មើគ្នានិងកែងគ្នាវាជាការេ។

ដូចនេះចតុកោណ $AHBK$ ជាការេ។

## លំហាត់ទី១៤

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន$\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច

$A(1,2,3),B(3,6,-1),C(4,3,3)$ និង $D(2,1,1)$ ។

១.ចូរសរសេរសមីការស្តង់ដានៃស្វ៊ែ$(S)$ មានអង្កត់ផ្ចិត$[AB]$ ។

២.បង្ហាញថា$C\in(S)$និង$D\in(S)$។សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(CD)$។

៣.សរសេរសមីការប្លង់$(P)$និងប្លង់$(Q)$ដែលកាត់តាមចំណុចរៀងគ្នា$C$និង$D$

ហើយកែងនឹងវ៉ិចទ័រ$\overrightarrow{AB}$ ។

៤.ចូរបង្ហាញថាបួនចំណុច$A,B,C,D$ មិនស្ថិតក្នុងប្លង់តែមួយ។

៥.គណនាមាឌតេត្រាអ៊ែត$ABCD$ ។

## ដំណោះស្រាយ

**១.សរសេរសមីការស្តង់ដានៃស្វ៊ែ$(S)$ មានអង្កត់ផ្ចិត$[AB]$**

គេមាន $A(1,2,3),B(3,6,-1),C(4,3,3)$ និង $D(2,1,1)$

តាង$I$ ជាផ្ចិតរបស់ស្វ៊ែ$(S)$ នោះវាជាចំណុចកណ្តាលនៃអង្កត់ $[AB]$ ។

តាមរូបមន្តកូអរដោនេនៃចំណុចកណ្តាល $I\left(\frac{x_a+x_b}{2},\frac{y_a+y_b}{2},\frac{z_a+z_b}{2}\right)$

គេបាន $I(2,4,1)$ហើយ $R=\frac{AB}{2}=\frac{1}{2}\sqrt{(3-1)^2+(6-2)^2+(-1-3)^2}=3$។

សមីការស្វ៊ែអាចសរសេរតាមរូបមន្ត $(S):(x-x_i)^2+(y-y_i)^2+(z-z_i)^2=R^2$

ដូចនេះ $(S):(x-2)^2+(y-4)^2+(z-1)^2=9$ ។

២.បង្ហាញថា $C\in(S)$ និង $D\in(S)$៖

គេមាន $C(4,3,3)$ និង $D(2,1,1)$ និង $(S):(x-2)^2+(y-4)^2+(z-1)^2=9$

ចំពោះ $C(4,3,3)$ នោះ $(4-2)^2+(3-4)^2+(3-1)^2=9$

$4+1+4=9$ ផ្ទៀងផ្ទាត់

ដូចនេះ $C\in(S)$។

ចំពោះ $D(0,1,1)$ នោះ $(2-2)^2+(1-4)^2+(1-1)^2=9$

$0+9+0=9$ ផ្ទៀងផ្ទាត់

ដូចនេះ $D\in(S)$

សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(CD)$៖

បន្ទាត់ $(CD)$ មានវ៉ិចទ័រប្រាប់ទិស $\overrightarrow{CD}=(-2,-2,-2)$ និងកាត់តាម $C(4,3,3)$

តាមរូបមន្ត $(CD):\begin{cases}x=x_c+at\\y=y_c+bt\\z=z_c+ct\quad,t\in\mathbb{R}\end{cases}$

ដូចនេះ $(CD):\begin{cases}x=4-2t\\y=3-2t\\z=3-2t\quad,t\in\mathbb{R}\end{cases}$

៣.សរសេរសមីការប្លង់ $(P)$ និងប្លង់ $(Q)$៖

គេមាន $A(1,2,3)$ និង $B(3,6,-1)$ នោះ $\overrightarrow{AB}=(2,4,-4)$

សរសេរសមីការប្លង់ $(P)$ និងប្លង់ $(Q)$ ដែលកាត់តាមចំណុចរៀងគ្នា $C$ និង $D$ ហើយកែងនឹងវ៉ិចទ័រ $\overrightarrow{AB}$ អាចសរសេរ៖

$(P): 2(x-4)+4(y-3)-4(z-3)=0$

$$2x-8+4y-12-4z+12=0$$
$$2x+4y-4z-8=0$$
$$x+2y-2z-4=0$$

ដូចនេះ $(P): x+2y-2z-4=0$ ។

ហើយ $(Q): 2(x-2)+4(y-1)-4(z-1)=0$

$$2x-4+4y-4-4z+4=0$$
$$2x+4y-4z-4=0$$
$$x+2y-2z-2=0$$

ដូចនេះ $(Q): x+2y-2z-2=0$ ។

**៤.បង្ហាញថាបួនចំណុច $A,B,C,D$ មិនស្ថិតក្នុងប្លង់តែមួយ៖**

គេមាន $A(1,2,3), B(3,6,-1), C(4,3,3)$ និង $D(2,1,1)$

គេបាន $\overrightarrow{AB}=(2,4,-4)$ , $\overrightarrow{AC}=(3,1,0)$, $\overrightarrow{AD}=(1,-1,-2)$

$$\left(\overrightarrow{AB}\times\overrightarrow{AC}\right).\overrightarrow{AD}=\begin{vmatrix}2 & 4 & -4\\ 3 & 1 & 0\\ 1 & -1 & -2\end{vmatrix}=2(-2-0)-4(-6-0)-4(-3-1)$$

$$=-4+24+12=32$$

ដោយ $\left(\overrightarrow{AB}\times\overrightarrow{AC}\right).\overrightarrow{AD}\neq 0$ នោះវ៉ិចទ័រ $\overrightarrow{AB}, \overrightarrow{AC}, \overrightarrow{AD}$ មិនកូប្លានែ។

ដូចនេះ $A,B,C,D$ មិនស្ថិតក្នុងប្លង់តែមួយ។

**៥.គណនាមាឌតេត្រាអ៊ែត $ABCD$ ៖**

$$V=\frac{1}{6}\left|\left(\overrightarrow{AB}\times\overrightarrow{AC}\right).\overrightarrow{AD}\right|=\frac{32}{6}=\frac{16}{3}$$ ( ឯកតាមាឌ ) ។

## លំហាត់ទី១៥

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច $A(3,-4,-2),B(1,0,-5),C(5,-2,-5)$ និង $D(4,-2,0)$ ។

១.គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$ រួចទាញថាបីចំណុច $A,B,C$ មិនស្ថិតនៅលើបន្ទាត់តែមួយ។ គណនាផ្ទៃក្រឡានៃត្រីកោណ $ABC$ ។

២.គណនា $\overrightarrow{AD}$ រួចផ្ទៀងផ្ទាត់ថា $\overrightarrow{AD}=-\frac{1}{6}\overrightarrow{AB}\times\overrightarrow{AC}$ ។ គណនារង្វាស់ $AD$ រួចទាញរកមាឌនៃតេត្រាអ៊ែត $ABCD$ ។

៣.គណនា $\overrightarrow{OB}$ និង $\overrightarrow{DC}$ រួចទាញថា $OBCD$ ជាប្រលេឡូក្រាម។

៤.សរសេរសមីការប្លង់ $(ABC)$ និងសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(d)$ គូសចេញពីគល់ $O$ ហើយកែងនឹងប្លង់ $(ABC)$ ត្រង់ $H$ ។

៥.គណនាកូអរដោនេនៃចំណុច $H$ រួចបង្ហាញថា $AHBC$ ជាប្រលេឡូក្រាម។

## ដំណោះស្រាយ

**១.គណនាផលគុណវ៉ិចទ័រ**

គេមាន $A(3,-4,-2),B(1,0,-5),C(5,-2,-5)$ និង $D(4,-2,0)$

នោះ $\overrightarrow{AB}=(-2,4,-3)$ , $\overrightarrow{AC}=(2,2,-3)$

$$\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ -2 & 4 & -3\\ 2 & 2 & -3\end{vmatrix}=-6\vec{i}-12\vec{j}-12\vec{k}$$

ដូចនេះ $\overrightarrow{AB}\times\overrightarrow{AC}=(-6,-12,-12)$ ។

**ទាញថាបីចំណុចមិនស្ថិតនៅលើបន្ទាត់តែមួយ៖**

គេមាន $\overrightarrow{AB}\times\overrightarrow{AC}\neq\vec{O}$ នោះវ៉ិចទ័រ $\overrightarrow{AB}\ \&\ \overrightarrow{AC}$ មិនកូលីនេអ៊ែគ្នា។

ដូច្នេះបីចំណុច $A,B,C$ មិនស្ថិតនៅលើបន្ទាត់តែមួយ។

គណនាផ្ទៃក្រឡានៃត្រីកោណ $ABC$ ៖

តាមរូបមន្ត $S_{ABC}=\frac{1}{2}|\overrightarrow{AB}\times\overrightarrow{AC}|$ ដោយ $\overrightarrow{AB}\times\overrightarrow{AC}=(-6,-12,-12)$

នោះ $|\overrightarrow{AB}\times\overrightarrow{AC}|=\sqrt{(-6)^2+(-12)^2+(-12)^2}=\sqrt{36+144+144}=\sqrt{324}=18$

ដូចនេះ $S_{ABC}=\frac{1}{2}\times18=9$ (ឯកតាផ្ទៃ)។




២.គណនា $\overrightarrow{AD}$ រួចផ្ទៀងផ្ទាត់ថា $\overrightarrow{AD}=-\frac{1}{6}\overrightarrow{AB}\times\overrightarrow{AC}$ ៖

យើងមាន $A(3,-4,-2)$ និង $D(4,-2,0)$ នោះ $\overrightarrow{AD}=(1,2,2)$

ដោយ $\overrightarrow{AB}\times\overrightarrow{AC}=(-6,-12,-12)$ នោះ $-\frac{1}{6}\overrightarrow{AB}\times\overrightarrow{AC}=(1,2,2)$

ដូចនេះ $\overrightarrow{AD}=-\frac{1}{6}\overrightarrow{AB}\times\overrightarrow{AC}$ ។

គណនារង្វាស់ $AD$ រួចទាញរកមាឌនៃតេត្រាអ៊ែត $ABCD$ ៖

យើងមាន $\overrightarrow{AD}=(1,2,2)$ នោះយើងបាន $AD=|\overrightarrow{AD}|=\sqrt{1+4+4}=3$

ដូចនេះ $AD=3$ (ឯកតាប្រវែង)។

ម្យ៉ាងទៀតគេមាន $\overrightarrow{AD}=-\frac{1}{6}\overrightarrow{AB}\times\overrightarrow{AC}$ នោះ $\overrightarrow{AB}\times\overrightarrow{AC}=-6\,\overrightarrow{AD}$

តាមរូបមន្តមាឌ $V=\frac{1}{6}\left|\left(\overrightarrow{AB}\times\overrightarrow{AC}\right).\overrightarrow{AD}\right|=\frac{1}{6}\left|\left(-6\,\overrightarrow{AD}\right).\overrightarrow{AD}\right|=|\overrightarrow{AD}|^2=AD^2$

ដូចនេះ $V_{ABCD}=3^2=9$ (ឯកតាមាឌ)។

៣.គណនា $\overrightarrow{OB}$ និង $\overrightarrow{DC}$ រួចទាញថា $OBCD$ ជាប្រលេឡូក្រាម៖

គេមាន $O(0,0,0),B(1,0,-5),C(5,-2,-5)$ និង $D(4,-2,0)$

យើងបាន $\overrightarrow{OB}=(1,0,-5)$ និង $\overrightarrow{DC}=(1,0,-5)$ ។

ដោយ $\overrightarrow{OB}=\overrightarrow{DC}\Leftrightarrow\begin{cases}OB=DC\\OB//DC\end{cases}$

ដូចនេះចតុកោណ $OBCD$ ជាប្រលេឡូក្រាម។

៤.សរសេរសមីការប្លង់ $(ABC)$ និងសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(d)$ ៖

ប្លង់ $(ABC)$ មានវ៉ិចទ័រណរម៉ាល់ $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}=(-6,-12\ ,-12)$ ហើយកាត់តាមចំណុច $A(3,-4,-2)$ អាចសរសេរ ៖

$$(ABC):a(x-x_a)+b(y-y_a)+c(z-z_a)=0$$
$$-6(x-3)-12(y+4)-12(z+2)=0$$
$$-6x+18-12y-48-12z-24=0$$
$$-6x-12y-12z-54=0$$
$$x+2y+2z+9=0$$

ដូចនេះ $(ABC):x+2y+2z+9=0$ ។

ម្យ៉ាងទៀតដោះបន្ទាត់$(d)$ គូសចេញពីគល់$O$ ហើយកែងនឹងប្លង់$(ABC)$ នោះ

គេបាន $\overrightarrow{u_d}=\overrightarrow{n}=(1,2,2)$ជាវ៉ិចទ័រប្រាប់ទិសនិង$O(0,0,0)$ជាចំណុចកាត់តាម

តាមរូបមន្ត $(d):\begin{cases} x=x_0+at \\ y=y_0+bt \\ z=z_0+ct \quad ,t\in\mathbb{R} \end{cases}$ ។ ដូចនេះ $(d):\begin{cases} x=t \\ y=2t \\ z=2t \quad ,t\in\mathbb{R} \end{cases}$

៥.គណនាកូអរដោនេនៃចំណុច $H$ ៖

ចំណុច $H$ គឺជាប្រសព្វរវាងបន្ទាត់$(d):\begin{cases} x=t \\ y=2t \\ z=2t \quad ,t\in\mathbb{R} \end{cases}$ និងប្លង់$(ABC)$

ដែលមានសមីការ $(ABC): x+2y+2z+9=0$ ។

យកសមីការ$(d)$ ជំនួសក្នុង$(ABC)$គេបាន $t+4t+4t+9=0$ ឬ $t=-1$ ។

យក $t=-1$ ជំនួសក្នុងសមីការ$(d)$ គេបាន $x=-1, y=-2, z=-2$ ។

ដូចនេះ $H(-1,-2,-2)$ ។

បង្ហាញថាចតុកោណ $AHBC$ ជាប្រលេឡូក្រាម៖

គេមាន $A(3,-4,-2), B(1,0,-5), C(5,-2,-5)$ និង $H(-1,-2,-2)$

គេបាន $\overrightarrow{CA}=(-2,-2,3)$ និង $\overrightarrow{BH}=(-2,-2,3)$ ។

ដោយ $\overrightarrow{CA}=\overrightarrow{BH}$ នាំឲ្យ $CA=BH$ និង $CA//BH$ ។

ដូចនេះចតុកោណ $AHBC$ ជាប្រលេឡូក្រាម។

www.mathtoday.wordpress.com

## លំហាត់ទី១៦

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបីចំណុច $A(2,-3,4),B(3,1,3),C(-1,0,4)$ និងប្លង់ $(P): x-2y+2z-7=0$ ។

១.គណនា $AB,AC$ និង $BC$ រួចបង្ហាញថា $ABC$ ជាត្រីកោណសម័ង្ស។

២.ផ្ទៀងផ្ទាត់ថា $B\in(P)$ និង $C\in(P)$ ។សរសេរសមីការប៉ារ៉ាម៉ែត្របន្ទាត់ $(BC)$ ។

៣. $H$ ជាជើងនៃចំណោលកែងនៃ $A$ លើប្លង់ $(P)$ ។គណនាកូអរដោនេនៃ $H$ ។

៤.គេតាង $\vec{u}=\frac{1}{3}\overrightarrow{HB}$ , $\vec{v}=\frac{1}{3}\overrightarrow{HC}$ និង $\vec{w}=\frac{1}{3}\overrightarrow{HA}$ ។

   ចូរស្រាយថា $\left(\vec{u},\vec{v},\vec{w}\right)$ ជាគោលអរតូនរម៉ាល់មានទិសដៅវិជ្ជមាន។

៥.ចូរសរសេរសមីការប្លង់ $(HAB),(HAC)$ និង $(HBC)$ ។

## ដំណោះស្រាយ

១.គណនា $AB,AC$ និង $BC$ រួចបង្ហាញថា $ABC$ ជាត្រីកោណសម័ង្ស៖

គេមាន $A(2,-3,4),B(3,1,3),C(-1,0,4)$

យើងបាន $AB=\sqrt{(3-2)^2+(1+3)^2+(3-4)^2}=\sqrt{18}=3\sqrt{2}$ ។

$$AC=\sqrt{(-1-2)^2+(0+3)^2+(4-4)^2}=\sqrt{18}=3\sqrt{2}$$

$$BC=\sqrt{(-1-3)^2+(0-1)^2+(4-3)^2}=\sqrt{18}=3\sqrt{2}$$

ដូចនេះ $AB=AC=BC=3\sqrt{2}$ (ឯកតាប្រវែង)។

ដោយ $AB=AC=BC=3\sqrt{2}$ នោះ $ABC$ ជាត្រីកោណសម័ង្ស។

២.ផ្ទៀងផ្ទាត់ថា $B\in(P)$ និង $C\in(P)$៖

គេមាន $B(3,1,3),C(-1,0,4)$ និងប្លង់ $(P):x-2y+2z-7=0$ ។

ចំពោះ $B(3,1,3)$ នោះ $3-2+6-7=0$

$0=0$ ផ្ទៀងផ្ទាត់

ដូចនេះ $B\in(P)$ ។

ចំពោះ $C(-1,0,4)$ នោះ $-1+0+8-7=0$

$0=0$ ផ្ទៀងផ្ទាត់

ដូចនេះ $C\in(P)$ ។

**សរសេរសមីការប៉ារ៉ាម៉ែត្របន្ទាត់ $(BC)$៖**

បន្ទាត់ $(BC)$ មានវ៉ិចទ័រប្រាប់ទិស $\overrightarrow{BC}=(-4,-1,1)$ និងកាត់តាម $B(3,1,3)$

តាមរូបមន្ត $(BC):\begin{cases}x=x_b+at\\y=y_b+bt\\z=z_b+ct\ \ ,t\in\mathbb{R}\end{cases}$

ដូចនេះ $(BC):\begin{cases}x=3-4t\\y=1-t\\z=3+t\ \ ,t\in\mathbb{R}\end{cases}$

៣.គណនាកូអរដោនេនៃ $H$៖

តាង $H(x_h,y_h,z_h)$ ។ដោយ $H$ ជាជើងនៃចំណោលកែងនៃ $A$ លើប្លង់ $(P)$ នោះ

$\overrightarrow{AH}\perp(P)$ ដោយ $\overrightarrow{n_p}\perp(P)$ ដែល នោះ $\overrightarrow{AH}//\overrightarrow{n_p}$

គេទាញ $\overrightarrow{AH}=\lambda\,\overrightarrow{n_p}$ ដោយ $\overrightarrow{AH}=(x_h-2,y_h+3,z_h-4)$ និង $\overrightarrow{n_p}=(1,-2,2)$

គេបាន $\begin{cases} x_h - 2 = \lambda \\ y_h + 3 = -2\lambda \\ z_h - 4 = 2\lambda \end{cases}$ នោះ $\begin{cases} x_h = 2 + \lambda \\ y_h = -3 - 2\lambda \quad (1) \\ z_h = 4 + 2\lambda \end{cases}$

ម្យ៉ាងទៀត $H \in (P)$ សមមូល $(2+\lambda) - 2(-3-2\lambda) + 2(4+2\lambda) - 7 = 0$

ឬ $2 + \lambda + 6 + 4\lambda + 8 + 4\lambda - 7 = 0$

$$9\lambda + 9 = 0$$

$$\lambda = -1$$

យក $\lambda = -1$ ជួសក្នុង $(1)$ នោះ $\begin{cases} x_h = 2 - 1 = 1 \\ y_h = -3 + 2 = -1 \\ z_h = 4 - 2 = 2 \end{cases}$

ដូចនេះ $H(1,-1,2)$ ។

៤.ស្រាយថា $(\vec{u},\vec{v},\vec{w})$ ជាគោលអរតូនរម៉ាល់មានទិសដៅវិជ្ជមាន៖

គេមាន $\vec{u} = \frac{1}{3}\overrightarrow{HB}$ , $\vec{v} = \frac{1}{3}\overrightarrow{HC}$ និង $\vec{w} = \frac{1}{3}\overrightarrow{HA}$

ដោយ $A(2,-3,4), B(3,1,3), C(-1,0,4)$ និង $H(1,-1,2)$

នោះ $\overrightarrow{HB} = (2,2,1), \overrightarrow{HC} = (-2,1,2)$ និង $\overrightarrow{HA} = (1,-2,2)$

គេបាន $\vec{u} = \left(\frac{2}{3},\frac{2}{3},\frac{1}{3}\right)$ , $\vec{v} = \left(-\frac{2}{3},\frac{1}{3},\frac{2}{3}\right)$ , $\vec{w} = \left(\frac{1}{3},-\frac{2}{3},\frac{2}{3}\right)$

គេមាន $|\vec{u}| = \sqrt{\frac{4}{9}+\frac{4}{9}+\frac{1}{9}} = 1$ , $|\vec{v}| = \sqrt{\frac{4}{9}+\frac{1}{9}+\frac{4}{9}} = 1$ , $|\vec{w}| = \sqrt{\frac{1}{9}+\frac{4}{9}+\frac{4}{9}} = 1$

$\begin{cases} \vec{u}.\vec{v} = -\frac{4}{9}+\frac{2}{9}+\frac{2}{9} = 0 \\ \vec{u}.\vec{w} = \frac{2}{9}-\frac{4}{9}+\frac{2}{9} = 0 \\ \vec{v}.\vec{w} = -\frac{2}{9}-\frac{2}{9}+\frac{4}{9} = 0 \end{cases}$ សមមូល $\begin{cases} \vec{u} \perp \vec{v} \\ \vec{u} \perp \vec{w} \\ \vec{v} \perp \vec{w} \end{cases}$

គេទាញបាន $\vec{u},\vec{v}$ និង $\vec{w}$ ជាវ៉ិចទ័រឯកតានិងអរតូកូណាល់គ្នាពីរៗ។

ម្យ៉ាងទៀត $\vec{u}\times\vec{v}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ \frac{2}{3} & \frac{2}{3} & \frac{1}{3}\\ -\frac{2}{3} & \frac{1}{3} & \frac{2}{3}\end{vmatrix}=\frac{1}{3}\vec{i}-\frac{2}{3}\vec{j}+\frac{2}{3}\vec{k}=\vec{w}$ ។

សរុបមកយើងសន្និដ្ឋានថា $(\vec{u},\vec{v},\vec{w})$ ជាគោលអរតូនរម៉ាល់មានទិសដៅវិជ្ជមាន។

**ជ.សរសេរសមីការប្លង់** $(HAB),(HAC)$ **និង** $(HBC)$




ប្លង់ $(HAB),(HAC)$ និង $(HBC)$ កាត់តាមចំណុច $H(1,-1,2)$ និងមានវ៉ិចទ័រ

នរម៉ាល់រៀងគ្នា $\vec{v}=\left(-\frac{2}{3},\frac{1}{3},\frac{2}{3}\right)$ , $\vec{u}=\left(\frac{2}{3},\frac{2}{3},\frac{1}{3}\right)$ , $\vec{w}=\left(\frac{1}{3},-\frac{2}{3},\frac{2}{3}\right)$ មានសមីការ៖

$(HAB):-\frac{2}{3}(x-1)+\frac{1}{3}(y+1)+\frac{2}{3}(z-2)=0$ ឬ $-2x+y+2z-1=0$

$(HAC):\frac{2}{3}(x-1)+\frac{2}{3}(y+1)+\frac{1}{3}(z-2)=0$ ឬ $2x+2y+z-2=0$

$(HBC):\frac{1}{3}(x-1)-\frac{2}{3}(y+1)+\frac{2}{3}(z-2)=0$ ឬ $x-2y+2z-7=0$

## លំហាត់ទី១៧

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច

$S(3,4,4)$ , $A(2,6,2),B(-1,3,5)$ និង $C(3,1,1)$ ។

១.គណនា $AB,AC$ , $SB$ និង $SC$ រួចទាញរកប្រភេទត្រីកោណ $ABC$ & $SBC$ ។

២.គណនាផលគុណស្កាលែ $\overrightarrow{SA}.\overrightarrow{AB}$ និង $\overrightarrow{SA}.\overrightarrow{AC}$ ។

៣.ស្រាយបញ្ជាក់ថាប្លង់ $(P)$ កាត់តាម $S$ ហើយកែងនឹងវិចទ័រ $\overrightarrow{SA}$ មានសមីការ

$x-2y+2z-3=0$ ។

៤.តាង $I$ ជាចំណុចកណ្ដាលនៃ $[BC]$ ។ គណនាកូអរដោនេនៃចំណុច $I$ ។

សរសេរសមីការប្លង់មេដ្យាទ័រ $(Q)$ នៃអង្កត់ $[BC]$ ។

៥.ចូរផ្ទៀងផ្ទាត់ថា $A\in(Q)$ និង $S\in(Q)$ ។ គណនារង្វាស់មុំ $\angle SIA$ ។

## ដំណោះស្រាយ

**១.គណនា $AB,AC$ , $SB$ និង $SC$ រួចទាញរកប្រភេទត្រីកោណ $ABC$ & $SBC$ ៖**



គេមាន $S(3,4,4)$ , $A(2,6,2),B(-1,3,5)$ និង $C(3,1,1)$

គេបាន $AB=\sqrt{(-1-2)^2+(3-6)^2+(5-2)^2}=\sqrt{27}=3\sqrt{3}$

$$AC=\sqrt{(3-2)^2+(1-6)^2+(1-2)^2}=\sqrt{27}=3\sqrt{3}$$

$$SB=\sqrt{(-1-3)^2+(3-4)^2+(5-4)^2}=\sqrt{18}=3\sqrt{2}$$

$$SC=\sqrt{(3-3)^2+(4-1)^2+(4-1)^2}=\sqrt{18}=3\sqrt{2}$$

ដូចនេះ $AB=AC=3\sqrt{3}$ ( ឯកតាប្រវែង )

និង $SB=SC=3\sqrt{2}$ ( ឯកតាប្រវែង ) ។

ដោយ $AB=AC$ និង $SB=SC$ នោះត្រីកោណ $ABC$ និងត្រីកោណ $SBC$ សុទ្ធតែជាត្រីកោណសមបាតមានកំពូល $A$ និង $S$ រៀងគ្នា។

២.គណនាផលគុណស្កាលែ $\overrightarrow{SA}.\overrightarrow{AB}$ និង $\overrightarrow{SA}.\overrightarrow{AC}$

គេមាន $S(3,4,4)$ , $A(2,6,2),B(-1,3,5)$ និង $C(3,1,1)$

គេបាន $\overrightarrow{SA}=(-1,2,-2),\overrightarrow{AB}=(-3,-3,3)$ ,$\overrightarrow{AC}=(1,-5,-1)$

យើងបាន $\overrightarrow{SA}.\overrightarrow{AB}=3-6-6=-9$ និង $\overrightarrow{SA}.\overrightarrow{AC}=-1-10+2=-9$

៣.ស្រាយបញ្ជាក់ថាប្លង់ $(P)$ មានសមីការ $x-2y+2z-3=0$

ប្លង់ $(P)$ កាត់តាម $S(3,4,4)$ ហើយកែងនឹងវ៉ិចទ័រ $\overrightarrow{SA}=(-1,2,-2)$ សរសេរ៖

$(P): a(x-x_s)+b(y-y_s)+c(z-z_s)=0$

$$-(x-3)+2(y-4)-2(z-4)=0 \text{ ឬ } -x+2y-2z+3=0$$

ដូចនេះ $(P): x-2y+2z-3=0$ ។

៤.គណនាកូអរដោនេនៃចំណុច $I$

ដោយ $I$ ជាចំណុចកណ្តាលនៃ $[BC]$ នោះ $I\left(\frac{x_b+x_c}{2},\frac{y_b+y_c}{2},\frac{z_b+z_c}{2}\right)$

ដោយ $B(-1,3,5)$ និង $C(3,1,1)$ នោះ $I\left(\frac{-1+3}{2},\frac{3+1}{2},\frac{5+1}{2}\right)$

ដូចនេះ ។

**សរសេរសមីការប្លង់មេដ្យាទ័រ $(Q)$ នៃអង្កត់ $[BC]$ ៖**

ប្លង់មេដ្យាទ័រ $(Q)$ នៃ $[BC]$ មានវ៉ិចទ័រណរម៉ាល់ $\overrightarrow{BC}=(4,-2,-4)$ និងកាត់តាម ចំណុច $I(1,2,3)$ កណ្តាលនៃអង្កត់ $[BC]$ អាចសរសេរ ៖

$$(Q): a(x-x_i)+b(y-y_i)+c(z-z_i)=0$$

$$4(x-1)-2(y-2)-4(z-3)=0$$

$$4x-4-2y+4-4z+12=0$$

$$4x-2y-4z+12=0$$

$$2x-y-2z+6=0$$

ដូចនេះ $(Q):2x-y-2z+6=0$ ។

**៥.ផ្ទៀងផ្ទាត់ថា $A\in(Q)$ និង $S\in(Q)$ ៖**

យើងមាន $A(2,6,2)$ , $S(3,4,4)$ និង $(Q):2x-y-2z+6=0$

យកកូអរដោនេ $A$ ជួសក្នុង $(Q)$ គេបាន $4-6-4+6=0$ ពិតនោះ $A\in(Q)$

យកកូអរដោនេ $S$ ជួសក្នុង $(Q)$ គេបាន $6-4-8+6=0$ ពិតនោះ $S\in(Q)$

ដូចនេះ $A\in(Q)$ និង $S\in(Q)$ ។

គណនារង្វាស់មុំ $\angle SIA$ ៖

តាង $\angle SIA = \theta$ នោះ $\theta$ ជាមុំផ្គុំដោយវ៉ិចទ័រ $\overrightarrow{IA}$ និង $\overrightarrow{IS}$ ។

គេមាន $\overrightarrow{IA}.\overrightarrow{IS} = |\overrightarrow{IA}|.|\overrightarrow{IS}|\cos\theta$ នោះ $\cos\theta = \dfrac{\overrightarrow{IA}.\overrightarrow{IS}}{|\overrightarrow{IA}|.|\overrightarrow{IS}|}$

ដោយ $I(1,2,3)$, $A(2,6,2)$ និង $S(3,4,4)$ នោះគេបាន $\overrightarrow{IA} = (1,4,-1)$

និង $\overrightarrow{IS} = (2,2,1)$ ។

គេបាន $\cos\theta = \dfrac{\overrightarrow{IA}.\overrightarrow{IS}}{|\overrightarrow{IA}|.|\overrightarrow{IS}|} = \dfrac{2+8-1}{\sqrt{1+16+1}\sqrt{4+4+1}} = \dfrac{9}{9\sqrt{2}} = \dfrac{\sqrt{2}}{2} = \cos 45^o$

ដូចនេះ $\angle SIA = 45^o$ ។

www.mathtoday.wordpress.com

## លំហាត់ទី១៨

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច

$A(2,3,-1),B(-1,0,-1),C(5,3,5)$ និង $D(8,6,5)$ ។

១.គណនា $\overrightarrow{AD}$ និង $\overrightarrow{BC}$ រួចទាញបញ្ជាក់ប្រភេទចតុកោណ $ABCD$ ។

២.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(BC)$ និង $(CD)$ ។

៣.$H$ ជាចំណោលកែងនៃ $A$ លើ $BC$ ហើយ $K$ ជាចំណោលកែងនៃ $H$ លើ $CD$ ។

គណនាកូអរដោនេនៃចំណុច $H$ និង $K$ ។

៤.គណនា $AH$ និង $BC$ រួចគណនាផ្ទៃក្រឡាចតុកោណ $ABCD$ ។

៥.ចូរស្រាយថា $KCH$ ជាត្រីកោណកែងសមបាត។

៦.រកកូអរដោនេនៃចំណុច $L$ ដោយដឹងថា $HKCL$ ជាការេ។

តើចំណុច $B,L,D$ រត់ត្រង់គ្នាឬទេ ?

## ដំណោះស្រាយ

**១.គណនា $\overrightarrow{AD}$ និង $\overrightarrow{BC}$ រួចទាញបញ្ជាក់ប្រភេទចតុកោណ $ABCD$ ៖**

គេមាន $A(2,3,-1),B(-1,0,-1),C(5,3,5)$ និង $D(8,6,5)$

យើងបាន $\overrightarrow{AD}=(6,3,6)$ និង $\overrightarrow{BC}=(6,3,6)$ ។

ដោយ $\overrightarrow{AD}=\overrightarrow{BC}$ នោះ $AD=BC$ និង $AD//BC$ ។

ដូចនេះ $ABCD$ ជាប្រលេឡូក្រាម។

២.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(BC)$ និង $(CD)$ ៖

បន្ទាត់ $(BC)$ និង $(CD)$ មានវ៉ិចទ័រប្រាប់ទិស $\overrightarrow{BC}=(6,3,6)$ និង $\overrightarrow{CD}=(3,3,0)$ ហើយកាត់តាមចំណុចរៀងគ្នា $B(-1,0,-1)$ និង $C(5,3,5)$ ។

ដូចនេះ $(BC):\begin{cases}x=-1+6t_1\\ y=\quad 3t_1\\ z=-1+6t_1 \quad , t_1\in\mathbb{R}\end{cases}$ និង $(CD):\begin{cases}x=5+3t_2\\ y=3+3t_2\\ z=5 \quad , t_2\in\mathbb{R}\end{cases}$

៣.គណនាកូអរដោនេនៃចំណុច $H$ និង $K$




យើងតាង $H(x_h,y_h,z_h)$ ជាចំណោលកែងនៃចំណុច $A$ លើ $BC$ នោះ $H\in(BC)$ និង $\overrightarrow{AH}\perp\overrightarrow{BC}$ ។

ដោយ $H\in(BC)$ សមមូល $\begin{cases}x_h=-1+6t_1\\ y_h=\quad 3t_1\\ z_h=-1+6t_1\end{cases}$ (1)

គេមាន $A(2,3,-1)$ នោះ $\overrightarrow{AH}=(6t_1-3,3t_1-3,6t_1)$ និង $\overrightarrow{BC}=(6,3,6)$

គេបាន $\overrightarrow{AH}\perp\overrightarrow{BC}\Leftrightarrow\overrightarrow{AH}.\overrightarrow{BC}=6(6t_1-3)+3(3t_1-3)+36t_1=0$

សមមូល $36t_1-18+9t_1-9+36t_1=0$

សមមូល $81t_1-27=0$ ឬ $t_1=\dfrac{1}{3}$ យកជួសក្នុង $(1)$ គេបាន $\begin{cases}x_h=-1+2=1\\y_h=1\\z_h=-1+2=1\end{cases}$

ដូចនេះ $H(1,1,1)$ ។

តាង $K(x_k,y_k,z_k)$ ជាចំណោលកែងនៃចំណុច $H$ លើ $(CD)$ នោះ $K\in(CD)$

និង $\overrightarrow{HK}\perp\overrightarrow{CD}$ ។

ដោយ $K\in(CD)$ សមមូល $\begin{cases}x_k=5+3t_2\\y_k=3+3t_2\\z_k=5\end{cases}$ $(2)$

គេមាន $H(1,1,1)$ នោះ $\overrightarrow{HK}=(3t_2+4,3t_2+2,4)$ និង $\overrightarrow{CD}=(3,3,0)$

គេបាន $\overrightarrow{HK}\perp\overrightarrow{CD}\Leftrightarrow\overrightarrow{HK}.\overrightarrow{CD}=3(3t_2+4)+3(3t_2+2)=0$

សមមូល $9t_2+12+9t_2+6=0$

សមមូល $18t_2+18=0$ ឬ $t_2=-1$ យកជួសក្នុង $(1)$ គេបាន $\begin{cases}x_k=5-3=2\\y_k=3-3=0\\z_k=5\end{cases}$

ដូចនេះ $K(2,0,5)$ ។

៤.គណនា $AH$ និង $BC$ រួចគណនាផ្ទៃក្រឡាចតុកោណ $ABCD$ ៖

យើងមាន $A(2,3,-1)$, $H(1,1,1)$, $B(-1,0,-1)$ , $C(5,3,5)$

យើងបាន $AH=\sqrt{(1-2)^2+(1-3)^2+(1+1)^2}=\sqrt{1+4+4}=\sqrt{9}=3$

$$BC=\sqrt{(5+1)^2+(3-0)^2+(5+1)^2}=\sqrt{36+9+36}=\sqrt{81}=9$$

ដូចនេះ $AH=3$ , $BC=9$ (ឯកតាប្រវែង)។

ផ្ទៃក្រឡាប្រលេឡូក្រាម $ABCD$ គឺ $S = AH \times BC = 3\times 9 = 27$ (ឯកតាផ្ទៃ)។

៥.ស្រាយថា $KCH$ ជាត្រីកោណកែងសមបាត៖

គេមាន $K(2,0,5)$ , $C(5,3,5)$ និង $H(1,1,1)$

គេបាន $\overrightarrow{KC} = (3,3,0)$ និង $\overrightarrow{KH} = (-1,1,-4)$

ដោយ $\overrightarrow{KC}.\overrightarrow{KH} = -3+3+0 = 0 \Leftrightarrow \overrightarrow{KC} \perp \overrightarrow{KH}$

ហើយ $KC = \sqrt{9+9+0} = 3\sqrt{2}$ , $KH = \sqrt{1+1+16} = 3\sqrt{2}$ នោះ $KC = KH$

ដូចនេះត្រីកោណ $KCH$ ជាត្រីកោណកែងសមបាតកំពូល $K$ ។

៦.រកកូអរដោនេនៃចំណុច $L$ ដោយដឹងថា $HKCL$ ជាការេ៖

គេមាន $KCH$ ជាត្រីកោណកែងសមបាតកំពូល $K$ នោះ $HKCL$ ជាការេលុះត្រា

តែ $\overrightarrow{HL} = \overrightarrow{KC}$ សមមូល $\begin{cases} x_l - 1 = 3 \\ y_l - 1 = 3 \\ z_l - 1 = 0 \end{cases}$ សមមូល $\begin{cases} x_l = 4 \\ y_l = 4 \\ z_l = 1 \end{cases}$

ដូចនេះ $L(4,4,1)$ ។

**តើចំណុច $B, L, D$ រត់ត្រង់គ្នាឬទេ ?**

គេមាន $B(-1,0,-1)$, $L(4,4,1)$ និង $D(8,6,5)$

គេបាន $\overrightarrow{BL} = (5,4,2)$ និង $\overrightarrow{BD} = (9,6,6)$

ដោយ $\frac{5}{9} \neq \frac{4}{6} \neq \frac{2}{6}$ នោះវ៉ិចទ័រ $\overrightarrow{BL}$ និង $\overrightarrow{BD}$ មិនកូលីនេអ៊ែគ្នា។

ដូចនេះបីចំណុច $B, L, D$ មិនរត់ត្រង់គ្នាទេ។

www.mathtoday.wordpress.com

## លំហាត់ទី១៩

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបីចំណុច $A(-4,1,-2)$, $B(-1,7,4)$ និង $C(4,-7,2)$ ។

១.គណនា $AB,AC$ និង $BC$ រួចទាញថា $ABC$ ជាត្រីកោណកែង។

២.កំណត់សមីការប្លង់ $(ABC)$ ។

៣.រកកូអរដោនេនៃចំណុច $I$ ដែលផ្ទៀងផ្ទាត់ $BC.\overrightarrow{IA}+AC.\overrightarrow{IB}+AB.\overrightarrow{IC}=\overrightarrow{O}$

៤.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(IA),(IB),(IC)$ ។

៥.គេឲ្យចំណុច $M(x,y,z)$ នៃលំហ។ ចូរស្រាយបញ្ជាក់ថា ៖

$$BC.MA^2+AC.MB^2+AB.MC^2=(BC+AC+AB)MI^2+BC.AC.AB$$

## ដំណោះស្រាយ

**១.គណនា $AB,AC$ និង $BC$ រួចទាញថា $ABC$ ជាត្រីកោណកែង៖**

គេមាន $A(-4,1,-2)$, $B(-1,7,4)$ និង $C(4,-7,2)$

យើងបាន $AB=\sqrt{(-1+4)^2+(7-1)^2+(4+2)^2}=\sqrt{9+36+36}=\sqrt{81}=9$

$$AC=\sqrt{(4+4)^2+(-7-1)^2+(2+2)^2}=\sqrt{64+64+16}=\sqrt{144}=12$$

$$BC=\sqrt{(4+1)^2+(-7-7)^2+(2-4)^2}=\sqrt{25+196+4}=\sqrt{225}=15$$

ដូចនេះ $AB=9,AC=12,BC=15$ (ឯកតាប្រវែង)។

ម្យ៉ាងទៀតគេមាន $AB^2+AC^2=9^2+12^2=225=BC^2$ (តាមពីតាគ័រ)

ដូចនេះ $ABC$ ជាត្រីកោណកែងត្រង់កំពូល $A$ ។

២.កំណត់សមីការប្លង់ $(ABC)$ ៖

គេមាន $A(-4,1,-2)$, $B(-1,7,4)$ និង $C(4,-7,2)$

គេបាន $\overrightarrow{AB}=(3,6,6)$ , $\overrightarrow{AC}=(8,-8,4)$

វ៉ិចទ័រណរម៉ាល់នៃប្លង់ $(ABC)$ គឺ $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}$

$$\vec{n}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 3 & 6 & 6\\ 8 & -8 & 4\end{vmatrix}=72\vec{i}-36\vec{j}-72\vec{k}$$

សមីការប្លង់ $(ABC)$ អាចសរសេរ៖

$$(ABC): a(x-x_a)+b(y-y_a)+c(z-z_a)=0$$

$$72(x+4)-36(y-1)-72(z+2)=0$$

$$2x+8-y+1-2z-4=0$$

$$2x-y-2z+5=0$$

ដូចនេះ $(ABC): 2x-y-2z+5=0$ ។

៣.រកកូអរដោនេនៃចំណុច $I$ ដែលផ្ទៀងផ្ទាត់ $BC.\overrightarrow{IA}+AC.\overrightarrow{IB}+AB.\overrightarrow{IC}=\overrightarrow{O}$

តាង $I(x_i,y_i,z_i)$ នោះ $\begin{cases}\overrightarrow{IA}=(-4-x_i,1-y_i,-2-z_i)\\ \overrightarrow{IB}=(-1-x_i,7-y_i,4-z_i)\\ \overrightarrow{IC}=(4-x_i,-7-y_i,2-z_i)\end{cases}$

ដោយ $AB=9, AC=12, BC=15$ នោះគេបាន ៖

$$\begin{cases}BC.\overrightarrow{IA}=(-60-15x_i,15-15y_i,-30-15z_i)\\ AC.\overrightarrow{IB}=(-12-12x_i,84-12y_i,48-12z_i)\\ AB.\overrightarrow{IC}=(36-9x_i,-63-9y_i,18-9z_i)\end{cases}$$

តាង $\vec{S} = BC.\overrightarrow{IA} + AC.\overrightarrow{IB} + AB.\overrightarrow{IC}$

គេបាន $\vec{S} = (-36-36x_i, 36-36y_i, 36-36z_i)$

ដោយ $\vec{S} = BC.\overrightarrow{IA} + AC.\overrightarrow{IB} + AB.\overrightarrow{IC} = \vec{O}$ សមមូល $\begin{cases} -36-36x_i = 0 \\ 36-36y_i = 0 \\ 36-36z_i = 0 \end{cases}$

គេទាញ $x_i = -1$ , $y_i = 1$ , $z_i = 1$ ។

ដូចនេះ $I(-1,1,1)$ ។

៤.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(IA),(IB),(IC)$ ៖

គេមាន $A(-4,1,-2), B(-1,7,4)$ និង $C(4,-7,2)$

បន្ទាត់ $(IA),(IB),(IC)$ មានវ៉ិចទ័រប្រាប់ទិសរៀងគ្នា ៖

$\overrightarrow{IA} = (-3,0,-3), \overrightarrow{IB} = (0,6,3)$ និង $\overrightarrow{IC} = (5,-8,1)$ ។

ដូចនេះសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(IA),(IB),(IC)$ អាចសរសេរដូចតទៅ៖

$$(IA): \begin{cases} x = -4-3t_1 \\ y = 1 \\ z = -2-3t_1 \end{cases}, (IB): \begin{cases} x = -1 \\ y = 7+6t_2 \\ z = 4+3t_2 \end{cases}, (IC): \begin{cases} x = 4+5t_3 \\ y = -7-8t_3 \\ z = 2+t_3 \end{cases}$$

ដែល $t_1, t_2, t_3 \in \mathbb{R}$ ។

៥.ស្រាយបញ្ជាក់ថា ៖

$$BC.MA^2 + AC.MB^2 + AB.MC^2 = (BC + AC + AB)MI^2 + BC.AC.AB$$

គេមាន $A(-4,1,-2), B(-1,7,4)$ និង $C(4,-7,2)$

$M(x,y,z)$ , $I(-1,1,1)$ និង $AB = 9$ , $AC = 12$ , $BC = 15$

គេបាន $\begin{cases} MA^2 = (-4-x)^2 + (1-y)^2 + (-2-z)^2 \\ MB^2 = (-1-x)^2 + (7-y)^2 + (4-z)^2 \\ MC^2 = (4-x)^2 + (-7-y)^2 + (2-z)^2 \end{cases}$

$$\begin{cases} MA^2 = x^2 + y^2 + z^2 + 8x - 2y + 4z + 21 \\ MB^2 = x^2 + y^2 + z^2 + 2x - 14y - 8z + 66 \\ MC^2 = x^2 + y^2 + z^2 - 8x + 14y - 4z + 69 \end{cases}$$

$$\begin{cases} BC.MA^2 = 15x^2 + 15y^2 + 15z^2 + 120x - 30y + 60z + 315 \\ AC.MB^2 = 12x^2 + 12y^2 + 12z^2 + 24x - 168y - 96z + 792 \\ AB.MC^2 = 9x^2 + 9y^2 + 9z^2 - 72x + 126y - 36z + 621 \end{cases}$$

បូកសមីការនេះអង្គនិងអង្គគេបាន៖

$$BC.MA^2 + AC.MB^2 + AB.MC^2 = 36(x^2 + y^2 + z^2) + 72(x - y - z) + 1728 \ (i)$$

ម្យ៉ាងទៀតគេមាន $MI^2 = (-1-x)^2 + (1-y)^2 + (1-z)^2$

ឬ $MI^2 = x^2 + y^2 + z^2 + 2x - 2y - 2z + 3$

ដោយ $AB = 9, AC = 12, BC = 15$ នោះ $\begin{cases} BC + AC + AB = 36 \\ BC.AC.AB = 1620 \end{cases}$ នោះគេបាន ៖

$(BC + AC + AB)MI^2 + BC.AC.AB = 36(x^2 + y^2 + z^2) + 72(x - y - z) + 1728 \ (ii)$ តាម $(i)$ និង $(ii)$ គេបានទំនាក់ទំនង ៖

$$BC.MA^2 + AC.MB^2 + AB.MC^2 = (BC + AC + AB)MI^2 + BC.AC.AB$$

www.mathtoday.wordpress.com

## លំហាត់ទី២០

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន$\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបីចំណុច

$A(1,-1,-3)$ , $B(2,-3,-1)$ និង $C(4,1,3)$ ។

១.គណនា $AB,AC$ និង $BC$ ។

២.រកកូអរដោនេនៃចំណុច $D$ ដោយដឹងថា $ABCD$ ជាប្រលេឡូក្រាម។

៣.រកកូអរដោនេចំណុច $I$ កណ្តាលអង្កត់$[BC]$ រួចសរសេរសមីការប្លង់មេដ្យាទ័រនៃអង្កត់$[BC]$ ។

៤.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(ID)$ ។

៥.សរសេរសមីការស្វ៊ែ$(S)$ មានផ្ចិត $I$ និងកាំ $r=AB$ ។

## ដំណោះស្រាយ

១.គណនា $AB,AC$ និង $BC$ ៖

យើងមាន $A(1,-1,-3)$ , $B(2,-3,-1)$ និង $C(4,1,3)$

យើងបាន $AB=\sqrt{(2-1)^2+(-3+1)^2+(-1+3)^2}=\sqrt{1+4+4}=3$

$$AC=\sqrt{(4-1)^2+(1+1)^2+(3+3)^2}=\sqrt{9+4+36}=7$$

$$BC=\sqrt{(4-2)^2+(1+3)^2+(3+1)^2}=\sqrt{4+16+16}=6$$

ដូចនេះ $AB=3$ , $AC=7$ , $BC=6$ (ឯកតាប្រវែង)

២.រកកូអរដោនេនៃចំណុច $D$ ដោយដឹងថា $ABCD$ ជាប្រលេឡូក្រាម៖

ចតុកោណ $ABCD$ ជាប្រលេឡូក្រាមលុះត្រាតែ $\overrightarrow{AD}=\overrightarrow{BC}$

តាង $D(x_d,y_d,z_d)$ ដោយ $A(1,-1,-3)$ , $B(2,-3,-1)$ និង $C(4,1,3)$

គេបាន $\overrightarrow{AD}=(x_d-1,y_d+1,z_d+3)$ និង $\overrightarrow{BC}=(2,4,4)$

ដោយ $\overrightarrow{AD}=\overrightarrow{BC}\Leftrightarrow\begin{cases}x_d-1=2\\y_d+1=4\\z_d+3=4\end{cases}$ នោះ $\begin{cases}x_d=3\\y_d=3\\z_d=1\end{cases}$

ដូចនេះ $D(3,3,1)$ ។

**៣.រកកូអរដោនេចំណុច $I$ កណ្ដាលអង្កត់ $[BC]$ ៖**

គេមាន $B(2,-3,-1)$ និង $C(4,1,3)$ នោះគេបាន $I\left(\frac{2+4}{2},\frac{-3+1}{2},\frac{-1+3}{2}\right)$

ដូចនេះ $I(3,-1,1)$ ។

**សរសេរសមីការប្លង់មេដ្យាទ័រនៃអង្កត់ $[BC]$ ៖**

វ៉ិចទ័រណ័រម៉ាល់នៃប្លង់មេដ្យាទ័រនៃអង្កត់ $[BC]$ គឺ $\overrightarrow{BC}=(2,4,4)$

សមីការប្លង់អាចសរសេរ $a(x-x_i)+b(y-y_i)+c(z-z_i)=0$

$$2(x-3)+4(y+1)+4(z-1)=0$$

$$2x-6+4y+4+4z-4=0$$

$$2x+4y+4z-6=0$$

ដូចនេះសមីការប្លង់មេដ្យាទ័រនៃអង្កត់ $[BC]$ គឺ $x+2y+2z-3=0$ ។

**៤.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(ID)$ ៖**

គេមាន $I(3,-1,1)$ និង $D(3,3,1)$

វ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $(ID)$ គឺ $\overrightarrow{ID}=(0,4,0)$

ដូចនេះ $(ID):\begin{cases}x=3\\y=-1+4t\\z=1\end{cases}\quad ,t\in\mathbb{R}$

៥.សរសេរសមីការស្វ៊ែ $(S)$ មានផ្ចិត $I$ និងកាំ $r=AB$ ៖

គេមាន $I(3,-1,1)$ និង $AB=3$

តាមរូបមន្ត $(S):(x-x_i)^2+(y-y_i)^2+(z-z_i)^2=r^2$

ដូចនេះ $(S):(x-3)^2+(y+1)^2+(z-1)^2=9$ (ជាសមីការស្តង់ដា)។

ឬ $(S):x^2+y^2+z^2-6x+2y-2z+2=0$ (ជាសមីការទូទៅ)។

www.mathtoday.wordpress.com

## លំហាត់ទី២១

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យពីរចំណុច

$A(1,1,0)$ និង $B(3,-3,4)$ ។

១.សរសេរសមីការប្លង់មេដ្យាទ័រ $(P)$ នៃអង្កត់ $[AB]$ ។

២.សរសេរសមីការទូទៅនៃស្វ៊ែ $(S)$ មានអង្កត់ផ្ចិត $AB$ ។

៣.ចូរផ្ទៀងផ្ទាត់ថា $O\in(S)$ ( $O$ ជាគល់នៃតម្រុយអរតូនរម៉ាល់ )។

សរសេរសមីការប្លង់ $(Q)$ ប៉ះនឹងស្វ៊ែ $(S)$ ត្រង់ $O$ ។

៤.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(L)$ ជាប្រសព្វរវាងប្លង់ $(P)$ និង $(Q)$ ។

## ដំណោះស្រាយ

១.សរសេរសមីការប្លង់មេដ្យាទ័រ $(P)$ នៃអង្កត់ $[AB]$ ៖

គេមាន $A(1,1,0)$ និង $B(3,-3,4)$ នោះ $\overrightarrow{AB}=(2,-4,4)$

យក $I$ ជាចំណុចកណ្ដាលនៃអង្កត់ $[AB]$ នោះ $I\left(\frac{1+3}{2},\frac{1-3}{2},\frac{0+4}{2}\right)$

ឬ $I(2,-1,2)$ ។ ប្លង់មេដ្យាទ័រ $(P)$ នៃអង្កត់ $[AB]$ គឺជាប្លង់ដែលកែងនឹង $[AB]$

ត្រង់ចំណុចកណ្ដាល $I$ ។ ហេតុនេះសមីការប្លង់ $(P)$ អាចសរសេរ៖

$$(P): a(x-x_i)+b(y-y_i)+c(z-z_i)=0$$

$$2(x-2)-4(y+1)+4(z-2)=0$$

$$2x-4-4y-4+4z-8=0$$

$$2x-4y+4z-16=0$$

ដូចនេះ $(P): x-2y+2z-8=0$ ។

២.សរសេរសមីការទូទៅនៃស្វ៊ែ $(S)$ មានអង្កត់ផ្ចិត $AB$ ៖

ស្វ៊ែ $(S)$ មានផ្ចិត $I(2,-1,2)$ និងកាំ $r=\frac{|\overrightarrow{AB}|}{2}=\frac{1}{2}\sqrt{4+16+16}=3$ ។

តាមរូបមន្ត $(S):(x-x_i)^2+(y-y_i)^2+(z-z_i)^2=r^2$

$$(x-2)^2+(y+1)^2+(z-2)^2=9$$

$$x^2-4x+4+y^2+2y+1+z^2-4z+4-9=0$$

ដូចនេះ $(S): x^2+y^2+z^2-4x+2y-4z=0$ ។

៣.ផ្ទៀងផ្ទាត់ថា $O\in(S)$ ៖

គេមាន $(S): x^2+y^2+z^2-4x+2y-4z=0$ និង $O(0,0,0)$

យកកូអរដោនេនៃចំណុច $O$ ជំនួសក្នុងសមីការ $(S)$ គេបាន $0=0$ ពិត

ដូចនេះ $O\in(S)$ ។

សរសេរសមីការប្លង់ $(Q)$ ប៉ះនឹងស្វ៊ែ $(S)$ ត្រង់ $O$ ៖

វ៉ិចទ័រណរម៉ាល់នៃប្លង់ $(Q)$ ដែលប៉ះនឹងស្វ៊ែ $(S)$ ត្រង់គល់ $O$ គឺ $\overrightarrow{OI}=(2,-1,2)$

សមីការប្លង់ $(Q)$ អាចសរសេរ $(Q): a(x-x_0)+b(y-y_0)+c(z-z_0)=0$

$$2(x-0)-(y-0)+2(z-0)=0$$

ដូចនេះ $(Q): 2x-y+2z=0$ ។

៤.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(L)$ ជាប្រសព្វរវាងប្លង់ $(P)$ និង $(Q)$ ៖

គេមាន $(P): x-2y+2z-8=0$ និង $(Q): 2x-y+2z=0$

យក $x=t$ , $t\in\mathbb{R}$ គេបាន $\begin{cases} t-2y+2z-8=0 & (1) \\ 2t-y+2z=0 & (2) \end{cases}$

យក $(2)-(1)$ គេបាន $t+y+8=0$ នោះ $y=-8-t$

តាម $(1)$ គេបាន $t-2(-8-t)+2z-8=0$

$$t+16+2t+2z-8=0 \text{ ឬ } z=-4-\frac{3}{2}t$$

ដូចនេះ $(L):\begin{cases} x=t \\ y=-8-t \\ z=-4-\frac{3}{2}t \quad , t\in\mathbb{R} \end{cases}$

www.mathtoday.wordpress.com

## លំហាត់ទី២២

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន$\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបីចំណុច

$A(1,1,1)$ , $B(2,-3,4)$ និង $C(3,-4,-2)$ ។

១.រកកូអរដោនេនៃចំណុច$G$ ដោយដឹងថា $\overrightarrow{GA}+\overrightarrow{GB}+\overrightarrow{GC}=\vec{O}$ ។

២.សរសេរសមីការទូទៅនៃស្វ៊ែ$(S)$មានផ្ចិត$O$និងកាំ$OG$ ។

៣.សរសេរសមីការប្លង់$(P)$ ប៉ះនឹងស្វ៊ែ$(S)$ ត្រង់$G$ ។

៤.សរសេរសមីការប្លង់$(Q)$ កាត់តាម$G$ ហើយកែងនឹង $\vec{n}=(9,3,1)$ ។

៥.ចូរផ្ទៀងផ្ទាត់ថាបីចំណុច$A,B,C$ ស្ថិតនៅក្នុងប្លង់ $(P)$ ។

៦.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(L)$ ជាប្រសព្វរវាងប្លង់ $(P)$ និង$(Q)$ ។

## ដំណោះស្រាយ

**១.រកកូអរដោនេនៃចំណុច$G$ ដោយដឹងថា $\overrightarrow{GA}+\overrightarrow{GB}+\overrightarrow{GC}=\vec{O}$ ៖**

តាង $G(x_g,y_g,z_g)$ ដោយ$A(1,1,1)$ , $B(2,-3,4)$ និង $C(3,-4,-2)$

នោះ $\begin{cases}\overrightarrow{GA}=(1-x_g,1-y_g,1-z_g)\\ \overrightarrow{GB}=(2-x_g,-3-y_g,4-z_g)\\ \overrightarrow{GC}=(3-x_g,-4-y_g,-2-z_g)\end{cases}$

គេបាន$\overrightarrow{GA}+\overrightarrow{GB}+\overrightarrow{GC}=(6-3x_g,-6-3y_g,3-3z_g)$

ដោយ $\overrightarrow{GA}+\overrightarrow{GB}+\overrightarrow{GC}=\overrightarrow{O}$ សមមូល $\begin{cases}6-3x_g=0\\-6-3y_g=0\\3-3z_g=0\end{cases}$ ឬ $\begin{cases}x_g=2\\y_g=-2\\z_g=1\end{cases}$

ដូចនេះ $G(2,-2,1)$ ។

២.សរសេរសមីការទូទៅនៃស្វ៊ែ $(S)$ មានផ្ចិត $O$ និងកាំ $OG$ ៖

គេមាន $G(2,-2,1)$ នោះ $OG=\sqrt{4+4+1}=3$

ដូចនេះសមីការទូទៅនៃស្វ៊ែ $(S)$ មានផ្ចិត $O$ និងកាំ $OG$ គឺ $(S):x^2+y^2+z^2=9$

៣.សរសេរសមីការប្លង់ $(P)$ ប៉ះនឹងស្វ៊ែ $(S)$ ត្រង់ $G$ ៖

វ៉ិចទ័រណរម៉ាល់នៃប្លង់ $(P)$ ប៉ះនឹងស្វ៊ែ $(S)$ ត្រង់ $G$ គឺ $\vec{n}=\overrightarrow{OG}=(2,-2,1)$

តាមរូបមន្ត $(P):a(x-x_g)+b(y-y_g)+c(z-z_g)=0$

$$2(x-2)-2(y+2)+(z-1)=0$$
$$2x-4-2y-4+z-1=0$$
$$2x-2y+z-9=0$$

ដូចនេះ $(P):2x-2y+z-9=0$ ។

៤.សរសេរសមីការប្លង់ $(Q)$ កាត់តាម $G$ ហើយកែងនឹង $\vec{n}=(9,3,1)$ ៖

តាមរូបមន្ត $(Q):a(x-x_g)+b(y-y_g)+c(z-z_g)=0$

$$9(x-2)+3(y+2)+(z-1)=0$$
$$9x-18+3y+6+z-1=0$$
$$9x+3y+z-13=0$$

ដូចនេះ $(Q):9x+3y+z-13=0$ ។

៥.ផ្ទៀងផ្ទាត់ថាបីចំណុច $A,B,C$ ស្ថិតនៅក្នុងប្លង់ $(P)$ ៖

គេមាន $A(1,1,1)$ , $B(2,-3,4)$ និង $C(3,-4,-2)$

និង $(Q): 9x+3y+z-13=0$ ។

ចំពោះ $A(1,1,1)$ នោះ $(Q):9(1)+3(1)+(1)-13=0$ ឬ $0=0$ ពិត

ចំពោះ $B(2,-3,4)$ នោះ$(Q): 9(2)+3(-3)+(4)-3=0$ ឬ$0=0$ ពិត

ចំពោះ$C(3,-4,-2)$ នោះ $(Q): 9(3)+3(-4)+(-2)-13=0$ ឬ$0=0$ ពិត

ដូចនេះ $A,B,C$ ស្ថិតនៅក្នុងប្លង់$(P)$ ។

៦.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(L)$ ជាប្រសព្វរវាងប្លង់ $(P)$ និង$(Q)$ ៖

គេមាន $\begin{cases}(P):\ 2x-2y+z-9=0\\(Q):\ 9x+3y+z-13=0\end{cases}$

យក$x=t$ នោះ $\begin{cases}2t-2y+z-9=0 & (1)\\9t+3y+z-13=0 & (2)\end{cases}$

យក$(2)-(1)$ គេបាន $7t+5y-4=0$ នោះ $y=\frac{4}{5}-\frac{7}{5}t$

តាម $(1)$: $2t-2\left(\frac{4}{5}-\frac{7}{5}t\right)+z-9=0$ នោះ $z=\frac{53}{5}-\frac{24}{5}t$

ដូចនេះ $(L):\begin{cases}x=t\\y=\frac{4}{5}-\frac{7}{5}t\\z=\frac{53}{5}-\frac{24}{5}t\ ,\ t\in\mathbb{R}\end{cases}$

www.mathtoday.wordpress.com

## លំហាត់ទី២៣

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច

$A(1,-2,-4)$ , $B(-1,-4,-3)$,$C(3,4,5)$ និង $D(7,-7,-2)$ ។

១.គណនាផលគុណស្កាលែ $\overrightarrow{AD}.\overrightarrow{AB}$ និង $\overrightarrow{AD}.\overrightarrow{AC}$ រួចទាញថា $\overrightarrow{AD}\perp\overrightarrow{BC}$ ។

២.គណនាជ្រុងទាំងបីនៃត្រីកោណ $ABC$ ។

៣.ស្រាយថាប្លង់$(ABC)$ មានសមីការ $6x-5y+2z-8=0$ ។

៤.យក $I$ ជាចំណុចកណ្តាលនៃ$[BC]$ ។ គណនាកូអរដោនេនៃចំណុច $I$ រួច
   សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(ID)$ ។

៤.សរសេរសមីការប្លង់មេដ្យាទ័រ$(Q)$ នៃអង្កត់$[BC]$ ។

៥.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(L)$ ជាប្រសព្វរវាងប្លង់ $(P)$ និង$(Q)$ ។

## ដំណោះស្រាយ

**១.គណនាផលគុណស្កាលែ $\overrightarrow{AD}.\overrightarrow{AB}$ និង $\overrightarrow{AD}.\overrightarrow{AC}$ រួចទាញថា $\overrightarrow{AD}\perp\overrightarrow{BC}$**

គេមាន $A(1,-2,-4)$ , $B(-1,-4,-3)$,$C(3,4,5)$ និង $D(7,-7,-2)$

គេបាន $\overrightarrow{AD}=(6,-5,2)$ , $\overrightarrow{AB}=(-2,-2,1)$ និង $\overrightarrow{AC}=(2,6,9)$

$\overrightarrow{AD}.\overrightarrow{AB}=(6)(-2)+(-5)(-2)+(2)(1)=-12+10+2=0$

$\overrightarrow{AD}.\overrightarrow{AC}=(6)(2)+(-5)(6)+(2)(9)=12-30+18=0$ ។

ដូចនេះ $\overrightarrow{AD}.\overrightarrow{AB}=0$ និង $\overrightarrow{AD}.\overrightarrow{AC}=0$ ។

ដោយ $\overrightarrow{AD}.\overrightarrow{AB}=0$ និង $\overrightarrow{AD}.\overrightarrow{AC}=0$ នោះគេទាញ $\overrightarrow{AD}\perp\overrightarrow{AB}$ និង $\overrightarrow{AD}\perp\overrightarrow{AC}$

នោះ $\overrightarrow{AD} \perp (ABC)$ ដោយ $\overrightarrow{BC} \subset (ABC)$ នោះ $\overrightarrow{AD} \perp \overrightarrow{BC}$ ។

២.គណនាជ្រុងទាំងបីនៃត្រីកោណ $ABC$ ៖

គេមាន $A(1,-2,-4)$ , $B(-1,-4,-3), C(3,4,5)$

គេបាន $AB = \sqrt{(-1-1)^2 + (-4+2)^2 + (-3+4)^2} = \sqrt{4+4+1} = 3$

$$AC = \sqrt{(3-1)^2 + (4+2)^2 + (5+4)^2} = \sqrt{4+36+81} = 11$$

$$BC = \sqrt{(3+1)^2 + (4+4)^2 + (5+3)^2} = \sqrt{16+64+64} = 12$$

ដូចនេះ $AB = 3$ , $AC = 11$, $BC = 12$ ( ឯកតាប្រវែង )

៣.ស្រាយថាប្លង់ $(ABC)$ មានសមីការ $6x - 5y + 2z - 8 = 0$ ៖

តាមសម្រាយខាងលើយើងមាន $\overrightarrow{AD} \perp (ABC)$ នោះ $\overrightarrow{AD} = (6,-5,2)$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(ABC)$ ។

សមីកាប្លង់ $(ABC)$ អាចសរសេរ $a(x - x_a) + b(y - y_a) + c(z - z_a) = 0$

$$6(x-1) - 5(y+2) + 2(z+4) = 0$$

$$6x - 6 - 5y - 10 + 2z + 8 = 0$$

$$6x - 5y + 2z - 8 = 0$$

ដូចនេះប្លង់ $(ABC)$ មានសមីការ $6x - 5y + 2z - 8 = 0$ ។

៤.គណនាកូអរដោនេនៃចំណុច $I$

គេមាន $B(-1,-4,-3)$ & $C(3,4,5)$ ដោយ $I$ ជាចំណុចកណ្តាលនៃ $[BC]$

នោះ $I\left(\frac{-1+3}{2}, \frac{-4+4}{2}, \frac{-3+5}{2}\right)$ ឬ $I(1,0,1)$ ។

ដូចនេះ $I(1,0,1)$ ។

សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(ID)$ ៖

វ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $(ID)$ គឺ $\overrightarrow{ID}=(6,-7,-3)$

ដូចនេះ $(ID):\begin{cases} x=1+6t \\ y=-7t \\ z=1-3t \ , t\in\mathbb{R} \end{cases}$

៤.សរសេរសមីការប្លង់មេដ្យាទ័រ $(Q)$ នៃអង្កត់ $[BC]$ ៖

គេមាន $B(-1,-4,-3)$ & $C(3,4,5)$ នោះ $\overrightarrow{BC}=(4,8,8)$

ចំណុចកណ្ដាលនៃ $[BC]$ គឺ $I(1,0,1)$ ។ សមីការប្លង់ $(Q)$ អាចសរសេរ៖

$$(Q): a(x-x_i)+b(y-y_i)+c(z-z_i)=0$$
$$4(x-1)+8(y-0)+8(z-1)=0$$
$$4x-4+8y+8z-8=0$$
$$4x+8y+8z-12=0$$
$$x+2y+2z-3=0$$

ដូចនេះ $(Q): x+2y+2z-3=0$ ។

៥.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(L)$ ជាប្រសព្វរវាងប្លង់ $(P)$ និង $(Q)$ ៖

គេមាន $(P): 6x-5y+2z-8=0$ និង $(Q): x+2y+2z-3=0$

យក $x=t \ ,t\in\mathbb{R}$ នោះ $\begin{cases} 6t-5y+2z-8=0 \\ t+2y+2z-3=0 \end{cases}$

បន្ទាប់ពីដោះស្រាយគេបាន $y=-\frac{5}{7}+\frac{5}{7}t \ , z=\frac{31}{14}-\frac{17}{14}t$ ។

ដូចនេះ $(L): x=t \ , y=-\frac{5}{7}+\frac{5t}{7}, z=\frac{31}{14}-\frac{17t}{14}$ ដែល $t\in\mathbb{R}$ ។

www.mathtoday.wordpress.com

## លំហាត់ទី២៤

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យពីរចំណុច $A(-4,1,3)$ និង $B(2,3,-1)$ និងប្លង់ $(P): x+2y-2z-1=0$ ។

១.ចូរសរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(AB)$ ។

២.គណនាកូអរដោនេនៃចំណុច $M$ ជាប្រសព្វរវាងបន្ទាត់ $(AB)$ និងប្លង់ $(P)$ រួចបង្ហាញថា $M$ ជាចំណុចកណ្តាលនៃអង្កត់ $[AB]$ ។

៣. $H$ ជាចំណោលកែងនៃចំណុច $B$ លើប្លង់ $(P)$ ។ សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(BH)$ រួចគណនាកូអរដោនេនៃចំណុច $H$ ។

៤. $K$ ជាចំណោលកែងនៃ $A$ លើបន្ទាត់ $(BH)$ ។ បង្ហាញថា $MH$ ជាបាតមធ្យមនៃត្រីកោណ $ABK$ រួចទាញរកកូអរដោនេនៃចំណុច $K$ ។

៥. $L$ ជាចំណោលកែងនៃ $A$ លើប្លង់ $(P)$ ។បង្ហាញថា $ALHK$ ជាចតុកោណកែងរួចទាញរកកូអរដោនេនៃចំណុច $L$ ។

## ដំណោះស្រាយ

**១.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(AB)$ ៖**

គេមាន $A(-4,1,3)$ និង $B(2,3,-1)$ នោះ $\overrightarrow{AB}=(6,2,-4)$ ជាវិចទ័រប្រាប់ទិសនៃបន្ទាត់ $(AB)$ ។ សមីការបន្ទាត់អាចសរសេរ ៖

$$(AB):\begin{cases} x=-4+6t \\ y=1+2t \\ z=3-4t \quad , t\in\mathbb{R} \end{cases}$$

២.គណនាកូអរដោនេនៃចំណុច $M$ ជាប្រសព្វរវាងបន្ទាត់ $(AB)$ និងប្លង់ $(P)$ ៖

គេមាន $(AB):\begin{cases} x=-4+6t \\ y=1+2t \\ z=3-4t \quad , t\in\mathbb{R} \end{cases}$ និង $(P): x+2y-2z-1=0$

យកសមីការ $(AB)$ ជំនួសក្នុង $(P)$ គេបាន ៖

$$(-4+6t)+2(1+2t)-2(3-4t)-1=0$$
$$-4+6t+2+4t-6+8t-1=0$$
$$18t-9=0$$
$$t=\frac{1}{2}$$

យក $t=\frac{1}{2}$ ជំនួសក្នុង $(AB)$ គេបាន $\begin{cases} x=-4+3=-1 \\ y=1+1=2 \\ z=3-2=1 \end{cases}$

ដូចនេះ $M(-1,2,1)$ ។

បង្ហាញថា $M$ ជាចំណុចកណ្ដាលនៃអង្កត់ $[AB]$ ៖

គេមាន $M(-1,2,1)$ និង $A(-4,1,3)$ និង $B(2,3,-1)$

ដោយ $\frac{x_a+x_b}{2}=\frac{-4+2}{2}=-1=x_m$ , $\frac{y_a+y_b}{2}=\frac{1+3}{2}=2=y_m$

និង $\frac{z_a+z_b}{2}=\frac{3-1}{2}=1=z_m$ នោះបញ្ជាក់ថាចំណុច $M$ ជាចំណុចកណ្ដាលនៃអង្កត់ $[AB]$ ។

៣.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(BH)$ រួចគណនាកូអរដោនេនៃ $H$

ដោយ $H$ ជាចំណោលកែងនៃចំណុច $B$ លើប្លង់ $(P)$ នោះបន្ទាត់ $(BH)\perp(P)$

គេបានវ៉ិចទ័រនរម៉ាល់ $\overrightarrow{n_p}=(1,2,-2)$ របស់ប្លង់$(P)$ ជាវ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $(BH)$ និងចំណុច $B(2,3,-1)\in(BH)$ នោះសមីការបន្ទាត់$(BH)$សរសេរ៖

$$(BH):\begin{cases}x=2+t\\y=3+2t\\z=-1-2t\quad,\ t\in\mathbb{R}\end{cases}$$

ម្យ៉ាងទៀតយកសមីការ$(BH)$ ជំនួសក្នុង$(P)$ គេបាន ៖

$$(2+t)+2(3+2t)-2(-1-2t)-1=0$$
$$2+t+6+4t+2+4t-1=0$$
$$9t+9=0$$
$$t=-1$$

យកតម្លៃ $t=-1$ ជួសក្នុង$(BH)$ គេបាន $\begin{cases}x=2-1=1\\y=3-2=1\\z=-1+2=1\end{cases}$

ដូចនេះ $H(1,1,1)$ ។

៨.បង្ហាញថា $MH$ ជាបាតមធ្យមនៃត្រីកោណ $ABK$ ៖



គេមាន $K$ ជាចំណោលកែងនៃ $A$ លើបន្ទាត់ $(BH)$ នោះ $AK \perp BK$
ហើយ $(BH) \perp (P)$ និង $MH \in (P)$ នោះ $MH \perp BH$ ហេតុនេះគេទាញ
$AK // MH$ ហើយដោយ $M$ ជាចំណុចកណ្ដាលនៃ $[AB]$ ( សម្រាយខាងលើ )
នោះគេទាញបានថា $H$ ជាចំណុចកណ្ដាលនៃ $[BK]$ ដែរ។
ដូចនេះ $MH$ ជាបាតមធ្យមនៃត្រីកោណកែង $BAK$ ។
ទាញរកកូអរដោនេនៃចំណុច $K$ ៖

ដោយ $H$ ជាចំណុចកណ្ដាលនៃ $[BK]$ នោះគេបាន $\begin{cases} x_h = \dfrac{x_b + x_k}{2} \\ y_h = \dfrac{y_b + y_k}{2} \\ z_h = \dfrac{z_b + z_k}{2} \end{cases}$

គេទាញ $\begin{cases} x_k = 2x_h - x_b = 2 - 2 = 0 \\ y_k = 2y_h - y_b = 2 - 3 = -1 \\ z_k = 2z_h - z_b = 2 + 1 = 3 \end{cases}$ ។

ដូចនេះ $H(0,-1,3)$ ។

**៥.បង្ហាញថា $ALHK$ ជាចតុកោណកែង រួចទាញរកកូអរដោនេនៃចំណុច $L$**

គេមាន $L$ ជាចំណោលកែងនៃ $A$ លើប្លង់ $(P)$ នោះ $AL \perp (P)$ ដោយ $LH \subset (P)$
នោះ $AL \perp LH$ ។ ម្យ៉ាងទៀត $AK \perp HK$ និង $LH \perp HK$ នោះគេទាញថា
$ALHK$ ជាចតុកោណកែង។
តាង $L(x_l, y_l, z_l)$ នោះ $\overrightarrow{AL} = (x_l + 4, y_l - 1, z_l - 3)$ និង $\overrightarrow{KH} = (1,2,-2)$

ដោយ $ALHK$ ជាចតុកោណកែងនោះ $\overrightarrow{AL} = \overrightarrow{HK}$ ឬ $\begin{cases} x_l + 4 = 1 \\ y_l - 1 = 2 \\ z_l - 3 = -2 \end{cases}$

គេទាញ $x_l = -3, y_l = 3, z_l = 1$ ។ ដូចនេះ $L(-3,3,1)$ ។

## លំហាត់ទី២៥

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន$\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបន្ទាត់ពីរ ៖

$$(L_1): \frac{x+1}{-1}=\frac{y+3}{-2}=\frac{z-5}{2} \quad \text{និង} \quad (L_2): \begin{cases} x=2+t \\ y=3 \\ z=-1-t \quad ,t\in\mathbb{R} \end{cases}$$

១.គណនាកូអរដោនេនៃចំណុចប្រសព្វ $M$ រវាងបន្ទាត់ $(L_1)$ និង $(L_2)$ ។

២.$A$ និង $B$ ជាពីរចំណុចស្ថិតនីលើបន្ទាត់$(L_2)$ ហើយមានអាប់ស៊ីសរៀងគ្នា $x_a=-1$ និង $x_b=5$ ។ គណនាកូអរដោនេនៃចំណុច $A$ និង $B$ ។

៣.$H$ និង $K$ ជាជើងនៃចំណោលកែងនៃចំណុច $A$ និង $B$ទៅលើបន្ទាត់$(L_1)$ រៀងគ្នា ។ គណនាកូអរដោនេនៃចំណុច$H$ និង $K$ ។

៤.គណនា $\overrightarrow{AK}$ និង $\overrightarrow{HB}$ រួចទាញរកប្រភេទនៃចតុកោណ $AHBK$ ។

៥.គណនា $AH$ និង $HK$ រួចទាញរកផ្ទៃក្រឡានៃចតុកោណ $AHBK$ ។

## ដំណោះស្រាយ

១.គណនាកូអរដោនេនៃចំណុចប្រសព្វ $M$ រវាងបន្ទាត់ $(L_1)$ និង $(L_2)$ ៖



$(L_1): \frac{x+1}{-1} = \frac{y+3}{-2} = \frac{z-5}{2}$ និង $(L_2): \begin{cases} x = 2+t \\ y = 3 \\ z = -1-t \quad , t \in \mathbb{R} \end{cases}$

តាង $M(x_m, y_m, z_m)$ ជាចំណុចប្រសព្វរវាងបន្ទាត់$(L_1)$ និង $(L_2)$ នោះគេបាន

$M \in (L_1)$ សមមូល $\frac{x_m+1}{-1} = \frac{y_m+3}{-2} = \frac{z_m-5}{2} \quad (1)$

$M \in (L_2)$ សមមូល $\begin{cases} x_m = 2+t \\ y_m = 3 \\ z_m = -1-t \end{cases} \quad (2)$

យកសមីការ$(2)$ ជំនួសក្នុង$(1)$ គេបាន $\frac{2+t+1}{-1} = \frac{3+3}{-2} = \frac{-1-t-5}{2}$

សមមូល $\frac{t+3}{-1} = -3 = \frac{-t-6}{2}$ សមមូល $\begin{cases} \frac{t+3}{-1} = -3 \\ \frac{-t-6}{2} = -3 \end{cases}$ សមមូល $t = 0$

យក $t = 0$ ជួសក្នុង$(2)$ គេបាន $x_m = 2$ , $y_m = 3$ , $z_m = -1$ ។

ដូចនេះ $M(2,3,-1)$ ។

**២.គណនាកូអរដោនេនៃចំណុច $A$ និង $B$**

ដោយ $A$ និង $B$ ជាពីរចំណុចស្ថិតនៅលើបន្ទាត់$(L_2)$ ហើយមានអាប់ស៊ីសរៀងគ្នា

$x_a = -1$ និង $x_b = 5$ នោះគេបាន $\begin{cases} x_a = 2+t = -1 \\ y_a = 3 \\ z_a = -1-t \end{cases}$ គេទាញ $t = -3$

នោះ $x_a = -1, y_a = 3, z_a = -1+3 = 2$ ឬ $A(-1 , 3 , 2)$ ។

ហើយ $\begin{cases} x_b = 2+t = 5 \\ y_b = 3 \\ z_b = -1-t \end{cases}$ គេទាញ $t=3$ ហើយ $x_b = 5, y_b = 3, z_b = -4$ ។

ដូចនេះ $A(-1,3,2)$ និង $B(5,3,-4)$ ។

៣.គណនាកូអរដោនេនៃចំណុច $H$ និង $K$

តាង $H(x_h, y_h, z_h)$ និង $K(x_k, y_k, z_k)$ ។ដោយ $H$ និង $K$ ជាចំណោលកែង នៃចំណុច $A$ និង $B$ ទៅលើបន្ទាត់ $(L_1)$ រៀងគ្នានោះ $H \in (L_1)$ និង $K \in (L_1)$

គេបាន $H \in (L_1) \Leftrightarrow \dfrac{x_h+1}{-1} = \dfrac{y_h+3}{-2} = \dfrac{z_h-5}{2} = p$ ឬ $\begin{cases} x_h = -1-p \\ y_h = -3-2p \\ z_h = 5+2p \end{cases}$ $(3)$

ហើយ $K \in (L_1) \Leftrightarrow \dfrac{x_k+1}{-1} = \dfrac{y_k+3}{-2} = \dfrac{z_k-5}{2} = q$ ឬ $\begin{cases} x_k = -1-q \\ y_k = -3-2q \\ z_k = 5+2q \end{cases}$ $(4)$

ដោយ $A(-1,3,2)$ និង $B(5,3,-4)$ នោះគេបាន ៖

$\overrightarrow{AH} = (-p, -2p-6, 2p+3)$ និង $\overrightarrow{BK} = (-q-6\ ,\ -2q-6\ ,\ 2q+9)$

បន្ទាត់ $(L_1)$ មានវ៉ិចទ័រប្រាប់ទិស $\overrightarrow{u_1} = (-1,-2,2)$ ។

គេមាន $\overrightarrow{AH} \perp \overrightarrow{u_1} \Leftrightarrow \overrightarrow{AH}.\overrightarrow{u_1} = 0$ ឬ $p+4p+12+4p+6=0$ នោះ $p=-2$

គេមាន $\overrightarrow{BK} \perp \overrightarrow{u_1} \Leftrightarrow \overrightarrow{BK}.\overrightarrow{u_1} = 0$ ឬ $q+6+4q+12+4q+18=0$ នោះ $q=-4$

ចំពោះ $p=-2$ តាម $(3)$ គេបាន $x_h = 1\ ,\ y_h = 1, z_h = 1$ ។

ចំពោះ $q=-4$ តាម $(4)$ គេបាន $x_k = 3\ ,\ y_k = 5\ ,\ z_k = -3$ ។

ដូចនេះ $H(1,1,1)$ និង $K(3,5,-3)$ ។

៨.គណនា $\overrightarrow{AK}$ និង $\overrightarrow{HB}$ រួចទាញរកប្រភេទនៃចតុកោណ $AHBK$ ៖

គេមាន $A(-1,3,2)$ , $K(3,5,-3)$ , $H(1,1,1)$, $B(5,3,-4)$

ដូចនេះ $\overrightarrow{AK}=(4,2,-5)$ និង $\overrightarrow{HB}=(4,2,-5)$ ។

ដោយសម្គាល់ឃើញថា $\overrightarrow{AK}=\overrightarrow{HB}=(4,2,-5)$ នោះ $AK=HB$ និង $AK//HB$

ដូចនេះចតុកោណ $AHBK$ ជាប្រលេឡូក្រាម។

៩.គណនា $AH$ និង $HK$ រួចទាញរកផ្ទៃក្រឡានៃចតុកោណ $AHBK$ ៖

គេមាន $A(-1,3,2)$ , $H(1,1,1)$ និង $K(3,5,-3)$

គេបាន $AH=\sqrt{(1+1)^2+(1-3)^2+(1-2)^2}=\sqrt{4+4+1}=\sqrt{9}=3$

$$HK=\sqrt{(3-1)^2+(5-1)^2+(-3-1)^2}=\sqrt{4+16+16}=\sqrt{36}=6$$

ដូចនេះ $AH=3$ ( ឯកតាប្រវែង ) និង $HK=6$ ( ឯកតាប្រវែង ) ។

ម្យ៉ាងទៀតដោយ $AH\perp HK$ និង $BK\perp HK$ នោះត្រីកោណកែង $AHK$ និង

ត្រីកោណកែង $BKH$ ប៉ុនគ្នាព្រោះ $AH=BK$ និង $HK$ ជ្រុងរួម។

គេបាន $S_{AHBK}=2S_{AHK}=2\left(\frac{1}{2}AH.HK\right)=AH.HK=18$ (ឯកតាផ្ទៃ)។

ដូចនេះ $S_{AHBK}=18$ (ឯកតាផ្ទៃ)។

www.mathtoday.wordpress.com

## លំហាត់ទី២៦

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច៖

$A(1,1,1),B(2,3,3),C(6,-1,5)$ និង $D\left(6,-4,\frac{7}{2}\right)$ ។

១.គណនាកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AB},\overrightarrow{AC},\overrightarrow{AD},\overrightarrow{BC}$ និង $\overrightarrow{CD}$ ។

២.បង្ហាញថា $\overrightarrow{AD}//\overrightarrow{BC}$ និង $\overrightarrow{AB}\perp\overrightarrow{AD}$ រួចរកប្រភេទនៃចតុកោណ $ABCD$ ។

៣.គណនា $\overrightarrow{AC}.\overrightarrow{CD}$ រួចទាញរកប្រភេទនៃត្រីកោណ $ACD$ ។

៤.$H$ ជាជើងនៃចំណោលកែងចំណុច $C$ លើ $[AD]$ ។គណនាកូអរដោនេនៃ $H$ ។

៥.គណនា $AB$ , $BC$ និង $AD$ រួចទាញរកផ្ទៃក្រឡានៃចតុកោណ $ABCD$ ។

## ដំណោះស្រាយ

**១.គណនាកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AB},\overrightarrow{AC},\overrightarrow{AD},\overrightarrow{BC}$ និង $\overrightarrow{CD}$ ៖**

គេមាន $A(1,1,1),B(2,3,3),C(6,-1,5)$ និង $D\left(6,-4,\frac{7}{2}\right)$

យើងបាន $\overrightarrow{AB}=(1,2,2),\overrightarrow{AC}=(5,-2,4),\overrightarrow{AD}=\left(5,-5,\frac{5}{2}\right),\overrightarrow{BC}=(4,-4,2)$

និង $\overrightarrow{CD}=\left(0,-3,-\frac{3}{2}\right)$ ។

**២.បង្ហាញថា $\overrightarrow{AD}//\overrightarrow{BC}$ និង $\overrightarrow{AB}\perp\overrightarrow{AD}$ រួចរកប្រភេទនៃចតុកោណ $ABCD$ ៖**

យើងមាន $\overrightarrow{AD}=\left(5,-5,\frac{5}{2}\right)$ និង $\overrightarrow{BC}=(4,-4,2)$

ដោយ $\frac{5}{4}=\frac{-5}{-4}=\frac{\frac{5}{2}}{2}$ នោះយើងទាញបានវ៉ិចទ័រ $\overrightarrow{AD}\,\&\,\overrightarrow{BC}$ កូលីនេអ៊ែគ្នា។

ម្យ៉ាងទៀតគេមាន $\overrightarrow{AB}=(1,2,2)$ និង $\overrightarrow{AD}=\left(5,-5,\frac{5}{2}\right)$

យើងបាន $\overrightarrow{AB}.\overrightarrow{AD}=(1)(5)+(2)(-5)+(2)\left(\frac{7}{2}\right)=5-10+5=0$

សមមូល $\overrightarrow{AB}\perp\overrightarrow{AD}$ ។

ដូចនេះ $\overrightarrow{AD}//\overrightarrow{BC}$ និង $\overrightarrow{AB}\perp\overrightarrow{AD}$ ។

ដោយ $\overrightarrow{AD}//\overrightarrow{BC}$ និង $\overrightarrow{AB}\perp\overrightarrow{AD}$ នោះគេទាញបាន $\overrightarrow{AB}\perp\overrightarrow{BC}$ ។

ដូចនេះចតុកោណ $ABCD$ ជាចតុកោណព្នាយកែងត្រង់ $A$ និង $B$ ។

៣.គណនា $\overrightarrow{AC}.\overrightarrow{CD}$ រួចទាញរកប្រភេទនៃត្រីកោណ $ACD$ ៖




យើងមាន $\overrightarrow{AC}=(5,-2,4)$ និង $\overrightarrow{CD}=\left(0,-3,-\frac{3}{2}\right)$

ដូចនេះ៖ $\overrightarrow{AC}.\overrightarrow{CD}=0+6-6=0$ ។

ដោយ $\overrightarrow{AC}.\overrightarrow{CD}=0\Leftrightarrow\overrightarrow{AC}\perp\overrightarrow{CD}$ នោះគេទាញបាន $ACD$ ជាត្រីកោណកែង ត្រង់កំពូល $C$ ។

៤.គណនាកូអរដោនេនៃ $H$

តាង $H(x_h,y_h,z_h)$ ។ ដោយ $H$ ជាជើងនៃចំណោលកែងចំណុច $C$ លើ $[AD]$

នោះយើងបាន $\overrightarrow{HC}=\overrightarrow{AB}$ ដោយ $\overrightarrow{HC}=(6-x_h,-1-y_h,5-z_h)$

និង $\overrightarrow{AB}=(1,2,2)$ នោះគេទាញបាន $\begin{cases}6-x_h=1\\-1-y_h=2\\5-z_h=2\end{cases}$ សមមូល $\begin{cases}x_h=5\\y_h=-3\\z_h=3\end{cases}$

ដូចនេះ $H(5,-3,3)$ ។

៥.គណនា $AB$ , $BC$ និង $AD$ រួចទាញរកផ្ទៃក្រឡានៃចតុកោណ $ABCD$ ៖

ដោយ $A(1,1,1),B(2,3,3),C(6,-1,5),D\left(6,-4,\frac{7}{2}\right)$

យើងបាន $AB=\sqrt{(2-1)^2+(3-1)^2+(3-1)^2}=\sqrt{1+4+4}=\sqrt{9}=3$

$$BC=\sqrt{(6-2)^2+(-1-3)^2+(5-3)^2}=\sqrt{16+16+4}=6$$

$$AD=\sqrt{(6-1)^2+(-4-1)^2+\left(\frac{7}{2}-1\right)^2}=\sqrt{25+25+\frac{25}{4}}=\frac{15}{2}$$

ដូចនេះ $AB=3,BC=6$ , $AD=\frac{15}{2}$ ( ឯកតាប្រវែង ) ។

ផ្ទៃក្រឡានៃចតុកោណព្នាយ $ABCD$ គឺ $S=\frac{(BC+AD)\times AB}{2}$

ដូចនេះ $S=\frac{(\frac{15}{2}+6)(3)}{2}=\frac{81}{4}$ ( ឯកតាផ្ទៃ )។

www.mathtoday.wordpress.com

## លំហាត់ទី២៧

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច

$A(4,1,4),B(3,5,5),C(3,-1,2)$ និង $D\left(\frac{5}{2},1,\frac{5}{2}\right)$ ។

១.គណនា $\overrightarrow{AB}.\overrightarrow{AD}$ និង $\overrightarrow{AD}.\overrightarrow{DC}$ រួចទាញរកប្រភេទនៃចតុកោណ $ABCD$ ។

២.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(AD)$ និង $(BC)$ ។

៣.$M$ ជាចំណុចស្ថិតនៅលើបន្ទាត់ $(AD)$ ដោយដឹងថាចំណុច $M$ មានអាប់ស៊ីស $x_m=1$ ។ ចូរគណនាកូអរដោនេនៃចំណុច $M$ ។

៤.គណនា $\overrightarrow{MB}.\overrightarrow{MC}$ រួចទាញរកប្រភេទនៃត្រីកោណ $MBC$ ។

៥.គណនា $MB$ និង $MC$ រួចទាញរកផ្ទៃក្រឡានៃត្រីកោណ $MBC$ ។

## ដំណោះស្រាយ

១.គណនា $\overrightarrow{AB}.\overrightarrow{AD}$ និង $\overrightarrow{AD}.\overrightarrow{DC}$ រួចទាញរកប្រភេទនៃចតុកោណ $ABCD$ ៖

គេមាន $A(4,1,4),B(3,5,5),C(3,-1,2)$ និង $D\left(\frac{5}{2},1,\frac{5}{2}\right)$

នោះ $\overrightarrow{AB}=(-1,4,1)$ , $\overrightarrow{AD}=\left(-\frac{3}{2},0,-\frac{3}{2}\right)$ និង $\overrightarrow{DC}=\left(\frac{1}{2},-2,-\frac{1}{2}\right)$

គេបាន $\overrightarrow{AB}.\overrightarrow{AD}=\frac{3}{2}+0-\frac{3}{2}=0$ និង $\overrightarrow{AD}.\overrightarrow{DC}=-\frac{3}{4}+0+\frac{3}{4}=0$ ។

ដូចនេះ $\overrightarrow{AB}.\overrightarrow{AD}=0$ និង $\overrightarrow{AD}.\overrightarrow{DC}=0$ ។

ដោយ $\overrightarrow{AB}.\overrightarrow{AD}=0$ និង $\overrightarrow{AD}.\overrightarrow{DC}=0$ សមមូល $\overrightarrow{AB}\perp\overrightarrow{AD}$ និង $\overrightarrow{AD}\perp\overrightarrow{DC}$

ហើយគេទាញបាន $\overrightarrow{AB}//\overrightarrow{DC}$ នោះ $ABCD$ ជាចតុកោណព្នាយកែង។

ដូចនេះ $ABCD$ ជាចតុកោណព្នាយកែងត្រង់ $A$ និង $D$ ។




២.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(AD)$និង $(BC)$

បន្ទាត់$(AD)$ និង $(BC)$ មានវ៉ិចទ័រប្រាប់ទិសរៀងគ្នា $\overrightarrow{AD}=\left(-\frac{3}{2},0,-\frac{3}{2}\right)$

និង $\overrightarrow{BC}=(0,-6,-3)$ ។ ដោយ $A(4,1,4)$ និង $B(3,5,5)$ នោះសមីការ

ប៉ារ៉ាម៉ែត្រនៃបន្ទាត់$(AD)$ និង $(BC)$ អាចសរសេរ៖

$$(AD):\begin{cases} x=4-\frac{3}{2}t \\ y=1 \\ z=4-\frac{3}{2}t \end{cases},t\in\mathbb{R} \quad \text{និង} \quad (BC):\begin{cases} x=3 \\ y=5-6u \\ z=5-3u \end{cases},u\in\mathbb{R}$$

៣.គណនាកូអរដោនេនៃចំណុច $M$ ៖

ដោយ $M$ ជាចំណុចស្ថិតនៅលើបន្ទាត់$(AD)$ហើយមានអាប់ស៊ីស $x_m=1$ នោះ:

គេបាន $\begin{cases} x_m=4-\frac{3}{2}t=1 \\ y_m=1 \\ z_m=4-\frac{3}{2}t \end{cases}$ គេទាញ $t=2$ ហើយ $x_m=1,\ y_m=1, z_m=1$ ។

ដូចនេះ $M(1,1,1)$ ។

៤.គណនា $\overrightarrow{MB}.\overrightarrow{MC}$ រួចទាញរកប្រភេទនៃត្រីកោណ $MBC$ ៖

គេមាន $M(1,1,1)$ , $B(3,5,5)$ និង $C(3,-1,2)$

នោះ $\overrightarrow{MB}=(2,4,4)$ និង $\overrightarrow{MC}=(2,-2,1)$ ។

គេបាន $\overrightarrow{MB}.\overrightarrow{MC}=(2)(2)+(4)(-2)+(4)(1)=4-8+4=0$ ។

ដូចនេះ $\overrightarrow{MB}.\overrightarrow{MC}=0$ ។

ម្យ៉ាងទៀតដោយ $\overrightarrow{MB}.\overrightarrow{MC}=0\Leftrightarrow\overrightarrow{MB}\perp\overrightarrow{MC}$ ។

ដូចនេះត្រីកោណ $MBC$ ជាត្រីកោណកែងត្រង់ $M$ ។

៥.គណនា $MB$ និង $MC$ រួចទាញរកផ្ទៃក្រឡានៃត្រីកោណ $MBC$ ៖

យើងមាន $MBC$ ជាត្រីកោណកែងត្រង់ $M$ ។ $\overrightarrow{MB}=(2,4,4)$ និង $\overrightarrow{MC}=(2,-2,1)$

យើងបាន $MB=|\overrightarrow{MB}|=\sqrt{4+16+16}=\sqrt{36}=6$

$MC=|\overrightarrow{MC}|=\sqrt{1+4+4}=\sqrt{9}=3$ ។

ដូចនេះ $MB=6$ ( ឯកតាប្រវែង ) និង $MC=3$ ( ឯកតាប្រវែង )។

ម្យ៉ាងទៀតដោយ $MBC$ ជាត្រីកោណកែងត្រង់ $M$ នោះយើងបាន៖

$S_{MBC}=\frac{1}{2}MB\times MC=\frac{1}{2}(6)(3)=9$ ( ឯកតាផ្ទៃក្រឡា )។

www.mathtoday.wordpress.com

## លំហាត់ទី២៨

ក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យស្វ៊ែ$(S)$សមីការ $(x-1)^2+(y+1)^2+(z-2)^2=9$ និងបន្ទាត់$(L)$: $\begin{cases} x=-4+3t \\ y=-7+4t \\ z=2+t \quad , t\in\mathbb{R} \end{cases}$

១.គណនាកូអរដោនេនៃចំណុចប្រសព្វ $A$ និង $B$ រវាងបន្ទាត់$(L)$និងស្វ៊ែ$(S)$ ។
(គេដឹងថាចំណុច $A$ មានអាប់ស៊ីសអវិជ្ជមាន )។

២.សរសេរសមីការប្លង់$(P)$ និង $(Q)$ ប៉ះទៅនឹងស្វ៊ែ$(S)$រៀងគ្នាត្រង់ $A$ និង $B$។

៣.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(d)$ ជាប្រសព្វរវាងប្លង់$(P)$ និង $(Q)$។

៤.សរសេរសមីការប្លង់$(\pi)$ កាត់តាមចំណុច $A$ ហើយកែងនឹងបន្ទាត់$(d)$ ។

៥.ចូរផ្ទៀងផ្ទាត់ថា $B\in(\pi)$ រួចសរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(\Delta)$ ដែលកែងនឹងប្លង់$(\pi)$ ត្រង់ $B$ ។

## ដំណោះស្រាយ

**១.គណនាកូអរដោនេនៃចំណុចប្រសព្វ $A$ និង $B$ រវាងបន្ទាត់$(L)$និងស្វ៊ែ$(S)$**

គេមាន $(x-1)^2+(y+1)^2+(z-2)^2=9 \quad (1)$

និង $\begin{cases} x=-4+3t \\ y=-7+4t \quad (2) \\ z=2+t \end{cases}$

យកសមីការ$(2)$ ជំនួសក្នុង$(1)$ គេបាន ៖

$$(-4+3t-1)^2+(-7+4t+1)^2+(2+t-2)^2=9$$

$$(3t-5)^2+(4t-6)^2+t^2=9$$

$$9t^2-30t+25+16t^2-48t+36+t^2-9=0$$

$$26t^2-78t+52=0$$

ដោយ $a+b+c=26-78+52=0$ គេទាញឫស $t_1=1$ , $t_2=\frac{c}{a}=2$ ។

ចំពោះ $t=1$ តាម$(2)$ គេបាន $\begin{cases} x=-4+3=-1 \\ y=-7+4=-3 \\ z=2+1=3 \end{cases}$

ចំពោះ $t=2$ តាម$(2)$ គេបាន $\begin{cases} x=-4+6=2 \\ y=-7+8=1 \\ z=2+2=4 \end{cases}$

ដូចនេះ $A(-1,-3,3)$ និង $B(2,1,4)$

( ព្រោះចំណុច $A$ មានអាប់ស៊ីសអវិជ្ជមាន )។

២.សរសេរសមីការប្លង់$(P)$ និង $(Q)$ ប៉ះទៅនឹងស្វ៊ែ$(S)$រៀងគ្នាត្រង់ $A$ និង $B$ ៖

ស្វ៊ែ $(S):(x-1)^2+(y+1)^2+(z-2)^2=9$ មានផ្ចិត $I(1,-1,2)$ ។

ដោយ $A(-1,-3,3)$ និង $B(2,1,4)$ នោះ $\overrightarrow{IA}=(-2,-2,1)$និង $\overrightarrow{IB}=(1,2,2)$

ជាវ៉ិចទ័រណរម៉ាល់នៃប្លង់$(P)$និង$(Q)$ ដែលប៉ះនឹងស្វ៊ែ$(S)$ ត្រង់ $A$ និង $B$ ។

សមីការប្លង់$(P)$ សរសេរ $-2(x+1)-2(y+3)+(z-3)=0$

$$-2x-2-2y-6+z-3=0$$
$$-2x-2y+z-11=0$$

សមីការប្លង់$(Q)$ សរសេរ $(x-2)+2(y-1)+2(z-4)=0$

$$x-2+2y-2+2z-8=0$$
$$x+2y+2z-12=0$$

ដូចនេះ $(P):-2x-2y+z-11=0$ និង $(Q):x+2y+2z-12=0$ ។

៣.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(d)$ ជាប្រសព្វរវាងប្លង់$(P)$ និង $(Q)$៖

គេមាន$(P): -2x-2y+z-11=0$ និង $(Q): x+2y+2z-12=0$

យក$z=t$ គេបាន $\begin{cases} -2x-2y+t-11=0 & (1) \\ x+2y+2t-12=0 & (2) \end{cases}$

បូកសមីការ$(1)\&(2)$ គេបាន $-x+3t-23=0$ ឬ $x=-23+3t$

តាម$(2)$ គេបាន $-23+3t+2y+2t-12=0$ ឬ $y=\frac{35}{2}-\frac{5}{2}t$

ដូចនេះ $(d): \begin{cases} x=-23+3t \\ y=\frac{35}{2}-\frac{5}{2}t \\ z=t & ,t\in\mathbb{R} \end{cases}$

៤.សរសេរសមីការប្លង់$(\pi)$ កាត់តាមចំណុច$A$ ហើយកែងនឹងបន្ទាត់$(d)$ ៖

បន្ទាត់$(d)$ មានវ៉ិចទ័រប្រាប់ទិស $\overrightarrow{u_d}=\left(3,-\frac{5}{2},1\right)$ ។

ដោយប្លង់$(\pi)\perp(d)$ នោះ $\overrightarrow{u_d}=\left(3,-\frac{5}{2},1\right)$ ជាវ៉ិចទ័រណរម៉ាល់របស់ប្លង់$(d)$ ។

គេបាន $(\pi): a(x-x_a)+b(y-y_a)+c(z-z_a)=0$

$$3(x+1)-\frac{5}{2}(y+3)+(z-3)=0$$

$$6x+6-5y-15+2z-6=0$$

$$6x-5y+2z-15=0$$

ដូចនេះ $(\pi): 6x-5y+2z-15=0$ ។

៥.ផ្ទៀងផ្ទាត់ថា$B\in(\pi)$ ៖

គេមាន $(\pi): 6x-5y+2z-15=0$ និង $B(2,1,4)$

យកកូអរដោនេនៃចំណុច $B$ ជំនួសក្នុងសមីការ $(\pi)$ គេបាន ៖

$$6(2)-5(1)+2(4)-15=0$$

$$12-5+8-15=0$$

$$0=0$$ ផ្ទៀងផ្ទាត់

ដូចនេះ $B\in(\pi)$ ។

សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(\Delta)$ ដែលកែងនឹងប្លង់ $(\pi)$ ត្រង់ $B$ ៖

ប្លង់ $(\pi): 6x-5y+2z-15=0$ មានវ៉ិចទ័រណរម៉ាល់ $\overrightarrow{n_\pi}=(6,-5,2)$ ។

ដោយបន្ទាត់ $(\Delta)$ កែងនឹងប្លង់ $(\pi)$ នោះវ៉ិចទ័រណរម៉ាល់ $\overrightarrow{n_\pi}=(6,-5,2)$ ជាវ៉ិចទ័រប្រាប់ទិសរបស់បន្ទាត់ $(\Delta)$ ។ ដោយបន្ទាត់ $(\Delta)$ កាត់តាមចំណុច $B(2,1,4)$ នោះសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(\Delta)$ សរសេរ ៖

$$(\Delta):\begin{cases}x=2+6t\\ y=1-5t\\ z=4+2t\quad ,\ t\in\mathbb{R}\end{cases}$$

www.mathtoday.wordpress.com

## លំហាត់ទី២៩

ក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យស្វ៊ែ $(S)$ សមីការ

$(x+5)^2+(y+2)^2+(z+1)^2=36$ និងបន្ទាត់ $(L)$: $\begin{cases} x=-1+2t \\ y=3+t \\ z=-3+2t \quad , t\in\mathbb{R} \end{cases}$

១.គណនាកូអរដោនេនៃផ្ចិត $I$ និងកាំ $r$ របស់ស្វ៊ែ $(S)$ ។

២.យក $H$ ជាជើងនៃចំណោលកែងនៃចំណុច $I$ លើបន្ទាត់ $(L)$ ។

គណនាកូអរដោនេនៃចំណុច $H$ និងរង្វាស់ $IH$ រួចទាញថាបន្ទាត់ $(L)$ ប៉ះទៅនឹងស្វ៊ែ $(S)$ ត្រង់ចំណុច $H$ ។

៣. $A$ និង $B$ ជាចំណុចពីរស្ថិតនៅលើបន្ទាត់ $(L)$ ហើយមានអាប់ស៊ីសរៀងគ្នា $x_a=-5$ និង $x_b=5$ ។ គណនាកូអរដោនេនៃចំណុច $A$ និង $B$ ។

៤.គណនា $AB$ , $IA$ និង $IB$ រួចទាញបញ្ជាក់ប្រភេទនៃត្រីកោណ $IAB$ ។

៥.គណនាផលគុណវ៉ិចទ័រ $\overrightarrow{IA}\times\overrightarrow{IB}$ រួចគណនាផ្ទៃក្រឡានៃត្រីកោណ $IAB$ ។

៦.សរសេរសមីការប្លង់ $(IAB)$ និងសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(IA),(IB),(IH)$

## ដំណោះស្រាយ

**១.គណនាកូអរដោនេនៃផ្ចិត $I$ និងកាំ $r$ របស់ស្វ៊ែ $(S)$ ៖**

គេមាន $(S):(x+5)^2+(y+2)^2+(z+1)^2=36$

មានទម្រង់ $(x-a)^2+(y-b)^2+(z-c)^2=r^2$ ដែល $\begin{cases} a=-5 \\ b=-2 \\ c=-1 \end{cases}$ និង $r=6$

ដូចនេះកូអរដោនេផ្ចិត $I(-5,-2,-1)$ និង កាំ $r=6$ ។

២.គណនាកូអរដោនេចំណុច $H$ និង $IH$ រួចទាញថា $(L)$ ប៉ះទៅនឹង $(S)$ ត្រង់ចំណុច $H$ ៖




តាង $H(x_h, y_h, z_h)$ ជាជើងនៃចំណោលកែងនៃចំណុច $I$ លើបន្ទាត់ $(L)$ នោះ

គេបាន $H \in (L)$ សមមូល $\begin{cases} x_h = -1 + 2t \\ y_h = 3 + t \\ z_h = -3 + 2t \end{cases}$ $(1)$

គេមាន $\overrightarrow{IH} \perp \overrightarrow{u_L} \Leftrightarrow \overrightarrow{IH} \,.\, \overrightarrow{u_L} = 0$ ដែល $\overrightarrow{u_L} = (2,1,2)$ ជាវ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $(L)$ ។ ដោយគេមាន $\overrightarrow{IH} = (2t+4 \,,\, t+5 \,,\, 2t-2)$

គេបាន $\overrightarrow{IH} . \overrightarrow{u_L} = 2(2t+4) + (t+5) + 2(2t-2) = 0$

$$4t + 8 + t + 5 + 4t - 4 = 0$$

$$9t + 9 = 0$$

គេទាញបាន $t=-1$ យកជួសក្នុង$(1)$ គេបាន $\begin{cases} x_h=-1-2=-3 \\ y_h=3-1=2 \\ z_h=-3-2=-5 \end{cases}$

ដូចនេះ $H(-3,2,-5)$ ។

ម្យ៉ាងទៀតដោយ $I(-5,-2,-1)$ និង $H(-3,2,-5)$

គេបាន $IH=\sqrt{(-3+5)^2+(2+2)^2+(-5+1)^2}=\sqrt{4+16+16}=6$

ដូចនេះ $IH=6$ (ឯកតាប្រវែង)។

ដោយ $IH\perp(L)$នោះ $IH$ ជាចម្ងាយពីចំណុច $I$ ទៅបន្ទាត់$(L)$ និង $IH=r=6$

ដូចនេះយើងអាចសន្និដ្ឋានបានថាបន្ទាត់$(L)$ប៉ះទៅនឹងស្វ៊ែ$(S)$ត្រង់ចំណុច $H$ ។

៣.គណនាកូអរដោនេនៃចំណុច $A$ និង $B$៖

មាន $A$ និង $B$ ជាចំណុចពីរស្ថិត នៅលើបន្ទាត់$(L)$ ហើយមានអាប់ស៊ីសរៀងគ្នា

$x_a=-5$ និង $x_b=5$ នោះគេបាន ៖

$\begin{cases} x_a=-1+2t=-5 \\ y_a=3+t \\ z_a=-3+2t \end{cases}$ សមមូល $t=-2$ , $x_a=-5$ , $y_a=1$ , $z_a=-7$ ។

$\begin{cases} x_b=-1+2t=5 \\ y_b=3+t \\ z_b=-3+2t \end{cases}$ សមមូល $t=3$ , $x_b=5$ , $y_b=6$, $z_b=3$ ។

ដូចនេះ $A(-5,1,-7)$ និង $B(5,6,3)$ ។

៤.គណនា $AB$ , $IA$ និង $IB$ រួចទាញបញ្ជាក់ប្រភេទនៃត្រីកោណ $IAB$ ៖

គេមាន $I(-5,-2,-1)$ , $A(-5,1,-7)$ និង $B(5,6,3)$

យើងបាន $AB=\sqrt{(5+5)^2+(6-1)^2+(3+7)^2}=\sqrt{100+25+100}=15$

$$IA=\sqrt{(-5+5)^2+(1+2)^2+(-7+1)^2}=\sqrt{9+36}=3\sqrt{5}$$

$$IB=\sqrt{(5+5)^2+(6+2)^2+(3+1)^2}=\sqrt{100+64+16}=6\sqrt{5}$$

ដូចនេះ $AB=15$ , $IA=3\sqrt{5}$ , $IB=6\sqrt{5}$ ( ឯកតាប្រវែង )។

ម្យ៉ាងទៀតគេមាន $IA^2+IB^2=\left(3\sqrt{5}\right)^2+\left(6\sqrt{5}\right)^2=225=AB^2$

តាមទ្រឹស្តីបទពីតាគ័រយើងទាញបានថា $IAB$ ជាត្រីកោណកែងត្រង់ $I$ ។

**៥.គណនាផលគុណវ៉ិចទ័រ $\overrightarrow{IA}\times\overrightarrow{IB}$ រួចគណនាផ្ទៃក្រឡានៃត្រីកោណ $IAB$ ៖**

គេមាន $I(-5,-2,-1)$ , $A(-5,1,-7)$ និង $B(5,6,3)$

គេបាន $\overrightarrow{IA}=(0,3,-6)$ និង $\overrightarrow{IB}=(10,8,4)$

នោះ $\overrightarrow{IA}\times\overrightarrow{IB}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 0 & 3 & -6\\ 10 & 8 & 4\end{vmatrix}=60\vec{i}-60\vec{j}-30\vec{k}$

ដូចនេះ $\overrightarrow{IA}\times\overrightarrow{IB}=(60,-60,-30)$ ។

ផ្ទៃក្រឡានៃត្រីកោណ $IAB$ គឺ ៖

$S=\frac{1}{2}\left|\overrightarrow{IA}\times\overrightarrow{IB}\right|=\frac{1}{2}\sqrt{3600+3600+900}=45$ ( ឯកតាផ្ទៃ )។

**៦.សរសេរសមីការប្លង់ $(IAB)$ និងសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(IA)$,$(IB)$,$(IH)$ ៖**

វ៉ិចទ័រណរម៉ាល់នៃប្លង់ $(IAB)$ គឺ $\vec{n}=\overrightarrow{IA}\times\overrightarrow{IB}=(60,-60,-30)$

ដោយប្លង់ $(IAB)$ កាត់តាមចំណុច $I(-5,-2,-1)$ នោះគេបាន៖

$(IAB): a(x-x_i)+b(y-y_i)+c(z-z_i)=0$

$$60(x+5)-60(y+2)-30(z+1)=0$$

ដូចនេះ $(IAB): 2x-2y-z+5=0$ ។

ម្យ៉ាងទៀតវ៉ិចទ័រប្រាប់ទិសនៃបន្ទាត់$(IA),(IB),(IC)$ គឺ ៖

$\overrightarrow{IA}=(0,3,-6)$ , $\overrightarrow{IB}=(10,8,4)$ , $\overrightarrow{IH}=(2,4,-4)$

ដូចនេះសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(IA),(IB),(IC)$អាចសរសេររៀងគ្នា ៖

$$(IA):\begin{cases}x=-5\\ y=-2+3u\\ z=-1+6u\end{cases},\ u\in\mathbb{R}$$

$$(IB):\begin{cases}x=-5+10v\\ y=-2+8v\\ z=-1+4v\end{cases},\ v\in\mathbb{R}$$

$$(IH):\begin{cases}x=-5+2w\\ y=-2+4w\\ z=-1-4w\end{cases},\ w\in\mathbb{R}$$

## លំហាត់ទី៣០

គេឲ្យប្លង់ពីរ $(\alpha): x+2y+2z-11=0$ , $(\beta): 2x-2y+z-1=0$

និងបន្ទាត់ $(\Delta): x=3+t\ , y=6-4t\ , z=7-t$ ដែល $t\in\mathbb{R}$

១.គណនាកូអរដោណេចំណុចប្រសព្វ $A$ និង $B$រវាងបន្ទាត់ $(\Delta)$ជាមួយប្លង់

$(\alpha)$ និង $(\beta)$ រៀងគ្នា ។

២.យក $C$ ជាចំណុចមានអាប់ស៊ីស $x=1$ហើយស្ថិតនៅក្នុងប្លង់$(\alpha)$និង $(\beta)$ ។

រកកូអរដោនេនៃចំណុច $C$ រួចរកក្រាបភេទនៃ $\Delta ABC$ ។

៣.កំណត់សមីការស្វ៊ែ $(S)$ មានផ្ចិតនៅលើបន្ទាត់ $(\Delta)$ ហើយប៉ះរួមទៅនឹងប្លង់

$(\alpha)$ និង $(\beta)$ ។

## ដំណោះស្រាយ

**១.គណនាកូអរដោណេចំណុចប្រសព្វ $A$ និង $B$ ៖**

យកសមីការ $(\Delta)$ ជួសក្នុងសមីការ $(\alpha)$ គេបាន៖

$$(3+t)+2(6-4t)+2(7-t)-11=0$$

$$3+t+12-8t+14-2t-11=0$$

$$-9t+18=0 \Rightarrow t=2$$

យក$t=2$ ជួសក្នុង $(\Delta)$ គេបាន $x=5, y=-2\ , z=5$ ។

ដូចនេះ $A(5\ ,-2\ ,5)$ ។

យកសមីការ $(\Delta)$ ជួសក្នុងសមីការ $(\beta)$ គេបាន៖

$$2(3+t)-2(6-4t)+(7-t)-1=0$$

$$6+2t-12+8t+7-t-1=0$$

$$9t=0 \Rightarrow t=0$$

យក$t=0$ ជួសក្នុង $(\Delta)$ គេបាន $x=3, y=6\ , z=7$ ។

ដូចនេះ $B(3\ ,6\ ,7)$ ។

២.រកកូអរដោនេនៃចំណុច $C$ រួចរកប្រភេទនៃ $\Delta ABC$

ចំពោះ $x=1$ គេបាន $\begin{cases}1+2y+2z-11=0\\2-2y+z-1=0\end{cases}$ ឬ $\begin{cases}2y+2z-10=0\\-2y+z+1=0\end{cases}$

គេទាញបាន $y=2\ ,\ z=3$ ។ ដូចនេះ $C(1,2,3)$ ។

គេមាន $\overrightarrow{CA}=(4,-4,2)\ ;\ \overrightarrow{CB}=(2,4,4)$

គេបាន $\overrightarrow{CA}.\overrightarrow{CB}=8-16+8=0\Leftrightarrow \overrightarrow{CA}\perp\overrightarrow{CB}$

ហើយ $|\overrightarrow{CA}|=\sqrt{16+16+4}=6\ ;|\overrightarrow{CB}|=\sqrt{4+16+16}=6$

គេទាញ $CA=CB=6$ ដូចនេះ $ABC$ ជាត្រីកោណកែងសមបាត

៣.កំណត់សមីការស្វ៊ែ $(S)$ ៖

តាង $I(a,b,c)$ ជាផ្ចិតរបស់ស្វ៊ែ $(S)$ មានផ្ចិតនៅលើបន្ទាត់ $(\Delta)$
ហើយប៉ះរួមទៅនឹងប្លង់ $(\alpha)$ និង $(\beta)$ ។

គេបាន $\begin{cases}a=3+t\\b=6-4t\\c=7-t\end{cases}$ (1) ហើយ $R=d(I,\alpha)=d(I,\beta)$

$$\frac{|(3+t)+2(6-4t)+2(7-t)-11|}{\sqrt{1+4+4}}=\frac{|2(3+t)-2(6-4t)+(7-t)-1|}{\sqrt{4+4+1}}$$

ឬ $\frac{|-9t+18|}{3}=\frac{|9t|}{3}\Rightarrow t=1$ យកជួសក្នុង $(1)$ គេបាន $\begin{cases}a=4\\b=2\\c=6\end{cases}$

ហើយ $R=\frac{9}{3}=3$ ។ ដូចនេះសមីការស្តង់ដានៃសមីការស្វ៊ែសរសេរ

$(S):(x-4)^2+(y-2)^2+(z-6)^2=9$ ។

www.mathtoday.wordpress.com

## លំហាត់ទី៣១

ក្នុងលំហប្រដាប់ដោយតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$

គេឲ្យប្លង់$(p)$: $x-2y+2z-6=0$ និងបន្ទាត់$(L)$: $\frac{x+1}{-1}=\frac{y-3}{2}=\frac{z+3}{-2}$ ។

១.ចូរបង្ហាញថា$(L)\perp(p)$ រួចគណនាកូអរដោនេចំណុចប្រសព្វ $M$ រវាងបន្ទាត់ $(L)$ ជាមួយប្លង់$(p)$ ។

២.តាង $A,B,C$ ជាចំណុចប្រសព្វរវាង$(p)$ជាមួយអ័ក្ស$(ox),(oy),(oz)$ រៀងគ្នា។ ចូរគណនា $\overrightarrow{AB}\times\overrightarrow{AC}$ រួចទាញរកផ្ទៃក្រឡានៃត្រីកោណ $ABC$ ។

៣.គណនាកូអរដោនេចំណុច $D$ ដោយដឹងថា $ABCD$ ជាប្រលេឡូក្រាម។

## ដំណោះស្រាយ

១.បង្ហាញថា$(L)\perp(p)$ រួចគណនាកូអរដោនេចំណុចប្រសព្វ $M$ រវាង$(L)$និង$(p)$ ៖

គេមានប្លង់$(p)$: $x-2y+2z-6=0$ និងបន្ទាត់$(L)$: $\frac{x}{-1}=\frac{y-3}{2}=\frac{z+3}{-2}$

វ៉ិចទ័រណរម៉ាល់នៃប្លង់$(p)$ គឺ $\vec{n}=(1,-2,2)$ ហើយវ៉ិចទ័រប្រាប់ទិសនៃបន្ទាត់$(L)$ គឺ $\vec{u}=(-1,2,-2)$ ។

គេបាន $\frac{a}{a'}=\frac{b}{b'}=\frac{c}{c'}=\frac{1}{-1}=\frac{-2}{2}=\frac{2}{-2}$ នោះ $\vec{n}$ និង$\vec{u}$ ជាវ៉ិចទ័រកូលីនេអ៊ែគ្នា។

ដូចនេះ $(L)\perp(p)$ ។

ម្យ៉ាងទៀតតាង $\frac{x}{-1}=\frac{y-3}{2}=\frac{z+3}{-2}=t$ នោះ $\begin{cases} x=-t \\ y=3+2t \\ z=-3-2t \end{cases}$ (1)

យក(1) ជំនួសក្នុង$(p)$ គេបាន៖

$$\begin{aligned}(-t)-2(3+2t)+2(-3-2t)-6&=0\\ -t-6-4t-6-4t-6&=0\\ -9t-18&=0\\ t&=-2\end{aligned}$$

យក$t=-2$ ជួសក្នុង(1) គេបានចំណុច $M(2,-1,1)$ ។

២.គណនា $\overrightarrow{AB}\times\overrightarrow{AC}$ រួចទាញរកផ្ទៃក្រឡានៃត្រីកោណ $ABC$

គេមាន $(p): x-2y+2z-6=0$

ចំពោះ $y=z=0$ នោះ $x-6=0$ ឬ $x=6$ គេបាន $A(6,0,0)$ ។

ចំពោះ $x=z=0$ នោះ $-2y-6=0$ ឬ $y=-3$ គេបាន $B(0,-3,0)$ ។

ចំពោះ $x=y=0$ នោះ $2z-6=0$ ឬ $z=3$ គេបាន $C(0,0,3)$ ។

គេមាន $\overrightarrow{AB}=(-6,-3,0)$ និង $\overrightarrow{AC}=(-6,0,3)$ ។

គេបាន $\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ -6 & -3 & 0\\ -6 & 0 & 3\end{vmatrix}=-9\vec{i}+18\vec{j}-18\vec{k}$ ។

ដូចនេះ $\overrightarrow{AB}\times\overrightarrow{AC}=(-9,18,-18)$ ។

ហើយផ្ទៃក្រឡាត្រីកោណ $ABC$ គឺ $S=\frac{1}{2}|\overrightarrow{AB}\times\overrightarrow{AC}|$

$S=\frac{1}{2}\sqrt{81+324+324}=\frac{27}{2}=13.5$ ឯកតាផ្ទៃ។

៣.គណនាកូអរដោនេចំណុច $D$ ដោយដឹងថា $ABCD$ ជាប្រលេឡូក្រាម




តាង $D(x_d,y_d,z_d)$ នោះ $\overrightarrow{AD}=(x_d-6,y_d,z_d)$ និង $\overrightarrow{BC}=(0,3,3)$ ។

ដោយ $ABCD$ ជាប្រលេឡូក្រាមនោះ $\overrightarrow{AD}=\overrightarrow{BC}$

សមមូល $\begin{cases}x_d-6=0\\ y_d=3\\ z_d=3\end{cases}$ ឬ $\begin{cases}x_d=6\\ y_d=3\\ z_d=3\end{cases}$

ដូចនេះ $D(6,3,3)$ ។

www.mathtoday.wordpress.com

## លំហាត់ទី៣២

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យវ៉ិចទ័រពីរ

$\vec{u}=2\vec{i}-\vec{j}$ និង $\vec{v}=2\vec{i}-2\vec{j}-\vec{k}$ ។

១.គណនា $\vec{n}=\vec{u}\times\vec{v}$ និង $|\vec{n}|$ ។

២.កំណត់សមីការប្លង់ $(p)$ កាត់តាមចំណុច $A(-1,2,-3)$ ហើយកែងនឹង $\vec{n}$ ។

៣.កំណត់សមីការស្វ៊ែ $(S)$ មានផ្ចិត $O$ ហើយប៉ះនឹងប្លង់ $(p)$ ។

## ដំណោះស្រាយ

**១.គណនា $\vec{n}=\vec{u}\times\vec{v}$ និង $|\vec{n}|$**

គេមាន $\vec{u}=2\vec{i}-\vec{j}$ និង $\vec{v}=2\vec{i}-2\vec{j}-\vec{k}$ ។

យើងបាន $\vec{n}=\vec{u}\times\vec{v}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 2 & -1 & 0\\ 2 & -2 & -1\end{vmatrix}$

$$=\begin{vmatrix}-1 & 0\\ -2 & -1\end{vmatrix}\vec{i}-\begin{vmatrix}2 & 0\\ 2 & -1\end{vmatrix}\vec{j}+\begin{vmatrix}2 & -1\\ 2 & -2\end{vmatrix}\vec{k}$$

$$=\vec{i}+2\vec{j}-2\vec{k}$$

ដូចនេះ $\vec{n}=(1,2,-2)$ និង $|\vec{n}|=\sqrt{1+4+4}=3$ ។

២.កំណត់សមីការប្លង់ $(p)$ កាត់តាមចំណុច $A(-1,2,-3)$ ហើយកែងនឹង $\vec{n}$

តាមរូបមន្ត $(p): a(x-x_A)+b(y-y_A)+c(z-z_A)=0$

ដោយ $A(-1,2,-3)$ និង $\vec{n}=(1,2,-2)$

គេបាន $(p): 1(x+1)+2(y-2)-2(z+3)=0$

ដូចនេះ $(p): x+2y-2z-9=0$ ។

៣.កំណត់សមីការស្វ៊ែ $(S)$ មានផ្ចិត $O$ ហើយប៉ះនឹងប្លង់ $(p)$

សមីការស្វ៊ែ $(S)$ ផ្ចិត $O$ មានរាង $(S): x^2+y^2+z^2=R^2$ ដែល $R$ ជាកាំ។

ដោយ $(S)$ ប៉ះនឹងប្លង់ $(p)$ នោះ $R=d(O,(p))$

គេបាន $R=\dfrac{|x_0+2y_0-2z_0-9|}{\sqrt{1+4+4}}=\dfrac{|0+0+0-9|}{3}=3$

ដូចនេះ $(S): x^2+y^2+z^2=9$ ។

www.mathtoday.wordpress.com

## លំហាត់ទី៣៣

ក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$ គេឲ្យបួនចំណុច

$A(1,2,3);B(2,3,-6);\ C(-2,1,-2)$ និង $D(0,4,0)$ ។

១.ចូរគណនាផលគុណវ៉ិចទ័រ $\overrightarrow{BC}\times\overrightarrow{BD}$ រួចទាញថាបីចំណុច $B,C,D$

មិនរត់ត្រង់គ្នា ។

គណនាផ្ទៃក្រលានៃត្រីកោណ $BCD$ រួចកំណត់សមីការប្លង់ $(BCD)$ ។

២.គណនាមាឌតេត្រាអ៊ែត $ABCD$ រួចទាញរកចម្ងាយពី $A$ ទៅប្លង់ $(BCD)$ ។

៣.$H$ ជាចំណោលកែងនៃ $A$ លើប្លង់បាត $(BCD)$ ។

កំណត់សមីការបន្ទាត់ $(AH)$ រួចរកកូអរដោនេ $H$ ។

## ដំណោះស្រាយ

**១)គណនាផលគុណវ៉ិចទ័រ $\overrightarrow{BC}\times\overrightarrow{BD}$ រួចទាញថាបីចំណុច $B,C,D$ មិនរត់ត្រង់គ្នា៖**

គេមាន $\overrightarrow{BC}=(-4\ ,-2\ ,\ 4)$ ; $\overrightarrow{BD}=(-2\ ,1\ ,\ 6)$

$$\text{គេបាន } \overrightarrow{BC}\times\overrightarrow{BD}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\-4&-2&4\\-2&1&6\end{vmatrix}=\begin{vmatrix}-2&4\\1&6\end{vmatrix}\vec{i}-\begin{vmatrix}-4&4\\-2&6\end{vmatrix}\vec{j}+\begin{vmatrix}-4&-2\\-2&1\end{vmatrix}\vec{k}$$

$$=-16\vec{i}+16\vec{j}-8\vec{k}$$

ដូចនេះ $\overrightarrow{BC}\times\overrightarrow{BD}=(-16\ ,16\ ,-8)$ ។

ដោយ $\overrightarrow{BC}\times\overrightarrow{BD}=(-16\ ,16\ ,-8)\neq\vec{O}=(0,0,0)$ នោះវ៉ិចទ័រ $\overrightarrow{BC}$ និង $\overrightarrow{BD}$

មិនកូលីនេអ៊ែគ្នា ។ ដូចនេះ $B,C,D$ មិនរត់ត្រង់គ្នា ។

គណនាផ្ទៃក្រលានៃត្រីកោណ $BCD$ ៖

តាមរូបមន្ត $S_{BCD}=\frac{1}{2}\left|\overrightarrow{BC}\times\overrightarrow{BD}\right|=\frac{1}{2}\sqrt{(-16)^2+16^2+(-8)^2}=12$ ( ឯកតាផ្ទៃ )។

កំណត់សមីការប្លង់ $(BCD)$ ៖

ប្លង់ $(BCD)$មានវ៉ិចទ័រណរម៉ាល់ $\vec{N}=\overrightarrow{BC}\times\overrightarrow{BD}=(-16\ ,16\ ,-8)$
ហើយកាត់តាម $B(2,3,-6)$ ។

តាមរូបមន្ត $(BCD): a(x-x_D)+b(y-y_D)+c(z-z_D)=0$

$$-16(x-2)+16(y-3)-8(z+6)=0$$
$$-16x+32+16y-48-8z-48=0$$
$$-16x+16y-8z-64=0$$

ដោយសម្រួលនឹង $-8$ គេបាន $(BCD): 2x-2y+z+8=0$ ។

២)គណនាមាឌតេត្រាអ៊ែត $ABCD$ ៖

តាមរូបមន្ត $V_{ABCD}=\frac{1}{6}\left|\left(\overrightarrow{BC}\times\overrightarrow{BD}\right).\overrightarrow{BA}\right|$

ដោយ $\overrightarrow{BC}\times\overrightarrow{BD}=(-16\ ,16\ ,-8)$ និង $\overrightarrow{BA}=(-1,-1,9)$ នោះ

$V_{BCDA}=\frac{1}{6}|16-16+72|=12$ ( ឯកតាមាឌ )

ទាញរកចម្ងាយពីចំណុច $A$ ទៅប្លង់$(BCD)$ ៖

តាមរូបមន្ត $V_{BCD}=\frac{1}{3}S_{BCD}\times d(A,(BCD))$

គេទាញ $d(A,(BCD)) = \frac{3V_{ABCD}}{S_{BCD}} = \frac{3\times 12}{12} = 3$ ( ឯកតាប្រវែង )។

៣) កំណត់សមីការបន្ទាត់$(AH)$រួចរកកូអរដោនេ $H$ ៖

វ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $(AH)$ គឺ $\vec{u} = (2,-2,1)$ ដែល $\vec{n} = (2,-2,1)$

ជាវ៉ិចទ័រណរម៉ាល់នៃប្លង់។

$(BCD): 2x - 2y + z + 8 = 0$ ព្រោះ $(AH) \perp (BCD)$ ។

តាមរូបមន្តសមីការប៉ារ៉ាម៉ែត្រ $(AH): \begin{cases} x = x_A + at \\ y = y_A + bt \\ z = z_A + ct \quad , t \in \mathbb{R} \end{cases}$

ដោយ $A(1,2,3)$ និង $\vec{u} = (2,-2,1)$

ដូចនេះ $(AH): \begin{cases} x = 1 + 2t \\ y = 2 - 2t \\ z = 3 + t \quad , t \in \mathbb{R} \end{cases}$ ។

រកកូអរដោនេ $H$ ៖

យកសមីការ $(AH)$ ជួសក្នុងសមីការប្លង់ $(BCD)$ គេបាន

$2(1+2t) - 2(2-2t) + 3 + t + 8 = 0$

សមមូល $2 + 4t - 4 + 4t + 3 + t + 8 = 0$

គេទាញ $t = -1$ យកជួសក្នុង $(AH)$ គេបាន $x = -1$ , $y = 4$ , $z = 2$ ។

ដូចនេះ $H(-1\ ,\ 4\ ,\ 2)$ ។

www.mathtoday.wordpress.com

## លំហាត់ទី៣៤

នៅក្នុងតម្រុយអរតូណម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$ មួយគេឲ្យមាន ចំណុច $A(0,2,1),B(2,1,-1),C(-4,5,3)$ និង $D(4,6,3)$ ។

១.ចូរស្រាយថា $\overrightarrow{AB}\times\overrightarrow{AC}=\overrightarrow{AD}$ រួចគណនាផ្ទៃក្រឡានៃ $\Delta ABC$ ។

២.កំណត់សមីការប្លង់ $(ABC)$ ។

៣.គណនា $(\overrightarrow{AB}\times\overrightarrow{AC}).\overrightarrow{AD}$ រួចទាញរកមាឌនៃតេត្រាអ៊ែត $ABCD$ ។

៤.ទាញរកចម្ងាយពីចំណុច $D$ ទៅប្លង់ $(ABC)$ ។

## ដំណោះស្រាយ

**១.ស្រាយថា $\overrightarrow{AB}\times\overrightarrow{AC}=\overrightarrow{AD}$ រួចគណនាផ្ទៃក្រឡានៃ $\Delta ABC$ ៖**

គេមាន $\overrightarrow{AB}=(2\ ,-1,-2)$ ,$\overrightarrow{AC}=(-4,3,2)$ និង $\overrightarrow{AD}=(4\ ,\ 4\ ,\ 2)$

គេបាន $$\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 2 & -1 & -2\\ -4 & 3 & 2\end{vmatrix}=4\,\vec{i}+4\,\vec{j}+2\,\vec{k}$$

ដូចនេះ $\overrightarrow{AB}\times\overrightarrow{AC}=\overrightarrow{AD}=(4,4,2)$ ។

**២.កំណត់សមីការប្លង់ $(ABC)$ ៖**

ប្លង់ $(ABC)$ មានវ៉ិចទ័រណរម៉ាល់ $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}=(4,4,2)$

តាមរូបមន្ត $(ABC): a(x-x_A)+b(y-y_A)+c(z-z_A)=0$

$$4(x-0)+4(y-2)+2(z-1)=0$$

ដូចនេះ $(ABC): 2x+2y+z-5=0$ ។

៣.គណនា $(\overrightarrow{AB}\times\overrightarrow{AC}).\overrightarrow{AD}$ រួចទាញរកមាឌនៃតេត្រាអ៊ែត $ABCD$ ៖

គេមាន $\overrightarrow{AB}\times\overrightarrow{AC}=\overrightarrow{AD}$ (តាមសម្រាយខាងលើ )

ដូចនេះ $(\overrightarrow{AB}\times\overrightarrow{AC}).\overrightarrow{AD}=|\overrightarrow{AD}|^2=16+16+4=36$ ។

តាមរូបមន្ត $V_{ABCD}=\frac{1}{6}\left|(\overrightarrow{AB}\times\overrightarrow{AC}).\overrightarrow{AD}\right|=\frac{1}{6}\times 36=6$ (ឯកតាមាឌ) ។

៤.ទាញរកចម្ងាយពីចំណុច $D$ ទៅប្លង់ $(ABC)$ ៖

គេមាន $V_{ABCD}=\frac{1}{3}S_{ABC}\times d(D,(ABC))$

ដែល $d(D,(ABC))=h$ ជាកម្ពស់នៃតេត្រាអ៊ែតគូសពីកំពូល $D$ ។

គេទាញ $d(D,(ABC))=\frac{3V_{ABCD}}{S_{ABC}}=\frac{3\times 6}{3}=6$ (ឯកតាប្រវែង) ។

www.mathtoday.wordpress.com

## លំហាត់ទី៣៥

ក្នុងតំរុយអរតូណរម៉ាល់ដែលមានទិសដៅវិជ្ជមាន $(0,\vec{i},\vec{j},\vec{k})$ គេឲ្យចំណុច

$A(0,0,2)$ ,$B(2,0,1)$ ,$C(2,2,3)$ និង $D(0,2,4)$ ។

១.បង្ហាញថាចតុកោណ $ABCD$ ជាប្រលេឡូក្រាម។

២.គណនាផលគុណវ៉ិចទរ័ $\overrightarrow{AB}\times\overrightarrow{AD}$រួចគណនាក្រឡាផ្ទៃប្រលេឡូក្រាម $ABCD$

៣.សរសេរសមីការប្លង់$(ABC)$និងសមីការប៉ារ៉ាម៉ែត្របន្ទាត់ $(L)$កែងទៅនឹងប្លង់ $(ABC)$ត្រង់ $D$។

៤.កំណត់កូអរដោនេនៃចំនុច $E$ បើគេដឹងថា $\overrightarrow{AE}=\frac{1}{2}\left(\overrightarrow{AB}\times\overrightarrow{AD}\right)$ ។

៥.គណនាមាឌរបស់ពីរ៉ាមីតដែលមានកំពស់$[AE]$ និងបាតជាចតុកោណ $ABCD$ ។

## ដំណោះស្រាយ

១. បង្ហាញថាចតុកោណ $ABCD$ ជាប្រលេឡូក្រាម ៖

$A(0,0,2)$ ,$B(2,0,1)$ ,$C(2,2,3)$ និង $D(0,2,4)$ ។

គេមាន $\overrightarrow{AB}(x_B-x_A,y_B-y_A,z_B-z_A)$

និង $\overrightarrow{CD}(x_D-x_C,y_D-y_C,z_D-z_C)$

នោះ $\overrightarrow{AB}(2,0,-1)$ និង $\overrightarrow{DC}(2,0,-1)$

ដោយ $\overrightarrow{AB}=\overrightarrow{DC}$ ( កូអរដោនេដូចគ្នា )

ដូចនេះ ចតុកោណ $ABCD$ ជាប្រលេឡូក្រាម។

២.គណនា $\overrightarrow{AB}\times\overrightarrow{AD}$ រួចគណនាក្រឡាផ្ទៃប្រលេឡូក្រាម $ABCD$

គេមាន $\overrightarrow{AB}(2,0,-1)$ និង $\overrightarrow{AD}(0,2,2)$

គេបាន $\overrightarrow{AB}\times\overrightarrow{AD}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 2 & 0 & -1\\ 0 & 2 & 2\end{vmatrix}=-2.\vec{i}-4.\vec{j}+4.\vec{k}$

ដូចនេះ $\overrightarrow{AB}\times\overrightarrow{AD}(-2,-4,4)$ ។

តាមរូបមន្តក្រឡាផ្ទៃប្រលេឡូក្រាម $ABCD$ ៖

$S_{ABCD}=\left\|\overrightarrow{AB}\times\overrightarrow{AD}\right\|=\sqrt{(-2)^2+(-4)^2+(4)^2}=6$ ( ឯកត្តាក្រឡាផ្ទៃ ) ។

**៣.សមីការប្លង់ $(ABC)$ និងសមីការប៉ារ៉ាម៉ែត្របន្ទាត់ $(L)$ កែងនឹងប្លង់ $(ABC)$ ត្រង់ $D$**

ដោយ $ABCD$ ជាប្រលេឡូក្រាមនោះបួនចំនុច $A,B,C,D$ នៅក្នុងប្លង់តែមួយ។

តាង $\overrightarrow{n}$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(ABC)$ នោះគេបាន៖

$\overrightarrow{n}=\overrightarrow{AB}\times\overrightarrow{AD}(-2,-4,4)$

សមីការប្លង់ $(ABC)$ អាចសរសេរតាមរូបមន្ត ៖

$(ABC): a(x-x_A)+b(y-y_A)+c(z-z_A)=0$

$(ABC): -2(x-0)-4(y-0)+4(z-4)=0$

$(ABC): -2x-4y+4z-16=0$

$(ABC): -x-2y+2z-8=0$

ម្យ៉ាងទៀតតាង $\overrightarrow{u}$ ជាវ៉ិចទ័រប្រាប់ទិសនៃ បន្ទាត់ $(L)$ កែងនឹងប្លង់ $(ABC)$ ត្រង់ $D$

គេបាន $\overrightarrow{u}=\overrightarrow{AB}\times\overrightarrow{AD}(-2,-4,4)$

តាមរូបមន្ត $(L):\begin{cases}x=x_D+at\\ y=y_D+bt\\ z=z_D+ct\quad ,t\in\mathbb{R}\end{cases}$

ដូចនេះ $(L):\begin{cases} x=-2t \\ y=2-4t \\ z=4+4t \quad ,t\in\mathbb{R} \end{cases}$

ឃ. កំណត់កូអរដោនេនៃចំនុច $E$ បើគេដឹងថា $\overrightarrow{AE}=\frac{1}{2}\left(\overrightarrow{AB}\times\overrightarrow{AD}\right)$




តាង $E(x_E,y_E,z_E)$ ។

គេមាន $\overrightarrow{AE}(x_E,y_E,z_E-2)$ និង $\overrightarrow{AB}\times\overrightarrow{AD}(-2,-4,4)$

ដោយ $\overrightarrow{AE}=\frac{1}{2}\left(\overrightarrow{AB}\times\overrightarrow{AD}\right)$ នាំឱ្យ $\begin{cases} x_E=-1 \\ y_E=-2 \\ z_E-2=2 \end{cases}$ ឬ $\begin{cases} x_E=-1 \\ y_E=-2 \\ z_E=4 \end{cases}$

ដូចនេះ $E(-1,-2,4)$ ។

ង. គណនាមាឌរបស់ពីរ៉ាមីតដែលមានកំពស់ $[AE]$ និងបាតជាចតុកោណ $ABCD$

យើងបាន $V=\frac{1}{3}S_{ABCD}\times AE$ ដោយ $S_{ABCD}=6$ និង $AE=3$

ដូចនេះ $V=6$ (ឯកតាមាឌ) ។

www.mathtoday.wordpress.com

## លំហាត់ទី៣៦

ក្នុងតម្រុយអរតូណរម៉ាល់ $(o,\vec{i},\vec{j},\vec{k})$ គេមានបួនចំណុច៖

$A(4,0,0)$ $B(0,-2,0)$ , $C(0,0,2)$ និង $D(4,2,2)$ ។

១.បង្ហាញថាចតុកោណ $ABCD$ ជាប្រលេឡូក្រាម ។

២.ចូរកំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(BC)$ និងសមីការនៃប្លង់កាត់តាមបី

ចំណុច $A,B$ និង $C$ ។

៣.យក $H$ ជាចំណោលកែងនៃ $A$ លើបន្ទាត់ $(BC)$ ។ រកកូអរដោនេនៃចំណុច

$H$ រួចគណនា $AH$ និងផ្ទៃក្រលាប្រលេឡូក្រាម $ABCD$ ។

៤.គេមានចំណុច $S(1,6,-6)$ ។ បង្ហាញថាបន្ទាត់ $(SA)$ កែងនឹងប្លង់ $(ABCD)$

រួចគណនាមាឌនៃពីរ៉ាមីត $SABCD$ ។

## ដំណោះស្រាយ

១.បង្ហាញថាចតុកោណ $ABCD$ ជាប្រលេឡូក្រាម

គេមាន $\overrightarrow{AD}=(0,2,2)$ និង $\overrightarrow{BC}=(0,2,2)$

ដោយ $\overrightarrow{AD}=\overrightarrow{BC}$ នោះ $ABCD$ ជាប្រលេឡូក្រាម ។

២.កំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(BC)$ ៖

បន្ទាត់ $(BC)$ មានវ៉ិចទ័រប្រាប់ទិស $\overrightarrow{BC}=(0,2,2)$

តាមរូបមន្ត $(BC):\begin{cases} x=x_B+at \\ y=y_B+bt \\ z=z_B+ct \quad , t\in\mathbb{R}\end{cases}$

ដូចនេះ $(BC):\begin{cases} x=0 \\ y=-2+2t \\ z=2t \quad ,t\in\mathbb{R}\end{cases}$

កំណត់សមីការនៃប្លង់កាត់តាមបីចំណុច $A,B$ និង $C$ ៖

តាង $(P): ax+by+cz+d=0$ ជាប្លង់កាត់តាមបីចំណុច $A,B$ និង $C$

នោះកូអរដោនេនៃចំណុច $A,B$ និង $C$ ផ្ទៀងផ្ទាត់សមីការ $(P)$

គេបានប្រព័ន្ធ $\begin{cases} 4a+d=0 \\ -2b+d=0 \\ 2c+d=0 \end{cases}$ នាំឲ្យ $a=-\dfrac{d}{4}$ , $b=\dfrac{d}{2}$ , $c=-\dfrac{d}{2}$

យក $a=-\dfrac{d}{4}$ , $b=\dfrac{d}{2}$ , $c=-\dfrac{d}{2}$ ជួសក្នុង $(P)$ គេបាន ៖

$-\dfrac{d}{4}x+\dfrac{d}{2}y-\dfrac{d}{2}z+d=0$ ឬ $(P): x-2y+2z-4=0$ ។

៣.រកកូអរដោនេនៃចំណុច $H$ រួចគណនា $AH$ និងផ្ទៃក្រលាប្រលេឡូក្រាម $ABCD$ ៖

តាង $H(x_H,y_H,z_H)$ ។

ដោយ $H\in(BC)$ នោះ $\begin{cases} x_H=0 \\ y_H=-2+2t \\ z_H=2t \end{cases}$ (1)

គេបាន $\overrightarrow{AH}=(-4\ ,\ -2+2t\ ,2t\ )$

ដោយ $\overrightarrow{AH}\perp\overrightarrow{BC}\Leftrightarrow\overrightarrow{AH}.\overrightarrow{BC}=0$

គេបាន $\overrightarrow{AH}.\overrightarrow{BC}=(0)(-4)+2(-2+2t)+2(2t)=0$ នោះ $t=\dfrac{1}{2}$

យក $t=\dfrac{1}{2}$ ជួសក្នុង (1) គេបាន $x_H=0, y_H=-2+1=-1$ , $z_H=1$ ។

ដូចនេះ $H(0,-1,1)$ ។

ហើយ $AH=\sqrt{(-4)^2+(-1)^2+1^2}=3\sqrt{2}$ និង $BC=\sqrt{0+4+4}=2\sqrt{2}$

គេបាន $S_{ABCD}=AH.BC=(3\sqrt{2})(2\sqrt{2})=12$ ។

ដូចនេះ $AH=3\sqrt{2}$ , $S_{ABCD}=12$ (ឯកតាផ្ទៃ)។

៤. បង្ហាញថាបន្ទាត់ $(SA)$ កែងនឹងប្លង់ $(ABCD)$ ៖

$\overrightarrow{SA}=(3\,,-6,6)$ , $\overrightarrow{AB}=(-4,-2,0)$ , $\overrightarrow{AD}=(0,2,2)$

គេមាន $\overrightarrow{SA}.\overrightarrow{AB}=-12+12+0=0 \Leftrightarrow \overrightarrow{SA}\perp\overrightarrow{AB}$

ហើយ $\overrightarrow{SA}.\overrightarrow{AD}=0-12+12=0 \Leftrightarrow \overrightarrow{SA}\perp\overrightarrow{AD}$

នោះគេទាញបាន $(SA)\perp(ABCD)$ ។

**គណនាមាឌនៃពីរ៉ាមីត** $SABCD$ ៖

តាមរូបមន្ត $V_{SABCD}=\frac{1}{3}S_{ABCD}\times SA$ ដោយ $SA=\sqrt{9+36+36}=9$

ដូចនេះ $V_{SABCD}=\frac{1}{3}\times 12\times 9=36$ (ឯកតាមាឌ)។

www.mathtoday.wordpress.com

## លំហាត់ទី៣៧

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$ គេឲ្យប្លង់

$(P): x+2y+2z-4=0$ ។ តាង $A,B$ និង $C$ ជាចំណុចប្រសព្វរវាងប្លង់ $(P)$

ជាមួយអក្ស័ $(ox)$ , $(oy)$ និង $(oz)$ រៀងគ្នា ។

១.ចូរគណនាកូអរដោនេនៃចំណុច $A,B$ និង $C$ រួចសង់ចំណុចនេះ។

២.គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$ រួចរកផ្ទៃក្រឡានៃ $\Delta ABC$ ។

៣.គណនាផលគុណស្កាលែ $(\overrightarrow{AB}\times\overrightarrow{AC})\cdot\overrightarrow{AO}$ ។ទាញរកមាឌចតុមុខ $OABC$

៤.សរសេរសមីការស្វ៊ែរចារឹកក្រៅចតុមុខ $OABC$ រួចបញ្ជាក់

កូអរដោនេផ្ចិត និងកាំរបស់ស្វ៊ែរ $(S)$ ផង។

## ដំណោះស្រាយ

**១.គណនាកូអរដោនេនៃចំណុច $A,B$ និង $C$ រួចសង់ចំណុចនេះ**

គេមាន $(P): x+2y+2z-4=0$

ចំពោះ $y=z=0$ នោះ $x-4=0 \Leftrightarrow x=4$ គេបាន $A(4,0,0)$ ។

ចំពោះ $x=z=0$ នោះ $2y-4=0 \Leftrightarrow y=2$ គេបាន $B(0,2,0)$ ។

ចំពោះ $x=y=0$ នោះ $2z-4=0 \Leftrightarrow z=2$ គេបាន $C(0,0,2)$ ។

**២.គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$ រួចរកផ្ទៃក្រឡានៃ $\Delta ABC$**

គេមាន $\overrightarrow{AB}=(-4,2,0)$ , $\overrightarrow{AC}=(-4,0,2)$




យើងបាន $\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ -4 & 2 & 0\\ -4 & 0 & 2\end{vmatrix}=4\,\vec{i}+8\,\vec{j}+8\,\vec{k}$

ដូចនេះ $\overrightarrow{AB}\times\overrightarrow{AC}=(4,8,8)$ ។

តាមរូបមន្តផ្ទៃក្រឡាត្រីកោ $S_{ABC}=\frac{1}{2}|\overrightarrow{AB}\times\overrightarrow{AC}|=\frac{1}{2}\sqrt{4^2+8^2+8^2}=6$

ដូចនេះ $S_{ABC}=6$ ខ្នាតផ្ទៃក្រឡា ។

៣.គណនាផលគុណស្កាលែ $(\overrightarrow{AB}\times\overrightarrow{AC})\cdot\overrightarrow{AO}$

គេមាន $\overrightarrow{AO}=(-4,0,0)$ និង $\overrightarrow{AB}\times\overrightarrow{AC}=(4,8,8)$

យើងបាន $(\overrightarrow{AB}\times\overrightarrow{AC})\cdot\overrightarrow{AO}=(-4)(4)+(0)(8)+(0)(8)=-16$

ដូចនេះ $(\overrightarrow{AB}\times\overrightarrow{AC})\cdot\overrightarrow{AO}=-16$ ។

ទាញរកមាឌចតុមុខ $OABC$ ៖

តាមរូបមន្ត $V_{OABC}=\frac{1}{6}\left|(\overrightarrow{AB}\times\overrightarrow{AC})\cdot\overrightarrow{AO}\right|=\frac{16}{6}=\frac{8}{3}$

ដូចនេះ $V_{OABC}=\frac{8}{3}$ ( ខ្នាតមាឌ )។

៤.សរសេរសមីការស្តង់ដានៃស្វ៊ែ$(S)$ ចារឹកក្រៅចតុមុខ $OABC$ ៖

តាង$(S): x^2+y^2+z^2+ax+by+cz+d=0$ ជាសមីការទូទៅនៃស្វ៊ែ។

ដោយស្វ៊ែ$(S)$ ចារឹកក្រៅចតុមុខ$OABC$នោះកូអរដោនេនៃចំណុច

$O,A,B,C$ ផ្ទៀងផ្ទាត់នឹងសមីការ$(S)$ ។

គេមាន$O(0,0,0)$ , $A(4,0,0)$, $B(0,2,0)$ ,$C(0,0,2)$

គេបាន $\begin{cases} d=0 \\ 16+4a+d=0 \\ 4+2b+d=0 \\ 4+2c+d=0 \end{cases}$ សមមូល $\begin{cases} a=-4 \\ b=-2 \\ c=-2 \\ d=0 \end{cases}$

គេបាន $(S): x^2+y^2+z^2-4x-2y-2z=0$

ដូចនេះ $(S):(x-2)^2+(y-1)^2+(z-1)^2=6$ ។

បញ្ជាក់កូអរដោនេផ្ចិត និងកាំរបស់ស្វ៊ែ$(S)$៖

គេមាន $(S):(x-2)^2+(y-1)^2+(z-1)^2=6=\left(\sqrt{6}\right)^2$

ដូចនេះកូអរដោនេផ្ចិត$I(2,1,1)$ និងកាំ$R=\sqrt{6}$ ។

www.mathtoday.wordpress.com

## លំហាត់ទី៣៨

ក្នុងតម្រុយអរតូណាម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$ គេមានចំណុច $A(1,2,3)$ និងប្លង់ $(\alpha): x+2y-2z-8=0$ ។

១.កំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(\Delta)$ គូសចេញពីចំណុច $A$ ហើយកែងនឹងប្លង់ $(\beta)$ ត្រង់ចំណុច $H$ ។

២.គណនាកូអរដោនេនៃចំណុច $H$ និងចំណុច $A'$ឆ្លុះគ្នានឹង $A$ ធៀបនឹង$(\alpha)$ ។

៣.កំណត់សមីការប្លង់ $(\beta)$ កាត់តាមចំណុច $A'$ ហើយស្របនឹងប្លង់$(\alpha)$ ។

## ដំណោះស្រាយ

**១.កំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(\Delta)$ ៖**

ប្លង់ $(\alpha): x+2y-2z-8=0$ មានវ៉ិចទ័រណរម៉ាល់ $\vec{n}=(1,2,-2)$

ដោយបន្ទាត់ $(\Delta)\perp(\alpha)$ នោះ $\vec{n}=(1,2,-2)$ ជាវ៉ិចទ័រប្រាប់ទិសនៃ $(\Delta)$ ដូចនេះសមីការបន្ទាត់ $(\Delta)$ កាត់តាម $A(1,2,3)$ សរសេរ ៖

$$(\Delta):\begin{cases} x=1+t \\ y=2+2t \\ z=3-2t \quad ; t\in\mathbb{R}\end{cases}$$

**២.គណនាកូអរដោនេនៃចំណុច $H$ និងចំណុច $A'$**

យកសមីការ $(\Delta)$ ជួសក្នុង $(\alpha)$ គេបាន ៖

$$(1+t)+2(2+2t)-2(3-2t)-8=0$$
$$1+t+4+4t-6+4t-8=0$$
$$9t-9=0$$

គេទាញបាន $t=\frac{9}{9}=1$ យកជួសក្នុងសមីការ $(\Delta)$ គេបាន $H(2,4,1)$ ។

ហើយដោយចំណុច $A'$ ឆ្លុះគ្នានឹង $A$ ធៀបនឹងប្លង់ $(\alpha)$ នោះចំណុច $H$

ជាចំណុចកណ្តាលនៃ $A$ និង $A'$ ។

គេបាន $x_{A'}=2x_H-x_A=4-1=3$ , $y_{A'}=2y_H-y_A=8-2=6$

និង $z_{A'}=2z_H-z_A=2-3=-1$ ។ដូចនេះ $A'(3,6,-1)$ ។

៣.កំណត់សមីការប្លង់ $(\beta)$ ៖

ដោយ $(\beta)//(\alpha)$ នោះ $\vec{n}=(1\ ,\ 2\ ,\ -2)$ ជាវ៉ិចទ័រណរម៉ាល់នៃ $(\beta)$

ដោយ $(\beta)$កាត់តាមចំណុច $A'(3,6,-1)$ នោះគេបាន

$$(\beta):1.(x-3)-2(y-6)+2(z+1)=0$$
$$(\beta):x-3-2y+12+2z+2=0$$
$$(\beta):x-2y+2z+11=0$$

ដូចនេះ $(\beta):x-2y+2z+11=0$ ។

www.mathtoday.wordpress.com

## លំហាត់ទី៣៩

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$ គេឲ្យពីរចំណុច $A(1,-2,2)$ និង $B(2,2,1)$ ។

១.គណនា $\overrightarrow{OA}.\overrightarrow{OB}$ , $|\overrightarrow{OA}|$ និង $|\overrightarrow{OB}|$ រួចរកប្រភេទនៃត្រីកោណ $OAB$ និងគណនាផ្ទៃក្រឡា $\Delta ABC$ ។

២.ចូររកកូអរដោនេនៃចំណុច $C$ ជាកំពូលនៃការេ $OACB$ ។

៣.គណនាផលគុណវិចទ័រ $\overrightarrow{CA}\times\overrightarrow{CB}$ រួចគណនាផ្ទៃក្រឡា $\Delta CAB$

៤.ចូរសរសេរសមីការប្លង់ $(ABC)$ និងសមីការឆ្លុះនៃបន្ទាត់ $(AB)$ ។

៥.គេឲ្យចំណុច $S(-1,5,1)$ ។គណនាមាឌតេត្រាអ៊ែត $SABC$ ។

## ដំណោះស្រាយ

**១.គណនា $\overrightarrow{OA}.\overrightarrow{OB}$ , $|\overrightarrow{OA}|$ និង $|\overrightarrow{OB}|$ រួចរកប្រភេទនៃត្រីកោណ $OAB$ និងគណនាផ្ទៃក្រឡារបស់ត្រីកោណនេះ**

គេមាន $A(1,-2,2)$ និង $B(2,2,1)$ នោះយើងបាន $\overrightarrow{OA}=(1,-2,2)$ និង $\overrightarrow{OB}=(2,2,1)$ ។

យើងបាន $\overrightarrow{OA}.\overrightarrow{OB}=(1)(2)+(-2)(2)+(2)(1)=0$

ហើយ $|\overrightarrow{OA}|=\sqrt{1+4+4}=3$ និង $|\overrightarrow{OB}|=\sqrt{4+4+1}=3$ ដោយ $\overrightarrow{OA}.\overrightarrow{OB}=0 \Leftrightarrow \overrightarrow{OA}\perp\overrightarrow{OB}$ និង $OA=OB=3$

ដូចនេះ $OAB$ ជាត្រីកោណកែងសមបាតកំពូល $O$ ។

ផ្ទៃក្រឡានៃត្រីកោណគឺ $S=\frac{1}{2}OA.OB=\frac{1}{2}\times3\times3=\frac{9}{2}$ ។

២.រកកូអរដោនេនៃចំណុច $C$ ជាកំពូលនៃការេ $OACB$




តាង $C(x_c,y_c,z_c)$ ជាកំពូលនៃការេ $OACB$ ។ គេមាន $\overrightarrow{AC}=(x_c-1,y_c+2,z_c-2)$ និង

$\overrightarrow{OB}=(2,2,1)$ ដោយ $\overrightarrow{AC}=\overrightarrow{OB}$ នោះ $\begin{cases} x_c-1=2 \\ y_c+2=2 \\ z_c-2=1 \end{cases}$ ឬ $\begin{cases} x_c=3 \\ y_c=0 \\ z_c=3 \end{cases}$ ។ ដូចនេះ $C(3,0,3)$

។

៣.គណនាផលគុណវ៉ិចទ័រ $\overrightarrow{CA}\times\overrightarrow{CB}$ រួចគណនាផ្ទៃក្រឡា $\Delta CAB$

គេមាន $A(1,-2,2)$ , $B(2,2,1)$ និង $C(3,0,3)$

នោះយើងបាន $\overrightarrow{CA}=(-2,-2,-1)$ , $\overrightarrow{CB}=(-1,2,-2)$

ដូចនេះ $\overrightarrow{CA}\times\overrightarrow{CB}=\begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ -2 & -2 & -1 \\ -1 & 2 & -2 \end{vmatrix}=6\vec{i}-3\vec{j}-6\vec{k}$ ។

ផ្ទៃក្រឡានៃ $\Delta CAB$ គឺ $S=\frac{1}{2}|\overrightarrow{CA}\times\overrightarrow{CB}|=\frac{1}{2}\sqrt{36+9+36}=\frac{9}{2}$ ។

ដូចនេះ $S_{CAB}=\frac{9}{2}$ ឯកតាផ្ទៃ។

៤.សរសេរសមីការប្លង់ $(ABC)$ និងសមីការឆ្លុះនៃបន្ទាត់ $(AB)$

វ៉ិចទ័រនរម៉ាល់នៃប្លង់ $(ABC)$ គឺ $\overrightarrow{CA}\times\overrightarrow{CB}=6\vec{i}-3\vec{j}-6\vec{k}$

តាមរូបមន្ត $(ABC): a(x-x_A)+b(y-y_A)+c(z-z_A)=0$

គេបាន $6(x-1)-3(y+2)-6(z-2)=0$

ដូចនេះ $(ABC):\ 2x-y-2z=0$ ។

៥.គណនាមាឌតេត្រាអ៊ែត $SABC$ ៖




តាមរូបមន្ត $V=\frac{1}{6}\left|\left(\overrightarrow{CA}\times\overrightarrow{CB}\right).\overrightarrow{CS}\right|$ ដោយ $\begin{cases}\overrightarrow{CA}\times\overrightarrow{CB}=(6,-3,-6)\\ \overrightarrow{CS}=(-4,5,-2)\end{cases}$

យើងបាន $V=\frac{1}{6}\left|-24-15+12\right|=\frac{9}{2}$ ។

ដូចនេះ $V=\frac{9}{2}$ ឯកតាមាឌ ។

www.mathtoday.wordpress.com

## លំហាត់ទី៤០

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន$\left(o,\vec{i},\vec{j},\vec{k}\right)$គេមានចំណុច $A(1,1,-1), B(4,-1,-3), C(-2,5,2)$ និង $D(3,2,7)$ ។

១.គណនាផលគុណវ៉ិចទ័រ$\overrightarrow{AB}\times\overrightarrow{AC}$រួចទាញថាបីចំណុច$A,B,C$មិនរត់ត្រង់គ្នា។

២.គណនាផ្ទៃក្រឡានៃត្រីកោណ$ABC$ ។

៣.សរសេរសមីការប្លង់$(ABC)$ និងសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(L)$គូសចេញពី$D$ ហើយកែងនិងប្លង់$(ABC)$។

៤.គណនាកូអរដោនេនៃចំណុច$H$ជាប្រសព្វរវាងបន្ទាត់$(L)$និងប្លង់$(ABC)$។

៥.កំណត់មាឌតេត្រាអ៊ែត$ABCD$រួចទាញរកចម្ងាយពីចំណុច$D$ទៅប្លង់$(ABC)$។

## ដំណោះស្រាយ

**១.គណនា $\overrightarrow{AB}\times\overrightarrow{AC}$រួចទាញថាបីចំណុច$A,B,C$មិនរត់ត្រង់គ្នា**

យើងមាន $A(1,1,-1), B(4,-1,-3), C(-2,5,2)$ និង $D(3,2,7)$

យើងបាន $\overrightarrow{AB}=(3,-2,-2)$ និង $\overrightarrow{AC}=(-3,4,3)$

នោះ $\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 3 & -2 & -2\\ -3 & 4 & 3\end{vmatrix}=2\vec{i}-3\vec{j}+6\vec{k}$ ។

ដូចនេះ $\overrightarrow{AB}\times\overrightarrow{AC}=2\vec{i}-3\vec{j}+6\vec{k}$ ។

ម្យ៉ាងទៀតដោយ$\overrightarrow{AB}\times\overrightarrow{AC}=2\vec{i}-3\vec{j}+6\vec{k}\neq\vec{O}$ នោះ$\overrightarrow{AB}$ និង$\overrightarrow{AC}$ ជាវ៉ិចទ័រមិនកូលីនេអ៊ែគ្នា។ ដូចនេះបីចំណុច$A,B,C$មិនរត់ត្រង់គ្នា ។

២.គណនាផ្ទៃក្រឡានៃត្រីកោណ $ABC$ ៖

តាមរូបមន្តផ្ទៃក្រឡាត្រីកោណ $ABC$ គឺ $S=\frac{1}{2}\left|\overrightarrow{AB}\times\overrightarrow{AC}\right|$

ដោយ $\overrightarrow{AB}\times\overrightarrow{AC}=2\vec{i}-3\vec{j}+6\vec{k}$ នោះ $\left|\overrightarrow{AB}\times\overrightarrow{AC}\right|=\sqrt{4+9+36}=7$ ។

ដូចនេះ $S=\frac{7}{2}=3.5$ (ឯកតាផ្ទៃក្រឡា)។

៣.សរសេរសមីការប្លង់ $(ABC)$ និងសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(L)$៖

វ៉ិចទ័រណរម៉ាល់នៃប្លង់ $(ABC)$ គឺ $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}=2\vec{i}-3\vec{j}+6\vec{k}$ ។

តាមរូបមន្ត $(ABC):a(x-x_a)+b(y-y_a)+c(z-z_a)=0$ ដោយ $A(1,1,-1)$

គេបាន $2(x-1)-3(y-1)+6(z+1)=0$

ដូចនេះ $(ABC):\ 2x-3y+6z+7=0$ ។

ម្យ៉ាងទៀតដោយ $(L)\perp(ABC)$ នោះ $\vec{u}=\overrightarrow{AB}\times\overrightarrow{AC}=(2,-3,6)$ ជាវ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $(L)$ កាត់តាម $D(3,2,7)$ ហើយកែងនិងប្លង់ $(ABC)$ ។

ដូចនេះសមីការបន្ទាត់ $(L):\begin{cases}x=3+2t\\y=2-3t\\z=7+6t\end{cases}$ ដែល $t\in\mathbb{R}$ ជាប៉ារ៉ាម៉ែត្រ។

៤.គណនាកូអរដោនេនៃចំណុច $H$ ជាប្រសព្វរវាងបន្ទាត់ $(L)$ និងប្លង់ $(ABC)$



គេមាន $(L):\begin{cases} x=3+2t \\ y=2-3t \\ z=7+6t \end{cases}$ និង $(ABC):2x-3y+6z+7=0$

យកសមីការ $(L)$ ជំនួសក្នុង $(ABC)$ គេបាន៖

$2(3+2t)-3(2-3t)+6(7+6t)+7=0$ សមមូល $t=-1$ ។

យក $t=-1$ ជំនួសក្នុងសមីការ $(L)$ គេបាន $H(1,5,1)$ ។

**៨.កំណត់មាឌតេត្រាអ៊ែត $ABCD$ រួចទាញរកចម្ងាយពីចំណុច $D$ ទៅប្លង់ $(ABC)$៖**

តាមរូបមន្ត $V=\frac{1}{6}\left|(\overrightarrow{AB}\times\overrightarrow{AC})\cdot\overrightarrow{AD}\right|$ ដោយ $\overrightarrow{AB}\times\overrightarrow{AC}=(2,-3,6)$

និង $\overrightarrow{AD}=(2,1,8)$ នោះ $V=\frac{1}{6}\left|(2)(2)+(-3)(1)+(6)(8)\right|=\frac{49}{6}$ ។

ដូចនេះ $V=\frac{49}{6}$ (ឯកតាមាឌ)។

ម្យ៉ាងទៀត $V=\frac{1}{3}S\times d(D,(ABC))$ នោះ $d\left(D,(ABC)\right)=\frac{3V}{S}=\frac{3\times\frac{49}{6}}{\frac{7}{2}}=7$ ។

ដូចនេះ $d\left(D,(ABC)\right)=7$ (ឯកតាមាឌ)។

www.mathtoday.wordpress.com

## លំហាត់ទី៤១

ក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$

គេឲ្យប្លង់ $(P): x+2y-2z+1=0$ និងចំណុច $A(2,4,1)$ និង $B(-2,8,3)$ ។

$(Q)$ ជាប្លង់កាត់តាមពីរចំណុច $A$ និង $B$ ហើយកែងនិងប្លង់ $(P)$ ។

$(L)$ ជាបន្ទាត់ប្រសព្វរវាងប្លង់ $(P)$ និងប្លង់ $(Q)$ ។

១.ចូររកសមីការប្លង់ $(Q)$ និងសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(L)$ ។

២. $H$ ជាជើងនៃចំណោលកែងចំណុច $A$ លើបន្ទាត់ $(L)$ ហើយ $A'$ ជាចំណុច

ឆ្លុះគ្នានៃ $A$ ធៀបនិងបន្ទាត់ $(L)$ ។គណនាកូអរដោនេនៃចំណុច $H$ និង $A'$ ។

៣.រកកូអរដោនេនៃចំណុច $M$ ស្ថិតនៅលើបន្ទាត់ $(L)$ ដោយដឹងថា $AM+BM$

មានតម្លៃអប្បបរមា ។

## ដំណោះស្រាយ

១.រកសមីការប្លង់ $(Q)$ និងសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(L)$

វ៉ិចទ័រណរម៉ាល់របស់ប្លង់ $(P): x+2y-2z+1=0$ គឺ $\vec{n}_P=(1,2,-2)$

វ៉ិចទ័រណរម៉ាល់របស់ប្លង់ $(Q)$ កាត់តាមពីរចំណុច $A$ និង $B$ ហើយកែងនិងប្លង់ $(P)$ គឺ

$\vec{n}_Q=\vec{n}_P\times\overrightarrow{AB}$

ដោយ $A(2,4,1)$ និង $B(-2,8,3)$ នោះ $\overrightarrow{AB}=(-4,4,2)$ ។

គេបាន $\vec{n}_Q=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 1 & 2 & -2\\ -4 & 4 & 2\end{vmatrix}=12\vec{i}+6\vec{j}+12\vec{k}$

សមីការប្លង់ $(Q)$ អាចសរសេរ $12(x-2)+6(y-4)+12(z-1)=0$ ឬ

$2x+y+2z-10=0$

ដូចនេះ $(Q): 2x+y+2z-10=0$ ។

ម្យ៉ាងទៀតសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(L)$ ជាប្រសព្វរវាងប្លង់ $(P)$ និងប្លង់ $(Q)$ គឺជាសំណុំចម្លើយនៃប្រព័ន្ធ

$\begin{cases} x+2y-2z+1=0 \\ 2x+y+2z-10=0 \end{cases}$ យក $x=t\in\mathbb{R}$ គេបាន $\begin{cases} t+2y-2z+1=0 & (1) \\ 2t+y+2z-10=0 & (2) \end{cases}$

បូកសមីការពីរនេះគេបាន $3t+3y-9=0$ នោះ $y=3-t$ យកជួសក្នុង $(2)$ គេបាន

$2t+3-t+2z-10=0$ គេទាញ $z=\frac{7}{2}-\frac{t}{2}$ ។

ដូចនេះ $(L): \begin{cases} x=t \\ y=3-t \\ z=\frac{7}{2}-\frac{t}{2} \end{cases}, t\in\mathbb{R}$

២.គណនាកូអរដោនេនៃចំណុច $H$ និង $A'$



តាង $H(x_H, y_H, z_H)$ ជាចំណុចត្រូវរក។ដោយ $H \in (L)$ នោះកូអរដោនេនៃ $H$ ត្រូវផ្ទៀងផ្ទាត់នឹងសមីការនៃបន្ទាត់ $(L)$ គឺ

$$\begin{cases} x_H = t \\ y_H = 3 - t \quad (1) \\ z_H = \dfrac{7}{2} - \dfrac{t}{2} \end{cases}$$

គេមាន $\overrightarrow{AH} = \left(t-2, -t-1, \dfrac{5}{2} - \dfrac{t}{2}\right)$ ហើយវ៉ិចទ័រប្រាប់ទិសនៃ $(L)$ គឺ

$\vec{u}_L = \left(1, -1, -\dfrac{1}{2}\right)$

ដោយ $\overrightarrow{AH} \perp (L)$ និង $\vec{u}_L // (L)$ នោះ $\overrightarrow{AH} \perp \vec{u}_L \Leftrightarrow \overrightarrow{AH}.\vec{u}_L = 0$

គេបាន $(1)(t-2) + (-1)(-t-1) + \left(-\dfrac{1}{2}\right)\left(\dfrac{5}{2} - \dfrac{t}{2}\right) = 0$

$$t - 2 + t + 1 - \frac{5}{4} + \frac{t}{4} = 0$$

$$-\frac{9}{4} + \frac{9t}{4} = 0$$

គេទាញបាន $t = 1$ យកជួសក្នុង $(1)$ នោះ $H(1,2,3)$ ។

ម្យ៉ាងទៀតដោយ $A'$ ជាចំណុចឆ្លុះគ្នានៃ $A$ ធៀបនិងបន្ទាត់ $(L)$ នោះ $H$ ជាចំណុចកណ្តាលនៃ $[AA']$៖

គេបាន $\begin{cases} x_{A'} = 2x_H - x_A = 2 - 2 = 0 \\ y_{A'} = 2y_H - y_A = 4 - 4 = 0 \\ z_{A'} = 2z_H - z_A = 6 - 1 = 5 \end{cases}$

ដូចនេះ $H(1,2,3)$ និង $A'(0,0,5)$ ។

៣.រកកូអរដោនេចំណុច $M$ នៅលើ $(L)$ ដោយដឹងថា $AM+BM$ មានតម្លៃអប្បបរមា ៖

តាង $M_0$ ជាប្រសព្វរវាងបន្ទាត់ $(BA')$ និងបន្ទាត់ $(L)$ ។

ចំពោះគ្រប់ចំណុច $M\in(L)$ គេមាន $AM+BM\geq AM_0+BM_0=BM_0+M_0A'$

ដូចនេះដើម្បីឲ្យ $AM+BM$

មានតម្លៃអប្បបរមាលុះត្រាតែចំណុច $M$ ត្រួតស៊ីគ្នាជាមួយនឹងចំណុច $M_0$ គឺ $M\equiv M_0$ ។

សមីការបន្ទាត់ $(BA'):\dfrac{x-x_{A'}}{x_{A'}-x_B}=\dfrac{y-y_{A'}}{y_{A'}-y_B}=\dfrac{z-z_{A'}}{z_{A'}-z_B}$

ដោយ $A'(0,0,5)$ និង $B(-2,8,3)$

នោះ $(BA'):\dfrac{x}{-2}=\dfrac{y}{8}=\dfrac{z-5}{-2}$ ឬ នោះ $(BA'):\dfrac{x}{-1}=\dfrac{y}{4}=\dfrac{z-5}{-1}$

តាង $\dfrac{x}{-1}=\dfrac{y}{4}=\dfrac{z-5}{-1}=u$ នោះ $(BA'):\begin{cases}x=-u\\y=4u\\z=-u+5\quad,u\in\mathbb{R}\end{cases}$

សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(L)$ គឺ $(L):\begin{cases}x=t\\y=3-t\\z=\dfrac{7}{2}-\dfrac{t}{2}\quad,t\in\mathbb{R}\end{cases}$

ផ្ទឹមសមីការ $(BA')$ និង $(L)$ គេបាន $\begin{cases}-u=t\\4u=3-t\\-u+5=\dfrac{7}{2}-\dfrac{t}{2}\end{cases}$ សមមូល $\begin{cases}-u-t=0\\4u+t=3\\-2u+t=-3\end{cases}$

នោះ $u=1,t=-1$ ។យក $u=1$ ជួសក្នុងសមីការ $(BA')$ គេបានចំណុចប្រសព្វ

រវាង $(BA')\&(L)$ គឺ $M_0(-1,4,4)$ ។

ដូចនេះ $AM+BM$ មានតម្លៃអប្បបរមាលុះត្រាតែ $M\equiv M_0(-1,4,4)$ ។

## លំហាត់ទី៤២

គេឲ្យប្លង់ $(p): x+2y-2z+1=0$ និងចំណុចពីរ $A(2,4,1)$ និង $B(6,0,-1)$
ចូររកកូអរដោនេនៃចំណុច $M$ ស្ថិតនៅក្នុងប្លង់ $(p)$ ដោយដឹងថា $MA+MB$
មានតម្លៃអប្បរមា ។

## ដំណោះស្រាយ

រកកូអរដោនេនៃចំណុច $M$

តាង $(L)$ ជាបន្ទាត់កាត់តាម $A$ ហើយកែងនិងប្លង់ $(p)$ ត្រង់ $(H)$ នោះវ៉ិចទ័រនរម៉ាល់
$\vec{n}=(1,2,-2)$ ជាវ៉ិចទ័រប្រាប់ទិសនៃបន្ទាត់។




សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់អាចសរសេរ $(L):\begin{cases} x=2+t \\ y=4+2t \\ z=1-2t \end{cases}, t\in\mathbb{R}$

យកសមីការ$(L)$ជួសក្នុង$(p)$គេបាន៖

$$(2+t)+2(4+2t)-2(1-2t)+1=0$$
$$2+t+8+4t-2+4t+1=0$$
$$9t+9=0$$
$$t=-1$$

យក$t=-1$ជួសក្នុង$(L)$គេបាន $\begin{cases} x=1 \\ y=2 \\ z=3 \end{cases}$ នោះ $H(1,2,3)$ ។

យក $A'$ជាចំណុចឆ្លុះគ្នានៃ $A$ធៀបនិងប្លង់$(p)$នោះ$H$ ជាចំណុចកណ្តាលនៃ $[AA']$ ។ គេបាន $\begin{cases} x_{A'}=2x_H-x_A=2-2=0 \\ y_{A'}=2y_H-y_A=4-4=0 \\ z_{A'}=2z_H-z_A=6-1=5 \end{cases}$ នោះ $A'(0,0,5)$ ។

យក $M_0$ ជាប្រសព្វរវាងបន្ទាត់$(BA')$និងប្លង់$(p)$ ។

ចំពោះគ្រប់ចំណុច$M\in(p)$ គេមាន ៖

$$AM+BM\geq AM_0+BM_0=BM_0+M_0A'$$

ដូចនេះដើម្បីឲ្យ $AM+BM$ មានតម្លៃអប្បបរមាលុះត្រាតែ $M\equiv M_0$ ។

កូអរដោនេនៃចំណុច $M_0$ ជាប្រសព្វរវាងបន្ទាត់$(BA')$និងប្លង់$(p)$ ។

បន្ទាត់$(BA')$មានវ៉ិចទ័រប្រាប់ទិស $\overrightarrow{BA'}=(-6,0,6)$នោះសមីការប៉ារ៉ាម៉ែត្រ

របស់វាអាចសរសេរ$(BA')$: $\begin{cases} x=6-6t \\ y=0 \\ z=-1+6t \ , t\in\mathbb{R} \end{cases}$

យកសមីការ$(BA')$ជួសក្នុង$(p)$គេបាន $6-6t+0+2-12t+1=0$

នោះ $t=\frac{1}{2}$ ជួសក្នុង$(BA')$គេបាន$M_0(3,0,2)$ ។

ដូចនេះ $M\equiv M_0(3,0,2)$ ។

## លំហាត់ទី៤៣

នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$ គេឲ្យបួនចំណុច $A(2,4,-5),B(6,-4,3),C(-1,1,7)$ និង $D(-4,7,1)$ ។

១.គណនាកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AB}$ , $\overrightarrow{BC}$ , $\overrightarrow{CD}$ និង $\overrightarrow{AD}$ រួចគណនារង្វាស់នៃជ្រុងនៃចតុកោណ $ABCD$ ។

២.ចូរបង្ហាញថា $\overrightarrow{AB}\perp\overrightarrow{AD}$ និង $\overrightarrow{AB}//\overrightarrow{CD}$ រួចទាញរកប្រភេទនៃចតុកោណ $ABCD$ និងគណនាផ្ទៃក្រឡារបស់វា។

៣.តាង $E$ ជាប្រសព្វរវាងបន្ទាត់ $(AD)$ និង $(BC)$ ។ គណនា $EC$ និង $ED$ ។

៤.គណនា $\overrightarrow{AB}\times\overrightarrow{AC}$ រួចទាញរកផ្ទៃក្រឡានៃត្រីកោណ $ABC$ និង $ACD$ ។

៥.រកសមីការនៃប្លង់ $(ABC)$ និងសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(AD)$ និង $(BC)$ ។

## ដំណោះស្រាយ

**១.គណនាកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AB}$ , $\overrightarrow{BC}$ , $\overrightarrow{CD}$ និង $\overrightarrow{AD}$ រួចគណនារង្វាស់នៃជ្រុងនៃចតុកោណ $ABCD$ ៖**

គេមាន $A(2,4,-5),B(6,-4,3),C(-1,1,7)$ និង $D(-4,7,1)$

យើងបាន $\overrightarrow{AB}=\overrightarrow{OB}-\overrightarrow{OA}=(6,-4,3)-(2,4,-5)=(4,-8,8)$

$$\overrightarrow{BC}=\overrightarrow{OC}-\overrightarrow{OB}=(-1,1,7)-(6,-4,3)=(-7,5,4)$$
$$\overrightarrow{CD}=\overrightarrow{OD}-\overrightarrow{OC}=(-4,7,1)-(-1,1,7)=(-3,6,-6)$$
$$\overrightarrow{AD}=\overrightarrow{OD}-\overrightarrow{OA}=(-4,7,1)-(2,4,-5)=(-6,3,6)$$

ហើយ $AB=|\overrightarrow{AB}|=\sqrt{16+64+64}=\sqrt{144}=12$

$$BC=|\overrightarrow{BC}|=\sqrt{49+25+16}=\sqrt{90}=3\sqrt{10}$$
$$CD=|\overrightarrow{CD}|=\sqrt{9+36+36}=\sqrt{81}=9$$
$$AD=|\overrightarrow{AD}|=\sqrt{36+9+36}=\sqrt{81}=9$$

ដូចនេះ $AB=12$ , $BC=3\sqrt{10}$ , $CD=9$ , $AD=9$ ( ឯកតាប្រវែង ) ។

២.បង្ហាញថា $\overrightarrow{AB}\perp\overrightarrow{AD}$ និង $\overrightarrow{AB}//\overrightarrow{CD}$ រួចទាញរកប្រភេទនៃចតុកោណ

$ABCD$ និងគណនាផ្ទៃក្រឡារបស់វា៖




យើងមាន $\overrightarrow{AB}=(4,-8,8)$ និង $\overrightarrow{AD}=(-6,3,6)$

យើងបាន $\overrightarrow{AB}.\overrightarrow{AD}=(4)(-6)+(-8)(3)+(8)(6)=-24-24+48=0$

សមមូល $\overrightarrow{AB}\perp\overrightarrow{AD}$ ពិត។

ម្យ៉ាងទៀត $\overrightarrow{AB}=(4,-8,8)$ និង $\overrightarrow{CD}=(-3,6,-6)$

ដោយ $\frac{a}{a'}=\frac{b}{b'}=\frac{c}{c'}=\frac{4}{-3}=\frac{-8}{6}=\frac{8}{-6}$ នោះ $\overrightarrow{AB}//\overrightarrow{CD}$ ពិត។

ដូចនេះ $\overrightarrow{AB}\perp\overrightarrow{AD}$ និង $\overrightarrow{AB}//\overrightarrow{CD}$ ។ ចតុកោណ $ABCD$ មាន $\overrightarrow{AB}\perp\overrightarrow{AD}$ និង $\overrightarrow{AB}//\overrightarrow{CD}$ ជាចតុកោណព្នាយកែង។

ផ្ទៃក្រឡារបស់ចតុកោណព្នាយនេះគឺ ៖

$$S=\frac{(AB+CD)\times AD}{2}=\frac{(12+9)(9)}{2}=94.5$$ ឯកតាផ្ទៃក្រលា។

៣.គណនា $EC$ និង $ED$ ៖

យើងតាង $ED=x$ និង $EC=y$ ។ ត្រីកោណកែង $ABE$ និង $DCE$

មានមុំ $E$ រួមនោះវាជាត្រីកោណកែងដូចគ្នា។




យើងបានផលធៀបដំណូច $\frac{ED}{EA}=\frac{EC}{EB}=\frac{DC}{AB}$

សមមូល $\frac{x}{x+9}=\frac{y}{y+3\sqrt{10}}=\frac{9}{12}$ នាំឲ្យគេទាញ $x=27$ , $y=9\sqrt{10}$ ។

ដូចនេះ $ED=27$ , $EC=9\sqrt{10}$ ។

៨.គណនា $\overrightarrow{AB}\times\overrightarrow{AC}$ រួចទាញរកផ្ទៃក្រឡានៃត្រីកោណ $ABC$ និង $ACD$ ៖

យើងមាន $\overrightarrow{AB}=(4,-8,8)$ និង $\overrightarrow{AC}=(-3,-3,12)$

យើងបាន $\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 4 & -8 & 8\\ -3 & -3 & 12\end{vmatrix}=-72\vec{i}-72\vec{j}-36\vec{k}$

ដូចនេះ $\overrightarrow{AB}\times\overrightarrow{AC}=(-72,-72,-36)$ ។

ផ្ទៃក្រឡានៃត្រីកោណ $ABC$ គឺ $S=\frac{1}{2}\left|\overrightarrow{AB}\times\overrightarrow{AC}\right|=\frac{1}{2}\sqrt{72^2+72^2+36^2}=54$ ។

ហើយ $S_{ACD}=S_{ABCD}-S_{ABC}=94.5-54=40.5$ ។

ដូចនេះ $S_{ABC}=54$ , $S_{ACD}=40.5$ (ឯកតាផ្ទៃក្រឡា)។

៥.សរសេរសមីការនៃប្លង់ $(ABC)$ និងសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(AD)$ និង $(BC)$ ៖

វិចទ័រណរម៉ាល់នៃប្លង់ $(ABC)$ គឺ $\overrightarrow{AB}\times\overrightarrow{AC}=(-72,-72,-36)$ ។

សមីការប្លង់នេះអាចសរសេរតាមរូបមន្ត៖

$(ABC):a(x-x_a)+b(y-y_a)+c(z-z_a)=0$ ដែល $A(2,4,-5)$

$(ABC):-72(x-2)-72(y-4)-36(z+5)=0$

$(ABC):2x-4+2y-8+z+5=0$

$(ABC):2x+2y+z-7=0$

ហើយបន្ទាត់ $(AD)$ និង $(BC)$ មានវិចទ័រប្រាប់ទិសរៀងគ្នា $\overrightarrow{AD}=(-6,3,6)$

និង $\overrightarrow{BC}=(-7,5,4)$ នោះសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ពីរនេះអាចសរសេរ៖

$(AB):\begin{cases}x=2-6t\\ y=4+3t\\ z=-5+6t\quad,t\in\mathbb{R}\end{cases}$ និង $(BC):\begin{cases}x=6-7t'\\ y=-4+5t'\\ z=3+4t'\ ,t'\in\mathbb{R}\end{cases}$

www.mathtoday.wordpress.com

## លំហាត់ទី៤៤

នៅក្នុងតម្រុយអរតូនរម៉ាល់ $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបន្ទាត់និងស្វ៊ែមានសមីការ

$(L):\dfrac{x-1}{-2}=\dfrac{y-4}{3}=\dfrac{z-3}{2}$ និង $(S):\ (x-1)^2+(y+1)^2+(z-2)^2=9$

ចូរបង្ហាញថាបន្ទាត់$(L)$ប៉ះនឹងស្វ៊ែ$(S)$ត្រង់ចំណុច $A$ មួយរួចគណនាកូអរដោនេនៃចំណុចប៉ះ $A$ ខាងលើ ។

## ដំណោះស្រាយ

បង្ហាញថាបន្ទាត់$(L)$ ប៉ះនឹងស្វ៊ែ

បន្ទាត់ $(L)$ កាត់តាមចំនុច $M_0(1\,;4\,;3)$ ហើយមានវ៉ិចទ័រប្រាប់ទិស

$\vec{u}(-2;3\,;2\,)$ ។

ស្វ៊ែ $(S)$ មានផ្ចិត $I(1\,;-1\,;2\,)$ និងកាំ $R=3$ ។

ចម្ងាយពីចំនុច $I$ ទៅបន្ទាត់ $(L)$ គឺ $d(I;(L))=\dfrac{|\overrightarrow{AM_0}\times\vec{u}|}{|\vec{u}|}$

ដោយ $\overrightarrow{IM_0}=(0\,;5\,;1\,)$ គេបាន $\overrightarrow{IM_0}\times\vec{u}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 0 & 5 & 1\\ -2 & 3 & 2\end{vmatrix}=7\,\vec{i}-2\,\vec{j}+10\,\vec{k}$

គេទាញ $d(I;(L))=\dfrac{\sqrt{7^2+(-2)^2+10^2}}{\sqrt{(-2)^2+3^2+2^2}}=\sqrt{\dfrac{153}{17}}=3$

ដោយ $d(I;(L))=R=3$ ។

ដូចនេះបន្ទាត់$(L)$ ប៉ះនឹងស្វ៊ែ $(S)$ត្រង់ចំនុច $A$ មួយ។

គណនាកូអរដោនេនៃចំណុចប៉ះ $A$ ខាងលើ

តាង $\frac{x-1}{-2}=\frac{y-4}{3}=\frac{z-3}{2}=t \Rightarrow \begin{cases} x=-2t+1 \\ y=3t+4 \\ z=2t+3 \end{cases} \quad (1)$

យកសមីការ$(1)$ជំនួសក្នុងសមីការស្វ៊ែ $(S)$គេបាន

$(-2t)^2+(3t+5)^2+(2t+1)^2=9$

$4t^2+9t^2+30t+25+4t^2+4t+1-9=0$

$17t^2+34t+17=0$

$17(t+1)^2=0 \Rightarrow t=-1$

យក $t=-1$ ជំនួសក្នុង $(1)$ គេបាន $A(3\,;1\,;1\,)$ ។

www.mathtoday.wordpress.com

## លំហាត់ទី៤៥

គេឲ្យគូប $ABCDEFGH$ មួយមានទ្រនុងស្មើ1 ។លំហមានទិសដៅតាមតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(A,\overrightarrow{AB},\overrightarrow{AD},\overrightarrow{AE})$ គេតាង $I,J,K$ ជាបីចំណុចផ្ទៀងផ្ទាត់ $\overrightarrow{AI}=\frac{1}{3}\overrightarrow{AE}$ ,$\overrightarrow{BK}=\frac{1}{3}\overrightarrow{BC}$ និង $\overrightarrow{CJ}=\frac{2}{3}\overrightarrow{CG}$ ។

១.កំណត់កូអរដោនេនៃចំណុច $I,J,K$ ។

២.គណនាផលគុណស្កាលែ $\overrightarrow{KI}.\overrightarrow{KJ}$ រួចទាញរកប្រភេទនៃត្រីកោណ $IJK$ ។

៣.គណនាផលគុណវិចទ័រ $\overrightarrow{KI}\times\overrightarrow{KJ}$ រួចគណនាផ្ទៃក្រឡានៃត្រីកោណ $IJK$ ។

៤.$L$ ជាចំណុចមួយនៃ$[GH]$ដែលផលគុណស្កាលែ $\overrightarrow{LI}.\overrightarrow{LJ}$ អប្បបរមា។

ចូរកំណត់កូអរដោនេនៃចំណុច $L$ ។

៥.ចូរស្រាយថាបួនចំណុច $I,J,K,L$ ស្ថិតនៅក្នុងប្លង់តែមួយ។

## ដំណោះស្រាយ

១.កំណត់កូអរដោនេនៃចំណុច $I,J,K$




ក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(A,\overrightarrow{AB},\overrightarrow{AD},\overrightarrow{AE})$យើងបាន៖

$A(0,0,0), B(1,0,0), C(1,1,0), D(0,1,0)$ , $E(0,0,1)$ , $F(1,0,1), G(1,1,1)$ និង $H(0,1,1)$ ។

ដោយ $\overrightarrow{AI}=\frac{1}{3}\overrightarrow{AE}$ , $\overrightarrow{BK}=\frac{1}{3}\overrightarrow{BC}$ និង $\overrightarrow{CJ}=\frac{2}{3}\overrightarrow{CG}$

នោះយើងបាន $I(0,0,\frac{1}{3})$ , $J(1,1,\frac{2}{3})$ និង $K(1,\frac{1}{3},0)$ ។

២.គណនាផលគុណស្កាលែ $\overrightarrow{KI}.\overrightarrow{KJ}$ រួចទាញរកប្រភេទនៃត្រីកោណ $IJK$

យើងមាន $\overrightarrow{KI}=(-1,-\frac{1}{3},\frac{1}{3})$ , $\overrightarrow{KJ}=(0,\frac{2}{3},\frac{2}{3})$

នោះយើងបាន $\overrightarrow{KI}.\overrightarrow{KJ}=(-1)(0)+(-\frac{1}{3})(\frac{2}{3})+(\frac{1}{3})(\frac{2}{3})=0-\frac{2}{9}+\frac{2}{9}=0$

ដូចនេះ $\overrightarrow{KI}.\overrightarrow{KJ}=0$ ។ ម្យ៉ាងទៀតដោយ $\overrightarrow{KI}.\overrightarrow{KJ}=0 \Leftrightarrow \overrightarrow{KI}\perp\overrightarrow{KJ}$

នោះត្រីកោណ $IJK$ ជាត្រីកោណកែងត្រង់កំពូល $K$ ។

៣.គណនាផលគុណវិចទ័រ $\overrightarrow{KI}\times\overrightarrow{KJ}$ រួចគណនាផ្ទៃក្រឡានៃត្រីកោណ $IJK$

យើងមាន $\overrightarrow{KI}=(-1,-\frac{1}{3},\frac{1}{3})$ , $\overrightarrow{KJ}=(0,\frac{2}{3},\frac{2}{3})$

យើងបាន $\overrightarrow{KI}\times\overrightarrow{KJ}=\begin{vmatrix}\overrightarrow{AB} & \overrightarrow{AD} & \overrightarrow{AE}\\ -1 & -\frac{1}{3} & \frac{1}{3}\\ 0 & \frac{2}{3} & \frac{2}{3}\end{vmatrix}=(-\frac{2}{9}-\frac{2}{9})\overrightarrow{AB}-(-\frac{2}{3}-0)\overrightarrow{AD}+(-\frac{2}{3}-0)\overrightarrow{AE}$

ដូចនេះ $\overrightarrow{KI}\times\overrightarrow{KJ}=-\frac{4}{9}\overrightarrow{AB}+\frac{2}{3}\overrightarrow{AD}-\frac{2}{3}\overrightarrow{AE}$ ។

ផ្ទៃក្រឡានៃត្រីកោណ $IJK$ ឲ្យតាមរូបមន្ត ៖

$$S_{IJK}=\frac{1}{2}|\overrightarrow{KI}\times\overrightarrow{KJ}|=\frac{1}{2}\sqrt{\frac{16}{81}+\frac{4}{9}+\frac{4}{9}}=\frac{\sqrt{22}}{9}$$ (ឯកតាផ្ទៃក្រឡា)។

៤.កំណត់កូអរដោនេនៃចំណុច $L$

ដោយ $L$ ជាចំណុចមួយនៃ $[GH]$ នោះគេបាន $L(x_0,1,1)$ ដែល $0<x_0<1$ ។

យើងមាន $\overrightarrow{LI}=(-x_0,-1,-\frac{2}{3})$ , $\overrightarrow{LJ}=(1-x_0,0,-\frac{1}{3})$

យើងបាន $\overrightarrow{LI}.\overrightarrow{LJ}=-x_0(1-x_0)+(-1)(0)+(-\frac{2}{3})(-\frac{1}{3})$

$$=-x_0+x_0^2+0+\frac{2}{9}=(x_0-\frac{1}{2})^2-\frac{1}{36}$$

ដើម្បីឲ្យផលគុណស្កាលែ $\overrightarrow{LI}.\overrightarrow{LJ}=\left(x_0-\frac{1}{2}\right)^2-\frac{1}{36}$

អប្បបរមាលុះត្រាតែ $\left(x_0-\frac{1}{2}\right)^2=0\Leftrightarrow x_0=\frac{1}{2}$ ។

ចំពោះ $x_0=\frac{1}{2}$ នោះ $L(\frac{1}{2},1,1)$ ។

**ង.ស្រាយថាបួនចំណុច $I,J,K,L$ ស្ថិតនៅក្នុងប្លង់តែមួយ**

យើងមាន $\overrightarrow{KI}\times\overrightarrow{KJ}=(-\frac{4}{9},\frac{2}{3},-\frac{2}{3})$ និង $\overrightarrow{KL}=(-\frac{1}{2},\frac{2}{3},1)$

យើងបាន $(\overrightarrow{KI}\times\overrightarrow{KJ}).\overrightarrow{KL}=(-\frac{4}{9})(-\frac{1}{2})+(\frac{2}{3})(\frac{2}{3})+(-\frac{2}{3})(1)$

$$=\frac{2}{9}+\frac{4}{9}-\frac{2}{3}=\frac{2+4-6}{9}=0$$

ដោយ $(\overrightarrow{KI}\times\overrightarrow{KJ}).\overrightarrow{KL}=0$ នោះបួនចំណុច $I,J,K,L$ ស្ថិតនៅក្នុងប្លង់តែមួយ។

www.mathtoday.wordpress.com

## លំហាត់ទី៤៦

គេឲ្យគូប $ABCDEFGH$ មួយមានទ្រនុងស្មើ$1cm$ ។ $K,L$ និង $M$ ជាចំណុចកណ្តាលរៀងគ្នានៃ $[EF],[CD]$និង$[DH]$។

១ )គណនាផលគុណស្កាលែ $\overrightarrow{MK}\cdot\overrightarrow{ML}$ រួចទាញរកឈ្មោះនៃ $\Delta KLM$

២ ) $P$ ជាចំណុចមួយនៃ $[EH]$ ហើយគេតាង $\angle KPL=\varphi$ ។

ចូរស្រាយបញ្ជាក់ថាគ្រប់ទីតាំងនៃ $P$ ប្រែប្រួលក្នុង$[EH]$គេមាន $\varphi\le\frac{\pi}{2}$ ។

តើពេលណាទើបគេបាន $\varphi=\frac{\pi}{2}$ ។

## ដំណោះស្រាយ

**១)គណនាផលគុណស្កាលែ $\overrightarrow{MK}\cdot\overrightarrow{ML}$ រួចទាញរកឈ្មោះនៃ $\Delta KLM$ ៖**

ជ្រើសរើសតម្រុយ $(A,\overrightarrow{AB},\overrightarrow{AD},\overrightarrow{AE})$ ។

យើងមាន $A(0,0,0)$, $B(1,0,0)$, $C(1,1,0)$, $D(0,1,0)$

$E(0,0,1), F(1,0,1), G(1,1,1,), H(0,1,1)$ ។




ដោយ $K,L$ និង $M$ ជាចំណុចកណ្តាលរៀងគ្នានៃ$[EF],[CD]$និង$[DH]$

នោះគេបាន $K(\frac{1}{2},0,1), L(\frac{1}{2},1,0), M(0,1,\frac{1}{2})$ ។

គេមាន $\overrightarrow{MK}=(\frac{1}{2},-1,\frac{1}{2})$ , $\overrightarrow{ML}=(\frac{1}{2},0,-\frac{1}{2})$

យើងបាន $\overrightarrow{MK}\cdot\overrightarrow{ML}=\frac{1}{4}+0-\frac{1}{4}=0$ ។ ដោយ $\overrightarrow{MK}\cdot\overrightarrow{ML}=0\Leftrightarrow\overrightarrow{MK}\perp\overrightarrow{ML}$ ។

ដូចនេះ $KLM$ ជាត្រីកោណកែងត្រង់ $M$ ។

២)ស្រាយបញ្ជាក់ថាគ្រប់ទីតាំងនៃ $P$ ប្រែប្រួលក្នុង $[EH]$ គេមាន $\varphi\le\frac{\pi}{2}$

ដោយ $P$ ជាចំណុចមួយនៃ $[EH]$ នោះគេបាន $P(0,t,1)$

ដែល $EP=t$ , $0\le t\le 1$ ។គេមាន $\overrightarrow{PK}=(\frac{1}{2},-t,0)$ , $\overrightarrow{PL}=(\frac{1}{2},1-t,-1)$

គេបាន $\overrightarrow{PK}\cdot\overrightarrow{PL}=(\frac{1}{2})(\frac{1}{2})-t(1-t)+(0)(-1)=\frac{1}{4}-t+t^2=\left(\frac{1}{2}-t\right)^2\ge 0$

គ្រប់ $t\in[0,1]$ ។

ដោយ $\overrightarrow{PK}.\overrightarrow{PL}\ge 0$ នោះមុំ $\angle KPL=\varphi$ ជាមុំស្រួច ឬ មុំកែង ។

ដូចនេះ គ្រប់ទីតាំងនៃ $P$ ប្រែប្រួលក្នុង $[EH]$ គេមាន $\varphi\le\frac{\pi}{2}$ ។

តើពេលណាទើបគេបាន $\varphi=\frac{\pi}{2}$ ៖

ដោយ $\overrightarrow{PK}\cdot\overrightarrow{PL}=\left(\frac{1}{2}-t\right)^2$

នោះដើម្បីឲ្យ $\varphi=\frac{\pi}{2}$ លុះត្រាតែ $\overrightarrow{PK}\cdot\overrightarrow{PL}=\left(\frac{1}{2}-t\right)^2=0\Leftrightarrow t=\frac{1}{2}$

ចំពោះ $t=\frac{1}{2}$ គេបាន $P(0,\frac{1}{2},1)$ នោះ $P$ ជាចំណុចកណ្តាលនៃអង្កត់ $[EH]$ ។

ដូចនេះដើម្បីឲ្យ $\varphi=\frac{\pi}{2}$ លុះត្រាតែ $P$ ជាចំណុចកណ្តាលនៃអង្កត់ $[EH]$ ។

www.mathtoday.wordpress.com

## លំហាត់ទី៤៧

គេឲ្យគូប $ABCDEFGH$ មួយមានទ្រនុងស្មើ1 ។លំហមានទិសដៅតាមតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(A,\overrightarrow{AB},\overrightarrow{AD},\overrightarrow{AE})$ យក $I,J,K$ និង $L$ ជាចំណុចកណ្តាលរៀងគ្នា នៃ $[EF]$, $[BC]$,$[DH]$ និង$[BF]$ ។

១.ចូរស្រាយបំភ្លឺថា $IJK$ ជាត្រីកោណសមង្ស័។

២.ចូរស្រាយបញ្ជាក់ថា $\overrightarrow{IJ}\times\overrightarrow{IK}=\frac{3}{4}\overrightarrow{AG}$ រួចគណនាផ្ទៃក្រឡានៃ $\Delta IJK$ ។

៣.ចូរស្រាយបញ្ជាក់ថាបន្ទាត់$(IJ)$និង$(KL)$អរតូកូណាល់គ្នា។

៤.គណនារង្វាស់មុំ $\angle ILJ$ ។

៥.គណនាផលគុណស្កាលែ $\overrightarrow{IL}.\overrightarrow{IK}$ និង $\overrightarrow{JL}.\overrightarrow{JK}$ រួចទាញរកប្រភេទនៃត្រីកោណ $ILK$ និងត្រីកោណ $JLK$ ។

៦.គណនា$(\overrightarrow{IJ}\times\overrightarrow{IK}).\overrightarrow{IL}$ រួចទាញថាចំណុច $I,J,K,L$ ស្ថិតនៅក្នុងប្លង់តែមួយ។

## ដំណោះស្រាយ

១.ស្រាយបំភ្លឺថា $IJK$ ជាត្រីកោណសមង្ស័

ក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(A,\overrightarrow{AB},\overrightarrow{AD},\overrightarrow{AE})$។



ដោយ $I,J,K$ និង $L$ ជាចំណុចកណ្តាលនៃទ្រនុង $[EF],[BC],[DH]$

និង $[BF]$ នោះយើងបាន $I\left(\frac{1}{2},0,1\right),J\left(1,\frac{1}{2},0\right),K\left(0,1,\frac{1}{2}\right),L\left(1,0,\frac{1}{2}\right)$

យើងមាន $\overrightarrow{IJ}=\left(\frac{1}{2},\frac{1}{2},-1\right)$, $\overrightarrow{IK}=\left(-\frac{1}{2},1,-\frac{1}{2}\right)$ និង $\overrightarrow{JK}=\left(-1,\frac{1}{2},\frac{1}{2}\right)$

យើងបាន $|\overrightarrow{IJ}|=\sqrt{\frac{1}{4}+\frac{1}{4}+1}=\frac{\sqrt{6}}{2}$ , $|\overrightarrow{IK}|=\sqrt{\frac{1}{4}+1+\frac{1}{4}}=\frac{\sqrt{6}}{2}$

និង $|\overrightarrow{JK}|=\sqrt{1+\frac{1}{4}+\frac{1}{4}}=\frac{\sqrt{6}}{2}$ នោះ $|\overrightarrow{IJ}|=|\overrightarrow{IK}|=|\overrightarrow{JK}|=\frac{\sqrt{6}}{2}$ ។

ដូចនេះ $IJK$ ជាត្រីកោណសមង្ស័។

២.ស្រាយបញ្ជាក់ថា $\overrightarrow{IJ}\times\overrightarrow{IK}=\frac{3}{4}\overrightarrow{AG}$ រួចគណនាផ្ទៃក្រឡានៃ $\Delta IJK$

យើងមាន $A(0,0,0)$ , $G(1,1,1)$ នោះ $\overrightarrow{AG}=\vec{i}+\vec{j}+\vec{k}$ $(1)$ ។

$$\overrightarrow{IJ}\times\overrightarrow{IK}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ \frac{1}{2} & \frac{1}{2} & -1\\ -\frac{1}{2} & 1 & -\frac{1}{2}\end{vmatrix}=\frac{3}{4}\vec{i}+\frac{3}{4}\vec{j}+\frac{3}{4}\vec{k}=\frac{3}{4}\left(\vec{i}+\vec{j}+\vec{k}\right)\ (2)$$

តាម $(1)\&(2)$ យើងបាន $\overrightarrow{IJ}\times\overrightarrow{IK}=\frac{3}{4}\overrightarrow{AG}$ ពិត។

តាមរូបមន្តផ្ទៃក្រឡាប្រលេឡូក្រាម ៖

$$S_{IJK}=\frac{1}{2}\left|\overrightarrow{IJ}\times\overrightarrow{IK}\right|=\frac{1}{2}\sqrt{\frac{9}{16}+\frac{9}{16}+\frac{9}{16}}=\frac{3\sqrt{3}}{8}$$ (ឯកតាផ្ទៃ)។

៣.ស្រាយបញ្ជាក់ថាបន្ទាត់ $(IJ)$ និង $(KL)$ អរត្តូកូណាល់គ្នា

យើងមាន $\overrightarrow{IJ}=\left(\frac{1}{2},\frac{1}{2},-1\right)$ និង $\overrightarrow{KL}=(1,-1,0)$នោះយើងបាន

$\overrightarrow{IJ}.\overrightarrow{KL}=\frac{1}{2}-\frac{1}{2}+0=0\Leftrightarrow\overrightarrow{IJ}\perp\overrightarrow{KL}$ ។

ដូចនេះបន្ទាត់$(IJ)$និង$(KL)$អរតូកូណាល់គ្នា។

៤.គណនារង្វាស់មុំ $\angle ILJ$

យើងមាន $\overrightarrow{LI}=\left(-\frac{1}{2},0,\frac{1}{2}\right)$ និង $\overrightarrow{LJ}=\left(0,\frac{1}{2},-\frac{1}{2}\right)$

នោះ $\overrightarrow{LI}.\overrightarrow{LJ}=0+0-\frac{1}{4}=-\frac{1}{4}$

និង $|\overrightarrow{LI}|=\sqrt{\frac{1}{4}+0+\frac{1}{4}}=\frac{\sqrt{2}}{2}$ , $|\overrightarrow{LJ}|=\sqrt{0+\frac{1}{4}+\frac{1}{4}}=\frac{\sqrt{2}}{2}$

យើងបាន $\cos\angle ILJ=\dfrac{-\frac{1}{4}}{\frac{\sqrt{2}}{2}\times\frac{\sqrt{2}}{2}}=-\frac{1}{2}$ នោះ $\angle ILJ=120^o$ ។

៥.គណនាផលគុណស្កាលែ $\overrightarrow{IL}.\overrightarrow{IK}$ និង $\overrightarrow{JL}.\overrightarrow{JK}$

យើងមាន $\overrightarrow{IL}=\left(\frac{1}{2},0,-\frac{1}{2}\right),\overrightarrow{IK}=\left(-\frac{1}{2},1,-\frac{1}{2}\right)$

នោះយើងបាន $\overrightarrow{IL}.\overrightarrow{IK}=-\frac{1}{4}+0+\frac{1}{4}=0$ ។

ហើយ $\overrightarrow{JL}=\left(0,-\frac{1}{2},\frac{1}{2}\right)$ , $\overrightarrow{JK}=\left(-1,\frac{1}{2},\frac{1}{2}\right)$

នោះយើងបាន $\overrightarrow{JL}.\overrightarrow{JK}=0-\frac{1}{4}+\frac{1}{4}=0$ ។

ដូចនេះ $\overrightarrow{IL}.\overrightarrow{IK}=0$ និង $\overrightarrow{JL}.\overrightarrow{JK}=0$។

ទាញរកប្រភេទនៃត្រីកោណ $ILK$ និងត្រីកោណ $JLK$

ដោយ $\overrightarrow{IL}.\overrightarrow{IK}=0 \Leftrightarrow \overrightarrow{IL}\perp\overrightarrow{IK}$ និង $\overrightarrow{JL}.\overrightarrow{JK}=0 \Leftrightarrow \overrightarrow{JL}\perp\overrightarrow{JK}$ ។

ដូចនេះត្រីកោណ $ILK$ និង $JLK$ ជាត្រីកោណកែងត្រង់កំពូល $I$ & $J$ រៀងគ្នា។

៦.គណនា $(\overrightarrow{IJ}\times\overrightarrow{IK}).\overrightarrow{IL}$

យើងមាន $\overrightarrow{IJ}\times\overrightarrow{IK}=\left(\frac{3}{4},\frac{3}{4},\frac{3}{4}\right)$ , $\overrightarrow{IL}=\left(\frac{1}{2},0,-\frac{1}{2}\right)$ នោះយើងបាន

$(\overrightarrow{IJ}\times\overrightarrow{IK}).\overrightarrow{IL}=\frac{3}{8}+0-\frac{3}{8}=0$ ។

ទាញថាបួនចំណុច $I,J,K,L$ ស្ថិតនៅក្នុងប្លង់តែមួយ៖

យើងមាន $(\overrightarrow{IJ}\times\overrightarrow{IK}).\overrightarrow{IL}=0$ នោះ $(\overrightarrow{IJ}\times\overrightarrow{IK})\perp\overrightarrow{IL}$

ដោយ $\overrightarrow{IJ}\times\overrightarrow{IK}$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(IJK)$ នោះគេទាញ $L\in(IJK)$ ។

ដូចនេះបួនចំណុច $I,J,K,L$ ស្ថិតនៅក្នុងប្លង់តែមួយ។

www.mathtoday.wordpress.com

## លំហាត់ទី៤៨

គូប $ABCDEFGH$ មួយមានទ្រនុងស្មើ1 ។លំហមានទិសដៅតាមតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(A,\overrightarrow{AB},\overrightarrow{AD},\overrightarrow{AE})$ គេតាង $I,J,K$ ជាបីចំណុចផ្ទៀងផ្ទាត់ $\overrightarrow{AI}=\frac{1}{3}\overrightarrow{AE}$ ,$\overrightarrow{BK}=\frac{1}{3}\overrightarrow{BC}$ និង $\overrightarrow{CJ}=\frac{2}{3}\overrightarrow{CG}$ ។

១.កំណត់កូអរដោនេនៃចំណុច $I,J,K$ ។

២.គណនាផលគុណស្កាលែ $\overrightarrow{KI}.\overrightarrow{KJ}$ រួចទាញរកប្រភេទនៃត្រីកោណ $IJK$

៣.គណនាផលគុណវ៉ិចទ័រ $\overrightarrow{KI}\times\overrightarrow{KJ}$ រួចគណនាផ្ទៃក្រឡានៃត្រីកោណ $IJK$

៤.$L$ ជាចំណុចមួយនៃ$[GH]$ដែលផលគុណស្កាលែ $\overrightarrow{LI}.\overrightarrow{LJ}$ អប្បបរមា។
 ចូរកំណត់កូអរដោនេនៃចំណុច $L$ ។

៥.ចូរស្រាយថាបួនចំណុច $I,J,K,L$ ស្ថិតនៅក្នុងប្លង់តែមួយ។

## ដំណោះស្រាយ

១.កំណត់កូអរដោនេនៃចំណុច $I,J,K$



ក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(A,\overrightarrow{AB},\overrightarrow{AD},\overrightarrow{AE})$ យើងបាន៖
$A(0,0,0)$, $B(1,0,0)$, $C(1,1,0)$, $D(0,1,0)$, $E(0,0,1)$, $F(1,0,1)$, $G(1,1,1)$ និង
$H(0,1,1)$ ។

ដោយ $\overrightarrow{AI}=\frac{1}{3}\overrightarrow{AE}$ , $\overrightarrow{BK}=\frac{1}{3}\overrightarrow{BC}$ និង $\overrightarrow{CJ}=\frac{2}{3}\overrightarrow{CG}$ នោះយើងបាន ៖
$I(0,0,\frac{1}{3})$ , $J(1,1,\frac{2}{3})$ និង $K(1,\frac{1}{3},0)$ ។

២.គណនាផលគុណស្កាលែ $\overrightarrow{KI}.\overrightarrow{KJ}$ រួចទាញរកប្រភេទនៃត្រីកោណ $IJK$

យើងមាន $\overrightarrow{KI}=(-1,-\frac{1}{3},\frac{1}{3})$ , $\overrightarrow{KJ}=(0,\frac{2}{3},\frac{2}{3})$

យើងបាន $\overrightarrow{KI}.\overrightarrow{KJ}=(-1)(0)+(-\frac{1}{3})(\frac{2}{3})+(\frac{1}{3})(\frac{2}{3})=0-\frac{2}{9}+\frac{2}{9}=0$

ដូចនេះ $\overrightarrow{KI}.\overrightarrow{KJ}=0$ ។

ម្យ៉ាងទៀតដោយ $\overrightarrow{KI}.\overrightarrow{KJ}=0 \Leftrightarrow \overrightarrow{KI}\perp\overrightarrow{KJ}$ នោះត្រីកោណ $IJK$
ជាត្រីកោណកែងត្រង់កំពូល $K$ ។

៣.គណនាផលគុណវិចទ័រ $\overrightarrow{KI}\times\overrightarrow{KJ}$ រួចគណនាផ្ទៃក្រឡានៃត្រីកោណ $IJK$

យើងមាន $\overrightarrow{KI}=(-1,-\frac{1}{3},\frac{1}{3})$ , $\overrightarrow{KJ}=(0,\frac{2}{3},\frac{2}{3})$

យើងបាន

$$\overrightarrow{KI}\times\overrightarrow{KJ}=\begin{vmatrix}\overrightarrow{AB} & \overrightarrow{AD} & \overrightarrow{AE}\\ -1 & -\frac{1}{3} & \frac{1}{3}\\ 0 & \frac{2}{3} & \frac{2}{3}\end{vmatrix}=(-\frac{2}{9}-\frac{2}{9})\overrightarrow{AB}-(-\frac{2}{3}-0)\overrightarrow{AD}+(-\frac{2}{3}-0)\overrightarrow{AE}$$

ដូចនេះ $\overrightarrow{KI}\times\overrightarrow{KJ}=-\frac{4}{9}\overrightarrow{AB}+\frac{2}{3}\overrightarrow{AD}-\frac{2}{3}\overrightarrow{AE}$ ។

ផ្ទៃក្រឡានៃត្រីកោណ $IJK$ ឲ្យតាមរូបមន្ត ៖

$$S_{IJK}=\frac{1}{2}|\overrightarrow{KI}\times\overrightarrow{KJ}|=\frac{1}{2}\sqrt{\frac{16}{81}+\frac{4}{9}+\frac{4}{9}}=\frac{\sqrt{22}}{9}$$ (ឯកតាផ្ទៃក្រឡា)។

**៤.កំណត់កូអរដោនេនៃចំណុច $L$**

ដោយ $L$ ជាចំណុចមួយនៃ $[GH]$ នោះគេបាន $L(x_0,1,1)$ ដែល $0<x_0<1$ ។

យើងមាន $\overrightarrow{LI}=(-x_0,-1,-\frac{2}{3})$ , $\overrightarrow{LJ}=(1-x_0,0,-\frac{1}{3})$

យើងបាន $\overrightarrow{LI}.\overrightarrow{LJ}=-x_0(1-x_0)+(-1)(0)+(-\frac{2}{3})(-\frac{1}{3})$

$$=-x_0+x_0^{\ 2}+0+\frac{2}{9}=(x_0-\frac{1}{2})^2-\frac{1}{36}$$

ដើម្បីឲ្យផលគុណស្កាលែ $\overrightarrow{LI}.\overrightarrow{LJ}=\left(x_0-\frac{1}{2}\right)^2-\frac{1}{36}$ អប្បបរមាលុះត្រាតែ

$\left(x_0-\frac{1}{2}\right)^2=0\Leftrightarrow x_0=\frac{1}{2}$ ។

ចំពោះ $x_0=\frac{1}{2}$ នោះ $L(\frac{1}{2},1,1)$ ។

**៥.ស្រាយថាបួនចំណុច $I,J,K,L$ ស្ថិតនៅក្នុងប្លង់តែមួយ**

យើងមាន $\overrightarrow{KI}\times\overrightarrow{KJ}=(-\frac{4}{9},\frac{2}{3},-\frac{2}{3})$ និង $\overrightarrow{KL}=(-\frac{1}{2},\frac{2}{3},1)$

យើងបាន $(\overrightarrow{KI}\times\overrightarrow{KJ}).\overrightarrow{KL}=(-\frac{4}{9})(-\frac{1}{2})+(\frac{2}{3})(\frac{2}{3})+(-\frac{2}{3})(1)$

$$=\frac{2}{9}+\frac{4}{9}-\frac{2}{3}=\frac{2+4-6}{9}=0$$

ដោយ $(\overrightarrow{KI}\times\overrightarrow{KJ}).\overrightarrow{KL}=0$ នោះបួនចំណុច $I,J,K,L$ ស្ថិតនៅក្នុងប្លង់តែមួយ។

## លំហាត់ទី៤៩

គេឲ្យគូប $ABCDEFGH$ មានទ្រនុងស្មើនឹង $1cm$ ។ $I$ ជាចំណុចកណ្ដាល នៃទ្រនុង $[EH]$, $K$ ជាផ្ចិតការេ $CDHG$ ហើយ $M$ និង $N$ ជាចំណុចពីរ នៃទ្រនុង $[BC]$ និង $[BF]$ រៀងគ្នាដោយដឹងថា $\overrightarrow{MI}\cdot\overrightarrow{MK}$ និង $\overrightarrow{NI}\cdot\overrightarrow{NK}$ មានតម្លៃអប្បបរមា ។ តើបួនចំណុច $I, K, M, N$ ស្ថិតនៅក្នុងប្លង់តែមួយ ឬទេ ? បើសិនជាវាមិនស្ថិតក្នុងប្លង់តែមួយទេចូរគណនាមាឌតេត្រាអ៊ែតដែលមានកំពូល $I, K, M, N$ ។

## ដំណោះស្រាយ

តើបួនចំណុច $I, K, M, N$ ស្ថិតនៅក្នុងប្លង់តែមួយឬទេ ?៖




យើងជ្រើសរើសតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(A, \overrightarrow{AB}, \overrightarrow{AD}, \overrightarrow{AE}\right)$

ដោយ $I$ ជាចំណុចកណ្ដាលនៃទ្រនុង $[EH]$ នោះ $I(0,\frac{1}{2},1)$ ហើយ $K$ ជា

ផ្ចិតការេ $CDHG$ នោះ $K(\frac{1}{2},1,\frac{1}{2})$ ។ $M$ និង $N$ ជាចំណុចពីរនៃទ្រនុង $[BC]$ និង $[BF]$ រៀងគ្នានោះ $M(1\ ,b,0)$ និង $N(1,0,c)$ ។

គេមាន $\overrightarrow{MI}=(-1,\frac{1}{2}-b,1)$ , $\overrightarrow{MK}=(-\frac{1}{2},1-b,\frac{1}{2})$ , $\overrightarrow{NI}=(-1,\frac{1}{2},1-c)$

និង $\overrightarrow{NK}=(-\frac{1}{2},1,\frac{1}{2}-c)$ ។

យើងមាន $\overrightarrow{MI}\cdot\overrightarrow{MK}=\frac{1}{2}+(\frac{1}{2}-b)(1-b)+\frac{1}{2}=b^2-\frac{3}{2}b+\frac{3}{2}=(b-\frac{3}{4})^2+\frac{15}{16}$

និង $\overrightarrow{NI}\cdot\overrightarrow{NK}=\frac{1}{2}+\frac{1}{2}+(1-c)(\frac{1}{2}-c)=(c-\frac{3}{4})^2+\frac{15}{16}$ ។

ដោយដឹងថា $\overrightarrow{MI}\cdot\overrightarrow{MK}$ និង $\overrightarrow{NI}\cdot\overrightarrow{NK}$ មានតម្លៃអប្បបរមានោះយើងបាន ៖

$b=\frac{3}{4}$ និង $c=\frac{3}{4}$ នោះគេបាន $M(1,\frac{3}{4},0)$ និង $N(1,0,\frac{3}{4})$ ។

យើងមាន $\overrightarrow{IK}=(\frac{1}{2},\frac{1}{2},-\frac{1}{2})$, $\overrightarrow{IM}=(1,\frac{1}{4},-1)$, $\overrightarrow{IN}=(1,-\frac{1}{2},-\frac{1}{4})$

យើងបាន $$\left(\overrightarrow{IM}\times\overrightarrow{IN}\right).\overrightarrow{IK}=\begin{vmatrix}\frac{1}{2} & \frac{1}{2} & -\frac{1}{2}\\ 1 & \frac{1}{4} & -1\\ 1 & -\frac{1}{2} & -\frac{1}{4}\end{vmatrix}=-\frac{9}{32}$$

ដោយ $\left(\overrightarrow{IM}\times\overrightarrow{IN}\right).\overrightarrow{IK}=-\frac{9}{32}\neq 0$ នោះបួនចំណុច $I,M,N,K$ មិនស្ថិតនៅក្នុងប្លង់តែមួយទេ។

ដូចនេះមាឌតេត្រាអ៊ែតដែលមានកំពូល $I,M,N,K$ កំណត់ដោយ ៖

$$V=\frac{1}{6}\left|\left(\overrightarrow{IM}\times\overrightarrow{IN}\right).\overrightarrow{IK}\right|=\frac{1}{6}\times\frac{9}{32}=\frac{3}{64}\ cm^3$$ ។

## លំហាត់ទី៥០

គេឲ្យគូប $ABCD$ មួយមានទ្រនុងស្មើ $1cm$ ។ $I$ ជាចំណុចកណ្ដាល $[EF]$

$J \in [BC]$ ដែល $IJ \perp IH$ ហើយ $K \in [CD]$ ដែល $\overrightarrow{CK} = \frac{3}{8}\overrightarrow{CD}$ ។

១.ចូរស្រាយបញ្ជាក់ថាបួនចំណុច $H, I, J, K$ ស្ថិតក្នុងប្លង់តែមួយ។

២.រកទីតាំងនៃចំណុច $P \in [DH]$ ដោយដឹងថា $\overrightarrow{PI}.\overrightarrow{PJ}$ មានតម្លៃតូចបំផុត។

## ដំណោះស្រាយ

១.ចូរស្រាយបញ្ជាក់ថាបួនចំណុច $H, I, J, K$ ស្ថិតក្នុងប្លង់តែមួយ

យើងជ្រើសរើសតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(A, \overrightarrow{AB}, \overrightarrow{AD}, \overrightarrow{AE})$



ដោយ $I$ ជាចំណុចកណ្ដាល $[EF]$ នោះ $I(\frac{1}{2},0,1)$ ហើយ $J\in[BC]$ នោះ $J(1,b,0)$ ។ គេមាន $\overrightarrow{IJ}=(\frac{1}{2},b,-1)$ និង $\overrightarrow{IH}=(-\frac{1}{2},1,0)$ ។

ដោយ $IJ\perp IH$ នោះគេបាន $\overrightarrow{IJ}.\overrightarrow{IH}=-\frac{1}{4}+b+0=0$ នោះ $b=\frac{1}{4}$ ។ គេបាន $J(1,\frac{1}{4},0)$ ។

ហើយ $K\in[CD]$ ដែល $\overrightarrow{CK}=\frac{3}{8}\overrightarrow{CD}$ នោះ $\overrightarrow{KD}=\frac{5}{8}\overrightarrow{CD}$ ឬ $\overrightarrow{DK}=\frac{5}{8}\overrightarrow{DC}$

គេបាន $K(\frac{5}{8},1,0)$ ។

គេមាន $\overrightarrow{IJ}=(\frac{1}{2},\frac{1}{4},-1)$, $\overrightarrow{IK}=(\frac{1}{8},1,-1)$ និង $\overrightarrow{IH}=(-\frac{1}{2},1,0)$ ។

គេបាន $$(\overrightarrow{IJ}\times\overrightarrow{IK}).\overrightarrow{IH}=\begin{vmatrix}\frac{1}{2} & \frac{1}{4} & -1\\ \frac{1}{8} & 1 & -1\\ -\frac{1}{2} & 1 & 0\end{vmatrix}=\frac{1}{2}(0+1)-\frac{1}{4}\left(0-\frac{1}{2}\right)-1\left(\frac{1}{8}+\frac{1}{2}\right)$$

$(\overrightarrow{IJ}\times\overrightarrow{IK}).\overrightarrow{IH}=\frac{1}{2}+\frac{1}{8}-\frac{1}{8}-\frac{1}{2}=0$ នោះបីវ៉ិចទ័រ $\overrightarrow{IJ}$, $\overrightarrow{IK}$ និង $\overrightarrow{IH}$ ស្ថិតនៅក្នុងប្លង់តែមួយ (វ៉ិចទ័រកូប្លានែ)។

ដូចនេះបួនចំណុច $H$ , $I$ , $J$ , $K$ ស្ថិតនៅក្នុងប្លង់តែមួយ ។

២.រកទីតាំងនៃចំណុច $P\in[DH]$ ដោយដឹងថា $\overrightarrow{PI}.\overrightarrow{PJ}$ មានតម្លៃតូចបំផុត ៖

ដោយ $P\in[DH]$ នោះ $P(0,1,c)$ ដែល $0<c<1$ ។

គេមាន $\overrightarrow{PI}=(\frac{1}{2},-1,1-c)$ និង $\overrightarrow{PJ}=(1,-\frac{3}{4},-c)$

យើងបាន $\overrightarrow{PI}.\overrightarrow{PJ}=\frac{1}{2}+\frac{3}{4}+c^2-c=\left(c-\frac{1}{2}\right)^2+1$ ។

ដើម្បីឲ្យ $\overrightarrow{PI}.\overrightarrow{PJ}$ មានតម្លៃអប្បបរមាលុះត្រាតែ $c-\frac{1}{2}=0$ ឬ $c=\frac{1}{2}$ ។

ដូចនេះចំណុច $P$ ស្ថិតនៅកណ្ដាលនៃអង្កត់ $[DH]$ ទើប $\overrightarrow{PI}.\overrightarrow{PJ}$ មានតម្លៃ

អប្បបរមា ។

www.mathtoday.wordpress.com

## ជំពូកទី០៥

# កម្រងលំហាត់ជ្រើសរើសបន្ថែមសម្រាប់ការងារផ្ទះ

០១.នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបីចំណុច

$A(1,2,3)$ , $B(5,6,-4)$ និង $C(9,1,7)$ ។

ក.គណនា $AB$ , $AC$ និង $BC$ ។

ខ.គណនាផលគុណស្កាលែ $\overrightarrow{AB}.\overrightarrow{AC}$ រួចទាញរកប្រភេទនៃ $\Delta ABC$ ។

គ.រកកូអរដោនេនៃចំណុច $P$ ដែល $\overrightarrow{AP}=\overrightarrow{AB}+\overrightarrow{AC}$ ។

ឃ.រកប្រភេទនៃចតុកោណ $PBAC$ ។

០២.ក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច

$A(1,4,-5),B(-1,6,-4),C(3,-2,4)$ និង $D(5,-4,3)$ ។

ក.គណនា $AB,AC,AD,BC,BD$ និង $CD$ ។

ខ.ចូរស្រាយថាចតុកោណ $ABCD$ ជាប្រលេឡូក្រាម។

គ.គណនាផលគុណស្កាលែ $\overrightarrow{AC}.\overrightarrow{DB}$ ។

ឃ. $I$ ជាចំណុចកណ្តាល $[AD]$ និង $J$ ជាចំណុចផ្ទៀងផ្ទាត់ $\overrightarrow{BJ}=\frac{1}{4}\overrightarrow{BC}$ ។

គណនាកូអរដោនេនៃចំណុច $I$ និង $J$ រួចគណនា $IJ$ ។

០៣.ក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបួនចំណុច

$A(6,-3,-1),B(1,-1,-5),C(6,9,5)$ និង $D(10,5,7)$ ។

ក.គណនា $AB, AC, AD, BC, BD$ និង $CD$ ។

ខ.ចូរស្រាយថា $AD//BC$ និង $DA \perp DC$ រួចទាញរកប្រភេទចតុកោណ $ABCD$ និងគណនាផ្ទៃក្រឡារបស់វា។

គ.គណនា $\overrightarrow{AB}.\overrightarrow{AC}$ រួចទាញរកប្រភេទនៃត្រីកោណ $ABC$ ។

ឃ.$H$ ជាចំណោលកែងនៃ $A$ លើ $[BC]$ ។ គណនា $BH$ និង $HC$ រួចរកកូអរដោនេនៃចំណុច $H$ ។

០៤.ក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o, \vec{i}, \vec{j}, \vec{k}\right)$ គេឲ្យបួនចំណុច

$A(-5,4,3), B(1,7,-3), C(7,-5,-3)$ និង $D(-9,2,-2)$ ។

ក.គណនា $AB, AC, AD, BC, BD$ និង $CD$ ។

ខ.ស្រាយថាមុខខាងទាំងអស់នៃតេត្រាអ៊ែត $ABCD$ សុទ្ធតែជាត្រីកោណកែង

០៥.នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o, \vec{i}, \vec{j}, \vec{k}\right)$ គេឲ្យចំណុច

$A(1,-1,-2), B(3,1,-1), C(-1,5,2)$ និង $D(-3,3,2)$ ។

ក.គណនាកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AB}, \overrightarrow{AC}, \overrightarrow{AD}, \overrightarrow{BC}, \overrightarrow{CD}$ និង $\overrightarrow{DB}$ ។

ខ.គណនារង្វាស់ទ្រនុងទាំងអស់របស់តេត្រាអ៊ែត $ABCD$ ។

គ.គណនាផលគុណស្កាលែ $\overrightarrow{AB}.\overrightarrow{CD}, \overrightarrow{AC}.\overrightarrow{DB}$ និង $\overrightarrow{AD}.\overrightarrow{BC}$ ។

ឃ.ចូរផ្ទៀងផ្ទាត់ថា $\overrightarrow{AB}.\overrightarrow{CD} + \overrightarrow{AC}.\overrightarrow{DB} + \overrightarrow{AD}.\overrightarrow{BC} = 0$ ។

០៦.នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o, \vec{i}, \vec{j}, \vec{k}\right)$ គេឲ្យចំណុច

$A(-2,2,-1), B(-1,-6,3), C(2,6,6)$ និង $D(6,1,-5)$ ។

ក.គណនា $\overrightarrow{AB}.\overrightarrow{AC}$ ,$|\overrightarrow{AB}|$និង$|\overrightarrow{AC}|$ រួចទាញរកប្រភេទនៃត្រីកោណ $ABC$ ។

ខ.គណនា $\overrightarrow{DA}.\overrightarrow{AB}$ និង $\overrightarrow{DA}.\overrightarrow{AC}$ រួចទាញថា $\overrightarrow{DA}\perp\overrightarrow{BC}$ ។

គ.ស្រាយថា $BCD$ ជាត្រីកោណសម័ង្ស ។

ឃ.រកកូអរដោនេនៃចំណុច $E$ ដោយដឹងថា $\overrightarrow{AE}=\overrightarrow{AB}+\overrightarrow{AC}+\overrightarrow{AD}$ ។

ង.ចូរស្រាយថា $(AE)\perp(BCD)$ ។

០៧.តម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យត្រីកោណ $ABC$

មានកំពូល $A(-1,1,5)$ , $B(5,7,2)$ និង $C(3,-7,-3)$ ។

ក.គណនា $AB,AC$ និង $BC$ រួចបង្ហាញថា $ABC$ ជាត្រីកោណកែងត្រង់ $A$ ។

ខ.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(AB)$,$(AC)$ និង $(BC)$ ។

គ.រកកូអរដោនេនៃចំណុច $I$ ដោយដឹងថា $BC.\overrightarrow{IA}+AC.\overrightarrow{IB}+AB.\overrightarrow{IC}=\overrightarrow{O}$ ។

ឃ.ចូរផ្ទៀងផ្ទាត់ថា $BC.IA^2+AC.IB^2+AB.IC^2=BC.AC.AB$ ។

ង.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(IA)$,$(IB)$,$(IC)$ ។

ច.ចំពោះគ្រប់ចំណុច $X$ នៃលំហចូរស្រាយបញ្ជាក់ទំនាក់ទំនង ៖

$BC.XA^2+AC.XB^2+AB.XC^2=(BC+AC+AB)XI^2+BC.AC.AB$ ។

០៨.នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យពីរចំណុច

$A(2,-5,4)$ និង $B(-2,7,-2)$ ។

ក.គណនាកូអរដោនេ $I$ កណ្ដាលអង្កត់$[AB]$រួចគណនាប្រវែង $AB$ ។

ខ.សរសេរសមីការទូទៅនៃស្វ៊ែ$(S)$ មានអង្កត់ផ្ចិត$AB$ ។

គ.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(AB)$និងសមីការប្លង់មេដ្យាទ័រនៃ$[AB]$ ។

ឃ.គេឲ្យចំណុច $C(3,-1,7)$ ។ ចូរផ្ទៀងផ្ទាត់ថា $C\in(S)$ រួចសរសេរសមីការនៃ

ប្លង់$(P)$ ប៉ះនឹងស្វ៊ែ$(S)$ ត្រង់ចំណុច $C$ ។

ង.$D$ ជាចំណុចមួយដែល$\overrightarrow{CD}=\overrightarrow{CA}+\overrightarrow{CB}$ ។ រកកូអរដោនេនៃចំណុច$D$ រួច

ទាញរកប្រភេទនៃចតុកោណ $CADB$ ។

០៩.នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន$\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យប្លង់

$(P):\ 2x+y-2z+6=0$ និងចំណុច $A(4,-1,2)$ ។

១.គណនាចម្ងាយពីចំណុច$A$ ទៅប្លង់$(P)$ ។

២.$H$ ជាជើងនៃចំណោលកែងនៃចំណុច$A$ លើប្លង់$(P)$ ។គណនាកូអរដោនេនៃ

ចំណុច$H$រួចសរសេរសមីការទូទៅនៃស្វ៊ែ$(S)$មានផ្ចិត$H$ហើយកាត់តាម$A$ ។

៣. $B$ ជាចំណុចមានអរដោនេ $y_b=0$ ហើយ $B\in(P)$ និង $B\in(S)$ ។

ចូរគណនាកូអរដោនេនៃចំណុច$B$ ។

៤.គេឲ្យចំណុច$D(4,-4,5)$ ។ ចូរផ្ទៀងផ្ទាត់ថា $D\in(P)$និង $D\in(S)$ ។

ចូរសរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(L)$ ប៉ះនឹងស្វ៊ែ$(S)$ ត្រង់ចំណុច$D$

ដោយដឹងថា $(L)\subset(P)$ ។

១០.នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យបន្ទាត់ $(L)$ មាន

សមីការប៉ារ៉ាម៉ែត្រ $(L):\begin{cases}x=-2+t\\ y=1-t\\ z=8-4t \quad ,t\in\mathbb{R}\end{cases}$ និងប្លង់ $(P):2x+y-2z+1=0$ ។

ក.គណនាកូអរដោនេនៃចំណុចប្រសព្វ $A$ រវាងបន្ទាត់ $(L)$ និងប្លង់ $(P)$ ។

ខ.គេឲ្យ $B(2,3,4)$ ។ ចូរផ្ទៀងផ្ទាត់ថា $B\in(P)$ ។

គ.ពីចំណុច $B$ គេគូសបន្ទាត់ $(BH)$ កែងនឹងបន្ទាត់ $(L)$ ដោយ $H\in(L)$ ។

គណនាកូអរដោនេនៃចំណុច $H$ រួចសរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(BH)$ ។

ឃ.គេយក $I$ ជាចំណុចកណ្តាលនៃ $[AB]$ ។ គណនាកូអរដោនេនៃចំណុច $I$ រួច

ទាញបង្ហាញថា $\overrightarrow{IH}$ ជាវ៉ិចទ័រនរម៉ាល់នៃប្លង់ $(P)$ ។

ង.$K$ ជាចំណុចឆ្លុះគ្នានៃចំណុច $H$ ធៀបនឹងប្លង់ $(P)$ ។គណនាកូអរដោនេនៃ $K$

រួចស្រាយបញ្ជាក់ថាចតុកោណ $AHBK$ ជាការេ។

១១.នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $\left(o,\vec{i},\vec{j},\vec{k}\right)$ គេឲ្យចំណុច

$A(1,1,5),B(4,-2,5),C(-2,1,-1)$ និង $D(-5,4,-1)$ ។

ក.គណនា $\overrightarrow{AD}$ និង $\overrightarrow{BC}$ រួចទាញបញ្ជាក់ប្រភេទចតុកោណ $ABCD$ ។

ខ.សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(BC)$ និង $(CD)$ ។

គ.$H$ ជាចំណោលកែងនៃ $A$ លើ $BC$ ហើយ $K$ ជាចំណោលកែងនៃ $H$ លើ $CD$ ។

គណនាកូអរដោនេនៃចំណុច $H$ និង $K$ ។

ឃ.គណនា $AH$ និង $BC$ រួចគណនាផ្ទៃក្រឡាចតុកោណ $ABCD$ ។

ង.ចូរស្រាយថា $KCH$ ជាត្រីកោណកែងសមបាត។

ច.រកកូអរដោនេនៃចំណុច $L$ ដោយដឹងថា $HKCL$ ជាការេ។

១២.នៅក្នុងតម្រុយអរតូនរម៉ាល់មានទិសដៅវិជ្ជមាន $(o,\vec{i},\vec{j},\vec{k})$ គេឲ្យចំណុច $A(-1,2,7)$, $B(-5,-6,-1)$, $C(2,-1,-5)$ និង $D(5,5,1)$ ។

ក.គណនាកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AB}$ , $\overrightarrow{BC}$ , $\overrightarrow{CD}$ និង $\overrightarrow{AD}$ រួចគណនារង្វាស់នៃជ្រុងនៃចតុកោណ $ABCD$ ។

ខ.ចូរបង្ហាញថា $\overrightarrow{AB}\perp\overrightarrow{AD}$ និង $\overrightarrow{AB}//\overrightarrow{CD}$ រួចទាញរកប្រភេទចតុកោណ $ABCD$ និងគណនាផ្ទៃក្រឡារបស់វា។

គ.តាង $E$ ជាប្រសព្វរវាងបន្ទាត់ $(AD)$ និង $(BC)$។ គណនា $EC$ និង $ED$ ។

ឃ.គណនា $\overrightarrow{AB}\times\overrightarrow{AC}$ រួចទាញរកផ្ទៃក្រឡានៃត្រីកោណ $ABC$ និង $ACD$ ។

ង.រកសមីការនៃប្លង់ $(ABC)$ និងសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(AD)$ និង $(BC)$។

www.mathtoday.wordpress.com